# សេចក្តីកែតម្រូវ

នៅទំព័រទី៣ «...អាចផលិតថាមពលអគ្គិសនីបានជាមធ្យម **១៩៩៨មេហ្គាវ៉ាត់** ក្នុងមួយឆ្នាំ។» សូមកែតម្រូវទៅជា «...អាចផលិតថាមពលអគ្គិសនីបានជាមធ្យម **១៩៩៨ជីហ្គាវ៉ាត់ម៉ោង** ក្នុងមួយឆ្នាំ។

សូមអភ័យទោសចំពោះកំហុសឆ្គងដោយអចេតនា។

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
The NGO Forum on Cambodia
ធ្វើការរួមគ្នាដើម្បីភាពប្រសើរឡើង
Working Together for Positive Change

# ទំនប់វារីអគ្គិសនីសេសានក្រោម២ : ស្ថានភាពជីវភាពបច្ចុប្បន្នរបស់ប្រជាពលរដ្ឋមូលដ្ឋាន

(ការសិក្សាជាមូលដ្ឋាន)




ភ្នំពេញ កម្ពុជា
ខែធ្នូ ឆ្នាំ២០១២

**ទំនប់វារីអគ្គិសនីសេសានក្រោម២ :**
**ស្ថានភាពជីវភាពបច្ចុប្បន្នរបស់ប្រជាពលរដ្ឋមូលដ្ឋាន**
( ការសិក្សាជាមូលដ្ឋាន )

កាលបរិច្ឆេទបោះពុម្ពផ្សាយ: ខែធ្នូ ឆ្នាំ២០១២
ស្រាវជ្រាវដោយ: លោក ស្រី សៅ វិច្ឆិកា មន្ត្រីស្រាវជ្រាវ
បោះពុម្ពផ្សាយដោយ: វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
កម្មវិធីដីធ្លី និង ជីវភាព
គម្រោងតាំងទីលំនៅថ្មី និងសិទ្ធិលំនៅឋាន
រចនាអត្ថបទដោយ: លោក ភួន យូ មន្ត្រីព័ត៌មាន និងការបោះពុម្ពផ្សាយ

© **វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា**

# ទំនប់វារីអគ្គិសនីសេសានក្រោម២ :
# ស្ថានភាពជីវភាពបច្ចុប្បន្នរបស់ប្រជាពលរដ្ឋមូលដ្ឋាន

( ការសិក្សាជាមូលដ្ឋាន )

ភ្នំពេញ កម្ពុជា

ខែធ្នូ ឆ្នាំ២០១២

# មាតិកា

**មាតិកា** ........ i
**បញ្ជីផែនទី បញ្ជីតារាង** ........ v
**បញ្ជីរូបភាព** ........ vi
**បញ្ជីក្រាហ្វិក** ........ vii
**តារាងពាក្យកាត់** ........ ix
**សេចក្តីថ្លែងអំណរគុណ** ........ x
**ខ្លឹមសារសង្ខេប** ........ xii
**ជំពូកទី១-សេចក្តីផ្តើម** ........ ១
១. សាវតា ........ ១
២. ព័ត៌មានសង្ខេបអំពីទន្លេសេសាន និងស្រែពក ........ ៥
៣.ការពិពណ៌នាអំពីគម្រោងទំនប់វារីអគ្គិសនីសេសានក្រោម២ ........ ៦
**ជំពូកទី២-វិធីសាស្ត្រស្រាវជ្រាវ** ........ ៩
គោលបំណង ........ ៩
១.ដំណាក់កាលនៃការស្រាវជ្រាវ ........ ៩
២.ការចុះអង្កេតផ្ទាល់មុនពេលចុះស្រាវជ្រាវ និងពេលចុះស្រាវជ្រាវ ........ ៩
៣. ការសាកល្បងបញ្ជីសំនួរ ........ ១០
៤.ការជ្រើសរើសទីតាំង ........ ១០
៥. ការជ្រើសរើសគំរូតាង ឬសំណាក ........ ១២
៦. ការវិភាគទិន្នន័យ ........ ១៤
៧. វិសាលភាព និងដែនកំណត់នៃការសិក្សា ........ ១៤
៨. ការសិក្សាលើឯកសារ ........ ១៥
៩.គោលគំនិតនៃការសិក្សា ........ ១៦
**ជំពូកទី៣- លទ្ធផលនៃការស្រាវជ្រាវ** ........ ១៧
**លក្ខណៈប្រជាសាស្ត្រ** ........ ១៧

១. ជនជាតិ................................................................................................១៧
២. ភាសា.....................................................................................................១៨
៣. មេគ្រួសារ...............................................................................................១៩
៤. ទំហំគ្រួសារ.............................................................................................១៩
៥. ឯកសារផ្លូវច្បាប់ក្នុងគ្រួសារ (ឬឯកសាររណប)....................................២០
**ធនធានជីវភាព**.........................................................................................២២
ធាតុសំខាន់ៗនៃធនធានជីវភាព.....................................................................២២
១. ធនធានមនុស្ស........................................................................................២២
១.១. ការអប់រំ............................................................................................ ២២
១.២. សុខភាព............................................................................................ ៣២
១.៣. សន្តិសុខក្នុងភូមិ.................................................................................៤១
២. ធនធានហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត..........................................................៤៣
២.១. កម្មសិទ្ធិដីធ្លី.......................................................................................៤៣
២.២. លំនៅដ្ឋាន.........................................................................................៤៨
២.៣. ប្រភពបំភ្លឺនៅពេលយប់......................................................................៥២
២.៤. មធ្យោបាយធ្វើដំណើរ........................................................................៥៣
២.៥. ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត......................................................................៥៤
៣. ធនធានហិរញ្ញវត្ថុ......................................................................................៥៨
៣.១. មុខរបរ និងប្រាក់ចំណូល.....................................................................៥៨
៣.២. ស្ថានភាពជីវភាព និងអត្រាភាពក្រីក្រ ....................................................៦៨
៤. ធនធានសង្គម..........................................................................................៧២
៤.១. ប្រពៃណី សាសនា និងការទំនាក់ទំនង....................................................៧២
៤.២ ការសន្សំប្រាក់ និងធនាគារស្រូវនៅក្នុងភូមិ...........................................៧៤
៥. ធនធានធម្មជាតិ .......................................................................................៧៥
៥.១. ព្រៃឈើ និងផលប្រយោជន៍...................................................................៧៥
៥.២. សត្វព្រៃ និងផលប្រយោជន៍..................................................................៧៧
៥.៣. ប្រភពទឹក និងផលប្រយោជន៍ ...............................................................៨០

**ការយល់ដឹង និងទស្សនៈរបស់ប្រជាពលរដ្ឋអំពីគម្រោងសាងសង់ទំនប់វារីអគ្គិសនីសេសានក្រោម២**........................................៨៥
១. គម្រោងសាងសង់ទំនប់........................................៨៥
១.១. ប្រភពព័ត៌មានអំពីគម្រោង ........................................៨៥
១.២. ព័ត៌មានដែលបានទទួលអំពីគម្រោង........................................៨៦
១.៣. ទស្សនៈរបស់អាជ្ញាធរមូលដ្ឋានចំពោះគម្រោង........................................៨៧
១.៤. ការប្រជុំពិភាក្សាពិគ្រោះយោបល់ពាក់ព័ន្ធនឹងគម្រោង........................................៨៧
២. ផលប៉ះពាល់នៃគម្រោង ........................................៩១
២.១. ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីផលប៉ះពាល់នៃគម្រោង........................................៩១
២.២. ផលប៉ះពាល់ចំពោះហេដ្ឋារចនាសម្ព័ន្ធក្នុងភូមិ........................................៩១
២.៣. ផលប៉ះពាល់ចំពោះមុខរបរ និងការរកប្រាក់ចំណូល........................................៩២
២.៤. ផលប៉ះពាល់ចំពោះការអប់រំរបស់កុមារ........................................៩២
២.៥. ផលប៉ះពាល់ចំពោះសាសនា និងប្រពៃណី........................................៩៤
២.៦. ផលប៉ះពាល់ចំពោះព្រៃឈើ និងសត្វព្រៃ........................................៩៥
២.៧. ផលប៉ះពាល់ចំពោះទន្លេ ត្រី ការនេសាទ និងឧបករណ៍នេសាទ...៩៦
២.៨. ផលប៉ះពាល់ចំពោះដីធ្លី នឹងដំណាំផ្សេងៗ........................................៩៨
៣. ការតាំងទីលំនៅថ្មី........................................៩៨
៣.១. ប្រភពព័ត៌មានអំពីការតាំងទីលំនៅថ្មី........................................៩៨
៣.២. ព័ត៌មានដែលទទួលបានអំពីការតាំងទីលំនៅថ្មី........................................៩៩
៣.៣. ការពិភាក្សាពិគ្រោះយោបល់អំពីការតាំងទីលំនៅថ្មី................១០០
៣.៤. ទស្សនៈចំពោះការតាំងទីលំនៅថ្មី........................................១០១
៣.៥. ការសម្រេចចិត្តរបស់ប្រជាពលរដ្ឋប្រសិនបើរដ្ឋាភិបាលតំរូវអោយមានការតាំងទីលំនៅថ្មី........................................១០២
៣.៦. ការរំពឹងទុកចំពោះជីវភាពពេលតាំងទីលំនៅថ្មី........................................១០៤
៣.៧. តំរូវការសំខាន់ហើយចាំបាច់សម្រាប់ការតាំងទីលំនៅថ្មី..........១០៥
៣.៨. រយៈពេលដែលសមស្របក្នុងការត្រៀមខ្លួនតាំងទីលំនៅថ្មី.......១០៧

៤. ការផ្តល់សំណង.......................................................................១០៨
៤.១. ប្រភពព័ត៌មានអំពីការផ្តល់សំណង.....................................១០៨
៤.២. ព័ត៌មានដែលទទួលបានអំពីការផ្តល់សំណង..........................១០៩
៤.៣. ការប្រជុំពិភាក្សាពិគ្រោះយោបល់អំពីសំណង........................១១០
៤.៤. សំណងដែលសមរម្យហើយអាចទទួលយកបាន....................១១១
**ជំពូក៤ សេចក្តីសន្និដ្ឋាន សំណូមពរ និង អនុសាសន៍**....................១១៥
១. សេចក្តីសន្និដ្ឋាន..................................................................១១៥
២. សំណូមពរ...........................................................................១១៨
៣. អនុសាសន៍..........................................................................១១៩
❖ ចំពោះរាជរដ្ឋាភិបាល..............................................................១១៩
❖ ចំពោះក្រុមហ៊ុនវិនិយោគទំនប់វារីអគ្គិសនី...................................១២១
❖ ចំពោះអង្គការមិនមែនរដ្ឋាភិបាលផ្សេងៗដែលធ្វើការងារពាក់ព័ន្ធ......១២៣
❖ ចំពោះសហគមន៍....................................................................១២៣
❖ ចំពោះអ្នកស្រាវជ្រាវបន្តទៀត...................................................១២៤
ឯកសារយោង.................................................................................១២៥
ឧបសម្ព័ន្ធ.....................................................................................១៣១

# បញ្ជីផែនទី


ផែនទី១: ទន្លេនៅតំបន់ភាគឦសានប្រទេសកម្ពុជា

ផែនទី២: ទីតាំងគម្រោងទំនប់វារីអគ្គិសនីសេសានក្រោម២

ផែនទី៣: ទីតាំងភូមិឃុំដែលបានជ្រើសរើសក្នុងការសិក្សា


# បញ្ជីតារាង


តារាងទី១: ភូមិ ឃុំដែលបានជ្រើសរើសក្នុងការសិក្សា

តារាងទី២: ចំនួនប្រជាពលរដ្ឋដែលត្រូវបានជ្រើសរើសតាមភូមិនីមួយៗ

តារាងទី៣: ក្រុមគោលដៅដែលបានចូលរួមក្នុងការសិក្សា

តារាងទី៤: ប្រភេទឯកសារផ្លូវច្បាប់ក្នុងគ្រួសារ

តារាងទី៥: ការអប់រំរបស់មេគ្រួសារ

តារាងទី៦: ការចុះឈ្មោះចូលរៀនរបស់កុមារអាយុពី៦-១១ឆ្នាំ

តារាងទី៧: ឧបសគ្គរារាំងការចុះឈ្មោះចូលរៀនរបស់កុមារអាយុ៦-១១ឆ្នាំ

តារាងទី៨: មូលហេតុនៃការបោះបង់ចោលការសិក្សារបស់កុមារអាយុ ក្រោម១៨ ឆ្នាំ

តារាងទី៩: ការប្រើប្រាស់សេវាសុខភាពនៅតាមភូមិនីមួយៗ

តារាងទី១០: មូលហេតុនៃការជ្រើសរើសសេវាព្យាបាលសុខភាពមួយញឹកញាប់

តារាងទី១១: ការចំណាយក្នុងការសាងសង់បង្គន់

តារាងទី១២: ប្រភេទដីកម្មសិទ្ធិផ្សេងពីដីលំនៅដ្ឋាន

តារាងទី១៣: ទំហំដីកម្មសិទ្ធិក្រៅពីដីលំនៅដ្ឋាន

តារាងទី១៤: ប្រភេទផ្ទះ

តារាងទី១៥: មធ្យោបាយធ្វើដំណើរ

តារាងទី១៦: ចម្ងាយជាមធ្យមពីឃុំទៅកាន់មណ្ឌលសុខភាពដែលជិតបំផុត

តារាងទី១៧: មុខរបរមេគ្រួសារ

តារាងទី១៨: ប្រភពចំណូលបន្ទាប់បន្សំទី១
តារាងទី១៩: ប្រភពចំណូលបន្ទាប់បន្សំទី២
តារាងទី២០: ចំនួនសមាជិកគ្រួសារធៀបនឹងប្រាក់ចំណូលប្រចាំឆ្នាំ
តារាងទី២១: ប្រាក់ចំណូលប្រចាំឆ្នាំតាមប្រភេទមុខរបរចំបង
តារាងទី២២: ចំនួនសមាជិកដែលមិនអាចរកចំណូលបាន
តារាងទី២៣: រយៈពេលនៃការខ្វះស្រូវ/អង្ករ
តារាងទី២៤: ប្រភេទទ្រព្យសម្បត្តិ
តារាងទី២៥: ផលប្រយោជន៍នៃព្រៃឈើចំពោះជីវភាពប្រជាពលរដ្ឋ
តារាងទី២៦: ផលប្រយោជន៍សត្វព្រៃចំពោះជីវភាពប្រជាពលរដ្ឋ
តារាងទី២៧: ផលប្រយោជន៍នៃទន្លេចំពោះប្រជាពលរដ្ឋ
តារាងទី២៨: ប្រភពព័ត៌មានអំពីគម្រោងសាងសង់ទំនប់វារីអគ្គិសនីសេសានក្រោម២
តារាងទី២៩: ផលប៉ះពាល់ចំពោះហេដ្ឋារចនាសម្ព័ន្ធក្នុងភូមិ
តារាងទី៣០: ប្រភពព័ត៌មានអំពីការតាំងទីលំនៅថ្មី
តារាងទី៣១: ទស្សនៈចំពោះទីតាំងបំរុងថ្មី
តារាងទី៣២: តំរូវការសំខាន់ហើយចាំបាច់សម្រាប់ការតាំងទីលំនៅថ្មី
តារាងទី៣៣: រយៈពេលដែលសមរម្យក្នុងការរើចេញពីភូមិដើម្បីតាំងទីលំនៅថ្មី
តារាងទី៣៤: ប្រភពព័ត៌មានអំពីការផ្តល់សំណង

# បញ្ជីរូបភាព

រូបភាពទី១: ប្រភេទផ្ទះឈើប្រក់ដំបូលស័ង្កសីដែលពេញនិយមនៅតំបន់សិក្សា
រូបភាពទី២: សាលារៀនបឋមសិក្សានៅភូមិស្រែគរមួយ ឃុំស្រែគរ ស្រុកសេសាន ខេត្តស្ទឹងត្រែង
រូបភាពទី៣: ផ្លូវថ្នល់ និងស្ពាននៅតំបន់សិក្សា
រូបភាពទី៤: វត្តអារាមនៅតាមភូមិគោលដៅដែលប្រជាពលរដ្ឋតែងតែទៅគោរពបូជា

រូបភាពទី៥: ប្រភេទប័ណ្ណបញ្ជាក់ភាពក្រីក្រ
រូបភាពទី៦: ព្រៃឈើនៅតាមដងផ្លូវចូលទៅកាន់ភូមិស្រែស្រណុក
រូបភាពទី៧: ប្រភេទសត្វព្រៃមួយចំនួនដែលប្រជាពលរដ្ឋអាចប្រមាញ់បាន
រូបភាពទី៨: ប្រភពទឹកទន្លេដែលប្រជាពលរដ្ឋប្រើប្រាស់ប្រចាំថ្ងៃ
រូបភាពទី៩: ដំណាំលក្ខណៈគ្រួសារដែលស្រោចស្រពដោយទឹកទន្លេ
រូបភាពទី១០: តំបន់ទេសចរណ៍ធម្មជាតិនៅភូមិក្លុក ឃុំក្លុក ស្រុកសេសាន ខេត្តស្ទឹងត្រែង


# បញ្ជីក្រាហ្វិក


ក្រាហ្វិកទី១: ជនជាតិ
ក្រាហ្វិកទី២: ចំនួនសមាជិកគ្រួសារ
ក្រាហ្វិកទី៣: ចម្ងាយពីផ្ទះទៅសាលារៀនបឋមសិក្សា
ក្រាហ្វិកទី៤: ចំនួនកុមារដែលមិនបានចុះឈ្មោះចូលរៀន
ក្រាហ្វិកទី៥: ចំនួនគ្រួសារដែលមានកុមារអាយុក្រោម១៨ឆ្នាំដែលបោះបង់ចោលការសិក្សា
ក្រាហ្វិកទី៦: សេវាព្យាបាលដែលប្រជាពលរដ្ឋប្រើប្រាស់ញឹកញាប់
ក្រាហ្វិកទី៧: ការអនាម័យទឹកសម្រាប់ពិសាក្នុងគ្រួសារ
ក្រាហ្វិកទី៨: ប្រភេទបង្គន់អនាម័យ
ក្រាហ្វិកទី៩: ចំនួនគ្រួសារដែលមានបង្កាន់ដៃឬកិច្ចសន្យា សម្គាល់សិទ្ធិដីធ្លី
ក្រាហ្វិកទី១០: ទំហំផ្ទះ
ក្រាហ្វិកទី១១: ស្ថានភាពផ្ទះ
ក្រាហ្វិកទី១២: ប្រភពបំភ្លឺនៅពេលយប់
ក្រាហ្វិកទី១៣: អ្នករកចំណូលចំបងក្នុងគ្រួសារ
ក្រាហ្វិកទី១៤: ប្រភពចំណូលចំបងក្នុងគ្រួសារ
ក្រាហ្វិកទី១៥: ប័ណ្ណបញ្ជាក់ភាពក្រីក្រ
ក្រាហ្វិកទី១៦: អត្រានៃភាពក្រីក្រ
ក្រាហ្វិកទី១៧: ការសន្សំប្រាក់ឬធនាគាស្រូវក្នុងភូមិ

ក្រាហ្វិកទី១៨: ប្រភពទឹកផ្ទាល់ខ្លួនដែលប្រជាពលរដ្ឋមាន
ក្រាហ្វិកទី១៩: ចម្ងាយពីផ្ទះទៅប្រភពទឹកប្រើប្រាស់ប្រចាំថ្ងៃនៅរដូវប្រាំង
ក្រាហ្វិកទី២០: ការសំរេចចិត្តរបស់ប្រជាពលរដ្ឋប្រសិនជាមានការតំរូវពីរដ្ឋាភិបាលអោយតាំងទីលំនៅថ្មី
ក្រាហ្វិកទី២១: ការរំពឹងទុកចំពោះជីវភាពពេលតាំងទីលំនៅថ្មី

# តារាងពាក្យកាត់

| ពាក្យកាត់ | ពាក្យពេញជាភាសាអង់គ្លេស | ពាក្យពេញជាភាសាខ្មែរ |
|---|---|---|
| ADB | Asian Development Bank | ធនាគារអភិវឌ្ឍន៍អាស៊ី |
| ADHOC | The Cambodian Human Rights and Develoment Association | សមាគមការពារសិទ្ធិមនុស្សនិងអភិវឌ្ឍន៍នៅកម្ពុជា |
| CEPA | Culture and Environment Preservartion Association | សមាគមថែរក្សាបរិស្ថាន និងវប្បធម៌ |
| CMDG | Cambodian Millennium Development Goals | គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា |
| CNRO | The Cambodia National Research Organization | អង្គការស្រាវជ្រាវជាតិកម្ពុជា |
| DPA | Development and Partners in Action | អភិវឌ្ឍន៍ និងភាពជាដៃគូក្នុងសកម្មភាព |
| EIA | Environmental Impact Assesment | ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន |
| ESIA | Environmental and Social Impact Assesment | ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម |
| EVN | Electricity of Vietnam | អគ្គិសនីវៀតណាម |
| FAO | Food and Agriculture Organization | អង្គការស្បៀងអាហារ និងកសិកម្ម |
| KW | Kilowatt | គីឡូវ៉ាត់ |
| MVi | My Village | អង្គការភូមិខ្ញុំ |
| MoE | Ministry of Environment | ក្រសួងបរិស្ថាន |
| MoRD | Ministry of Rural Development | ក្រសួងអភិវឌ្ឍន៍ជនបទ |
| MoEYS | Ministry of Education, Youth and Sport | ក្រសួងអប់រំ យុវជន និងកីឡា |
| MW | Megawatt | មេហ្គាវ៉ាត់ |
| NIS | National Institute of Statistic | វិទ្យាស្ថានជាតិស្ថិតិ |
| NGO | Non Government Organization | អង្គការមិនមែនរដ្ឋាភិបាល |
| Riel | Cambodian Currency | រូបិយប័ណ្ណកម្ពុជា ប្រាក់រៀល |
| UNDP | United Nation Development Program | កម្មវិធីសហប្រជាជាតិដើម្បីការអភិវឌ្ឍន៍ |
| 3SPN | 3S (Sesan, Srepok, Sekong) Rivers Protection Network | បណ្តាញការពារទន្លេសេសាន ស្រែពក សេកុង |

# សេចក្តីថ្លែងអំណរគុណ

ការសិក្សាស្រាវជ្រាវអំពីស្ថានភាពជីវភាពបច្ចុប្បន្នរបស់ប្រជាពលរដ្ឋ ដែលនឹងត្រូវទទួលរងផលប៉ះពាល់ដោយសារគម្រោងសាងសង់ទំនប់វារីអគ្គិសនីសេសានក្រោម២នេះ គឺជាគំនិតផ្តួចផ្តើមឡើងដោយបណ្តាញប្រព្រឹត្តកម្មតាំងទីលំនៅថ្មីនៃគម្រោងសិទ្ធិលំនៅដ្ឋាននៃ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ក្នុងគោលបំណងស្វែងយល់ពីស្ថានភាពជីវភាពបច្ចុប្បន្នរបស់ប្រជាពលរដ្ឋ និងដើម្បីបង្ហាញពីទស្សនៈ និងការយល់ដឹងរបស់ប្រជាពលរដ្ឋទៅលើគម្រោងសាងសង់ទំនប់វារីអគ្គិសនីសេសានក្រោម២ ផលប៉ះពាល់ការតាំងទីលំនៅថ្មី និងការផ្តល់សំណង។

អ្នកនិពន្ធសូមថ្លែងអំណរគុណចំពោះលោក **ឈិត សំអាត** នាយកប្រតិបត្តិ និង លោក **ខាំ ស៊ីង្ហន** អតីតនាយកប្រតិបត្តិរង វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា ដែលបានជួយជ្រោមជ្រែងឲ្យមានការសិក្សានេះកើតឡើង។

អ្នកនិពន្ធ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ប្រជាពលរដ្ឋទាំងអស់ដែលបានចំណាយពេលវេលាដ៏មានតម្លៃចូលរួមផ្តល់ព័ត៌មាននានានៅក្នុងការសិក្សាស្រាវជ្រាវ និងបានផ្តល់កន្លែងស្នាក់នៅ ក៏ដូចជាបានជួយគាំទ្រតាមធ្យោបាយផ្សេងៗដល់ក្រុមការងារក្នុងការសិក្សានេះ។

ម្យ៉ាងទៀតសូមថ្លែងអំណរគុណចំពោះលោក **ស៊ុន យ៉ូវ៉ា** លោក **មី បាំង** លោក **ពាក្យ សាវ៉ែន** និងលោក **ប៉ោ ណារិទ្ធ** អង្គការភូមិខ្ញុំ និងលោក **ញឹម ស៊ីញន** អង្គការឌី ភី អេ នៅខេត្តស្ទឹងត្រែង ដែលបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការជួយសម្របសម្រួលជាមួយអជ្ញាធរមូលដ្ឋាន និងអាជ្ញាធរខេត្តស្ទឹងត្រែង ក៏ដូចជាជួយបង្ហាញទីតាំងភូមិសាស្ត្រក្នុងការចុះសិក្សាតាមមូលដ្ឋាន។ ស្របពេលជាមួយគ្នានេះដែរ អ្នកនិពន្ធសូមអរគុណដល់ លោក **មៀច មាន** អ្នកសម្របសម្រួលបណ្តាញការពារទន្លេសេសាន ស្រែពក សេកុង ដែលបានជួយផ្តល់គំនិតទាក់ទងនឹងទីតាំងភូមិសាស្ត្រដែលបានជ្រើសក្នុងការសិក្សា និងអរគុណដល់ លោក **សុខ សុខុម** អង្គការស៊ី អិន វ៉ូ និងលោក **ផាន់ ស៊ីថាន** អតីតបុគ្គលិកមជ្ឈមណ្ឌលសិទ្ធិលំនៅដ្ឋាន

និងការបណ្តេញចេញដែលបានចុះជួយស្រង់ទិន្នន័យ ភូមិ ឃុំ ចំនួនប្រជាពលរដ្ឋ និងថតរូបភាពនៅតំបន់សិក្សានីមួយៗ។

ជាចុងក្រោយ សូមថ្លែងអំណរគុណដល់អាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់នៅខេត្តស្ទឹងត្រែង និងខេត្តរតនគិរី ដែលបានជួយសហការ និងសម្របសម្រួលអោយក្រុមការងារស្រាវជ្រាវ បានធ្វើការយ៉ាងរលូននៅតាមតំបន់គោលដៅទាំងឡាយដោយសុវត្ថិភាព និងជោគជ័យ។

# ខ្លឹមសារសង្ខេប

ប្រទេសកម្ពុជា បាននឹងកំពុងឈានដល់របត់អភិវឌ្ឍន៍មួយ ដែលវិស័យឧស្សាហកម្ម និងកម្មវិធីវិនិយោគជាច្រើនកំពុងមានចលនាយ៉ាងសកម្មក្នុងប្រទេស។ កង្វះខាតហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត បានក្លាយជាឧបសគ្គមួយក្នុងចំណោមឧបសគ្គនានា ដែលចូលរួមបង្អាក់សកម្មភាពវិនិយោគនៅក្នុងប្រទេសដោយរួមទាំងវិស័យថាមពលអគ្គិសនីផងដែរ។ រាជរដ្ឋាភិបាលកម្ពុជាបានមើលឃើញថា ឧស្សាហកម្មអគ្គិសនីគឺជាតម្រូវការចាំបាច់មួយសម្រាប់ប្រជាពលរដ្ឋ ក៏ដូចជាដំណើរការអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងប្រទេស ដូច្នេះគម្រោងវិនិយោគទំនប់វារីអគ្គិសនីជាច្រើនត្រូវបានអនុម័ត និងកំពុងពិចារណា ដើម្បីឆ្លើយតបនឹងតម្រូវការទាំងនេះ។

គម្រោងសាងសង់ទំនប់វារីអគ្គិសនីសេសានក្រោម២ ត្រូវបានរដ្ឋាភិបាលចាត់ទុកថាជាគម្រោងមួយដែលមានលទ្ធភាពអាចផលិតថាមពលអគ្គិសនីបានច្រើនក្នុងចំណោមទំនប់វារីអគ្គិសនីដទៃទៀតនៅក្នុងប្រទេសកម្ពុជា។ ស្របពេលគ្នានេះដែរ ប្រជាពលរដ្ឋទាំងអស់ដែលកំពុងរស់នៅតំបន់គម្រោងដែលបានចូលរួមក្នុងការសិក្សានេះ សុទ្ធតែបានឮដំណឹងអំពីគម្រោងសាងសង់ទំនប់វារីអគ្គិសនីសេសានក្រោម២នេះ។ ព័ត៌អំពីការសាងសង់ទំនប់វារីអគ្គិសនីត្រូវបានផ្សព្វផ្សាយដោយអាជ្ញាធរមូលដ្ឋាន និងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត ដោយគ្មានព័ត៌មានជាក់លាក់ ផ្លូវការណាមួយត្រូវបានផ្សព្វផ្សាយដោយមន្ត្រីជំនាញជាន់ខ្ពស់ និងមន្ត្រីមកពីក្រុមហ៊ុនទទួលសាងសង់គម្រោងនេះឡើយ។

ប្រជាពលរដ្ឋស្ទើរតែទាំងអស់ យល់ថាការសាងសង់ទំនប់វារីអគ្គិសនី នឹងធ្វើអោយមានផលប៉ះពាល់ដល់ជីវភាពរស់នៅ មុខរបរ ដីស្រែចំការ ដំណាំដាំដុះ ទ្រព្យសម្បត្តិផ្សេងៗ ការអប់រំ សាសនា ប្រពៃណី ហេដ្ឋារចនាសម្ព័ន្ធក្នុងភូមិ និងធនធានធម្មជាតិដូចជាព្រៃឈើ សត្វព្រៃ ទន្លេ ត្រី និងជីវចំរុះផ្សេងៗជាដើម។ ដូច្នេះប្រជាពលរដ្ឋមិនចង់អោយមានគម្រោងសាងសង់នេះកើតឡើងនៅតំបន់ដែលពួកគេរស់នៅឡើយ តែទោះជាយ៉ាងណាក៏ដោយប្រជាពលរដ្ឋមិនប្រឆាំងនឹងការអភិវឌ្ឍ

របស់រាជរដ្ឋាភិបាលទេ ប៉ុន្តែសំណូមពរសូមអោយរដ្ឋាភិបាលគិតគូរពីផលប៉ះពាល់ទាំងឡាយដោយយកចិត្តទុកដាក់ជាមុន ព្រោះគម្រោងនេះ នឹងបង្កអោយមានផលប៉ះពាល់ធំធេងដល់ការរស់នៅរបស់អ្នកភូមិ ។

បើទោះជាមានការពិភាក្សាពិគ្រោះយោបល់ ជាមួយប្រជាពលរដ្ឋមួយចំនួនតូចអំពីគម្រោងសាងសង់ផលប៉ះពាល់ ការផ្តល់សំណង និងការតាំងទីលំនៅថ្មីដោយសារគម្រោងសាងសង់ទំនប់វារីអគ្គិសនីសេសានក្រោម២ ក៏ដោយ ប៉ុន្តែអ្នកភូមិភាគច្រើនមិនបានដឹងថាមានការពិភាក្សាអំពីបញ្ហាទាំងនេះឡើយ ហេតុនេះព័ត៌មានជាក់លាក់ឬដំណឹងច្បាស់លាស់ អំពីគម្រោងសាងសង់ផលប៉ះពាល់សំណងនិងការតាំងទីលំនៅថ្មីមិនត្រូវបានផ្សព្វផ្សាយឲ្យបានទូលំទូលាយឡើយ។

ប្រជាពលរដ្ឋភាគច្រើន នឹងយល់ព្រមចាកចេញពីភូមិកំណើតទៅរស់នៅទីតាំងថ្មីដោយសារគម្រោងសាងសង់ទំនប់វារីអគ្គិសនី ប្រសិនបើមានតំរូវការពីរាជរដ្ឋាភិបាល បើទោះបីជាពួកគេមិនពេញចិត្តចំពោះការសំរេចចិត្តនេះក៏ដោយ។ លក្ខខណ្ឌចាំបាច់ក្នុងការសម្រេចចិត្តនេះ គឺប្រជាពលរដ្ឋត្រូវការសំណងដែលសមរម្យយុត្តិធម៌ និងអាចទទួលយកបានជាមុន ទើបពួកគេអាចចាកចេញទៅនៅកន្លែងថ្មីនិងកសាងជីវភាពរស់នៅថ្មីបាន។

ប្រជាពលរដ្ឋភាគច្រើន បានព្យាករពីការប្រែប្រួលជាអវិជ្ជមានចំពោះជីវភាពរបស់ពួកគេក្រោយពេលធ្វើការបំលាស់ទី ព្រោះកន្លែងថ្មីជាកន្លែងដែលមិនទាន់មានផ្ទះ ដំណាំដាំដុះ គ្មានមុខរបរដើម្បីបានចំណូលមិនអាចប្រកបរបរនេសាទបាន ពុំមានទឹកប្រើប្រាស់គ្រប់គ្រាន់/ប្រភពទឹកនៅឆ្ងាយ ដូច្នេះនឹងធ្វើអោយប៉ះពាល់ដល់ជីវភាពរស់នៅប្រចាំថ្ងៃ។ លើសពីនេះ ប្រជាពលរដ្ឋនៅតំបន់សិក្សាពុំទាន់បានត្រៀមរៀបចំទុកជាមុនសម្រាប់ការចាកចេញទៅតំបន់តាំងទីលំនៅថ្មីនៅឡើយទេ ពីព្រោះពួកគេមិនទាន់បានទទួលព័ត៌មាន ឬសេចក្តីជូនដំណឹងជាផ្លូវការ។ តំរូវការចាំបាច់បំផុតក្នុងការផ្លាស់ទីលំនៅទៅកាន់តំបន់ផ្សេងដោយសារការអភិវឌ្ឍទំនប់វារីអគ្គិសនីនៅសេសានក្រោម២ មានបីចំណុចធំៗគឺៈ ដីស្រែ និងដីចំការ ផ្ទះសំបែង និងហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋានដូចជាផ្លូវ សាលារៀន វត្តអារាម និងមណ្ឌលសុខភាព

ជាដើម ក្នុងចំណោមតម្រូវការសំខាន់ហើយចាំបាច់ផ្សេងទៀត ដូចជាប្រភពទឹក ដំណាំហូបផ្លែ គោក្របី និងរបស់របរផ្សេងៗទៀតដូចដែលមាននៅកន្លែងរស់នៅចាស់។ ជាពិសេស ការជូនដំណឹងជាមុន ហើយទុកពេលវេលាមួយសមរម្យក្នុងការត្រៀមខ្លួនចាកចេញក៏ជាតម្រូវការសំខាន់មួយដែរ សម្រាប់ប្រជាពលរដ្ឋដែលត្រូវទទួលរងផលប៉ះពាល់។

ក្រៅពីសិក្សាទៅលើទស្សនៈ និងការយល់ដឹងរបស់ប្រជាពលរដ្ឋទាក់ទងនឹងគម្រោងសាងសង់ទំនប់វារីអគ្គិសនី ការសិក្សានេះបានពិនិត្យទៅលើស្ថានភាពរស់នៅទូទៅប្រចាំថ្ងៃរបស់គ្រួសារនីមួយៗ ដោយផ្តោតសំខាន់លើ៥ចំណុចដែលជាធនធានសម្រាប់ជីវិតប្រចាំថ្ងៃគឺធនធានមនុស្ស ធនធានហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តធនធានហិរញ្ញវត្ថុ ធនធានសង្គម និងធនធានធម្មជាតិ។ ធនធានទាំងនេះមានធាតុតូចៗជាច្រើនទៀតដែលជាចលករសម្រាប់អោយធនធាននីមួយៗដំណើរការទៅបាន។

**ទី១-ធនធានមនុស្ស:** តាមលទ្ធផលនៃការសិក្សានេះបង្ហាញថា ការអប់រំជាទូទៅនៅមានកម្រិតនៅឡើយ។ អត្រាចុះឈ្មោះចូលរៀននៅថ្នាក់បឋមសិក្សាមានកម្រិតខ្ពស់ក៏ពិតមែន តែអត្រាកុមារបោះបង់ចោលការសិក្សា ស្ថិតក្នុងកម្រិតមួយគួរយកចិត្តទុកដាក់ ក្នុងចំណោមក្មេងអាយុក្រោម១៨ឆ្នាំ។ កុមារដែលមានលទ្ធភាពអាចរៀនចប់បឋមសិក្សាស្ទើរតែគ្មានទាល់តែសោះ នៅតាមណ្ឌាភូមិគោលដៅនីមួយៗ។ យុវជនដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ ភាគច្រើនបានឈប់រៀនមុនពេលបញ្ចប់បឋមសិក្សា។ កត្តាដែលរារាំងការទទួលបានការអប់រំរបស់កុមាររួមមានកត្តាឪពុកម្តាយមិនបានជួយជំរុញកូនអោយទៅរៀន ស្ថានភាពជីវភាពគ្រួសារជួបការលំបាក តម្រូវការកំលាំងពលកម្មកុមារក្នុងការរកប្រាក់ចំណូល សាលារៀន និងគ្រូបង្រៀនមិនគ្រប់គ្រាន់សម្រាប់កុមារ ហើយកុមារមួយចំនួនទៅតាមឪពុកម្តាយនៅស្រែចំការនៅរដូវធ្វើស្រែចំការដែលឆ្ងាយពីសាលារៀន និងជាពិសេស មិនមានអនុវិទ្យាល័យ ឬវិទ្យាល័យនៅក្នុងតំបន់។

កង្វះខាតសេវាសុខភាពមានស្ថានភាពខ្ពស់ ដោយសារមណ្ឌលសុខភាពនៅឆ្ងាយពីភូមិធ្វើអោយប្រជាពលរដ្ឋ មានការលំបាកក្នុងការទទួលសេវាព្យាបាល

ផ្សេងៗ។ ទោះជាចម្ងាយផ្លូវទៅកាន់មណ្ឌលសុខភាពជាឧបសគ្គមួយក្នុងការទទួលសេវាព្យាបាលសុខភាព ប៉ុន្តែមណ្ឌលសុខភាពនៅតែមានភាពពេញនិយមជាងគេសម្រាប់ប្រជាពលរដ្ឋនៅទីនោះ បើធៀបនឹងសេវាព្យាបាលឯកជនផ្សេងៗ ព្រោះមណ្ឌលសុខភាពត្រូវបានគេជឿជាក់ថាមានប្រសិទ្ធភាព ក្នុងការព្យាបាលជម្ងឺអោយជាសះស្បើយ។

បញ្ហាអសន្តិសុខមួយចំនួន ដែលត្រូវបានលើកឡើងក្នុងចំណោមប្រជាពលរដ្ឋដែលបានចូលរួមក្នុងការសិក្សាដូចជា មានក្មេងស្ទាវវាយតប់គ្នា ចោរលួចគោក្របី និងការប្រើអំពើរហិង្សាក្នុងគ្រួសារជាដើម ដែលកើតមាននៅតាមភូមិមួយចំនួន។ បញ្ហាមួយចំនួនដូចជាការប្រើអំពើហិង្សាក្នុងគ្រួសារ និងការវាយតប់គ្នាជាដើម ជួនកាលត្រូវបានដោះស្រាយដោយអាជ្ញាធរភូមិ និងជួនកាលដោយប៉ូលីស។ គួរឲ្យកត់សម្គាល់ នៅតាមភូមិមួយចំនួន ប្រជាពលរដ្ឋមានការចងក្រងគ្នាជាក្រុមក្នុងភូមិ ដើម្បីរក្សាសន្តិសុខភូមិដោយខ្លួនឯង ប៉ុន្តែក្រុមនេះមិនមែនជាក្រុមផ្លូវការដែលមានគណៈកម្មការនោះទេ គ្រាន់តែជាក្រុមដែលកើតឡើងដោយប្រជាពលរដ្ឋ ប្រធានភូមិ និងអនុប្រធានភូមិប៉ុណ្ណោះ។ ដោយឡែក នៅភូមិខ្លះប្រជាពលរដ្ឋបានស្នើអោយមានប៉ូលីសជួយការពារសន្តិសុខពេលមានបុណ្យទានសំខាន់ៗក្នុងភូមិ ដែលមានការរាំលេងកំសាន្ត ដើម្បីការពារការប្រើហិង្សាផ្សេងៗរបស់ក្រុមក្មេងស្ទាវ។

**ទី២-ធនធានហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តៈ** ពុំទាន់មានឯកសារនៃការចុះបញ្ជីដីជាផ្លូវការ ដែលបញ្ជាក់ពីការកាន់កាប់ដីនៅតំបន់សិក្សានៅឡើយទេ ជាពិសេសតំបន់ដែលស្ថិតក្នុងផែនការគម្រោងទំនប់ ពីព្រោះទីនោះជាតំបន់មិនទាន់វិនិច្ឆ័យ។ ជាក់ស្តែង ប្រជាពលរដ្ឋប្រមាណជា១២% ប៉ុណ្ណោះ ដែលមានពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លី(បង្កាន់ដៃទទួលស្គាល់សិទ្ធិកាន់កាប់ដី) ត្រឹមថ្នាក់ភូមិ ឃុំ ឬកិច្ចសន្យាលក់-ទិញ។ ការកាន់កាប់ដីនៅតំបន់នោះ ត្រូវបានធ្វើឡើងពីមួយជំនាន់ទៅមួយជំនាន់ ដោយមិនសូវខ្វាយខ្វល់ពីលិខិតស្នាមផ្លូវការឡើយ ដោយសារប្រជាពលរដ្ឋនៅតំបន់នោះយល់ថា គ្រួសាររបស់គេជាម្ចាស់កម្មសិទ្ធិពិតប្រាកដ លើដីទាំងឡាយដែលគ្រួសារគេមាន។ ចំពោះលំនៅដ្ឋានវិញឃើញថា ប្រជាពលរដ្ឋទាំងអស់ ដែល

បានចូលរួមក្នុងការសិក្សានេះ សុទ្ធតែរស់នៅលើផ្ទះកម្មសិទ្ធិរបស់ខ្លួន ឬផ្ទះកម្មសិទ្ធិរបស់ឪពុកម្តាយចំពោះគ្រួសារធំដែលនៅជុំគ្នាមានសមាជិកច្រើន។

បើទោះជាមានទំនប់វារីអគ្គិសនីតូចៗមួយចំនួននៅខេត្តស្ទឹងត្រែង និងរតនគិរី ប៉ុន្តែការផ្គត់ផ្គង់អគ្គិសនីគឺនៅមានកម្រិត ដោយទំនប់ទាំងនេះ មិនអាចផ្គត់ផ្គង់បានគ្រប់គ្រាន់ទូទាំងខេត្តនោះទេ។ ក្នុងចំណោមភូមិដែលបានជ្រើសរើសក្នុងការសិក្សា មិនទាន់មានការប្រើប្រាស់បណ្តាញអគ្គិសនីនៅឡើយទេ ដោយក្នុងនោះមានប្រជាពលរដ្ឋប្រមាណ៩% ប៉ុណ្ណោះ ដែលមានលទ្ធភាពប្រើប្រាស់អគ្គិសនីដែលដើរដោយការបញ្ឆេះម៉ាស៊ីនភ្លើង ឬម៉ាស៊ីនគោយន្តដើម្បីបំភ្លឺ ប៉ុន្តែប្រជាពលរដ្ឋភាគច្រើនលើសលប់នៅតាមភូមិនីមួយៗ គឺប្រើប្រាស់ចង្កៀងប្រេងកាតជាប្រភពបំភ្លឺចំបងនៅពេលយប់។

បើនិយាយអំពីមធ្យោបាយធ្វើដំណើរវិញ ជាទូទៅនៅតាមផ្ទះនីមួយៗតែងមានម៉ូតូ កង់ និងទូកជាមធ្យោបាយធ្វើដំណើរប្រចាំថ្ងៃ តែស្ទើរតែគ្មានអ្នកមានរថយន្តនោះទេ។ ចំណែកហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗផ្សេងៗទៀតនៅក្នុងភូមិ រួមមានសាលារៀន សាលាឆទាន វត្តអារាម ប៉ុស្តិ៍សុខភាព អណ្តូងទឹក ផ្លូវថ្នល់ និងស្ពានតូចៗជាដើម តែមិនមានមណ្ឌលសុខភាពនោះទេ។

**ទី៣-ធនធានហិរញ្ញវត្ថុ:** ប្រជាពលរដ្ឋភាគច្រើនប្រកបរបរកសិកម្ម ហើយជីវភាពពួកគេពឹងផ្អែកទាំងស្រុងលើវិស័យនេះ។ លើសពីនេះ ពួកគេក៏មានមុខរបរបន្ទាប់បន្សំផ្សេងៗទៀតដូចជានេសាទ រកអនុផលព្រៃឈើ លក់ដូរតិចតួច ស៊ីឈ្នួលដោយប្រើកំលាំងពលកម្ម និងចិញ្ចឹមសត្វលក្ខណៈគ្រួសារនៅផ្ទះជាដើម ដែលអាចរកប្រាក់ចំណូលបន្ថែមសម្រាប់ការផ្គត់ផ្គង់ជីវភាពគ្រួសារទាំងមូល។ អ្នករកប្រាក់ចំណូលចំបងភាគច្រើនគឺជាមេគ្រួសារ ហើយជាមធ្យមក្នុងមួយគ្រួសាររកប្រាក់ចំណូលបាន ២៣៦៧.៥ដុល្លាអាមេរិក ក្នុងមួយឆ្នាំ។

ប្រាក់ចំណូលជាមធ្យមសម្រាប់មនុស្សម្នាក់ក្នុងគ្រួសារមួយៗ នៅក្នុងការសិក្សានេះ បានត្រឹមតែ៥១ភាគរយ ក្នុងចំណោម១០០ភាគរយ នៃប្រាក់ចំណូលសម្រាប់មនុស្សម្នាក់តាមស្តង់ដាប្រទេសកម្ពុជា របស់វិទ្យាស្ថានស្ថិតិជាតិឆ្នាំ២០១០

ប៉ុណ្ណោះ។ ក្រៅពីនេះ បើពិនិត្យទៅលើអត្រាភាពក្រីក្រក្នុងចំណោមគ្រួសារទាំងអស់ ការសិក្សាបង្ហាញថា មានគ្រួសារប្រមាណ៣.២ភាគរយប៉ុណ្ណោះ ដែលស្ថិតក្នុងស្ថានភាពក្រីក្រ ចំណែកគ្រួសារភាគច្រើនមានស្ថានភាពមិនស្ថិតក្នុងភាពក្រីក្រ ឬអាចនិយាយថាជីវភាពមធ្យម ប៉ុន្តែការសិក្សានេះមិនអាចបញ្ជាក់ថា ភាគច្រើននៃប្រជាពលរដ្ឋទាំងនេះ ស្ថិតក្នុងស្ថានភាពមធ្យម ឬមានកម្រិតណានោះទេ ត្រឹមតែអាចបញ្ជាក់ថាស្ថានភាពរស់នៅរបស់ពួកគេអាចទប់ទល់នឹងជីវភាពប្រចាំថ្ងៃបាន ដោយមិនជួបការលំបាក ខ្វះមុខ ខ្វះក្រោយ។

**ទី៤-ធនធានសង្គម:** ការទំនាក់ទំនង ភាពជិតស្និទ្ធិ និងការជួបជុំគ្នា តែងកើតមាននៅគ្រប់សហគមន៍ទាំងអស់។ ប្រជាពលរដ្ឋតែងមានការជួបជុំ ប្រាស្រ័យទាក់ទងគ្នា និងការជួយគ្នាទៅវិញទៅមកជាប្រចាំ ដែលបង្ហាញពីទំនាក់ទំនង និងការរស់នៅជាក្រុម ឬសហគមន៍ដែលពិបាកនឹងកសាងសាជាថ្មី បើសិនជាត្រូវទៅនៅកន្លែងផ្សេងៗគ្នា។ ទំនៀមទំលាប់ប្រពៃណី សាសនា និងជំនឿផ្សេងៗក៏តែងកើតមាន និងប្រារព្ធជាក្រុមសម្រាប់ភូមិនីមួយៗ ជាតម្រូវការក្នុងការរស់នៅប្រចាំថ្ងៃ។ ប្រជាពលរដ្ឋភាគច្រើន គឺជាអ្នកកាន់សានាព្រះពុទ្ធតែងប្រារព្ធពិធីសាសនាជួបជុំគ្នា និងតែងមានជំនឿទៅលើការសែនព្រេនក្នុងព្រៃ និងសែនអ្នកតាក្នុងភូមិ ប៉ុន្តែក៏មានប្រជាពលរដ្ឋមួយចំនួនមានជំនឿទៅលើតែអ្នកតា និងដូងព្រលឹងផ្សេងៗ ឬព្រះសែនដែរ ពីព្រោះតំបន់ដែលពួកគេរស់នៅជាតំបន់ដែលមានព្រៃឈើ និងមានការរស់នៅលាយឡំជាមួយជនជាតិដើមភាគតិច។ ចំពោះទំលាប់នៃការជួយគ្នា ឬប្រវ៉ាស់ដៃគ្នានៅរដូវធ្វើស្រែចំការ ក៏នៅតែកើតមានសម្រាប់ភូមិមួយចំនួនដែរ។

**ទី៥-ធនធានធម្មជាតិ:** ភាគឦសាននៃប្រទេសកម្ពុជា ជាពិសេសនៅតំបន់គម្រោងទំនប់វារីអគ្គិសនីសេសានក្រោម២ នៃខេត្តស្ទឹងត្រែងគឺជាតំបន់ដែលមានព្រៃឈើ សត្វព្រៃ និងទន្លេ។ ប្រជាពលរដ្ឋភាគច្រើនរស់នៅតាមដងទន្លេ និងតំបន់ព្រៃឈើ ដែលធនធានធម្មជាតិទាំងនេះអំណោយផលសម្រាប់ទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋបានមួយផ្នែកធំ។ ប្រជាពលរដ្ឋអាចទាញយកផលប្រយោជន៍ និងអនុផលពីព្រៃឈើសម្រាប់ជីវភាពប្រចាំថ្ងៃដូចជា ឈើធ្វើផ្ទះ គ្រឿងសង្ហារឹម អុស

ដុត ផ្លែឈើ ឱសថបុរាណ។ល។ អ្នកភូមិមួយចំនួននៅតែបន្តប្រមាញ់សត្វព្រៃធ្វើជាអាហារ ហើយមានករណីតិចតួចប៉ុណ្ណោះ ដែលអ្នកភូមិអាចរកសត្វព្រៃបានច្រើនជាងតម្រូវការបរិភោគ សម្រាប់លក់ ប៉ុន្តែមិនមែនជាប្រចាំនោះទេ។ ដោយសារបច្ចុប្បន្នមានការហាមប្រាមអ្នកភូមិក្នុងការប្រមាញ់សត្វព្រៃមួយចំនួន ក្នុងគោលបំណងអភិរក្ស ប្រជាជនអាចរកសត្វព្រៃតិចតួចប៉ុណ្ណោះសម្រាប់បរិភោគ។ ចំណែកទន្លេ ជាប្រភពទឹកដ៏សំខាន់សម្រាប់ជីវភាពរស់នៅតាមដងទន្លេ ដោយសារមានទន្លេ អ្នកភូមិមានទឹកប្រើប្រាស់គ្រប់គ្រាន់សម្រាប់ជីវភាពប្រចាំថ្ងៃ ការងារកសិកម្ម អាចនេសាទត្រី សម្រាប់ជាអាហារ និងសម្រាប់លក់ដូរបាន។

ប្រជាពលរដ្ឋ និងប្រធានភូមិ/អនុប្រធានភូមិ សំណូមពរទៅកាន់រាជរដ្ឋាភិបាល ក៏ដូចជាក្រុមហ៊ុនវិនិយោគសាងសង់ទំនប់វារីអគ្គិសនី កុំអោយសាងសង់ទំនប់វារីអគ្គិសនីសេសានក្រោម២នេះឡើង ព្រោះវានឹងមានផលប៉ះពាល់ធំធេងដល់ប្រជាពលរដ្ឋ និងបរិស្ថាន។ ប៉ុន្តែប្រសិនបើរាជរដ្ឋាភិបាលនៅតែយល់ថាការសាងសង់ទំនប់នេះ គឺជាការអភិវឌ្ឍដែលនឹងផ្តល់ផលប្រយោជន៍ច្រើនឆ្លើយតបនឹងតម្រូវការប្រទេសជាតិទាំងមូល ដូច្នេះ ប្រជាពលរដ្ឋទាំងឡាយសំណូមពរអោយរាជរដ្ឋាភិបាលគិតគូរយ៉ាងយកចិត្តទុកដាក់ក្នុងការផ្តល់សំណង ឬផ្តល់តម្លៃជំនួសជូនចំពោះការបាត់បង់ផ្សេងៗ របស់ប្រជាពលរដ្ឋដែលនឹងត្រូវទទួលរងផលប៉ះពាល់អោយបានសមរម្យ យុត្តិធម៌ និងអាចទទួលយកបាន ធ្វើយ៉ាងណាកុំអោយជីវភាពរបស់ប្រជាពលរដ្ឋជួបការលំបាកជាងពេលដែលពួកគេរស់នៅភូមិកំណើត មុនពេលមានគម្រោងសាងសង់ទំនប់វារីអគ្គិសនី។

# ជំពូកទី១-សេចក្តីផ្តើម

## ១. សាវតា

ប្រទេសកម្ពុជាជាប្រទេសកំពុងអភិវឌ្ឍន៍ ដែលមានប្រជាពលរដ្ឋប្រមាណជា ១៤.៥២១.២៧៥នាក់ [1] ក្នុងនោះប្រជាពលរដ្ឋប្រមាណជា៨០% រស់នៅតំបន់ជនបទ [2] និងលើសពី៧០% ប្រកបរបរកសិកម្ម។ [3] ដោយសារសង្គ្រាមរ៉ាំរ៉ៃជាច្រើនឆ្នាំ ពិសេសសង្គ្រាមស៊ីវិលកំឡុងឆ្នាំ១៩៧០-១៩៧៩ បានធ្វើអោយហេដ្ឋារចនាសម្ព័ន្ធក្នុងប្រទេសកម្ពុជា រួមទាំងវិស័យថាមពលអគ្គិសនី ត្រូវបានបំផ្លាញយ៉ាងធ្ងន់ធ្ងរ។ ខណៈពេលនោះ ប្រទេសកម្ពុជាមានខ្សែបញ្ជូនចរន្តអគ្គិសនីតែមួយគត់ ដែលមានប្រភពមកពីស្ថានីយ៍ទំនប់វារីអគ្គិសនីគីរីរម្យ១ ដែលមានថាមពលត្រឹមតែ១១៥គីឡូវ៉ាត់ប៉ុណ្ណោះ ស្របពេលដែលបណ្តាញអគ្គិសនីផ្សេងៗ នៅក្នុងប្រទេសនាពេលនោះស្ទើរតែបំផ្លាញទាំងស្រុង។[4]

ក្នុងឆ្នាំ២០១១ ព្រះរាជាណាចក្រកម្ពុជាមានរោងចក្រអគ្គិសនីចំនួនបួនគឺ រោងចក្រវារីអគ្គិសនីគិរីរម្យនិងកំចាយ រោងចក្រវារីអគ្គិសនីអូជុំ រោងចក្រវារីអគ្គិសនីទីរូមខេត្តមណ្ឌលគិរី និងរោងចក្រក្រុមហ៊ុនកាត់ដេរ អេស អិល ហ្គាមិន (កម្ពុជា)។ ក្នុងនោះ មធ្យោបាយផលិតអគ្គិសនីពីរោងចក្រដៀសែលមាន៩៣% រោងចក្រវារីអគ្គិសនីមាន៣% រោងចក្រប្រើឡចំហាយដើរដោយធ្យូងថ្មមាន៣% និងរោងចក្រប្រើអុស និងជីវម៉ាសដទៃទៀតមាន១%។ [5] ប្រជាពលរដ្ឋកម្ពុជាប្រមាណ២៦.៤% មានភ្លើងអគ្គិសនីប្រើប្រាស់ ហើយក្នុងនោះប្រជាពលរដ្ឋនៅតំបន់ជនបទមានត្រឹម

---

[1] វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ «ជំរឿនសហគ្រាសនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១១»

[2] (UNICEF, 2010)

[3] របាយការណ៍អភិវឌ្ឍន៍មនុស្ស ឆ្នាំ២០១១ (Cambodia Human Development Report 2011)

[4] www.energypedia.info/index.php/Cambodia_Country_Situation#Energy_Situation (Searched website on March 28, 2011)

[5] «របាយការណ៍វិស័យអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១១», ចេញផ្សាយឆ្នាំ២០១២ ដោយអាជ្ញាធរអគ្គិសនីកម្ពុជា

តែ១៣% ប៉ុណ្ណោះមានភ្លើងអគ្គិសនីប្រើប្រាស់ ខណៈដែលប្រជាពលរដ្ឋនៅតំបន់ទីក្រុងមានរហូតដល់៨៧% មានភ្លើងអគ្គិសនីប្រើប្រាស់។[6] ដោយសារការផ្គត់ផ្គង់ថាមពលអគ្គិសនីនៅមានកម្រិតបែបនេះ បច្ចុប្បន្នប្រទេសកម្ពុជាបាននឹងកំពុងនាំចូលថាមពលអគ្គិសនីពីប្រទេសជិតខាងដូចជាប្រទេសវៀតណាម ឡាវ និងថៃ ប្រមាណជា៤២% នៃថាមពលអគ្គិសនីសរុបក្នុងប្រទេស ដើម្បីបំពេញតម្រូវការប្រជាពលរដ្ឋក្នុងស្រុក ពិសេសប្រជាពលរដ្ឋដែលរស់នៅតាមតំបន់ព្រំដែន និងតំបន់ទីប្រជុំជន។[7] បើយោងតាមយុទ្ធសាស្ត្រអនុភាពអគ្គិសនីនៅកម្ពុជា (១៩៩៩-២០១៦) របស់ក្រសួងឧស្សាហកម្មរ៉ែ និងថាមពលបានបង្ហាញថា ប្រទេសកម្ពុជាមានតម្រូវការថាមពលអគ្គិសនីប្រចាំឆ្នាំចាប់ពី៥២២ម៉េហ្គាវ៉ាត់ ក្នុងឆ្នាំ១៩៩៨ ទៅ២៦៣៤ម៉េហ្គាវ៉ាត់ ក្នុងឆ្នាំ២០១៦។[8] ដោយសារតម្រូវការថាមពលអគ្គិសនីប្រចាំឆ្នាំមានការកើនឡើង រដ្ឋាភិបាលបានបង្កើនសមត្ថភាពផ្គត់ផ្គង់អគ្គិសនីពី៤៧២មេហ្គាវ៉ាត់ ក្នុងឆ្នាំ២០០៩ ទៅដល់៥៣៨មេហ្គាវ៉ាត់ ក្នុងឆ្នាំ២០១០។[9]

ការផលិតថាមពលអគ្គិសនី និងការអភិវឌ្ឍគម្រោងទំនប់វារីអគ្គិសនីជាផែនការណ៍យុទ្ធសាស្ត្រសំខាន់ក្នុងការអភិវឌ្ឍជាតិ។ រាជរដ្ឋាភិបាលកម្ពុជាមានបំណងបង្កើនការផលិតថាមពលអគ្គិសនីក្នុងស្រុក តាមរយៈការសាងសង់ទំនប់វារីអគ្គិសនីលើសពី២០កន្លែង ទូទាំងប្រទេស។[10] ទំនប់វារីអគ្គិសនីសេសានក្រោម២ គឺជាទំនប់មួយក្នុងចំណោមទំនប់ដទៃ ដែលរដ្ឋាភិបាលយល់ឃើញថា មានសក្កានុពលក្នុងការបង្កើតថាមពលអគ្គិសនី ពីព្រោះតាមការប៉ាន់ប្រមាណ ទំនប់វារីអគ្គិសនីនេះ

---

[6] «របាយការណ៍ជំរឿនប្រជាសាស្ត្រកម្ពុជាឆ្នាំ២០០៨», ចេញផ្សាយឆ្នាំ២០០៩ដោយវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ

[7] http://www.sihanoukville-cambodiajournal.com/2011/12/08/new-hydro-dam-in-kampot/ (Searched website on May 11, 2012)

[8] http://www.business-in-asia.com/cambodia/cambodiainsight.html (Searched website on March 28, 2011)

[9] Cambodia Outlook Brief 2011, N$^{\underline{0}}$ 3 (CDRI) or http://www.cdri.org.kh/webdata/policybrief/ob11/ob3e.pdf (Searched website on Sep 14, 2012)

[10] The New York times: http://www.nytimes.com/2012/01/17/business/global/17iht-rbog-cam17.html?_r=2 (Searched website on May 11, 2012)

អាចបង្កើតថាមពលអគ្គិសនីបានប្រហែលជា៤០០ម៉េហ្គាវ៉ាត់[11] និងអាចផលិតថាមពលអគ្គិសនីបានជាមធ្យម១៩៥៨មេហ្គាវ៉ាត់ក្នុងមួយឆ្នាំ។[12] ជាក់ស្តែងរាជរដ្ឋាភិបាលកម្ពុជា បានអនុម័តប្រគល់ការវិនិយោគសាងសង់ទំនប់វារីអគ្គិសនីសេសានក្រោម២ ទៅអោយក្រុមហ៊ុនអគ្គិសនីវៀតណាម (EVN) និងក្រុមហ៊ុន (Royal Group) ដែលគម្រោងខ្នាតធំនេះមានភាគហ៊ុន៥១% ជារបស់ក្រុមហ៊ុន (EVN) និង៤៩% ជារបស់ក្រុមហ៊ុន (Royal Group)[13] ដើម្បីធ្វើការអភិវឌ្ឍន៍ដោយមានគម្រោងទឹកប្រាក់ចំនួន៨១៦លានដុល្លាអាមេរិក។[14] គម្រោងនេះនឹងសាងសង់ប្រវែង៨គីឡូម៉ែត្រ នៅលើទន្លេសេសាន ចន្លោះរវាងភូមិភ្លុក និងចំណុចប្រសព្វទន្លេសេសាន និងទន្លេស្រែពក។[15] ពិធីចុះហត្ថលេខាត្រូវបានរៀបចំឡើងកាលពីថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១១ ក្រោមអធិបតីភាពនាយករដ្ឋមន្ត្រីនៃប្រទេសទាំងពីរគឺកម្ពុជា និងវៀតណាម។[16]

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលត្រូវបានសិក្សាដោយក្រុមអ្នកជំនាញ(PECC1)[17] បានរកឃើញថាជាមួយនឹងកម្រិតកំពស់ទឹកក្នុងអាងស្តុក៨០ម៉ែត្រ ទំហំផ្ទៃដីចំនួន៨១៣.២គីឡូម៉ែត្រការ៉េ នៃឃុំស្រែគរ ឃុំតាឡាត និងឃុំក្បាលរមាស ដែលស្ថិតក្នុងស្រុកសេសាន ខេត្តស្ទឹងត្រែងនឹងត្រូវបានលិចលង់ទាំងស្រុងដោយអាងស្តុកទឹក ហើយឃុំភ្លុក ក្នុងស្រុកសេសាន ខេត្តស្ទឹងត្រែង និងឃុំស្រែអង្គ្រងក្នុងស្រុកកូនមុំ ខេត្តរតនគិរី នឹងត្រូវលិចលង់មួយផ្នែក ប៉ុន្តែបើកម្រិតកំពស់ទឹកក្នុងអាងស្តុកទឹក៧៥ម៉ែត្រ ជាជម្រើសក្នុងការសាងសង់នោះ ផ្ទៃទឹកនឹងមិនលិចលង់ដល់ឃុំ

[11] The Cambodia Daily, Volume 47, Issue 73, Tuesday, January 25, 2011
[12] http://en.wikipedia.org/wiki/Lower_Se_San_2_Dam#History (Searched website on May 03, 2011)
[13] http://www.banktrack.org/show/dodgydeals/lower_sesan_2_hydropower_project (Searched website on November 20, 2011)
[14] http://english.thesaigontimes.vn/Home/business/environment/18592/ (Searched website on December 10, 2011)
[15] របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ខែធ្នូឆ្នាំ២០០៩ របាយការណ៍បញ្ចប់ «គម្រោងវារីអគ្គិសនីសេសានក្រោម២»
[16] http://thesoutheastasiaweekly.com/?p=962 (Searched website on November 28, 2011)
[17] (PECC-1) Power Engineering Consulting Company 1

នៅខេត្តរតនគិរីទេ។[18] ការព្រួយបារម្ភជាច្រើនត្រូវបានលើកឡើងជុំវិញបញ្ហាគម្រោងសាងសង់ទំនប់វារីអគ្គិសនីសេសានក្រោម២ ស្ថិតនៅខេត្តស្ទឹងត្រែងដោយអង្គការបរិស្ថាននានា ប្រជាពលរដ្ឋ និងជាពិសេសប្រជាពលរដ្ឋប្រមាណជា៥ ០០០នាក់នឹងត្រូវផ្លាស់ទីលំនៅថ្មីបន្ទាប់ពីគម្រោងចាប់ផ្តើមដំណើរការ។[19] ជាពិសេស គម្រោងវារីអគ្គិសនីនេះនឹងធ្វើអោយមានផលប៉ះពាល់ ដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុង និងជុំវិញតំបន់គម្រោង ជាពិសេសតាមរយៈការបាត់បង់ដី ការបាត់បង់ព្រៃឈើ និងអនុផលព្រៃឈើ ការបាត់បង់ត្រី បញ្ហាគុណភាព និងបរិមាណទឹក និងហេដ្ឋារចនាសម្ព័ន្ធជាដើម។[20] ក្រៅពីផលប៉ះពាល់នៃការបាត់បង់ដីលំនៅដ្ឋាន និងដីកសិកម្មរបស់ប្រជាពលរដ្ឋ អាងស្តុកទឹកនៃគម្រោងនេះនឹងត្រូវបំផ្លាញដីព្រៃរហូតដល់៣០,០០០ ហិចតា ដោយរួមបញ្ចូលទាំងព្រៃសម្បទានឯកជនចំនួនជាង១០,០០០ហិចតាដែរ។ គួរកត់សម្គាល់ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន គឺមិនបានបញ្ជាក់ច្រើនទៅលើផលប៉ះពាល់នៃការនេសាទ និងមិនបានប៉ាន់ប្រមាណពីតម្លៃនិងរៀបចំខ្ទង់ចំណាយ នៃសំណងចំពោះផលប៉ះពាល់ទៅលើសហគមន៍ដែលរស់នៅខ្សែទឹកខាងក្រោម ដែលត្រូវរងផលប៉ះពាល់ដោយប្រយោលពីគម្រោងចំពោះការកាត់បន្ថយទិន្នផលត្រី។[21] ប្រជាពលរដ្ឋដែលនឹងត្រូវទទួលរងផលប៉ះពាល់ដោយផ្ទាល់ និងដោយប្រយោលគឺរួមមានទាំងជនជាតិដើមភាគតិចជាច្រើនដែលជាជនងាយរងគ្រោះ ពីព្រោះប្រជាពលរដ្ឋយ៉ាងហោចណាស់៨៧ភូមិ ដែលរស់នៅតាមដងទន្លេសេសាន និងទន្លេស្រែពក ព្រមទាំងនៅតំបន់អាងស្តុកទឹកអាចនឹងបាត់បង់ផលប្រយោជន៍ជាច្រើនពីធនធានត្រី។[22]

---

[18] របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ខែធ្នូឆ្នាំ២០០៩ របាយការណ៍បញ្ចប់ «គម្រោងវារីអគ្គិសនីសេសានក្រោម២»។

[19] http://www.internationalrivers.org/en/node/2970 (Searched website on April 05, 2011)

[20] របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ខែធ្នូឆ្នាំ២០០៩ របាយការណ៍បញ្ចប់ «គម្រោងវារីអគ្គិសនីសេសានក្រោម២»។

[21] April 2012, Mark Grimsditch "Understanding New Threats and Challenges from Hydropower Development to Biodiversity and Community Rights in the 3SRivers Basin".

[22] http://en.wikipedia.org/wiki/Lower_Se_San_2_Dam (Searched website on August 27, 2012)

# ២. ព័ត៌មានសង្ខេបអំពីទន្លេសេសាន និងស្រែពក

ផែនទី១- ទន្លេនៅតំបន់ភាគឦសានប្រទេសកម្ពុជា




នៅតំបន់ភាគឦសានប្រទេសកម្ពុជាមានដៃទន្លេចំនួនបីសំខាន់ៗ ដែលហូរចាក់ទៅទន្លេមេគង្គ ដូចជាទន្លេសេកុង សេសាន និងស្រែពក ក៏ប៉ុន្តែក្នុងនោះមានតែទន្លេចំនួនពីរគឺទន្លេសេសាន និងស្រែពកដែលស្ថិតនៅតំបន់គម្រោងទំនប់វារីអគ្គិសនីសេសានក្រោម២ ក្នុងស្រុកសេសាន ខេត្តស្ទឹងត្រែង។ ទន្លេសេសាន និងទន្លេស្រែពកមានប្រភពមកពីប្រទេសវៀតណាម [23] ហើយទន្លេស្រែពកនៅក្នុងប្រទេសកម្ពុជាហូរកាត់ខេត្តរតនគិរី មណ្ឌលគិរី និងស្ទឹងត្រែង ដែលនៅទីនោះវាហូរចូលក្នុងទន្លេសេសាន។ ទន្លេសេសានហូរចូលទន្លេសេកុង នៅលើចំណុចដែលទន្លេសេកុងហូរចូលទន្លេមេគង្គ។[24] ទន្លេសេសានមានប្រវែងសរុប៤៦២គីឡូម៉ែត្រ ជាមួយនឹងផ្ទៃរងទឹកភ្លៀង១៨.៨៨៨ គីឡូម៉ែត្រការ៉េ ហើយហូរកាត់ប្រទេសកម្ពុជាប្រវែង២៥២

[23] http://www.worldfishcenter.org/resource_centre/WF_3136.pdf (Searched website on June 19, 2012)

[24] លោកភីតធ័រ ស្ទីស, ខែមិនា ឆ្នាំ២០០៦ «ការចិញ្ចឹមជីវិតនៅតំបន់អាងទន្លេស្រែពកនៅប្រទេសកម្ពុជា»។

គីឡូម៉ែត្រ ចំណែកទន្លេស្រែពកមានប្រវែងសរុប៥២០គីឡូម៉ែត្រ ជាមួយនឹងផ្ទៃរងទឹកភ្លៀង៣០,៩៤២គីឡូម៉ែត្រការ៉េ ហើយហូរកាត់ប្រទេសកម្ពុជាប្រវែង២៥៥គីឡូម៉ែត្រ ដែលទន្លេទាំងពីរ ជាប្រភពទឹកដ៏សំខាន់សម្រាប់ផ្គត់ផ្គង់ដល់ជីវភាពប្រជាពលរដ្ឋ តាមដងទន្លេ។

## ៣. ការពិពណ៌នាអំពីគម្រោងទំនប់វារីអគ្គសនីសេសានក្រោម២

គម្រោងទំនប់វារីអគ្គិសនីសេសានក្រោម២ នឹងសាងសង់ឡើងក្នុងស្រុកសេសាន ខេត្តស្ទឹងត្រែង នៅលើទន្លេសេសាន ចន្លោះរវាងភូមិភ្លុក និងចំណុចប្រសព្វទន្លេសេសាន និងទន្លេស្រែពក ហើយមានចម្ងាយប្រហែលជា២៥ គីឡូម៉ែត្រនៃខ្សែទឹកខាងលើទៅទីរួមខេត្តស្ទឹងត្រែង។ ទំនប់មេនឹងចាក់ដីបង្ហាប់ស្មើសាច់ដែលមានប្រវែងសរុប៨គីឡូម៉ែត្រ កំពស់ខ្នងទំនប់៨៣ម៉ែត្រ ធៀបនឹងនីវ៉ូទឹកសមុទ្រ ឬប្រហែល៤០ម៉ែត្រ ខ្ពស់ជាងបាតទន្លេ និងមានទទឹងខ្នងលើ៨ម៉ែត្រ។ អាគារផលិតថាមពលនៅលើច្រាំងខាងឆ្វេងបំពាក់ដោយតួបីនចំនួន៥គ្រឿង ដែលមួយគ្រឿងៗមានសមត្ថភាពផលិតភ្លើង៨០មេហ្គាវ៉ាត់។ អាងស្តុកទឹកមានមាឌស្តុកទឹក១.៧៩ពាន់លានម៉ែត្រគូប ផ្ទៃអាង៣៣៥គីឡូម៉ែត្រការ៉េ ជាមួយនឹងនីវ៉ូទឹកក្នុងអាងស្តុកទឹកឡើងដល់កំពស់៧៥ម៉ែត្រ ធៀបនឹងនីវ៉ូទឹកសមុទ្រ។ ទំនប់នេះមានសមត្ថភាពផលិតថាមពលអគ្គិសនី៤០០មេហ្គាវ៉ាត់ ជាមួយថាមពលមធ្យមប្រចាំឆ្នាំ ១៩៥៣.៩លានគីឡូវ៉ាត់ម៉ោង ដោយចំណាយទឹកប្រាក់ចំនួន៨១៦ លានដុល្លាអាមេរិក។[25]

គម្រោងទំនប់វារីអគ្គិសនីសេសានក្រោម២ ត្រូវបានវិនិយោគហ៊ុនគ្នារវាងក្រុមហ៊ុនអគ្គិសនីវៀតណាម៥១% និងក្រុមហ៊ុនរ៉ូយ៉ាល់គ្រុបនៅកម្ពុជាចំនួន៤៩%[26] ដែលត្រូវបានផ្សព្វផ្សាយជាសាធារណៈនៅខែមេសា ឆ្នាំ២០១១ ដែលមានឈ្មោះថាក្រុមហ៊ុនវារីអគ្គិសនីកម្ពុជា វៀតណាម នឹងចាប់ផ្តើមដំណើរការប្រើប្រាស់នៅឆ្នាំ

---

[25] របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ខែធ្នូឆ្នាំ២០០៩ របាយការណ៍បញ្ចប់ «គម្រោងវារីអគ្គិសនីសេសានក្រោម២»

[26] http://www.banktrack.org/show/dodgydeals/lower_sesan_2_hydropower_project (Searched website on November 20, 2011)

២០១៧។[27] គួរកត់សម្គាល់ អគ្គិសនីដែលផលិតបាននឹងលក់ក្នុងតម្លៃ0.0៦២ដុល្លាអាមេរិក ក្នុងមួយគីឡូវ៉ាត់ម៉ោង ជាតម្លៃលក់ដុំទៅអោយអគ្គិសនីកម្ពុជា[28] ហើយថាមពលអគ្គិសនីដែលផលិតបាននឹងផ្គត់ផ្គង់តម្រូវការក្នុងស្រុកចំនួន៥0% និងនាំចេញទៅវៀតណាមចំនួន៥0%។[29] គម្រោងទំនប់វារីអគ្គិសនីខ្នាតធំនេះជាប្រភេទគម្រោងសាងសង់ ប្រតិបត្តិការ និងផ្ទេរ (BOT) ដែលមានរយៈពេលប្រតិបត្តិការ ៣0ឆ្នាំ ប្រើប្រាស់កំលាំងកម្មករប្រហែល៣,000នាក់ ហើយគេរំពឹងថាទំនប់នេះនឹងមានអាយុដំណើរការបាន១00ឆ្នាំ។

របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ត្រូវបានរៀបចំឡើងចាប់ពី ខែមករា ឆ្នាំ២00៨ ដល់ខែកក្កដា ឆ្នាំ២00៩ ដោយក្រុមហ៊ុនឃីខនសាល់ធេនខេមបូឌា (KCC) នៅក្រោមកិច្ចសន្យាពីក្រុមហ៊ុនផាវ័រអិនជិនញៀរីនខនសាល់ធីង-ទី១ (PECC-1) ដែលជាក្រុមហ៊ុនវៀតណាម។ ការចុះអនុស្សារណៈយោគយល់ (MOU) រវាងអគ្គិសនីវៀតណាម (EVN) និងក្រសួងឧស្សាហាកម្មរ៉ែ និងថាមពល នៃប្រទេសកម្ពុជាបានចុះហត្ថលេខានៅក្នុងខែមិថុនា ឆ្នាំ២00៧ អនុញ្ញាតអោយក្រុមហ៊ុន (EVN) ដើម្បីធ្វើការសិក្សាពីសមិទ្ធិលទ្ធភាព។[30]

---

[27] http://khmernz.blogspot.com/2011/04/sesan-dam-to-proceed-this-year.html (Searched website on September 19, 2012)

[28] របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ខែធ្នូឆ្នាំ២00៩ របាយការណ៍បញ្ចប់ «គម្រោងវារីអគ្គិសនីសេសានក្រោម២»

[29] April 2012, Mark Grimsditch “Understanding New Threats and Challenges from Hydropower Development to Biodiversity and Community Rights in the 3SRivers Basin”.

[30] របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ខែធ្នូឆ្នាំ២00៩ របាយការណ៍បញ្ចប់ «គម្រោងវារីអគ្គិសនីសេសានក្រោម២»

ផែនទី២- ទីតាំងគម្រោងទំនប់វារីអគ្គិសនីសេសានក្រោម២



# ជំពូកទី២-វិធីសាស្ត្រស្រាវជ្រាវ

## គោលបំណង

គោលបំណងសំខាន់នៃការសិក្សានេះ គឺស្វែងយល់ពីស្ថានភាពជីវភាពបច្ចុប្បន្នរបស់ប្រជាពលរដ្ឋ ដែលនឹងត្រូវទទួលរងផលប៉ះពាល់ដោយសារគម្រោងទំនប់វារីអគ្គិសនីសេសានក្រោម២ និងដើម្បីបង្ហាញពីទស្សនៈ និងការយល់ដឹងរបស់ប្រជាពលរដ្ឋទៅលើគម្រោង ផលប៉ះពាល់ ការផ្តល់សំណង និងការតាំងទីលំនៅថ្មី។

## ១. ដំណាក់កាលនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ត្រូវបានចែកចេញជាពីរដំណាក់កាលគឺ ការសិក្សាស្រាវជ្រាវជាមូលដ្ឋាន និងការសិក្សាស្រាវជ្រាវបញ្ចប់។ នៅក្នុងរបាយការណ៍ស្រាវជ្រាវជាមូលដ្ឋាននេះ នឹងបង្ហាញតែព័ត៌មានផ្សេងៗក្នុងដំណាក់កាលដែលប្រជាពលរដ្ឋមិនទាន់ប្តូរទីលំនៅថ្មីប៉ុណ្ណោះ ចំណែកឯការប្រមូលព័ត៌មានសម្រាប់ការសិក្សាស្រាវជ្រាវបញ្ចប់នឹងត្រូវធ្វើឡើង បន្ទាប់ពីប្រជាពលរដ្ឋបានប្តូរទីលំនៅថ្មីរយៈពេល២-៣ឆ្នាំ ដោយសារគម្រោងសាងសង់ទំនប់ ដើម្បីធ្វើការប្រៀបធៀបអំពីស្ថានភាពជីវភាពមុន និងក្រោយពេលប្តូរទីលំនៅថ្មី។

## ២. ការចុះអង្កេតផ្ទាល់មុនពេលចុះស្រាវជ្រាវ និងពេលចុះស្រាវជ្រាវ

ក្រុមការងារស្រាវជ្រាវបានចុះទៅមើលស្ថានភាពប្រជាពលរដ្ឋ ស្ថានភាពភូមិសាស្ត្រ និងស្រង់ស្ថិតិប្រជាពលរដ្ឋតាមភូមិគោលដៅនីមួយៗ ដោយរួមបញ្ចូលទាំងការសាកសួរព័ត៌មានតាមបែបមិនផ្លូវការមួយចំនួនពីប្រជាពលរដ្ឋ មេឃុំ ក៏ដូចជាអង្គការមូលដ្ឋាននៅតំបន់នោះពីថ្ងៃទី២១-២៤ ខែមិនា ឆ្នាំ២០១១ ដើម្បីជាគំនិតនិងយោបល់បន្ថែមក្នុងការធ្វើអោយការស្រាវជ្រាវ ក៏ដូចជាការរៀបចំបញ្ជីសំណួរអាចប្រមូលព័ត៌មានបានគ្រប់ជ្រុងជ្រោយ។ លើសពីនេះ កំឡុងពេលប្រមូលទិន្នន័យពីថ្ងៃទី២៩ ខែមេសា ដល់ថ្ងៃទី ០៥ ខែឧសភា ឆ្នាំ២០១១ តាមភូមិនីមួយៗជាមួយក្រុមគោលដៅ អ្នកស្រាវជ្រាវក៏ធ្វើការអង្កេតដោយផ្ទាល់ពីស្ថានភាពទូទៅក្នុងភូមិ និងសាកសួរព័ត៌មានផ្សេងៗ ទាក់ទងនឹងស្ថានភាពជីវភាពប្រជាពលរដ្ឋតាមបែបជជែកលេងជាមួយនឹងប្រជាពលរដ្ឋមួយចំនួន ដែលមិនត្រូវបានជ្រើសរើសអោយចូលរួមក្នុងការសិក្សានេះដើម្បីជាព័ត៌មានបន្ថែមសម្រាប់ជាគំនិតក្នុងការសរសេររបាយការណ៍។

## ៣. ការសាកល្បងបញ្ជីសំណួរ

បញ្ជីសំណួរត្រូវបានសាកល្បងចំនួន២លើក ដើម្បីវាយតម្លៃពីគុណភាពដើម្បីប្រមូលព័ត៌មាន។ លើកទី១ ត្រូវបានសាកល្បងដោយអ្នកស្រាវជ្រាវជាមួយបុគ្គលិកក្នុងអង្គការជាមួយគ្នា និងលើកទី២ត្រូវបានសាកល្បងដោយក្រុមអ្នកប្រមូលទិន្នន័យជាមួយប្រជាពលរដ្ឋ ដែលមានស្ថានភាពប្រហាក់ប្រហែលនឹងក្រុមគោលដៅ បន្ទាប់មកធ្វើការកែលំអរឡើងវិញនូវសំណួរមួយចំនួនអោយកាន់តែប្រសើរឡើង និងងាយយល់សម្រាប់ប្រជាពលរដ្ឋដើម្បីប្រមូលព័ត៌មាន។

## ៤. ការជ្រើសរើសទីតាំង

ខេត្តស្ទឹងត្រែង និងរតនគិរី មានព្រំប្រទល់ជាប់គ្នាហើយស្ថិតនៅភូមិភាគឦសាននៃប្រទេសកម្ពុជា។ ដោយសារតែគម្រោងសាងសង់ទំនប់វារីអគ្គិសនីសេសានក្រោម២ នឹងត្រូវសាងសង់នៅក្នុងស្រុកសេសាន ខេត្តស្ទឹងត្រែង ដូច្នេះឃុំចំនួន៥ មានដូចជាឃុំភ្លុក ស្រែគរ តាឡាត និងក្បាលរមាស នៃស្រុកសេសាន ខេត្តស្ទឹងត្រែង និងឃុំស្រែអង្រ្គង នៃស្រុកកូនមុំ ខេត្តរតនគិរី នឹងអាចទទួលរងផលប៉ះពាល់ដោយផ្ទាល់ និងដោយប្រយោលដោយសារទំនប់នេះ។ ដូច្នេះការសិក្សាស្រាវជ្រាវបានជ្រើសរើសភូមិចំនួន១៤ ដែលស្ថិតនៅឃុំទាំងនោះមកធ្វើការសិក្សាស្រាវជ្រាវ (សូមមើលតារាង និងផែនទីខាងក្រោម)។

តារាងទី១- ភូមិ ឃុំដែលបានជ្រើសរើសក្នុងការសិក្សា

| ខេត្ត | ស្ទឹងត្រែង | | | | រតនគិរី |
|---|---|---|---|---|---|
| ស្រុក | សេសាន | | | | កូនមុំ |
| ឃុំ | តាឡាត | ស្រែគរ | ភ្លុក | ក្បាលរមាស | ស្រែអង្រ្គង |
| ភូមិ | ១. តាឡាត | ១. ស្រែគរមួយ | ១.ភ្លុក | ១. ក្របីជ្រុំ | ១. ភូមិ ១ |
| | ២. រំពាត់ | ២. ស្រែគរពីរ | - | ២. ក្បាលរមាស | ២. ភូមិ ២ |
| | ៣. ស្វាយរៀង | - | - | ៣. ស្រែស្រណុក | ៣. ភូមិ ៣ |
| | ៤. ខ្សាច់ថ្មី | - | - | ៤. ច្រប់ | - |

# ផែនទី៣- ទីតាំងភូមិ ឃុំដែលបានជ្រើសរើសក្នុងការសិក្សា



| N◦ | Khmer Name | Latin Name |
|---|---|---|
| 1 | តាឡាត | Talat |
| 2 | រំពោត | Rum Poit |
| 3 | ស្វាយរៀង | Svay Rieng |
| 4 | ខ្សាច់ថ្មី | Khsach Tmey |
| 5 | ស្រែគរមួយ | Srekor Muoy |
| 6 | ស្រែគរពីរ | Srekor Pie |
| 7 | ភ្លុក | Phluk |
| 8 | គ្របីជ្រុំ | Krobei Chrum |
| 9 | ក្បាលរមាស | Kbal Romeas |
| 10 | ស្រែស្រណុក | Sre Sronok |
| 11 | ច្រប់ | Chrop |
| 12 | ភូមិ ១ | Phum 1 |
| 13 | ភូមិ ២ | Phum 2 |
| 14 | ភូមិ ៣ | Phum 3 |

## ៥. ការជ្រើសរើសគំរូតាង ឬសំណាក

តាមរបាយការណ៍ជំរឿនឆ្នាំ២០០៨ បានបង្ហាញថា ខេត្តស្ទឹងត្រែង និងខេត្តរតនគិរី គឺជាខេត្តដែលមានជនជាតិដើមភាគតិចរស់នៅច្រើន។ ហេតុនេះការសិក្សាក៏បានរួមបញ្ចូលប្រជាពលរដ្ឋជនជាតិដើមភាគតិច និងប្រជាពលរដ្ឋទូទៅដែលអាចនឹងទទួលរងផលប៉ះពាល់ ដោយសារគម្រោងសាងសង់ទំនប់វារីអគ្គិសនីសេសានក្រោម២។ ដើម្បីអោយការជ្រើសរើសចំនួនអ្នកតបសម្ភាសន៍ក្នុងការសិក្សានេះមានលក្ខណៈស្ថិតិវិទ្យាសាស្ត្រ និងត្រឹមត្រូវដែលអាចតំណាងអោយប្រជាពលរដ្ឋទូទាំងភូមិបាន ការសិក្សាបានគណនាតាមរូបមន្តដូចមានបង្ហាញក្នុងប្រអប់ខាងក្រោម។

រូបមន្ត:[31]

$$n=N/1+Ne^{2}$$

⇨ n=២១១០/១+២១១០×(០.០៥)^២ = **៣៣៦ ≈៣៥០**

n = ចំនួនសំណាក

N = ចំនួនប្រជាពលរដ្ឋសរុប*

e = កម្រិតលំអៀង

* N ក្នុងការសិក្សានេះតំណាងឲ្យចំនួនគ្រួសារសរុបដែលមានក្នុងតារាងទី២ខាងក្រោម
(ជ្រើសរើសម្នាក់ក្នុងមួយគ្រួសារដើម្បីសម្ភាសន៍)

ផ្អែកតាមរូបមន្តខាងលើ ចំនួនប្រជាពលរដ្ឋដែលត្រូវបានជ្រើសរើសតាមភូមិនីមួយៗដូចមានក្នុងតារាងខាងក្រោម ត្រូវបានកំណត់សម្រាប់ការសម្ភាសន៍:

[31] Yamane Formula 1967 or http://edis.ifas.ufl.edu/pd006 (Searched website on March 20, 2011)

តារាងទី២- ចំនួនប្រជាពលរដ្ឋដែលត្រូវបានជ្រើសរើសតាមភូមិនីមួយៗ

| ល | ឃុំ<br>ភូមិ | ចំនួនគ្រួសារសរុប | | ចំនួនគ្រួសារដែលបានជ្រើសរើសក្នុងការសិក្សា | | |
|---|---|---|---|---|---|---|
| | | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួនប្រធានភូមិ |
| ខេត្តស្ទឹងត្រែង | | | | | | |
| ១ | ឃុំតាឡាត | ៧១៤ | ៣៤ | ១១៥ | ៥.៤ | ៤ |
| ១.១ | ភូមិតាឡាត | ៧២ | ៣ | ១២ | ០.៦ | ១ |
| ១.២ | ភូមិរំពាត់ | ៥៦ | ៣ | ៩ | ០.៤ | ១ |
| ១.៣ | ភូមស្វាយរៀង | ២៧៦ | ១៣ | ៤៤ | ២ | ១ |
| ១.៤ | ភូមិខ្សាច់ថ្មី | ៣១០ | ១៥ | ៥០ | ២.៤ | ១ |
| ២ | ឃុំស្រែគរ | ៣៤១ | ១៦ | ៥៥ | ២.៦ | ២ |
| ២.១ | ភូមិស្រែគរមួយ | ១៧៦ | ៨ | ២៨ | ១.៣ | ១ |
| ២.២ | ភូមិស្រែគរពីរ | ១៦៥ | ៨ | ២៧ | ១.៣ | ១ |
| ៣ | ឃុំភ្លុក | ១៨៨ | ៩ | ៣០ | ១.៤ | ១ |
| ៣.១ | ភូមិភ្លុក | ១៨៨ | ៩ | ៣០ | ១.៤ | ១ |
| ៤ | ឃុំក្បាលរមាស | ៥០៦ | ២៤ | ៨២ | ៣.៩ | ៤ |
| ៤.១ | ភូមិក្របីជ្រុំ | ១៩៥ | ៩ | ៣១ | ១.៥ | ១ |
| ៤.២ | ភូមិក្បាលរមាស | ១២៨ | ៦ | ២១ | ១ | ១ |
| ៤.៣ | ភូមិស្រែស្រណុក | ១២៣ | ៦ | ២០ | ០.៩ | ១ |
| ៤.៤ | ភូមិច្រប់ | ៦០ | ៣ | ១០ | ០.៥ | ១ |
| ខេត្តរតនៈគិរី | | | | | | |
| ៥ | ឃុំស្រែអង្រ្គង | ៣៦១ | ១៧ | ៥៨ | ២.៧ | ៣ |
| ៥.១ | ភូមិ១ | ១០៥ | ៥ | ១៧ | ០.៨ | ១ |
| ៥.២ | ភូមិ២ | ១៣១ | ៦ | ២១ | ១ | ១ |
| ៥.៣ | ភូមិ៣ | ១២៥ | ៦ | ២០ | ០.៩ | ១ |
| សរុប | | ២១១០ | ១០០% | ៣៤០ | ១៦% | ១៤ |

*(ប្រភពទិន្នន័យបានមកពីការចុះប្រមូលទិន្នន័យកត់ត្រាផ្ទាល់នៅតាមឃុំ និងភូមិនីមួយៗក្នុងឆ្នាំ២០១១)*

តារាងទី៣-ក្រុមគោលដៅដែលបានចូលរួមក្នុងការសិក្សា

| ក្រុមគោលដៅ | ចំនួន |
|---|---|
| ១. ការសម្ភាសន៍ពាក់កណ្ដាលទំរង់ការតាមផ្ទះ | ៣១៥ នាក់ |
| ២. ការសម្ភាសន៍បុគ្គលសំខាន់ (ប្រធានភូមិ/អនុប្រធានភូមិ) | ១៣ នាក់ |
| ៣. ការពិភាក្សាក្រុម | ៥ ក្រុម x ៥នាក់ (២៥នាក់) |
| សរុប | ៣៥៣ នាក់ |

## ៦. ការវិភាគទិន្នន័យ

ការសិក្សានេះប្រើវិធីសាស្ត្ររួមគ្នាទាំងបែបគុណភាព និងបែបបរិមាណដើម្បីទទួលបានព័ត៌មានជាតួលេខ និងព័ត៌មានស៊ីជំរៅទាក់ទងនឹងប្រធានបទ។ ព័ត៌មានបែបគុណភាពដែលបានទទួលពីការពិភាក្សាក្រុម ការសម្ភាសន៍បុគ្គលសំខាន់ និងការសម្ភាសន៍គ្រួសារតាមផ្ទះ ត្រូវបានវាយបញ្ចូលទៅក្នុងប្រព័ន្ធកុំព្យូទ័រ។ បន្ទាប់មកព័ត៌មានទាំងនោះត្រូវបានធ្វើចំណាត់ថ្នាក់វិភាគ និងសរសេរជារបាយការណ៍តាមបែបពិព័ណ៌នាព័ត៌មានលំអិត ពិសេសបង្ហាញពីទស្សនៈ អារម្មណ៍ និងការយល់ដឹងរបស់អ្នកតបសម្ភាសន៍។ ចំណែកព័ត៌មានបែបបរិមាណត្រូវបានដាក់កូដ បញ្ចូលទិន្នន័យតាមកម្មវិធី SPSS Data Entry Builder និងវិភាគតាមកម្មវិធី SPSS តាមបែបបរិមាណ ដោយរៀបចំជាក្រាហ្វិក តារាង និងគំនូសទិន្នន័យផ្សេងៗតាមកម្មវិធី Microsoft Office Excel។ ទាំងព័ត៌មានបែបបរិមាណ និងគុណភាពត្រូវបានលើកយកមកព័ណ៌នាក្នុងរបាយការណ៍នេះ ដោយមានការដកស្រង់ឃ្លា ឬពាក្យពេជន៍ដែលសំខាន់ៗមកបញ្ជាក់បន្ថែមផងដែរ។

## ៧. វិសាលភាព និងដែនកំណត់នៃការសិក្សា

ដោយសារគម្រោងសាងសង់ទំនប់វារីអគ្គិសនីសេសានក្រោម២ មានវិសាលភាពប៉ះពាល់ទៅលើខេត្តស្ទឹងត្រែង និងរតនគិរី ដូច្នេះការសិក្សាផ្ដោតសំខាន់ទៅលើប្រជាពលរដ្ឋដែលនឹងត្រូវទទួលរងផលប៉ះពាល់ដោយសារគម្រោង ហើយនឹងត្រូវប្ដូរទីលំនៅថ្មី។ ជាពិសេសទៀតនោះ ការសិក្សាផ្ដោតសំខាន់ទៅលើជីវភាពបច្ចុប្បន្ន

របស់ប្រជាពលរដ្ឋ និងការយល់ដឹងអំពីព័ត៌មាននៃផលប៉ះពាល់របស់គម្រោងសំណង និងការតាំងទីលំនៅថ្មី។

ព័ត៌មាននៃការសិក្សានេះនឹងតំណាងអោយសម្លេង និងការព្រួយបារម្ភរបស់ប្រជាពលរដ្ឋទូទាំង១៨ភូមិ ដែលអាចនឹងទទួលរងផលប៉ះពាល់ដោយសារគម្រោងសាងសង់ទំនប់វារីអគ្គិសនីសេសានក្រោម២ ដែលបានបង្ហាញខាងលើ ប៉ុន្តែការសិក្សានេះមិនអាចតំណាងអោយករណីការសាងសង់ទំនប់ ឬការសិក្សស្រាវជ្រាវផ្សេងទៀតទូទាំងប្រទេសឡើយ។ ព័ត៌មានដែលបានបង្ហាញក្នុងរបាយការណ៍នេះជាព័ត៌មានមូលដ្ឋានសម្រាប់ជាគំនិត និងការពិចារណារបស់មហាជនទូទៅក្នុងការគិតគូរពីដំណោះស្រាយ ក៏ដូចជារិះរកវិធីសាស្រ្តណាដែលមានប្រសិទ្ធភាពដើម្បីអោយការអភិវឌ្ឍ គេចផុតពីផលប៉ះពាល់ជាអវិជ្ជមានទៅលើប្រជាពលរដ្ឋទូទៅក្នុងទ្រង់ទ្រាយធំ។

ការសិក្សានេះមិនបានបង្ហាញពីគោលជំហរប្រឆាំងនឹងរាជរដ្ឋាភិបាល ឬគណៈបក្សនយោបាយណាមួយឡើយ តែវាជាការសិក្សាមួយដោយឯករាជ្យក្នុងគោលបំណងបង្ហាញនូវអ្វីដែលជាព័ត៌មានជាក់ស្តែង ដែលប្រជាពលរដ្ឋបានបង្ហាញក៏ដូចជាសំណូមពរដើម្បីអោយអង្គការសង្គមស៊ីវិល រដ្ឋាភិបាល ក៏ដូចជាម្ចាស់ជំនួយផ្សេងៗទទួលបានព័ត៌មាន ឬបានឮពីកង្វល់នានា និងចូលរួមកាត់បន្ថយភាពក្រីក្រ ពង្រឹងការអភិវឌ្ឍប្រកបដោយនិរន្តរភាព ដើម្បីអោយប្រទេសកម្ពុជាកាន់តែរីកចំរើនឡើងក្នុងស្ថានភាពសន្តិភាព។

## ៨. ការសិក្សាលើឯកសារ

ឯកសារស្រាវជ្រាវ និងឯកសារសំខាន់ៗជាច្រើនដែលពាក់ព័ន្ធនឹងប្រធានបទត្រូវបានសិក្សាសម្រាប់ការសិក្សាស្រាវជ្រាវនេះ ហើយឯកសារទាំងនោះមានប្រភពពីអង្គការក្នុងស្រុក អង្គការអន្តរជាតិ និងស្ថាប័នរាជរដ្ឋាភិបាលនានា។ លើសពីនេះព័ត៌មាន និងទិន្នន័យមួយចំនួនដែលជាទិន្នន័យបន្ទាប់បន្សំទាក់ទងនឹងប្រធានបទតាមរយៈអត្ថបទស្រាវជ្រាវ និងសារព័ត៌មានផ្សេងៗដែលលើកយកមកប្រើជាឯកសារយោងក្នុងការសិក្សានេះដើម្បីផ្ទៀងផ្ទាត់ទិន្នន័យ និងបញ្ជាក់បន្ថែម ក៏ត្រូវបានប្រមូលពីប្រព័ន្ធគេហទំព័រផ្សេងៗផងដែរ។

# ៩. គោលគំនិតនៃការសិក្សា



# ជំពូកទី៣- លទ្ធផលនៃការស្រាវជ្រាវ

## លក្ខណៈប្រជាសាស្ត្រ

### ១. ជនជាតិ

តាមរយៈការសម្ភាសន៍តាមគ្រួសារគោលដៅបានបង្ហាញថា ក្នុងចំណោមមេគ្រួសារទាំងអស់ មានជនជាតិខ្មែរ៧០% ជនជាតិឡាវ២០% ជនជាតិព្នង៦% ជនជាតិគ្រឹង២% និងជនជាតិព្រៅ២%។ ចំពោះជនជាតិវៀតណាម និងជនជាតិទំពួនមានតិចជាងគេមិនដល់មួយភាគរយផង គឺត្រឹមតែ០.៦%ប៉ុណ្ណោះ សម្រាប់ជនជាតិទាំងពីរនេះ។ ហេតុផលមួយ ដែលសមាមាត្រដ៏ធំនៃជនជាតិសំខាន់ពីររស់នៅលាយឡំគ្នា ពិសេសជនជាតិឡាវ និងខ្មែរ ដោយសារតែតំបន់សិក្សាភាគច្រើនស្ថិតនៅជិតព្រំដែនប្រទេសឡាវ។ (សូមមើលក្រាហ្វិកទី១)

តាមរយៈការសម្ភាសន៍ជាមួយប្រធានភូមិ និងអនុប្រធានភូមិ ឃើញថានៅភូមិតាឡាត ស្វាយរៀង និងខ្សាច់ថ្មី ក្នុងឃុំតាឡាត ស្រុកសេសាន ខេត្តស្ទឹងត្រែង និងភូមិ១ ភូមិ២ និងភូមិ៣ ក្នុងឃុំស្រែអង្រ្កង ស្រុកកូនមុំខេត្តរតនគិរី មានប្រជាពលរដ្ឋភាគច្រើនជាជនជាតិខ្មែរ។ ចំណែកភូមិស្រែគរមួយ និងស្រែគរពីរ ក្នុងឃុំស្រែគរ ភូមិភ្លុក ក្នុងឃុំភ្លុក និងភូមិក្របីជ្រុំ ក្នុងឃុំក្បាលរមាស ស្ថិតក្នុងស្រុកសេសាន ខេត្តស្ទឹងត្រែង ប្រជាពលរដ្ឋភាគច្រើនជាជនជាតិឡាវ។ ចំពោះភូមិក្បាលរមាស ក្នុងឃុំក្បាលរមាស ប្រជាពលរដ្ឋភាគច្រើនជាជនជាតិព្នង ភូមិរំពាត់ ក្នុងឃុំតាឡាត ប្រជាពលរដ្ឋភាគច្រើនជាជនជាតិគ្រឹង និងភូមិច្រប់ ក្នុងឃុំក្បាលរមាស ប្រជាពលរដ្ឋភាគច្រើនជាជនជាតិព្រៅ។

ក្រាហ្វិកទី១- ជនជាតិ




## ២. ភាសា

ដោយសារភាពចម្រុះជាតិពិន្ទុនៃជនជាតិ ការប្រាស្រ័យទាក់ទងគ្នាពីសហគមន៍មួយទៅសហគមន៍ខាងភាសាក៏មានភាពចម្រុះគ្នាដែរ។ ភាសាខ្មែរ ឡាវ និងភាសាជនជាតិដើមភាគតិច ត្រូវបានគេប្រើប្រាស់ក្នុងការប្រាស្រ័យទាក់ទងគ្នានៅក្នុងតំបន់សិក្សា។ ភាសាឡាវ ត្រូវបាននិយមប្រើប្រាស់ប្រចាំថ្ងៃដោយប្រជាពលរដ្ឋភាគច្រើន បើទោះជាភាគច្រើនលើសលប់នៃប្រជាពលរដ្ឋនៅតំបន់សិក្សាជាជនជាតិខ្មែរក៏ដោយ។ តាមរយៈការសង្កេតផ្ទាល់នៅតាមតំបន់គោលដៅទាំងឡាយ ភាគច្រើន មនុស្សចាស់នៅក្នុងភូមិជាច្រើននៅស្រុកសេសាន ខេត្តស្ទឹងត្រែង អាចស្តាប់ភាសាខ្មែរបានខ្លះ តែមិនច្រើនទេ ហើយពួកគេមិនអាចនិយាយភាសាខ្មែរបានឡើយ។ ចំពោះមនុស្សវ័យជំទង់ ឬក្មេងៗអាចនិយាយ និងស្តាប់ភាសាខ្មែរបានល្អ ប៉ុន្តែពួកគេនៅតែប្រើប្រាស់ភាសាឡាវ ឬភាសាជនជាតិដើមភាគតិចក្នុងការទំនាក់ទំនងគ្នាប្រចាំថ្ងៃនៅក្នុងភូមិរៀងៗខ្លួន។

## ៣. មេគ្រួសារ

តាមរយៈការសិក្សាអំពីសេដ្ឋកិច្ចសង្គមឆ្នាំ២០០៩ បានបង្ហាញថា មេគ្រួសារភាគច្រើនគឺជាបុរស ហើយមេគ្រួសារជាស្ត្រីមានតិចតួចបំផុតនៅតំបន់ជនបទ។ [32] ដូចគ្នានេះដែរ ក្នុងចំណោមគ្រួសារគោលដៅដែលចូលរួមក្នុងការសិក្សាទាំង៣១៥គ្រួសារ មានបុរសជាមេគ្រួសារច្រើនជាងស្ត្រី ដែលក្នុងនោះមេគ្រួសារជាបុរសមាន៨៧% ខណៈពេលដែលមេគ្រួសារជាស្ត្រីមានត្រឹមតែ១៣%ប៉ុណ្ណោះ។ អ្វីដែលគួរអោយកត់សម្គាល់នោះគឺ ក្នុងចំណោម១៣%ដែលជាស្ត្រីមេគ្រួសារ មាន៨%ជាស្ត្រីមេម៉ាយ។

## ៤. ទំហំគ្រួសារ

ការរស់នៅរបស់ប្រជាពលរដ្ឋនៅតាមតំបន់សិក្សានេះ នៅមានលក្ខណៈជាគ្រួសារធំៗ ដែលមានសមាជិកជាច្រើនរស់នៅលាយឡំគ្នាដូចជាជីដូនជីតា ឪពុកម្ដាយ កូន កូនប្រសារ និងចៅរស់នៅមូលផ្តុំរួមគ្នាបង្កើតបានជាគ្រួសារធំ ហើយគ្រួសារខ្លះទៀតមានឪពុកមា ម្ដាយមីង និងក្មួយរស់នៅជាមួយផងដែរ។ ជាមធ្យមក្នុងមួយគ្រួសារមានសមាជិកចំនួន៥,៥៨នាក់ (ប្រហែល៦នាក់) ហើយគ្រួសារភាគច្រើនប្រមាណ៦៧.៩% មានចំនួនសមាជិកពី ៥-៩នាក់។ (សូមមើលក្រាហ្វិកទី២)

[32] វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ «ការសិក្សាពីសេដ្ឋកិច្ចសង្គមឆ្នាំ២០០៩»

ក្រាហ្វិកទី២- ចំនួនសមាជិកគ្រួសារ




## ៥. ឯកសារផ្លូវច្បាប់ក្នុងគ្រួសារ (ឬឯកសាររណប)

ការយល់ដឹងពីសារៈសំខាន់នៃការមានឯកសារផ្ទាល់ខ្លួន ដើម្បីបញ្ជាក់អត្តសញ្ញាណគ្រួសារក្នុងចំណោមអ្នកផ្តល់ការសម្ភាសន៍មានលក្ខណៈចម្រុះ ដោយសារគ្រួសារមួយចំនួន មិនទាន់មានឯកសារបញ្ជាក់អត្តសញ្ញាណគ្រប់គ្រាន់នៅឡើយ។ ការកាន់កាប់ឯកសារអត្តសញ្ញាណជាច្រើន រួមមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងសៀវភៅគ្រួសារមានចំនួនច្រើនជាងគេ បើប្រៀបធៀបទៅនឹងសៀវភៅស្នាក់នៅ និងពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លី(បង្កាន់ដៃទទួលស្គាល់សិទ្ធិកាន់កាប់ដី) ត្រឹមថ្នាក់ភូមិឃុំ ឬកិច្ចសន្យាលក់-ទិញ ដែលប្រជាពលរដ្ឋបានបង្ហាញកំឡុងពេលសម្ភាសន៍។

កង្វះខាតឯកសារសំអាង មិនមែនជាបច្ច័យល្អសម្រាប់ប្រជាពលរដ្ឋឡើយ ជាពិសេសប្រជាពលរដ្ឋ ដែលកំពុងតាំងទីលំនៅក្នុងតំបន់នៃការសិក្សានេះ។ ការសិក្សាពិនិត្យឃើញថា មានប្រមាណជាមួយភាគបួន នៃអ្នកដែលផ្តល់ការសម្ភាសន៍មិនមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ហើយច្រើនជាងមួយភាគបួន នៃអ្នកផ្តល់ការសម្ភាសន៍មិនមានសៀវភៅគ្រួសារ។ ទោះជាយ៉ាងណាក៏ដោយ នៅមានគ្រួសារតិចតួច ដែលខកខានមិនបានកសាងឯកសារផ្លូវច្បាប់សម្រាប់សម្គាល់អត្តសញ្ញាណ

របស់ខ្លួននៅឡើយដោយសារជាប់រវល់នៅស្រែចំការ និងមួយចំនួនបានធ្វើបាត់ ឬមិនចាំថាបានទុកឯកសារទាំងនោះនៅកន្លែងណានៅកំឡុងពេលសម្ភាសន៍។ ការរកឃើញនេះ ត្រូវបានបញ្ជាក់ថាត្រឹមត្រូវដោយប្រធានភូមិ ឬអនុប្រធានភូមិដែលមានភារកិច្ចសម្របសម្រួលអោយប្រជាពលរដ្ឋក្នុងភូមិរបស់ខ្លួនទទួលបានអត្តសញ្ញាណកម្ម។ ភាពប្រថុយប្រថានជាច្រើន អាចនឹងកើតឡើងទាក់ទងនឹងការបាត់បង់ភាពជាកម្មសិទ្ធិលើដីលំនៅដ្ឋាន ដោយសារការយល់ដឹងពីសារៈសំខាន់នៃពាក្យសុំកាន់កាប់ដីជាផ្លូវការមិនទាន់ច្បាស់លាស់។ (សូមមើលតារាងទី ៤)

តារាងទី៤- ប្រភេទឯកសារផ្លូវច្បាប់ក្នុងគ្រួសារ

| ប្រភេទឯកសារផ្លូវច្បាប់ | មាន | | គ្មាន | |
|---|---|---|---|---|
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ | ២៤០ | **៧៦** | ៧៥ | ២៤ |
| សៀវភៅគ្រួសារ | ២០០ | **៦៣** | ១១៥ | ៣៧ |
| សៀវភៅស្នាក់នៅ | ៩៨ | **៣១** | ២១៧ | ៦៩ |
| ពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លី | ៣៨ | **១២** | ២៧៧ | ៨៨ |

# ធនធានជីវភាព

## ធាតុសំខាន់ៗនៃធនធានជីវភាព

ធនធានជីវភាពត្រូវបានបែងចែកជា៥សំខាន់ៗគឺ ធនធានមនុស្ស ធនធានហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ធនធានហិរញ្ញវត្ថុ ធនធានធម្មជាតិ និងធនធានសង្គម។[33] ធនធានទាំងនេះ មិនត្រឹមតែមានទំនាក់ទំនងគ្នានោះទេ តែវាគឺជាតម្រូវការចាំបាច់សម្រាប់ជីវភាពប្រចាំថ្ងៃរបស់មនុស្សម្នាក់ៗ។




## ១. ធនធានមនុស្ស

### ១.១. ការអប់រំ

#### ១.១.១. ការអប់រំរបស់មេគ្រួសារ

មេគ្រួសារដែលបានចូលរួមក្នុងការសិក្សា ជាមធ្យមបានរៀនត្រឹមថ្នាក់ទី៣ (បឋមសិក្សា) ប៉ុណ្ណោះ។ ក្នុងនោះ មេគ្រួសារដែលទទួលបានការអប់រំនៅថ្នាក់បឋមសិក្សាមានភាគរយខ្ពស់ជាងគេ គឺរហូតដល់៥០.៨០% ថ្នាក់អនុវិទ្យាល័យមាន

[33] Oliver Serrat, Southeast Asia Department, Asian Development Bank “The Livelihoods Framework”. Asset Pantegone, Scoones, 1998.

១០.១០% ថ្នាក់វិទ្យាល័យមាន៤.៤០% និងអ្នកដែលមិនធ្លាប់បានចូលរៀនសោះមាន៣៣.៦០%។ ទាំងនេះអាចបញ្ជាក់បានថា ចំណេះដឹង និងការសំរេចចិត្តផ្សេងៗក្នុងគ្រួសារអាចជាកង្វល់សម្រាប់គ្រួសារមួយចំនួន។

តាមរយៈការសិក្សានេះ ស្ត្រីដែលជាមេគ្រួសារទាំង១៣% ក្នុងចំណោមអ្នកផ្តល់ការសម្ភាសន៍ មានតែ៦.៣០% បានរៀននៅថ្នាក់បឋមសិក្សា ចំណែក៦.៣០% ទៀត គឺមិនដែលបានចូលរៀននៅសាលាទាល់តែសោះ។ ចំណែក៨៧%ដែលជាបុរសមេគ្រួសារមាន៤៤.១០% បានចូលរៀននៅថ្នាក់បឋមសិក្សា មាន៣១%បានចូលរៀននៅថ្នាក់អនុវិទ្យាល័យ ១៣%រៀនបានត្រឹមថ្នាក់វិទ្យាល័យ ៤%ទៀតបានចូលរៀននៅវត្ត និងគួរអោយកត់សម្គាល់មាន២៧% គឺមិនដែលបានចូលរៀនសោះ។ (សូមមើលតារាងទី៥)

តារាងទី៥- ការអប់រំរបស់មេគ្រួសារ

| ការអប់រំ | បឋមសិក្សា | អនុវិទ្យាល័យ | វិទ្យាល័យ | រៀននៅវត្ត | មិនដែលបានរៀន | សរុប |
|---|---|---|---|---|---|---|
| ស្ត្រី | ២០ | ១ | ១ | ០ | ២០ | **៤២** |
| | ៦.៣០% | ០.៣០% | ០.៣០% | ០.០០% | ៦.៣០% | **១៣.៣០%** |
| បុរស | ១៣៩ | ៣១ | ១៣ | ៤ | ៨៦ | **២៧៣** |
| | ៤៤.១០% | ៩.៨០% | ៤.១០% | ១.៣០% | ២៧.៣០% | **៨៦.៧០%** |
| **សរុប** | ១៥៩ | ៣២ | ១៤ | ៤ | ១០៦ | **៣១៥** |
| | **៥០.៤០%** | **១០.១០%** | **៤.៤០%** | **១.៣០%** | **៣៣.៦០%** | **១០០%** |

ប្រៀបធៀបរវាងការអប់រំរបស់មេគ្រួសារជាបុរស និងមេគ្រួសារជាស្ត្រី តួលេខបង្ហាញថា មេគ្រួសារជាស្ត្រីទទួលបានការអប់រំតិចជាងបុរស ពីព្រោះស្ត្រីប្រមាណ៤៧.៦% នៃស្ត្រីជាមេគ្រួសារទាំងអស់មិនបានទទួលការអប់រំ ឬចូលរៀនទាល់តែសោះ តែមេគ្រួសារជាបុរសវិញមានអត្រាប្រមាណ៣១.៥% ប៉ុណ្ណោះ ដែលមិនបានទទួលការអប់រំ ឬចូលរៀន។ តាមរយៈការប្រៀបធៀបនេះបានបង្ហាញពីគំលាតខុសគ្នាប្រមាណ១៦% នៃការទទួលបានការអប់រំរវាងបុរស និងស្ត្រីជាមេ

គ្រួសារ ដែលទិន្នន័យនេះហាក់មានភាពប្រហាក់ប្រហែលគ្នាជាមួយនឹងឯកសាររបស់អង្គការ FAO ដែលបង្ហាញថាជាមធ្យមស្ត្រីទទួលបានការអប់រំតិចជាងបុរសប្រមាណជា២០%។[34] ប៉ុន្តែគម្លាតនេះ អាចនឹងមានផលប៉ះពាល់ចំពោះចំណេះដឹងក្នុងការសម្រេចចិត្តផ្សេងៗ ក្នុងជីវភាពប្រចាំថ្ងៃរបស់មេគ្រួសារជាស្ត្រីផងដែរ។

### ១.១.២ ការអប់រំរបស់កុមារ

#### ចម្ងាយពីផ្ទះទៅសាលារៀនបឋមសិក្សា

ជាទូទៅសាលារៀនបឋមសិក្សា និងវត្តអារាមគឺនៅជិតគ្នា ហើយសាលារៀនបឋមសិក្សាមាននៅស្ទើរគ្រប់ភូមិទាំងអស់នៅតំបន់គោលដៅដែលបានសិក្សាក្នុងឆ្នាំ២០១១។ បើតាមរបាយការណ៍ពីមន្ទីរអប់រំខេត្តស្ទឹងត្រែងឆ្នាំ២០០៧ សាលារៀនបឋមសិក្សាក្នុងឃុំទាំង៥ ដែលបានជ្រើសរើសក្នុងការសិក្សានេះមានចំនួន១២។

ដោយសារមានសាលារៀនបឋមសិក្សាជាច្រើននៅតាមឃុំនីមួយៗ និងស្ទើរគ្រប់ភូមិ ដូច្នេះជាមធ្យមសាលារៀនបឋមសិក្សាមានចម្ងាយ១១១៩,៨ ម៉ែត្រ ឬត្រឹមតែជាង១គីឡូម៉ែត្រពីផ្ទះគ្រួសារគោលដៅ ដែលចម្ងាយផ្លូវបែបនេះអំណោយផលយ៉ាងច្រើនសម្រាប់ការរៀនសូត្ររបស់កុមារ។

ក្រាហ្វិកខាងក្រោមបង្ហាញថា មានគ្រួសារចំនួន៩៦.៣% ដែលរស់នៅក្នុងចម្ងាយត្រឹមតែ១០០-៥០០ម៉ែត្រពីផ្ទះទៅសាលារៀន និង២៤.៨% ដែលរស់នៅក្នុងចម្ងាយ៥០១-១០០០ម៉ែត្រ ពីផ្ទះទៅសាលារៀន ដែលងាយស្រួលសម្រាប់កុមារធ្វើដំណើរទៅសាលារៀនបាន។ ក្រៅពីនេះក៏មានគ្រួសារត្រឹមតែ៧.៩% ដែលរស់នៅឆ្ងាយពីសាលារៀនក្នុងចម្ងាយលើសពី២០០០ម៉ែត្រ ឬលើសពី២គីឡូម៉ែត្រ ដែលចម្ងាយនេះអាចនឹងមានការលំបាកសម្រាប់កុមារតូច ដែលទើបនឹងដល់អាយុចូលរៀនក្នុងការធ្វើដំណើរទៅកាន់សាលារៀន។ (សូមមើលក្រាហ្វិកទី៣)

ក្រុមអ្នកផ្តល់សម្ភាសន៍ទាំងអស់ រួមទាំងប្រជាពលរដ្ឋ ប្រធានភូមិ និងក្រុមពិភាក្សា សុទ្ធតែមានជំនឿថាចម្ងាយផ្លូវទៅសាលារៀនមិនមែនជាឧបសគ្គឡើយ

[34] www.fao.org/sd/WPdirect/WPre0106.htm (Searched website on May 9, 2012)

សម្រាប់កុមារនៅក្នុងតំបន់នេះ ពោលគឺពិតជាផ្តល់ភាពងាយស្រួលដែលមានសាលារៀនក្នុងភូមិ ឬនៅជិតភូមិ ប៉ុន្តែមានឧបសគ្គខ្លះចំពោះកុមារដែលបានទៅតាមឪពុកម្តាយនៅស្រែចំការនៅរដូវធ្វើស្រែដែលឆ្ងាយពីភូមិ ដែលតម្រូវឲ្យពួកគេនៅឆ្ងាយពីសាលារៀនដែរ។ ឧបសគ្គនេះញ៉ាំងអោយពួកគេអាចនឹងខកខានការសិក្សា ឬមិនអាចទៅសាលារៀនបាន។

ក្រាហ្វិកទី៣- ចម្ងាយពីផ្ទះទៅសាលារៀនបឋមសិក្សា




## ការចុះឈ្មោះចូលរៀនរបស់កុមារអាយុពី៦-១១ឆ្នាំ

ដោយសារសាលារៀនបឋមសិក្សាផ្តល់អំណោយផល សម្រាប់ការចូលរៀនរបស់កុមារ គ្រួសារប្រមាណជា៧០% ក្នុងចំណោម៨៥% ដែលមានកុមារអាយុពី៦-១១ឆ្នាំ (*ឬចំនួន៨៣% ក្នុងចំណោម១០០%នៃគ្រួសារដែលមានកូនអាយុពី៦-១១ឆ្នាំទាំងអស់*) បានបញ្ជូនកូនតូចដែលដល់អាយុចូលរៀនទៅចុះឈ្មោះចូលរៀន ប៉ុន្តែមានគ្រួសារត្រឹមតែ១៥% ប៉ុណ្ណោះ ដែលមិនបាននាំកូនដល់អាយុចូលរៀនទៅចុះឈ្មោះចូលរៀន។ ស្ថិតិនេះត្រូវបានបញ្ជាក់ថាត្រឹមត្រូវតាមរយៈការពិភាក្សាជាមួយប្រជាពលរដ្ឋក្នុងក្រុមពិភាក្សា។ (សូមមើលតារាងទី៦)

បើតាមទិន្នន័យទូទាំងប្រទេសដែលបង្ហាញដោយអង្គការ UNDP ឆ្នាំ២០១០ បានកត់សម្គាល់ថា ការចុះឈ្មោះចូលរៀនរបស់កុមារនៅថ្នាក់បឋមសិក្សាមាន

៩៥.៨%។[35] ដូច្នេះតាមរយៈការសិក្សានេះ ក៏ដូចជាតាមរយៈទិន្នន័យទូទាំងប្រទេសបង្ហាញថាភាគច្រើនប្រជាពលរដ្ឋបានយល់ដឹងក្នុងការបញ្ជូនកូនដែលដល់អាយុចូលរៀនអោយទៅចុះឈ្មោះចូលរៀននៅថ្នាក់បឋមសិក្សា។

តារាងទី៦- ការចុះឈ្មោះចូលរៀនរបស់កុមារអាយុពី៦-១១ឆ្នាំ

| គ្រួសារដែលមានកុមារអាយុ ៦-១១ឆ្នាំ | ចំនួន | ភាគរយ |
|---|---|---|
| បានចុះឈ្មោះចូលរៀន | ២២២ | ៧០ |
| មិនបានចុះឈ្មោះចូលរៀន | ៤៧ | ១៥ |
| មិនមានកុមារស្ថិតក្នុងអាយុនេះ | ៤៦ | ១៥ |
| **សរុប** | **៣១៥** | **១០០** |

តាមរយៈការប៉ាន់ប្រមាណរបស់ប្រធានភូមិ ឬអនុប្រធានភូមិបង្ហាញថាជាមធ្យមការចុះឈ្មោះចូលរៀនរបស់កុមារមានចំនួន៦៦%។ ក្នុងនោះដែរ មានភូមិចំនួន៧ ដែលការចុះឈ្មោះចូលរៀនរបស់កុមារហាក់មានសន្ទុះខ្លាំងជាងគេរហូតដល់៨០ទៅ៩០% ដូចជាភូមិច្រប់ ភូមិស្រែគរមួយ ភូមិស្រែគរពីរ ភូមិក្របីជ្រុំ ភូមិខ្សាច់ថ្មី ភូមិភ្លុក ក្នុងស្រុកសេសាន ខេត្តស្ទឹងត្រែង និងភូមិ២ ក្នុងស្រុកកូនមុំ ខេត្តរតនគិរី។ ចំណែកភូមិចំនួន៤ទៀតដូចជា ភូមិស្វាយរៀង ភូមិរំពាត់ ភូមិតាឡាត ក្នុងស្រុកសេសាន ខេត្តស្ទឹងត្រែង និងភូមិ៣ ក្នុងស្រុកកូនមុំ ខេត្តរតនគិរី មានអត្រាចុះឈ្មោះចូលរៀនរបស់កុមារប្រហែលជា៥០% ហើយអត្រាភាគរយចុះឈ្មោះចូលរៀនរបស់កុមារដែលតិចជាងគេប្រហែលជា៣០%ប៉ុណ្ណោះ គឺមាននៅភូមិចំនួន២គឺភូមិ១ ក្នុងស្រុកកូនមុំ ខេត្តរតនគិរី និងភូមិក្បាលរមាស ក្នុងស្រុកសេសាន ខេត្តស្ទឹងត្រែង។ ដោយឡែក មាន១៣% នៃគ្រួសារទាំងអស់ដែលមានកូនគ្រប់អាយុចូលរៀន១នាក់មិនបានចុះឈ្មោះចូលរៀន និង២% ទៀតមានកូនដែលដល់អាយុចូលរៀន២នាក់មិនបានទៅចុះឈ្មោះចូលរៀន។(សូមមើលក្រាហ្វិកទី៤)

[35] UNDP, September 2010 «Current Status of Cambodian Millennium Development Goals (CMDG)» or http://www.un.org.kh/undp/media/files/pages/CMDG_current_status_19092010.pdf (Searched website on May 10, 2012)

ក្រាហ្វិកទី៤- ចំនួនកុមារដែលមិនបានចុះឈ្មោះចូលរៀន




## ឧបសគ្គរាំងការចុះឈ្មោះចូលរៀនរបស់កុមារអាយុ៦-១១ឆ្នាំ

កត្តាជាច្រើនរួមមានចម្ងាយផ្លូវទៅកាន់សាលារៀន (ចំពោះកុមារដែលទៅតាមឪពុកម្តាយនៅស្រែចំការឆ្ងាយពីផ្ទះ) គ្មានមធ្យោបាយធ្វើដំណើរទៅសាលារៀន ភាពក្រីក្ររបស់គ្រួសារ តម្រូវការកំលាំងពលកម្មរបស់គ្រួសារ សុទ្ធតែមានឥទ្ធិពលទៅលើការចុះឈ្មោះចូលរៀនរបស់កុមារ។ ក្នុងចំណោមគ្រួសារទាំង១៥% ដែលមានកូនគ្រប់អាយុចូលរៀន ខកខានមិនបានបញ្ជូនកូនទៅចុះឈ្មោះចូលរៀនដោយផ្អែកលើហេតុផលណាមួយក្នុងចំណោមហេតុផលខាងក្រោម។ (សូមមើលតារាងទី៧)

ការរកឃើញនេះក៏មានការយល់ស្របដោយក្រុមពិភាក្សា និងការសម្ភាសន៍ប្រធានភូមិ ឬអនុប្រធានភូមិដែលបានចូលរួមក្នុងការសិក្សានេះដែរ។

តារាងទី៧- ឧបសគ្គរាំងការចុះឈ្មោះចូលរៀនរបស់កុមារអាយុ៦-១១ឆ្នាំ

| មូលហេតុរាំងការចុះឈ្មោះចូលរៀន | ចំនួន | ភាគរយ |
|---|---|---|
| ឪពុកម្តាយយល់ថាកុមារនៅក្មេងពេក | ១៧ | ៣៣.៣ |
| កុមារខ្ជិលទៅរៀនដោយខ្លួនឯង | ១៣ | ២៥.៥ |
| សាលារៀននៅឆ្ងាយ/គ្មានមធ្យោបាយធ្វើដំណើរ | ៦ | ១១.៨ |
| គ្រួសារគ្មានលុយផ្គត់ផ្គង់ការសិក្សាកូន | ៦ | ១១.៨ |
| កុមារជួយធ្វើកិច្ចការងារផ្ទះឬនៅមើលថែរប្អូនតូចនៅផ្ទះ | ៥ | ៩.៨ |
| គ្រូឧស្សាហ៍អវត្តមាន | ២ | ៣.៩ |
| កុមារធ្វើការស៊ីឈ្នួលអោយគេដើម្បីរកលុយ ឬអាហារ | ២ | ៣.៩ |
| សរុប | ៥១ | ១០០ |

*ចំនួនអ្នកតបសម្ភាសន៍សរុប៣១៥នាក់

## ចំនួនកុមារអាយុក្រោម១៨ឆ្នាំ ដែលបោះបង់ចោលការសិក្សា

បើទោះជាមានសាលាបឋមសិក្សា ច្រើននៅក្នុងឃុំទាំង៥ ក្នុងតំបន់សិក្សាក៏ដោយ សិស្សដែលបានបន្តការសិក្សារបស់ពួកគេនៅអនុវិទ្យាល័យ និងខ្ពស់ជាងនេះ មានចំនួនតិចតួច។ ជាទូទៅ កុមារបោះបង់ចោលការសិក្សានៅពេលគេបញ្ចប់ថ្នាក់ទី១-៥ ឬនៅបឋមសិក្សា។[36] ក្នុងចំណោមគ្រួសារទាំងអស់ មានគ្រួសារចំនួន ៧៥% ដែលមានកុមារគ្រប់អាយុចូលរៀន តែក្រោម១៨ឆ្នាំ។ គួរអោយកត់សម្គាល់ មានគ្រួសារចំនួន១៩% ក្នុងចំណោមគ្រួសារទាំង៧៥% ដែលមានកុមារគ្រប់អាយុចូលរៀន តែក្រោម១៨ឆ្នាំ បានបោះបង់ចោលការសិក្សា បន្ទាប់ពីពួកគេបានចូលរៀនហើយ។ (សូមមើលក្រាហ្វិកទី៥)

[36] របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ខែធ្នូឆ្នាំ២០០៩ របាយការណ៍បញ្ចប់ «គម្រោងវារីអគ្គិសនីសេសានក្រោម២»

ក្រាហ្វិកទី៥-ចំនួនគ្រួសារដែលមានកុមារអាយុក្រោម១៨ឆ្នាំដែលបោះបង់ចោលការសិក្សា




ទិន្នន័យដែលទទួលបានពីការពិភាក្សាជាមួយប្រធានភូមិ ឬអនុប្រធានភូមិ បានបង្ហាញថា កុមារដែលមានអាយុក្រោម១៨ឆ្នាំចូលរៀនហើយឈប់ទៅវិញកើតឡើងច្រើនជាងគេគឺ ប្រហែលជា៥០% នៃកុមារទាំងអស់ដែលស្ថិតនៅក្នុងភូមិចំនួនពីរគឺ ភូមិ១ នៃឃុំស្រែអង្គ្រង ស្រុកកូនមុំ ខេត្តរតនគិរី និងភូមិក្បាលរមាស នៃឃុំក្បាលរមាស ស្រុកសេសាន ខេត្តស្ទឹងត្រែង។ បន្ទាប់មកកុមារដែលឈប់រៀនប្រហែលជា៣០% នៃកុមារទាំងអស់ដែលស្ថិតនៅក្នុងភូមិតាឡាតនិងភូមិខ្សាច់ថ្មី នៃឃុំតាឡាត ស្រុកសេសាន ខេត្តស្ទឹងត្រែង។ ក្រៅពីនេះ មានកុមារឈប់រៀនប្រហែលជា១០% ដែលស្ថិតនៅភូមិចំនួនប្រាំគឺ ភូមិច្រប់ ឃុំក្បាលរមាស ភូមិស្វាយរៀង ឃុំតាឡាត ភូមិស្រែគរពីរ ឃុំស្រែគរ ដែលស្ថិតក្នុងស្រុកសេសាន ខេត្តស្ទឹងត្រែង ជាមួយភូមិ៣ និងភូមិ២ ក្នុងឃុំស្រែអង្គ្រង ស្រុកកូនមុំ ខេត្តរតនគិរី។ ចំណែកឯភូមិចំនួនបីទៀតគឺភូមិរំពាត់ ក្នុងឃុំតាឡាត ភូមិភ្លុក ក្នុងឃុំភ្លុក និងភូមិក្របីជ្រុំ ក្នុងឃុំក្បាលរមាស នៃស្រុកសេសាន ខេត្តស្ទឹងត្រែង មានកុមារឈប់រៀនតិចតួចប៉ុណ្ណោះ ប្រហែលជា៥%។ ផ្សេងពីភូមិដែលបានរៀបរាប់ទាំងអស់នេះ គឺមានតែភូមិស្រែគរ

មួយ ដែលមិនបានបញ្ជាក់ពីភាគរយនៃកុមារដែលឈប់រៀន គ្រាន់តែមានការបញ្ជាក់ថាមានកុមារឈប់រៀនច្រើន។

## កត្តាដែលធ្វើអោយកុមារអាយុក្រោម១៨ឆ្នាំ បោះបង់ចោលការសិក្សា

ការពិនិត្យទៅលើស្ថានភាពបោះបង់ចោលការសិក្សារបស់សិស្ស ក៏ត្រូវបានដាក់បញ្ចូលសម្រាប់ការសិក្សានេះដែរ។ កត្តានានាដែលលើកយកមកពិភាក្សារួមមានបញ្ហាមធ្យោបាយធ្វើដំណើរមកសាលារៀន បញ្ហាប្រាក់ផ្គត់ផ្គង់ការសិក្សា បញ្ហាការជួយរកប្រាក់ផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃ បញ្ហាពេលវេលាសម្រាប់ជួយកិច្ចការផ្ទះដូចជាការថែរក្សាប្អូនៗ ដើម្បីទុកលទ្ធភាពឲ្យឪពុកម្តាយធ្វើស្រែចំការ ឬក៏ស្ថានភាពសុខភាពជាដើម។ ហេតុផលទាំងនេះ ក៏ត្រូវបានរកឃើញដោយរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ របស់គម្រោងទំនប់វារីអគ្គិសនីសេសានក្រោម២ដែរ។ (សូមមើលតារាងទី៨)

ទោះជាយ៉ាងណា ការពិភាក្សាក្រុមហាក់ពន្យល់ពីភាពខុសគ្នាមួយចំនួនជាមួយក្រុមអ្នកផ្តល់ចម្លើយខាងលើ។ ក្រុមពិភាក្សាបង្ហាញថា គ្រូបង្រៀនមិនបានមកបង្រៀនអោយបានទៀងទាត់ ប៉ុន្តែក្រុមនេះ ក៏មានការយល់ស្របដែរលើបញ្ហាជីវភាពខ្វះខាតដែលបង្ខំឲ្យកុមារត្រូវជួយធ្វើកិច្ចការងារនៅផ្ទះ និងស្រែចំការដើម្បីដោះស្រាយជីវភាពគ្រួសារ ហើយក៏ទទួលស្គាល់ដែរថាមានកុមារមួយចំនួនទៀតគឺខ្ជិលទៅរៀនដោយខ្លួនឯង *«ជីវភាពខ្វះខាតកូនជួយរកលុយដោយដើរព្រៃនិងនេសាទ តែឪពុកម្តាយបែជាមិនជំរុញយកូនចូលរៀន។ ខ្ញុំគិតថាបើក្មេងមានចំណេះដឹងខ្លះថ្ងៃក្រោយវាអាចជួយចិញ្ចឹមខ្លួនឯងបាន»*។

ចំណែកប្រធានភូមិ ឬអនុប្រធានភូមិនៅតាមបណ្តាភូមិគោលដៅបានបញ្ចេញមតិថា កុមារត្រូវឈប់រៀនដោយសារឪពុកម្តាយមិនបានយកចិត្តទុកដាក់ជំរុញកូនអោយទៅរៀន គ្រួសារខ្លះត្រូវការកំលាំងពលកម្មកុមារក្នុងការរួមចំណែកជួយជីវភាពគ្រួសារ ក្មេងមួយចំនួនមានចិត្តខ្ជិលទៅរៀន ឬរៀនលែងចូលដោយខ្លួនឯង និងជាពិសេសនោះគ្រូបង្រៀនមិនបានមកបង្រៀនអោយបានទៀងទាត់ *«កុមារប្រហែល៣០% រៀនហើយឈប់រៀនវិញដោយសារតែវាមិនយល់ពីសារៈសំខាន់នៃ*

*ការសិក្សា វាចូលចិត្តដើរលេង ហើយម្តាយឪពុកវាមិនយកចិត្តទុកដាក់ប្រាប់វាអោយមករៀន ហើយគ្រូក៏ឧស្សាហ៍អត់មកបង្រៀនបានជិតដល់ ដូច្នេះសិស្សខ្លះធ្វើអោយវាខ្ជិលមករៀន*»។

តារាងទី៨- មូលហេតុនៃការបោះបង់ចោលការសិក្សារបស់កុមារអាយុក្រោម១៨ឆ្នាំ

| មូលហេតុនៃការបោះបង់ចោលការសិក្សា | ចំនួន | ភាគរយ |
|---|---|---|
| ឪពុកម្តាយគ្មានលុយផ្គត់ផ្គង់ការសិក្សា | ១៦ | ២០.៨ |
| កុមារជួយធ្វើកិច្ចការងារផ្ទះ ឬនៅមើលថែប្អូនតូច | ១៦ | ២០.៨ |
| កុមារខ្ជិលទៅរៀនដោយខ្លួនឯង | ១២ | ១៥.៦ |
| សាលារៀននៅឆ្ងាយ/គ្មានមធ្យោបាយធ្វើដំណើរ (ចំពោះកុមារដែលទៅតាមឪពុកម្តាយនៅស្រែចំការឆ្ងាយពីផ្ទះ) | ១១ | ១៤.៣ |
| កុមារធ្វើការស៊ីឈ្នួលដើម្បីរកលុយ ឬអាហារ | ១១ | ១៤.៣ |
| គ្រូឧស្សាហ៍អវត្តមាន | ៩ | ១១.៧ |
| កុមារឆាប់រៀបការ | ១ | ១.៣ |
| កុមារមានជម្ងឺធ្ងន់ធ្ងរ | ១ | ១.៣ |
| **សរុប** | **៧៧** | **១០០** |

*ចំនួនអ្នកតបសម្ភាសន៍សរុប៣១៥នាក់

## ការលើកទឹកចិត្ត និងផ្សព្វផ្សាយអំពីការអប់រំនៅក្នុងភូមិ

តាមរយៈការផ្តល់ព័ត៌មានពីប្រធានភូមិ និងអនុប្រធានភូមិតាមបណ្តាភូមិគោលដៅបានអោយដឹងថា ការអប់រំផ្សព្វផ្សាយអំពីការអប់រំ ឬការជំរុញកុមារអោយទៅចុះឈ្មោះចូលរៀន ត្រូវបានធ្វើឡើងដោយអាជ្ញាធរភូមិ ឃុំតាមរយៈការហៅប្រជាពលរដ្ឋមកប្រជុំ ដើម្បីជំរុញដល់ឪពុកម្តាយកុមារអោយបញ្ជូនកូនៗទៅសាលារៀន «*ក្នុងភូមិនេះការលើកទឹកចិត្ត និងផ្សព្វផ្សាយអោយកុមារចូលរៀនគឺបានច្រើន មានអង្គការផ្សេងៗ ហើយខាងភូមិមានការប្រជុំផ្សព្វផ្សាយប្រចាំខែ និងនៅក្នុងពិធីបុណ្យផ្សេងៗនៅក្នុងភូមិ ហើយខាងភូមិ ក៏មានក្រុមផ្សព្វផ្សាយតាមផ្ទះដែរ*»។

## ១.២ សុខភាព

### មណ្ឌលសុខភាព

បើយោងតាមការពិភាក្សាក្រុមជាមួយប្រជាពលរដ្ឋ នៅតាមភូមិគោលដៅ ឃើញថា គ្រប់ភូមិទាំងអស់គ្មានមណ្ឌលសុខភាពក្នុងភូមិទេ តែមានប៉ុស្តិ៍សុខភាព[37] ចំនួន២ប៉ុណ្ណោះ ក្នុងចំណោមភូមិទាំង១៤។ ការពិភាក្សាក្នុងភូមិទាំង៥ បង្ហាញថា ភូមិក្របីជ្រុំ និងភូមិខ្សាច់ថ្មី មានចម្ងាយប្រមាណ៣០គីឡូម៉ែត្រ ពីមណ្ឌលសុខភាព ភូមិស្រែគរមួយ មានចម្ងាយ២០គីឡូម៉ែត្រ ពីមណ្ឌលសុខភាព ភូមិភ្លុកមានចម្ងាយ៨ គីឡូម៉ែត្រ ពីមណ្ឌលសុខភាព និងភូមិ២ មានចម្ងាយកន្លះគីឡូម៉ែត្រប៉ុណ្ណោះ ពីប៉ុស្តិ៍សុខភាព។ ចំណែកការសម្ភាសន៍គ្រួសារគោលដៅតាមផ្ទះបង្ហាញថា ប្រជាពលរដ្ឋមានការលំបាកក្នុងការទទួលសេវានៅមណ្ឌលសុខភាព ពីព្រោះមណ្ឌលសុខភាពជាទូទៅនៅឆ្ងាយពីភូមិដែលជាមធ្យមមានចម្ងាយ២១,៦៨៤ម៉ែត្រ ឬប្រហាក់ប្រហែលនឹង២១គីឡូម៉ែត្រ ដែលចម្ងាយនេះមានភាពប្រហាក់ប្រហែលទៅនឹងការបញ្ជាក់ពីប្រធានភូមិ ឬអនុប្រធានភូមិដែលបានលើកឡើងថា មណ្ឌលសុខភាពជាមធ្យមមានចម្ងាយ១៧គីឡូម៉ែត្រ ពីភូមិ។

ជាទូទៅ មណ្ឌលសុខភាពនៅតាមតំបន់ជនបទមិនមានសេវាព្យាបាលជម្ងឺកម្រិតធ្ងន់ធ្ងរនោះទេ តែផ្តល់ជាសេវាទប់ស្កាត់ ឬបង្ការជម្ងឺច្រើនជាង។ នៅមណ្ឌលសុខភាពមានសេវាព្យាបាលជម្ងឺដូចជាគ្រុនចាញ់ របេង គ្រុនក្តៅ គ្រុនពោះវៀន មុតរបួស ពន្យាកំណើត សំរាលកូន ពិនិត្យផ្ទៃពោះ រាករូស ក្អួត ពិនិត្យឈាម ចាក់ថ្នាំបង្កា និងសេវាបញ្ជូនអ្នកជម្ងឺទៅមន្ទីរពេទ្យបង្អែកខេត្តជាដើម។

---

[37] ប៉ុស្តិ៍សុខភាពជាកន្លែងផ្តល់សេវាសុខភាពក្នុងភូមិមានទ្រង់ទ្រាយតូចជាងមណ្ឌលសុខភាពដែលផ្តល់សេវាសុខភាពកម្រិតបឋម (ឧ.ផ្តល់ថ្នាំបង្ការ ថ្នាំគ្រាប់តិចតួច និងការផ្តល់ព្រឹក្សាខ្លះៗជាដើម) ដល់អ្នកភូមិដាច់ស្រយាលឆ្ងាយពីមណ្ឌលសុខភាព ហើយជាទូទៅ ប៉ុស្តិ៍សុខភាពមានបុគ្គលិកផ្តល់សេវាសុខភាពម្នាក់ប្រចាំការ។

## សេវាសុខភាពផ្សេងៗក្រៅពីមណ្ឌលសុខភាពដែលមានក្នុងតំបន់

តាមរយៈការពិភាក្សាក្រុមឃើញថា សេវាសម្រាប់បំរើដល់ប្រជាពលរដ្ឋក្នុងតំបន់មានដូចជាពេទ្យក្នុងភូមិដែលមានទទួលសេវាព្យាបាលជម្ងឺស្រាលៗ និងលក់ថ្នាំ តែមិនមែនជាពេទ្យដែលបានទទួលស្គាល់ពីក្រសួង ឬមន្ទីរសុខាភិបាលខេត្តនោះទេ។ សេវាក្នុងតំបន់នោះរួមមាន ព្យាបាលជម្ងឺគ្រុនចាញ់ គ្រុនពោះវៀន រាករូស ឈឺក្បាល ឈឺក្រពះ ការព្យាបាលតាមផ្ទះ(ពេទ្យមកចាក់ថ្នាំដល់ផ្ទះ) និងក្រៅពីនេះមានដូចជា ការផ្តល់ថ្នាំបង្ការ សេវាពន្យាកំណើត ពិនិត្យផ្ទៃពោះ និងសេវាជម្ងឺទូទៅផ្សេងទៀត។

## សេវាព្យាបាលសុខភាពដែលប្រជាពលរដ្ឋប្រើប្រាស់ញឹកញាប់

ប្រជាពលរដ្ឋភាគច្រើនស្មើនឹង៤៨.៦% គឺទៅរកសេវាព្យាបាលនៅមណ្ឌលសុខភាពញឹកញាប់ជាងគេ បន្ទាប់មក២៥.៤% ទៅរកសេវាគ្រូពេទ្យព្យាបាលក្នុងភូមិ ឬគ្រូពេទ្យព្យាបាលតាមផ្ទះ ១៨.១%ទៅរកសេវាព្យាបាលនៅគ្លីនិកឯកជន៥.៤% ទិញថ្នាំតាមតូបលក់ចាប់ហួយតូចៗក្នុងភូមិ និង១.៩%ទិញថ្នាំពីឱសថស្ថានដើម្បីព្យាបាលជម្ងឺ។ (សូមមើលក្រាហ្វិកទី៦)

បើតាមព័ត៌មានពីប្រធានភូមិ ឬអនុប្រធានភូមិបានបង្ហាញថា ៦១% នៃប្រជាពលរដ្ឋក្នុងតំបន់គឺស្វែងរកសេវាសុខភាពនៅមណ្ឌលសុខភាព ៨%ស្វែងរកសេវានៅគ្លីនិកឯកជន ៨%ទិញថ្នាំតាមតូបចាប់ហួយ ៨% ទៅរកសេវាគ្រូបុរាណ/ថ្នាំបុរាណ/ការបន់ស្រន់ និង១៥%ទៀតទៅរកសេវាព្យាលតាមផ្ទះដោយគ្រូពេទ្យក្នុងភូមិ។

អ្នកភូមិជាទូទៅ ព្យាបាលជម្ងឺដោយការទិញថ្នាំតាមឱសថស្ថាន តែបើពួកគេនៅមិនជាសះស្បើយទេ គឺហៅពេទ្យក្នុងភូមិមកព្យាបាលនៅផ្ទះ ហើយបើការព្យាបាលនេះនៅតែមិនមានប្រសិទ្ធភាពទៀតទើបត្រូវបញ្ជូនទៅកាន់មន្ទីរពេទ្យខេត្ត។ ដោយឡែក មានអ្នកចូលរួមក្នុងការសិក្សាចំនួនពីររូប ដែលបញ្ជាក់ថា ប្រជាពលរដ្ឋមួយចំនួនតូចប៉ុណ្ណោះ ដែលជ្រើសរើសយកការព្យាបាលដោយអបិយជំនឿសែនព្រេនផ្សេងៗ លុះពេលដែលជម្ងឺមិនបានជាសះស្បើយ ទើបទៅរកពេទ្យឯកជនទិញថ្នាំ ហើយបើការទិញថ្នាំនៅតែមិនជាសះស្បើយទៀត ទើបទៅរកសេវាព្យាបាលនៅមណ្ឌលសុខភាព។

ក្រាហ្វិកទី៦- សេវាព្យាបាដែលប្រជាពលរដ្ឋប្រើប្រាស់ញឹកញាប់




គួរកត់សម្គាល់ថា នៅភូមិក្របីជ្រុំ ក្នុងឃុំក្បាលរមាស ស្រុកសេសាន ខេត្តស្ទឹងត្រែង ប្រជាពលរដ្ឋនាំគ្នាទៅរកសេវាព្យាបាលនៅមណ្ឌលសុខភាព «មណ្ឌលសុខភាពឈ្មោះអូរពួង់» នៅឃុំស្រែអង្រ្គងស្រុកកូនមុំ ខេត្តរតនគិរី ព្រោះវានៅជិតជាងទៅខេត្តស្ទឹងត្រែង។ ចំពោះការប្រើប្រាស់សេវាសុខភាពនៅតាមភូមិនីមួយៗមានបង្ហាញក្នុងតារាងខាងក្រោម។ (សូមមើលតារាងទី៩)

ប្រជាពលរដ្ឋយល់ថា រាល់ការទៅព្យាបាលនៅពេទ្យរដ្ឋមិនរហ័សដូចនៅពេទ្យឯកជនទេ តែការព្យាបាលនៅពេទ្យឯកជនត្រូវចំណាយអស់ប្រាក់ច្រើនជាង *«ពេទ្យមានការខ្វះខាតមិនបានបំរើសេវា២៤ម៉ោងទេ ជាក់ស្តែងខ្ញុំគ្រូនទៅប៉ុស្តិ៍សុខភាពម៉ោង៧ព្រឹក មិនទាន់បើកទ្វាខ្ញុំមកផ្ទះវិញ ហើយម៉ោង១០ ខ្ញុំទៅទៀតអត់ទៀត (មិនទាន់បើកទ្វា) ល្ងាចទៅទៀត អត់ទៀត(មិនទាន់បើកទ្វា) ជម្ងឺមិនចាំម៉ោងទេ... ទៅប៉ុស្តិ៍សុខភាពមិនជួបពេទ្យ ក៏លក់មាន់ លក់ទា ទៅរកពេទ្យឈ្នួល ...»* ។

តារាងទី៩- ការប្រើប្រាស់សេវាសុខភាពនៅតាមភូមិនីមួយៗ

| ឈ្មោះភូមិ | មណ្ឌលសុខភាព | តូបលក់ថាប់ហួយ | ឱសថស្ថាន | គ្លីនិកឯកជន | គ្រូពេទ្យព្យាបាលតាមផ្ទះ/តាមភូមិ | ថ្នាំបុរាណ/គ្រូខ្មែរ/បន់ស្រន់ | សរុប |
|---|---|---|---|---|---|---|---|
| តាឡាត | ២ | ២ | - | ៥ | ៣ | - | ១២ |
| រំពាត់ | - | - | - | ៤ | ៣ | ២ | ៩ |
| ស្វាយរៀង | ១៣ | ១១ | - | ៩ | ១២ | - | ៤៥ |
| ខ្សាច់ថ្មី | ១៧ | ២ | - | ១១ | ១៥ | - | ៤៥ |
| ស្រែគរមួយ | ១៥ | - | ២ | - | ៥ | - | ២២ |
| ស្រែគរពីរ | ៦ | - | - | ១០ | ១១ | - | ២៧ |
| ភ្លុក | ១៩ | ១ | - | ៣ | ២ | - | ២៥ |
| ក្របីជ្រុំ | ១០ | - | ១ | ៤ | ១០ | - | ២៥ |
| ក្បាលរមាស | ៨ | ១ | ១ | - | ១២ | - | ២២ |
| ស្រែស្រណុក | ១២ | - | ១ | ៥ | ២ | - | ២០ |
| ច្រប់ | ៨ | - | - | ១ | ១ | - | ១០ |
| ភូមិ១ | ១៥ | - | - | ១ | ១ | - | ១៧ |
| ភូមិ២ | ១០ | - | - | ៤ | ២ | - | ១៦ |
| ភូមិ៣ | ១៨ | - | ១ | - | ១ | - | ២០ |
| **សរុប** | ១៥៣ | ១៧ | ៦ | ៥៧ | ៨០ | ២ | ៣១៥ |

**មូលហេតុនៃការជ្រើសរើសសេវាសុខភាពមួយប្រភេទដែលញឹកញាប់ជាងគេ**

តាមរយៈតារាងខាងក្រោមបង្ហាញថា មូលហេតុដែលប្រជាពលរដ្ឋជ្រើសរើសយកសេវាព្យាបាលពីមណ្ឌលសុខភាពច្រើនជាងគេ ដោយសារតែប្រជាពលរដ្ឋ២៦% យល់សេវាមណ្ឌលសុខភាព មានប្រសិទ្ធភាពអាចព្យាបាលអោយជាសះស្បើយ ២៤.៤%យល់ថាមណ្ឌលសុខភាពនៅជិតផ្ទះជាងកន្លែងដទៃ ១៧.៥%យល់ថាសេវាព្យាបាលមានតម្លៃទាប ឬត្រូវចំណាយលុយតិច ១៥.៦%យល់ថាសេវាកម្មល្អ (អ្នកផ្តល់សេវារួសរាយរាក់ទាក់ ផ្តល់សេវារហ័ស) និងមានមូលហេតុផ្សេងៗទៀតដូចមានបង្ហាញក្នុងតារាងខាងក្រោម។ ចំពោះសេវាព្យាបាលជម្ងឺដែលប្រជាពលរដ្ឋចូលចិត្តប្រើប្រាស់ញឹកញាប់ជាងគេបន្ទាប់មក គឺសេវាគ្រូពេទ្យព្យាបាលតាមភូមិ ឬ

គ្រូពេទ្យព្យាបាលតាមផ្ទះ ដោយសារតែគ្រូពេទ្យព្យាបាលមាននៅក្នុងភូមិ ឬនៅជិតភូមិស្រាប់ដែលងាយទៅរកមាន២១% ដោយសារជម្ងឺមិនសូវធ្ងន់ធ្ងរ (ឧ.ឈឺក្បាល ចុកពោះ គ្រុនផ្តាសាយ រាករូស) មាន១២.១% និងមានមូលហេតុផ្សេងៗទៀតដូចមានបង្ហាញក្នុងតារាងខាងក្រោម។ ចំណែកអ្នកដែលជ្រើសយកសេវាព្យាបាលនៅគ្លីនិកឯកជនញឹកញាប់ជាងគេដោយសារតែមាន១២.៧% យល់ថាសេវាកម្មល្អមាន ១១.៩%យល់ថាសេវាព្យាបាលមានប្រសិទ្ធភាពធ្វើអោយជាសះស្បើយ និងមានមូលហេតុផ្សេងៗទៀត ដូចមានបង្ហាញក្នុងតារាងខាងក្រោម។ បន្ទាប់មកចំពោះអ្នកដែលជ្រើសរើសទៅរកសេវាព្យាបាលដោយការទិញថ្នាំពីតូបចាប់ហួយតូចៗនៅក្នុងភូមិ ដោយសារតែជម្ងឺមិនធ្ងន់ធ្ងរមាន៣.៨%កន្លែងលក់ថ្នាំនៅជិតផ្ទះមាន៣.៨% ចំណាយលុយអស់តិចមាន២.២% និងមានមូលហេតុមួយចំនួនដូចមានបង្ហាញក្នុងតារាងខាងក្រោម។ ចំពោះប្រជាពលរដ្ឋដែលជ្រើសរើសការព្យាបាលដោយការទៅទិញថ្នាំនៅឱសថស្ថានដោយសារតែមាន១.៦% និយាយថាវាមានប្រសិទ្ធភាព ក្នុងការព្យាបាលបានជាសះស្បើយ មាន១.៣% និយាយថាវាមានសេវាកម្មល្អ និងមានមូលហេតុផ្សេងៗទៀតដូចមានបង្ហាញក្នុងតារាងខាងក្រោម។ គួរអោយចាប់អារម្មណ៍ចំពោះប្រជាពលរដ្ឋដែលនៅមានជំនឿលើការព្យាបាលតាមវិធីបុរាណ ឬការសែនព្រេនបានបង្ហាញថា ការព្យាបាលបែបនេះមានប្រសិទ្ធភាព និងជាជំនឿពីដូនតាផង។ (សូមមើលតារាងទី១០)

## តារាងទី១០- មូលហេតុនៃការជ្រើសរើសសេវាព្យាបាលសុខភាពមួយញឹកញាប់

| មូលហេតុ | មណ្ឌលសុខភាព | តូបលក់ថាប់ហួយ | ឱសថស្ថាន | គ្លីនិកឯកជន | គ្រូពេទ្យព្យាបាលតាមផ្ទះ/ភូមិ | ព្យាបាលតាមបែបបុរាណ/គ្រូបុរាណ/បន់ស្រន់ |
|---|---|---|---|---|---|---|
| មានប្រសិទ្ធភាព (ព្យាបាលជាសះស្បើយ) | ៨២ | ០ | ៥ | ៣៦ | ១៧ | ១ |
| | ២៦ % | ០ % | ១.៦ % | ១១.៤ % | ៥.៤ % | ០.៣ % |
| សេវាព្យាបាលមានតម្លៃទាប/ចំណាយលុយអស់តិច | ៥៥ | ៧ | ១ | ២ | ១៨ | ០ |
| | ១៧.៥ % | ២.២ % | ០.៣ % | ០.៦ % | ៥.៧ % | ០ % |
| មិនស្គាល់កន្លែងព្យាបាលដទៃទៀត | ៦ | ២ | ០ | ៣ | ៥ | ០ |
| | ១.៩ % | ០.៦ % | ០ % | ១ % | ១.៦ % | ០ % |
| សេវាកម្មល្អ | ៤៩ | ០ | ៤ | ៤០ | ១៧ | ១ |
| | ១៥.៦ % | ០ % | ១.៣ % | ១២.៧ % | ៥.៤ % | ០.៣ % |
| សេវាព្យាបាលនៅជិតផ្ទះ | ៧៧ | ១២ | ០ | ១៤ | ៦៦ | ០ |
| | ២៤.៤ % | ៣.៨ % | ០ % | ៤.៤ % | ២១ % | ០ % |
| ជម្ងឺមិនធ្ងន់ធ្ងរ | ២៨ | ១២ | ០ | ៧ | ៣៨ | ១ |
| | ៨.៩ % | ៣.៨ % | ០ % | ២.២ % | ១២.១ % | ០.៣ % |
| គ្មានមណ្ឌលសុខភាពនៅក្នុងភូមិ | ២ | ១ | ០ | ០ | ០ | ០ |
| | ០.៦ % | ០.៦ % | ០ % | ០ % | ០ % | ០ % |
| មានការផ្សព្វផ្សាយ | ២ | ០ | ០ | ០ | ០ | ០ |
| | ០.៦ % | ០ % | ០ % | ០ % | ០ % | ០ % |
| ផ្លូវងាយស្រួលធ្វើដំណើរ | ៣ | ០ | ០ | ០ | ០ | ០ |
| | ១ % | ០ % | ០ % | ០ % | ០ % | ០ % |
| ជំនឿពីដូនតាមក | ០ | ០ | ០ | ០ | ០ | ១ |
| | ០ % | ០ % | ០ % | ០ % | ០ % | ០.៣ % |
| ជម្ងឺធ្ងន់ធ្ងរ | ១ | ០ | ០ | ០ | ០ | ០ |
| | ០.៣ % | ០ % | ០ % | ០ % | ០ % | ០ % |
| សរុប / ៣១៥ | ១៥៣ | ១៧ | ៦ | ៥៧ | ៨០ | ២ |

នៅភូមិក្របីជ្រុំ ក្នុងឃុំក្បាលរមាស ស្រុកសេសាន ខេត្តស្ទឹងត្រែង ទាំងសេវាលក់ថ្នាំពេទ្យតាមភូមិ មណ្ឌលសុខភាព និងគ្រូពេទ្យដែលព្យាបាលតាមភូមិសុទ្ធតែ

មានប្រសិទ្ធភាពក្នុងការព្យាបាលបានជាសះស្បើយ ប៉ុន្តែគ្រូពេទ្យតាមភូមិ និងមណ្ឌលសុខភាព ព្យាបាលបានតែជម្ងឺតិចតួចប៉ុណ្ណោះ ពេលណាមានជម្ងឺធ្ងន់ត្រូវទៅព្យាបាលនៅមន្ទីពេទ្យខេត្ត។ នៅភូមិភ្លុក ក្នុងឃុំភ្លុក ស្រុកសេសាន ខេត្តស្ទឹងត្រែង និងភូមិ២ ក្នុងឃុំស្រែអង្គ្រង ស្រុកកូនមុំ ខេត្តរតនគិរីវិញ ប្រជាពលរដ្ឋយល់ថា សេវាព្យាបាលសុខភាពដែលមានផ្តល់អោយសុទ្ធតែបានកាត់បន្ថយជម្ងឺរបស់ប្រជាពលរដ្ឋក្នុងតំបន់ ហើយពេទ្យមណ្ឌលសុខភាពបានសហការជាមួយពេទ្យឃុំភ្លុក និងឃុំស្រែអង្គ្រងចុះមកផ្សព្វផ្សាយពីបញ្ហាសុខភាពដល់ប្រជាពលរដ្ឋក្នុងភូមិ ដូច្នេះប្រជាពលរដ្ឋបានចេះដឹងពីក្បួនអនាម័យ និងការការពារពីជម្ងឺផ្សេងៗដូចជាជម្ងឺគ្រុនចាញ់ *«ពេលមានពេទ្យថ្នាក់លើ ចុះមកណែនាំប្រជាពលរដ្ឋពីសុខភាព ឃើញថាប្រជាពលរដ្ឋរាល់ថ្ងៃកាត់បន្ថយការឈឺថ្កាត់ និងដាំបន្លែបង្កាជុំវិញផ្ទះហូបដោយគ្មានជាតិគីមី»*។

## ទឹកស្អាតសម្រាប់ពិសា

តាមរយៈការសិក្សាបានបង្ហាញថា ប្រជាពលរដ្ឋភាគច្រើនស្មើនឹង៧៨% បានដាំទឹកពុះសម្រាប់ពិសាក្នុងក្រុមគ្រួសារ បន្ទាប់មកមានប្រជាពលរដ្ឋ៨.៩% បានប្រើប្រាស់ធុងចម្រោះទឹកស្អាតដើម្បីពិសា និងមានតែ០.៣% ឬមួយគ្រួសារប៉ុណ្ណោះដែលទិញទឹកបរិសុទ្ធដែលផលិតក្នុងតំបន់សម្រាប់ការពិសាប្រចាំថ្ងៃ។ ទាំងនេះបង្ហាញថា ប្រជាពលរដ្ឋភាគច្រើនស្មើនឹង៨៧% បានយល់ដឹងអំពីអនាម័យទឹកសម្រាប់ពិសាក្នុងគ្រួសារដែលអាចបង្ការពីជម្ងឺមួយចំនួនផងដែរ។ ជាពិសេសចំណេះដឹងនៃក្បួនអនាម័យក្នុងគ្រួសារ ក៏ត្រូវបានពេទ្យឃុំចុះអប់រំតាមភូមិមួយចំនួនដែរ។ ដោយឡែក នៅមានប្រជាពលរដ្ឋប្រមាណជា១៣% ដែលមិនបានដាំទឹកពុះ ឬច្រោះទឹកអោយស្អាតសម្រាប់ពិសាប្រចាំថ្ងៃសម្រាប់ក្រុមគ្រួសារទេ គឺពួកគេពិសាទឹកឆៅព្រោះជាទំលាប់តាំងពីមុនមក។ (សូមមើលក្រហ្វិកទី៧)

ក្រាហ្វិកទី៧- ការអនាម័យទឹកសម្រាប់ពិសាក្នុងគ្រួសារ




## បង្គន់អនាម័យ

ជាទូទៅប្រជាពលរដ្ឋនៅតាមតំបន់ជនបទដាច់ស្រយាលភាគច្រើន មិនមានបង្គន់អនាម័យប្រើប្រាស់នោះទេ ដោយសារពួកគេមានទំលាប់មិនប្រើបង្គន់តាំងពីមុនមក ដោយការចូលទៅបន្ទោបង់ក្នុងព្រៃក្បែរផ្ទះ ឬក្នុងទឹក ឬជីកកប់ជាដើម ហើយមិនបានយល់ដឹងពីការប្រើប្រាស់បង្គន់អនាម័យ។ ទន្ទឹមនឹងនេះដែរ ការសិក្សាស្រាវជ្រាវដែលធ្វើឡើងជាមួយប្រជាពលរដ្ឋនៃភូមិគោលដៅបានបង្ហាញថា មានប្រជាពលរដ្ឋតែ១៥% ប៉ុណ្ណោះ ដែលមានបង្គន់អនាម័យ ដោយក្នុងនោះរួមមានបង្គន់ចាក់ទឹក១២% និងបង្គន់ជីករណ្តៅ៣%។ ដោយឡែក មានប្រជាពលរដ្ឋរហូតដល់ ៨៥% មិនមានបង្គន់អនាម័យសម្រាប់ប្រើប្រាស់ក្នុងគ្រួសារទេ។ អ្វីដែលគួរអោយចាប់អារម្មណ៍ ការសិក្សាក្នុងចំណោមភូមិទាំង១៤ មានភូមិចំនួន២ គឺភូមិតាឡាត និងភូមិរំពាត់ ក្នុងឃុំតាឡាត ស្រុកសេសាន ខេត្តស្ទឹងត្រែង មិនមានគ្រួសារគោលដៅដែលតបសម្ភាសន៍ណាមានបង្គន់អនាម័យសោះ។ ចំណែកឯភូមិចំនួន៤ ទៀតគឺ ភូមិក្បាលរមាស ភូមិស្រែស្រណុក និងភូមិច្រប់ ក្នុងឃុំក្បាលរមាស ស្រុកសេសាន ខេត្តស្ទឹងត្រែង និងភូមិ៣ ក្នុងឃុំស្រែអង្គ្រង ស្រុកកូនមុំ ខេត្តរតនគិរី មានតែអ្នកតប

សម្ភាសន៍ម្នាក់ប៉ុណ្ណោះពីភូមិនីមួយៗដែលនិយាយថា គ្រួសាររបស់គេមានបង្គន់អនាម័យ។ (សូមមើលក្រាហ្វិកទី៨)

ក្រាហ្វិកទី៨- ប្រភេទបង្គន់អនាម័យ




តាមការប៉ាន់ស្មានរបស់ប្រធានភូមិ ឬអនុប្រធានភូមិ ប្រជាពលរដ្ឋរស់នៅភូមិ១ ក្នុងឃុំស្រែអង្គ្រង ស្រុកកូនមុំ ខេត្តរតនគិរីមានលទ្ធភាពច្រើនជាងគេ ក្នុងការកសាងបង្គន់អនាម័យ ដែលស្ថិតិបង្ហាញថា គ្រួសារដែលមានបង្គន់មានចំនួន២៥០គ្រួសារ ហើយបន្ទាប់មកគឺ ភូមិស្រែគរមួយ ក្នុងឃុំស្រែគរ ស្រុកសេសាន ខេត្តស្ទឹងត្រែង ដែលបង្គន់អនាម័យចំនួន៩០ត្រូវបានប្រើប្រាស់។ ប្រការដែលប្រជាពលរដ្ឋនៅតាមជនបទពុំសូវជាមានអ្នកប្រើប្រាស់បង្គន់អនាម័យ ដោយសារពួកគេនិយមរស់នៅតាមទំលាប់ដែលអនុវត្តពីមួយជំនាន់ទៅមួយជំនាន់ និងម៉្យាងទៀតដោយសារគ្រួសារមួយចំនួនមិនមានថវិការសាងសង់បង្គន់។ ចំពោះគ្រួសារដែលមានបង្គន់ប្រើប្រាស់ តម្លៃសម្រាប់ការសាងសង់មានកម្រិតខុសៗគ្នាទៅតាមប្រភេទបង្គន់ តែការចំណាយសម្រាប់ការសាងសង់ប្រហែលជាមិនជាខ្ពស់ពេកទេ ព្រោះមានអង្គការមួយចំនួន *(ឧ.អង្គការកាកបាទក្រហមដែលអ្នកតបសម្ភាសន៍ម្នាក់នៅចាំឈ្មោះ)* បានផ្ដល់ជំនួយខ្លះចំពោះការសាងសង់បង្គន់សម្រាប់គ្រួសារមួយចំនួន ហើយគ្រួសារមួយចំនួនគ្រាន់តែចំណាយថវិកាខ្លះក្នុងការទិញសម្ភារៈសាងសង់ តែពលកម្មក្នុងការសាងសង់គឺសមាជិកគ្រួសារធ្វើដោយខ្លួនឯង។ (សូមមើលតារាងទី១១)

តារាងទី១១- ការចំណាយក្នុងការសាងសង់បង្គន់

| ការចំណាយ | បង្គន់ជីករណ្ដៅ | ភាគរយ | បង្គន់ចាក់ទឹក | ភាគរយ | ចំនួនសរុប |
|---|---|---|---|---|---|
| តិចជាង១០,០០០រៀល | ២ | ០.៧ | ៧ | ២.៣ | **៩** |
| ១០,០០០-៦៩,៩០០រៀល | ៦ | ២ | ៨ | ២.៦ | **១៤** |
| ៧០,០០០-១២,៩០០រៀល | - | - | ២ | ០.៧ | **២** |
| ១៣០,០០០-១៨៩,៩០០រៀល | - | - | ១ | ០.៣ | **១** |
| ១៩០,០០០-២៤៩,៩០០រៀល | - | - | ២ | ០.៧ | **២** |
| ៤០០,០០០រៀល-លើសពីនេះ | ១ | ០.៣ | ១៧ | ៥.៤ | **១៨** |
| **សរុប** | **៩** | **៣** | **៣៧** | **១២** | **៤៦** |

*ចំនួនអ្នកតបសម្ភាសន៍សរុប៣១៥នាក់

## ១.៣. សន្តិសុខក្នុងភូមិ

បញ្ហាសន្តិសុខជារឿងមួយក្នុងចំណោមបញ្ហានានា ដែលបានកត់សម្គាល់នៅក្នុងការសិក្សានេះ។ មានប្រជាពលរដ្ឋ៥៣% ដែលនិយាយថាក្នុងភូមិរបស់ខ្លួនមានបញ្ហាអសន្តិសុខកើតឡើង ចំណែក៤៧%ទៀតនិយាយថា មិនមានបញ្ហាអសន្តិសុខកើតឡើងក្នុងភូមិទេ។ តាមរយៈការអះអាងបញ្ជាក់ពីប្រជាពលរដ្ឋក៏ដូចជាអាជ្ញាធរក្នុងភូមិផ្ទាល់ បញ្ហាអសន្តិសុខត្រូវបានកំណត់លើសកម្មភាពមួយចំនួន រួមមានសកម្មភាពក្មេងទំនើងវាយតប់គ្នាពេលមានបុណ្យទាន សកម្មភាពចោរលួចចោរប្លន់ សកម្មភាពរំលោភសេពសន្ថវៈ និងសកម្មភាពហិង្សាក្នុងគ្រួសារជាដើម។ ក្នុងចំណោមគ្រួសារដែលនិយាយថាមានបញ្ហាអសន្តិសុខនៅក្នុងភូមិ ភាគច្រើនកើតឡើងនៅភូមិខ្សាច់ថ្មី ក្នុងឃុំតាឡាត និងភូមិក្របីជ្រុំ ក្នុងឃុំក្បាលរមាស ក្នុងស្រុកសេសាន ខេត្តស្ទឹងត្រែង។ ចំណែកភូមិដែលកើតមានបញ្ហាអសន្តិសុខតិចជាងគេបំផុតគឺភូមិច្រប់ ក្នុងឃុំក្បាលរមាស ស្រុកសេសាន ខេត្តស្ទឹងត្រែង និងភូមិ២ ក្នុងឃុំស្រែអង្គ្រង ស្រុកកូនមុំ ខេត្តរតនគិរី។

ប្រធានភូមិ និងអនុប្រធានភូមិ ដែលបានចូលរួមក្នុងការសិក្សានេះ បានបញ្ចេញយោបល់ទាក់ទងនឹងសន្តិសុខផ្សេងៗ នៅក្នុងភូមិរបស់ខ្លួនដោយក្នុងនោះមានប្រធានភូមិ និងអនុប្រធានភូមិចំនួន៥រូប មកពីភូមិស្រែគរមួយ និងស្រែគរពីរ ក្នុងឃុំស្រែគរ ភូមិក្របីជ្រុំ និងភូមិក្បាលរមាស ក្នុងឃុំក្បាសរមាស ស្រុកសេសាន ខេត្តស្ទឹងត្រែង និងភូមិ២ ក្នុងឃុំស្រែអង្គ្រង ស្រុកកូនមុំ ខេត្តរតនគិរី បញ្ជាក់ថាមិនមានបញ្ហាអសន្តិសុខផ្សេងៗកើតឡើងក្នុងភូមិ រំខានដល់ការរស់នៅរបស់ប្រជាពលរដ្ឋទេ ដោយសារតែភូមិមួយចំនួនមានក្រុមការពារសន្តិសុខភូមិដោយខ្លួនឯង និងមានប៉ូលីសការពារពេលមានបុណ្យទានម្តងៗ។ ចំណែកប្រធានភូមិ និងអនុប្រធានភូមិចំនួន៨រូបផ្សេងទៀត មកពីភូមិរំពាត់ ស្វាយរៀង តាឡាត ខ្សាច់ថ្មី ក្នុងឃុំតាឡាត ភូមិភ្លុក ក្នុងឃុំភ្លុក ភូមិច្រប់ ក្នុងឃុំក្បាលរមាស ដែលស្ថិតក្នុងស្រុកសេសាន ខេត្តស្ទឹងត្រែង និងភូមិ១ ភូមិ៣ ឃុំស្រែអង្គ្រង ស្រុកកូនមុំ ខេត្តរតនគិរី បង្ហាញថានៅក្នុងភូមិរបស់ខ្លួនមានជួបបញ្ហាអសន្តិសុខ ដូចជាបញ្ហាក្មេងទំនើងផឹកស្រាស្រវឹងបង្ករការវាយតប់គ្នាពេលមានបុណ្យទាន ការទទួលទានគ្រឿងស្រវឹងប្រើអំពើហិង្សាក្នុងគ្រួសារ មានអ្នកមកពីក្រៅភូមិលួចកាប់ព្រៃសហគមន៍ លួចបាញ់គោក្របី និង លួចគោក្របីអ្នកភូមិ បញ្ហាជម្លោះរវាងអ្នកភូមិ និងក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច ដោយសារក្រុមហ៊ុនរំលោភយកដីអ្នកភូមិ និងមានបទល្មើសនេសាទ។ *«ពេលមានកម្មវិធីបុណ្យរាំលេង ក្មេងៗផឹកស្រាហើយវាយតប់គ្នា...។ អំពើហិង្សាក្នុងគ្រួសារមានតិចតួចដោយសារការផឹកស្រាមិនធ្វើការងារ។ ... ប្រជាជនភូមិនេះមានការបាត់បង់គោក្របីដោយសារចោរលួច ព្រោះពួកគាត់លែងក្របីគោចោល (ចិញ្ចឹមសត្វដោយលែងអោយដើរដោយសេរី)»* ។

ការសាកសួរប្រជាពលរដ្ឋតាមគ្រួសារគោលដៅសម្ភាសន៍ បានបង្ហាញថា ៩១% និយាយថា នៅភូមិរបស់ពួកគេមានការចងក្រងជាក្រុមដែលមានការចូលរួមពីប្រជាពលរដ្ឋក្នុងភូមិ ប្រធានភូមិ និងអនុប្រធានភូមិ ដើម្បីការពារសន្តិសុខក្នុងភូមិ (ក្រុមនេះកើតឡើងដោយប្រជាពលរដ្ឋក្នុងភូមិ និងប្រធានភូមិ/អនុប្រធានភូមិ ក្នុងគោលបំណង រក្សាសន្តិសុខពេលមានកម្មវិធីបុណ្យទានប្រពៃណីរាំលេងផ្សេងៗ និង

រក្សាសុវត្ថិភាពក្នុងភូមិពីពួកចោរ ក្មេងស្ទាវ និងការប្រើអំពើហិង្សាតែមិនមានគណៈកម្មការនោះទេ) ហើយក្នុងនោះមានប្រជាពលរដ្ឋចំនួន២ភូមិគឺ ភូមិភ្លុក ក្នុងឃុំភ្លុក និងភូមិក្របីជ្រុំ ក្នុងឃុំក្បាលរមាស ស្រុកសេសាន ខេត្តស្ទឹងត្រែង ដែលបានបញ្ជាក់ថា ក្នុងភូមិរបស់ខ្លួនមានក្រុមការពារសន្តិសុខច្រើនជាងគេ។ ចំណែកប្រជាពលរដ្ឋចំនួន៥៩%ទៀត បានបញ្ជាក់ថាមិនមានការចងក្រងគ្នាជាក្រុមការពារសន្តិសុខក្នុងភូមិទេ។ មានភូមិចំនួន៧ ដែលមានការចងក្រងគ្នាជាក្រុមដើម្បីការពារសន្តិសុខក្នុងភូមិ ដូចជាភូមិភ្លុក ក្នុងឃុំភ្លុក ភូមិស្វាយរៀង និងភូមិតាឡាត ក្នុងឃុំតាឡាត ភូមិក្របីជ្រុំ ភូមិក្បាលរមាស និងភូមិច្រប់ ក្នុងឃុំក្បាលរមាស ស្ថិតក្នុងស្រុកសេសាន ខេត្តស្ទឹងត្រែង និងភូមិ១ ក្នុងឃុំស្រែអង្រ្គង ស្រុកកូនមុំ ខេត្តរតនគិរី ។ គួរអោយកត់សម្គាល់ ក្នុងចំណោមភូមិទាំង៧ខាងលើនេះ មានភូមិមួយចំនួនត្រូវបានសមត្ថកិច្ចចុះជួយដោះស្រាយ និងមានភូមិមួយចំនួនទៀត ត្រូវបានអាជ្ញាធរក្នុងភូមិដូចជាប្រធានភូមិ ឬអនុប្រធានភូមិជាអ្នកដោះស្រាយ ពេលជួបបញ្ហាអសន្តិសុខ។ ជាបទពិសោធន៍សម្រាប់ភូមិមួយក្នុងចំណោមភូមិទាំងអស់ មានអនុប្រធានភូមិម្នាក់បានបង្ហាថា*«ក្នុងភូមិមានគណៈកម្មការយេនឌ័រគណៈកម្មការភូមិ និងចាស់ព្រឹទ្ធាចារ្យក្នុងភូមិជាអ្នកដោះស្រាយដោយអោយគ្រួសារដែលប្រើអំពើហិង្សាផ្តិតមេដៃថាលែងបង្កបញ្ហាទៀត ហើយការដោះស្រាយនេះតែងតែមានប្រសិទ្ធភាព»* ។

# ២. ធនធានហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត

## ២.១. កម្មសិទ្ធិដីធ្លី

### ២.១.១. ច្បាប់ទាក់ទងនឹងកម្មសិទ្ធិដីធ្លី

ច្បាប់ភូមិបាលនៃប្រទេសកម្ពុជា ឆ្នាំ២០០១ បានបង្ហាញពីចំណុចមួយចំនួនទាក់ទងនឹងសិទ្ធិកាន់កាប់ដីភោគៈត្រឹមត្រូវតាមច្បាប់របស់ប្រជាពលរដ្ឋដូចជា ជំពូកទី៤ មាត្រា៣៨ បានចែងថាដើម្បីក្លាយទៅជាកម្មសិទ្ធិលើអចលនវត្ថុបាន លុះត្រាតែភោគៈនោះត្រូវបានកាន់កាប់ដោយពិតប្រាកដ គ្មានហិង្សាដឹងឮជាសាធារណៈ គ្មានអាក់ខាន និងដោយសុច្ចរិត។ ចំណែកជំពូកទី១ មាត្រា៦ បានចែងថាមានតែភោគៈ

ត្រឹមត្រូវតាមច្បាប់ប៉ុណ្ណោះដែលអាចនាំឲ្យបានកម្មសិទ្ធិ ហើយមាត្រា៥ ក៏បានចែងដែរថា គ្មានបុគ្គលណាមួយត្រូវបានគេដកហូតកម្មសិទ្ធិរបស់ខ្លួនបានទេ ប្រសិនបើការដកហូតនេះមិនមែនដើម្បីប្រយោជន៍សាធារណៈ។ ការដកហូតត្រូវធ្វើទៅតាមទំរង់ និងនីតិបញ្ញត្តិដោយច្បាប់ និងបទបញ្ជា បន្ទាប់ពីបានផ្តល់សំណងជាមុនដោយសមរម្យ និងយុត្តិធម៌។ មួយវិញទៀត ដោយសារការសិក្សានេះមានការចូលរួមពីប្រជាពលរដ្ឋជនជាតិដើមភាគតិច ដូច្នេះមានការជជែកទាក់ទងនឹងកម្មសិទ្ធិលើអចលនវត្ថុរបស់ពួកគេ ដូចជាក្នុងមាត្រា២៣ នៃច្បាប់ភូមិបាលបង្ហាញថា សហគមន៍ជនជាតិដើមភាគតិច គឺជាក្រុមមនុស្សដែលរស់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលសមាជិកទាំងអស់បង្ហាញនូវការឯកភាពនៃជាតិពិន្ទុ សង្គមវប្បធម៌ និងសេដ្ឋកិច្ច ប្រតិបត្តិរបៀបរស់នៅតាមប្រពៃណី និងដាំដុះលើដីដែលខ្លួនកាន់កាប់ទៅតាមក្បួនខ្នាតទំនៀមទំលាប់នៃការប្រើប្រាស់ជាសមូហភាព។ ក្នុងការរង់ចាំការកំណត់ផ្លូវច្បាប់នូវលក្ខន្តិកៈរបស់សហគមន៍ ហើយត្រូវអនុវត្តតាមបញ្ញត្តិនៃច្បាប់នេះ។ ក្រៅពីច្បាប់ភូមិបាល សិទ្ធិជាម្ចាស់លើកម្មសិទ្ធិ ត្រូវបានការពារដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៨ ក្នុងនោះ មាត្រា៤៤ ចែងថាជនណាក៏ដោយ ទោះជាបុគ្គលក្តីសមូហភាពក្តី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ។ មានតែរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិខ្មែរទេ ទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី។

យោងតាមមាត្រាមួយចំនួនទាក់ទងនឹងច្បាប់ភូមិបាល និងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាខាងលើនេះ ប្រជាពលរដ្ឋដែលកំពុងរស់នៅតំបន់គោលដៅនៃការសិក្សាគឺមានសិទ្ធិជាម្ចាស់កម្មសិទ្ធិស្របច្បាប់លើដីធ្លី ដែលពួកគេកំពុងរស់នៅពីព្រោះពួកគេសុទ្ធតែរស់នៅទីនោះតាំងពីយូរ និងជាប្រចាំលើទឹកដីដូនតារបស់គេដែលមិនមែនជាដីសាធារណៈរបស់រដ្ឋដោយគ្មានជម្លោះ និងពិសេសមុនឆ្នាំ២០០១។

### ២.១.២. កម្មសិទ្ធិដីលំនៅដ្ឋាន

នៅខេត្តស្ទឹងត្រែង និងរតនគិរី ដែលជាតំបន់គោលដៅនៃការសិក្សាមិនទាន់បានចាប់ផ្តើមចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធនៅឡើយទេ។[38] យ៉ាងណាមិញមាន

[38] ព្រឹត្តិប័ត្តកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី ច្បាប់ទី២«ដីជាជីវិត» ខែវិច្ឆិកា ២០១១

គ្រួសារចំនួន១២% ប៉ុណ្ណោះមានពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លី (បង្កាន់ដៃទទួលស្គាល់សិទ្ធិកាន់កាប់ដី) ត្រឹមថ្នាក់ភូមិឃុំ ឬកិច្ចសន្យាលក់-ទិញ។ ចំណែក ៨៨% ផ្សេងទៀត ការកាន់កាប់ដីគឺ គ្មានលិខិតស្នាមសម្រាប់បញ្ជាក់ពីភាពជាម្ចាស់កម្មសិទ្ធិលើដីធ្លីរបស់ខ្លួននៅឡើយទេ។ លើសពីនេះ ប្រជាពលរដ្ឋយល់ថា សព្វថ្ងៃពួកគេរស់នៅលើដីដែលជាកម្មសិទ្ធិបន្តពីដូនតារយៈពេលយូរមកហើយ ដូច្នេះពួកគេមានភាពជាម្ចាស់លើដីធ្លីទាំងនេះដោយស្របច្បាប់ ទោះមិនមានលិខិតស្នាម ឬឯកសារបញ្ជាក់ផ្សេងៗក៏ដោយ។ (សូមមើលក្រាហ្វិកទី៩)

ក្រាហ្វិកទី៩- ចំនួនគ្រួសារដែលមានបង្កាន់ដៃ ឬកិច្ចសន្យាសម្គាល់សិទ្ធិដីធ្លី




### ២.១.៣.កម្មសិទ្ធិដី និងទំហំដីកម្មសិទ្ធក្រៅពីដីលំនៅដ្ឋាន

តាមស្ថិតិដែលបានស្រង់ពីគ្រួសារនៅភូមិគោលដៅទាំង១៤ភូមិ បង្ហាញថាមានប្រជាពលរដ្ឋ៩២.១% មានដីស្រែ ៥៧.៨% មានដីចំការ ២៥.៩%មានដីព្រៃ ៨.៣%មានដីទំនេរទុកចោលមិនមានដាំដំណាំ និង៣.៥%មិនមានដីផ្សេងក្រៅពីដីលំនៅដ្ឋាន។[39] ដូចគ្នានេះដែរ បើយោងតាមតារាងខាងក្រោមបង្ហាញថា ក្រៅពីដី

[39] ចំនួនភាគរយនៃប្រភេទដីនីមួយៗដែលប្រជាពលរដ្ឋមានគឺធៀបនឹងមួយរយភាគរយ (ឧ.ប្រជាពលរដ្ឋដែលមានដីស្រែមានចំនួន៩២.១ភាគរយ ក្នុងចំណោមមួយរយភាគរយ ប្រជាពលរដ្ឋដែលមានចំការមានចំនួន៥៧.៨ភាគរយ ក្នុងចំណោមមួយរយភាគរយ)។

លំនៅដ្ឋាន គ្រួសារភាគច្រើនស្មើនឹង៣៨% មានដីស្រែ និងដីចំការ បន្ទាប់មកគឺគ្រួសារដែលមានតែដីស្រែមាន២៥% គ្រួសារដែលមានទាំងដីស្រែ ដីចំការ និងដីព្រៃមាន១១% និងគ្រួសារដែលមានទាំងដីស្រែ និងដីព្រៃមាន១០%។ ជាពិសេស ប្រជាពលរដ្ឋដែលចូលរួមក្នុងការសិក្សានេះប្រមាណ៦៧% មានដីផ្សេងក្រៅពីដីលំនៅដ្ឋានច្រើនជាងមួយប្រភេទ។ (សូមមើលតារាងទី១២)

ប្រជាពលរដ្ឋភាគច្រើន មានដីស្រែ ដីចំការ សម្រាប់ដាំដំណាំ ដោយសារតែជីវភាពពួកគេស្ទើរតែពឹងផ្អែកទាំងស្រុងលើវិស័យកសិកម្ម ដែលមានដំណាំស្រូវជាចំបង ចំណែកប្រជាពលរដ្ឋដែលមិនមានដីស្រែចំការគឺ ពួកគេប្រកបរបរដោយស៊ីឈ្នួលដោយប្រើកំលាំង លក់ដូរតិចតួច នេសាទ រកអនុផលព្រៃឈើជាដើម ដែលផ្សេងពីការងារស្រែចំការ។

តារាងទី១២- ប្រភេទដីកម្មសិទ្ធិផ្សេងពីដីលំនៅដ្ឋាន

| ប្រភេទដីផ្សេងក្រៅពីដីលំនៅដ្ឋាន | ចំនួន | ភាគរយ |
|---|---|---|
| ១. មានតែដីស្រែ | ៧៩ | <u>២៥</u> |
| ២. មានតែដីចំការ | ៨ | ៣ |
| ៣. មានតែដីព្រៃ | ៣ | ១ |
| ៤. គ្មានដីផ្សេងក្រៅពីដីលំនៅដ្ឋាន | ១១ | ៤ |
| ៥. មានដីស្រែ និងដីចំការ | ១១៩ | <u>៣៨</u> |
| ៦. មានដីស្រែ និងដីព្រៃ | ៣០ | <u>១០</u> |
| ៧. មានដីចំការ និងដីព្រៃ | ៣ | ១ |
| ៨. មានដីស្រែ និងដីទំនេរទុកចោល | ៥ | ១ |
| ៩. មានដីស្រែ ដីចំការ និងដីព្រៃ | ៣៥ | <u>១១</u> |
| ១០. មានដីស្រែ ដីចំការ និងដីទំនេរទុកចោល | ១៣ | ៤ |
| ១១. មានដីស្រែ ដីព្រៃ និងដីទំនេរទុកចោល | ៤ | ១ |
| ១២. មានដីស្រែ ដីចំការ ដីព្រៃ និងដីទំនេរទុកចោល | ៤ | ១ |
| **សរុប** | **៣១៥** | **១០០** |

ចំពោះដីកម្មសិទ្ធិផ្សេងក្រៅពីដីលំនៅដ្ឋាន មានប្រជាពលរដ្ឋ៤២.៦% មានដី ១,៥០ហិចតា ឬតិចជាងនេះ ៤៣.៨% មានដី២-៣,៥០ហិចតា ៩.៩% មានដី៤-៥,៥០ ហិចតា ២.២%មានដី ៦-៧,៥០ហិចតា និង១.៦%មានដី៨ហិចតា ឬលើសពីនេះក្នុង ចំណោមប្រជាពលរដ្ឋ១០០%។ ដោយឡែក មានប្រជាពលរដ្ឋចំនួន១១គ្រួសារ ឬ ៣.៥% ដែលមិនមានដីផ្សេងក្រៅពីដីលំនៅដ្ឋាន។ យោងតាមតារាងខាងក្រោម ក្នុងចំណោមប្រជាពលរដ្ឋទាំង៩២.១% ដែលមានដីស្រែ ក្នុងនោះមានប្រជាពលរដ្ឋ ៤១.៦% មានដីទំហំពី២ទៅ៣,៥ហិចតា និង៣៨.៤%មានដីស្រែ១,៥ហិចតា ឬ តិចជាងនេះ។ ចំណែកប្រជាពលរដ្ឋ៥៧.៨% ដែលមានដីចំការ ក្នុងនោះមានប្រជា ពលរដ្ឋ២៧% មានដីចំការ ១,៥ហិចតា ឬតិចជាងនេះ ចំណែក២៣.១% មានដីចំការ ពី២ទៅ៣.៥ហិចតា។ (សូមមើលតារាងទី១៣)

តារាងទី១៣- ទំហំដីកម្មសិទ្ធិក្រៅពីដីលំនៅដ្ឋាន

| ទំហំដី | ដីស្រែ | | ដីចំការ | | ដីព្រៃ | | ដីទំនេរទុកចោល | | គ្មានដី | |
|---|---|---|---|---|---|---|---|---|---|---|
| *(គិតជាហិចតា)* | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន |
| ០ ហិចតា ឬគ្មាន | - | - | - | - | - | - | - | - | ៣.៥ | ១១ |
| ១,៥ ហិចតា ឬ តិចជាងនេះ | <u>៣៨.៤</u> | ១២១ | <u>២៧</u> | ៨៥ | ១០.១ | ៣២ | ២.៥ | ៨ | - | - |
| ២-៣,៥ ហិចតា | <u>៤១.៦</u> | ១៣១ | <u>២៣.១</u> | ៧៣ | ១១.១ | ៣៥ | ៤.៤ | ១៤ | - | - |
| ៤-៥,៥ ហិចតា | ៨.៣ | ២៦ | ៦ | ១៩ | ២.៩ | ៩ | ១ | ៣ | - | - |
| ៦-៧,៥ ហិចតា | ២.២ | ៧ | ១.៣ | ៤ | ០.៦ | ២ | - | - | - | - |
| ៨ ហិចតា ឬ លើសពីនេះ | ១.៦ | ៥ | ០.៣ | ១ | ០.៦ | ២ | ០.៣ | ១ | - | - |
| **សរុប** | **៩២.១** | **២៩០** | **៥៧.៨** | **១៨២** | **២៥.៤** | **៨០** | **៨.៣** | **២៦** | **៣.៥** | **១១** |

*ចំនួនអ្នកតបសម្ភាសន៍សរុប៣១៥នាក់

## ២.២. លំនៅដ្ឋាន

### ២.២.១. កម្មសិទ្ធិផ្ទះ

អ្នកតបសម្ភាសន៍ដែលរស់នៅតាមភូមិគោលដៅក្នុងការសិក្សា បានបង្ហាញថាពួកគេទាំងអស់គ្នាសុទ្ធតែរស់នៅផ្ទះជាកម្មសិទ្ធិផ្ទាល់របស់ខ្លួន ឬគ្រួសារមួយចំនួនរស់នៅផ្ទះជាកម្មសិទ្ធិផ្ទាល់របស់ឪពុកម្តាយ ព្រោះពួកគេរស់នៅជាគ្រួសារធំមានសមាជិកច្រើនរស់នៅជុំគ្នា ហើយមិនមានគ្រួសារណាមួយរស់នៅដោយការជួល ឬនៅផ្ទះអ្នកដទៃឡើយ។

### ២.២.២. ប្រភេទផ្ទះ

ជាទូទៅប្រជាពលរដ្ឋនៅតាមតំបន់ជនបទនៃប្រទេសកម្ពុជា គឺសាងសង់ផ្ទះអំពីឈើ ដំបូលប្រក់ស័ង្កសី ឬស្លឹកតាមជីវភាពជាក់ស្តែង។ ទន្ទឹមនឹងនេះ ប្រភេទផ្ទះដែលពេញនិយម និងមានច្រើនជាងគេនៅតំបន់គោលដៅនៃការសិក្សា គឺជាប្រភេទផ្ទះឈើដែលមានដំបូលស័ង្កសី ជញ្ជាំងឈើ ក្តារ កុងផ្លាកកេ ឬស័ង្កសី និងមានកំរាលជាឈើដែលមានចំនួន៦៥.៤%។ ប្រភេទផ្ទះបែបនេះ ពេញនិយមជាងគេដោយសារតែនៅតំបន់សិក្សាជាតំបន់ដែលមានព្រៃឈើ ហេតុនេះតម្លៃឈើក៏មិនថ្លៃដូចនៅតំបន់ទីក្រុង ឬតំបន់ដែលគ្មានព្រៃឈើ ហើយដំបូលស័ង្កសីក៏ជាប្រភេទដំបូលដែលមានតម្លៃទាបជាងដំបូលក្បឿង ឬដំបូលហ្វីប្រូស៊ីម៉ង់ដទៃទៀតដែរ ដូច្នេះផ្ទះឈើប្រក់ដំបូលស័ង្កសី ជាប្រភេទផ្ទះដែលអាចធ្វើទៅបានសម្រាប់ជីវភាពប្រជាពលរដ្ឋនៅតំបន់សិក្សា។ ចំណែកឯប្រភេទផ្ទះផ្សេងៗទៀតមានភាគរយប្រហាក់ប្រហែលគ្នាក្នុងចំនួនតិចតួចដូចជាផ្ទះដែលមានដំបូលប្រក់ស្បូវ ស្លឹក ផ្ទាំងកៅស៊ូ ផ្លាស្ទិក ផ្ទាំងកៅស៊ូខ្មៅ ឬសម្ភារៈស្រាលៗ ដទៃទៀតដែលមិនរឹងមាំ មានជញ្ជាំងធ្វើពីកូនឈើឫស្សី ស្បូវ ស្លឹក ឬសម្ភារៈស្រាលៗដទៃទៀត និងមានកំរាលជារនាបឫស្សីមានចំនួន៩.៥% និងមានប្រភេទផ្ទះដែលមានដំបូលស័ង្កសី ជញ្ជាំងធ្វើពីកូនឈើឫស្សី ស្បូវ ស្លឹក ឬសម្ភារៈស្រាលៗដទៃទៀត និងមានកំរាលជារនាបឫស្សីមានចំនួន៨.៦%។ (សូមមើលតារាងទី១៤)

តារាងទី១៤- ប្រភេទផ្ទះ

| ប្រភេទដំបូល | ប្រភេទជញ្ជាំង | ប្រភេទកំរាល | តាឡាត | វាំពាត់ | ស្វាយរៀង | ខ្សាច់ថ្មី | ស្រែគមួយ | ស្រែគពីរ | ភ្លុក | ក្របីជ្រុំ | ក្បាលរមាស | ស្រែស្រណុក | ច្រប់ | ភូមិ១ | ភូមិ២ | ភូមិ៣ | ចំនួន | % |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ក្បឿង, បេតុង, ហ្វីប្រូស៊ីម៉ង់ | ឈើ, ក្ដារ, កុងផ្លាកកេ, ឬស័ង្កសី | កំរាលឈើ | - | - | ២ | - | ១ | - | - | ១ | - | - | - | - | - | ១ | ៥ | ១.៦ |
| ស័ង្កសី | ឈើ, ក្ដារ, កុងផ្លាកកេ, ឬស័ង្កសី | កំរាលផ្ទាល់ដី (គ្មានកំរាល) | - | - | - | - | - | - | ១ | - | - | - | - | - | - | - | ១ | ០.៣ |
| ស័ង្កសី | ឈើ, ក្ដារ, កុងផ្លាកកេ, ឬស័ង្កសី | កំរាលឈើ | ១០ | ៧ | ២៤ | ៣៧ | ១៨ | ២៤ | ១៥ | ១៦ | ១០ | ៧ | ៧ | ៨ | ១០ | ១៣ | ២០៦ | ៦៥.៤ |
| ស័ង្កសី | ឈើ, ក្ដារ, កុងផ្លាកកេ, ឬស័ង្កសី | កំរាលរនាបឫស្សី | - | - | ៤ | ២ | - | - | ១ | - | ១ | - | - | ២ | ២ | - | ១២ | ៣.៨ |
| ស័ង្កសី | ឈើ, ក្ដារ, កុងផ្លាកកេ, ឬស័ង្កសី | កំរាលបេតុង/ ឥដ្ឋ/ការ៉ូ | - | - | - | - | - | - | ១ | ២ | - | - | - | - | - | - | ៣ | ១.០ |
| ស័ង្កសី | កូនឈើ, ឫស្សី,ស្បូវ, ស្លឹកឬសំភារៈស្រាលៗដទៃទៀត | កំរាលឈើ | - | - | - | ១ | ២ | ១ | ៤ | ១ | ១ | ៦ | - | ៤ | ១ | ១ | ២២ | ៧.០ |
| ស័ង្កសី | កូនឈើ, ឫស្សី,ស្បូវ, ស្លឹកឬសំភារៈស្រាលៗដទៃទៀត | កំរាលរនាបឫស្សី | - | - | ៦ | ៤ | ២ | ២ | ២ | ១ | ៤ | - | - | ២ | ២ | ២ | ២៧ | ៨.៦ |
| ស្បូវ, ស្លឹក, ផ្ទាំងកៅស៊ូ, ផ្លាស្ទិក, ផ្ទាំងកៅស៊ូខ្មៅ ឬសំភារៈស្រាលៗដទៃទៀត | ឈើ, ក្ដារ, កុងផ្លាកកេ, ឬស័ង្កសី | កំរាលផ្ទាល់ដី (គ្មានកំរាល) | - | - | - | - | - | - | - | - | - | - | ១ | - | - | - | ១ | ០.៣ |
| ស្បូវ, ស្លឹក, ផ្ទាំងកៅស៊ូ, ផ្លាស្ទិក, ផ្ទាំងកៅស៊ូខ្មៅ ឬសំភារៈស្រាលៗដទៃទៀត | ឈើ, ក្ដារ, កុងផ្លាកកេ, ឬស័ង្កសី | កំរាលឈើ | ១ | - | - | - | - | - | - | - | - | ១ | ២ | - | - | - | ៤ | ១.៣ |
| ស្បូវ, ស្លឹក, ផ្ទាំងកៅស៊ូ, ផ្លាស្ទិក, ផ្ទាំងកៅស៊ូខ្មៅ ឬសំភារៈស្រាលៗដទៃទៀត | ឈើ, ក្ដារ, កុងផ្លាកកេ, ឬស័ង្កសី | កំរាលរនាបឫស្សី | - | - | - | - | - | - | - | - | ១ | - | - | - | - | - | ១ | ០.៣ |
| ស្បូវ, ស្លឹក, ផ្ទាំងកៅស៊ូ, ផ្លាស្ទិក, ផ្ទាំងកៅស៊ូខ្មៅ ឬសំភារៈស្រាលៗដទៃទៀត | កូនឈើ, ឫស្សី,ស្បូវ, ស្លឹកឬសំភារៈស្រាលៗដទៃទៀត | កំរាលផ្ទាល់ដី (គ្មានកំរាល) | - | - | - | - | - | - | - | - | - | - | - | - | ១ | - | ១ | ០.៣ |
| ស្បូវ, ស្លឹក, ផ្ទាំងកៅស៊ូ, ផ្លាស្ទិក, ផ្ទាំងកៅស៊ូខ្មៅ ឬសំភារៈស្រាលៗដទៃទៀត | កូនឈើ, ឫស្សី,ស្បូវ, ស្លឹកឬសំភារៈស្រាលៗដទៃទៀត | កំរាលឈើ | - | - | - | - | - | - | - | ២ | - | - | - | - | - | - | ២ | ០.៦ |
| ស្បូវ, ស្លឹក, ផ្ទាំងកៅស៊ូ, ផ្លាស្ទិក, ផ្ទាំងកៅស៊ូខ្មៅ ឬសំភារៈស្រាលៗដទៃទៀត | កូនឈើ, ឫស្សី,ស្បូវ, ស្លឹកឬសំភារៈស្រាលៗដទៃទៀត | កំរាលរនាបឫស្សី | ១ | ២ | ៨ | ១ | - | - | ១ | ៣ | ៤ | ៦ | - | ១ | - | ៣ | ៣០ | ៩.៥ |
| សរុប | | | ១២ | ៩ | ៤៤ | ៤៥ | ២៣ | ២៧ | ២៥ | ២៦ | ២១ | ២០ | ១០ | ១៧ | ១៦ | ២០ | ៣១៥ | ១០០ |



រូបភាពទី១- ប្រភេទផ្ទះឈើប្រក់ដំបូលស័ង្កសីដែលពេញនិយមនៅតំបន់សិក្សា

### ២.២.៣. ទំហំផ្ទះ

ផ្ទះប្រជាពលរដ្ឋតាមជនបទពិសេសនៅតំបន់គោលដៅសិក្សា មានទំហំសមល្មមបើធៀបនឹងចំនួនសមាជិកគ្រួសារ។ ប្រជាពលរដ្ឋចំនួន៥៥.៩% មានផ្ទះទំហំ ៥១ម៉ែត្រការ៉េ ឬលើសពីនេះ ចំណែក៣៥.២%មានផ្ទះទំហំ ២១ទៅ៥០ ម៉ែត្រការ៉េ និង៨.៩% មានផ្ទះទំហំ២០ម៉ែត្រការ៉េ ឬលើសពីនេះ។ (សូមមើលក្រាហ្វិទី១០)

យោងតាមការសិក្សាសេដ្ឋកិច្ចសង្គមឆ្នាំ២០០៩ បង្ហាញថាជាមធ្យមមនុស្សម្នាក់ត្រូវការកន្លែងស្នាក់នៅទំហំ៨.៥ម៉ែត្រការ៉េ នៅតំបន់ជនបទ។ បើប្រៀបធៀបទិន្នន័យនេះ ជាមួយនឹងការសិក្សានៅតំបន់គោលដៅដែលក្នុងមួយគ្រួសារមានសមាជិក៥.៥៨នាក់ (ឬប្រហែល៦នាក់) ឃើញថាប្រជាពលរដ្ឋចំនួន៥៥.៩% មានសមាជិកម្នាក់ៗស្នាក់នៅផ្ទះដែលមានទំហំធំល្មមស្មើនឹង៩ម៉ែត្រការ៉េ ចំណែកប្រជាពលរដ្ឋចំនួន៣៥.២% មានសមាជិកម្នាក់ៗស្នាក់នៅផ្ទះដែលមានទំហំ៦ម៉ែត្រការ៉េ ដែលតូចជាងតម្រូវការតិចតួច និងប្រជាពលរដ្ឋចំនួន៨.៩% មានសមាជិកម្នាក់ៗស្នាក់នៅផ្ទះ ដែលមានទំហំ៤ម៉ែត្រការ៉េ ដែលតូចជាងតម្រូវការប្រហែលជាពាក់កណ្ដាល។ ទិន្នន័យនេះបញ្ជាក់ថាប្រជាពលរដ្ឋលើសពីពាក់កណ្ដាល គឺរស់នៅផ្ទះដែលមានទំហំសមល្មមបើធៀបជាមួយសមាជិកគ្រួសារ។

ក្រាហ្វិកទី១០- ទំហំផ្ទះ




## ២.២.៤. ស្ថានភាពទូទៅនៃផ្ទះ

តាមរយៈការអង្កេតផ្ទាល់តាមផ្ទះនីមួយៗនៅភូមិគោលដៅ បានបង្ហាញថា មានប្រជាពលរដ្ឋចំនួន៥៧.១% កំពុងរស់នៅផ្ទះដែលមានស្ថានភាពមធ្យម (ផ្ទះដែលមើលទៅមិនរឹងមាំពេក ហើយក៏មិនទ្រុឌទ្រោមដែរ) អាចរស់នៅបាន ចំណែក ៣៥.៦% កំពុងរស់នៅផ្ទះដែលមានស្ថានភាពល្អមានសុវត្ថិភាព (ផ្ទះដែលមើលទៅមានសភាពរឹងមាំល្អ) និង៧.៣%ប៉ុណ្ណោះ ដែលកំពុងរស់នៅផ្ទះដែលមានស្ថានភាពទ្រុឌទ្រោម (ផ្ទះដែលមើលទៅមិនមានសភាពរឹងមាំ ទាំងជញ្ជាំង ជណ្ដើរ ជើងសរសរ ដែលអាចនឹងបង្កអោយមានគ្រោះថ្នាក់បាន)។ ទាំងនេះបង្ហាញថា ប្រជាពលរដ្ឋភាគច្រើន រស់នៅក្នុងផ្ទះដែលស្ថិតក្នុងស្ថានភាពអាចរស់នៅមានសុវត្ថិភាព ប៉ុន្តែមានតែប្រជាពលរដ្ឋមួយចំនួនតូចប៉ុណ្ណោះ ដែលរស់នៅផ្ទះដែលមានស្ថានភាពទ្រុឌទ្រោម ដែលគួរមានការយកចិត្តទុកដាក់ពីសុវត្ថិភាពក្នុងការរស់នៅក្នុងលំនៅដ្ឋានមួយសមរម្យដែរ។ (សូមមើលក្រហ្វិកទី១១)

ក្រាហ្វិកទី១១- ស្ថានភាពផ្ទះ




## ២.៣. ប្រភពបំភ្លឺនៅពេលយប់

ការប្រើប្រាស់អគ្គិសនីនៅតំបន់ជនបទមិនទាន់មានភាពផុសផុល ដូចនៅទីក្រុងនោះទេ ព្រោះមិនទាន់មានបណ្តាញអគ្គិសនី ដោយឡែកមានតំបន់ជនបទមួយចំនួនជាប់ព្រំដែនប្រទេសថៃ ឡាវ និងវៀតណាមដែលមានភ្លើងអគ្គិសនីប្រើប្រាស់ ដោយសារមានការភ្ជាប់បណ្តាញអគ្គិសនីពីប្រទេសទាំងនោះ។ នៅខេត្តស្ទឹងត្រែង មានក្រុមហ៊ុនផ្គត់ផ្គង់អគ្គិសនីខ្នាតតូចចំនួន២ កំពុងប្រតិបត្តិការដោយឯកជន និងរដ្ឋ (អគ្គិសនី EDC) ដោយប្រើម៉ាស៊ីនភ្លើង ហើយការផ្គត់ផ្គង់នេះគ្របដណ្តប់ ៧0% នៅតំបន់ទីរួមខេត្តប៉ុណ្ណោះ។ ក្រៅពីនេះមានរោងចក្រវារីអគ្គិសនីតូចៗចំនួន ២ទៀត នៅអូរពងមាន់ និងនៅសៀមបូក ដែលដំណើរការដោយឯកជន។

នៅតំបន់គោលដៅដែលបានសិក្សាបង្ហាញថា មានប្រជាពលរដ្ឋចំនួន ៥៩.៧% កំពុងប្រើប្រាស់ចង្កៀងប្រេងកាត ប្រជាពលរដ្ឋចំនួន២០.៣% កំពុងប្រើប្រាស់អំពូល ឬចង្កៀងសាកអាគុយ ប្រជាពលរដ្ឋ៨.៩%ប៉ុណ្ណោះ កំពុងប្រើប្រាស់អគ្គិសនីឯកជន *(អគ្គិសនីដែលដើរដោយម៉ាស៊ីនភ្លើងរួមរបស់ភូមិ ហើយប្រជាពលរដ្ឋរៃលុយគ្នា ទិញសាំងឬប្រេងសម្រាប់ចាក់ និងអគ្គិសនីដែលប្រជាពលរដ្ឋបង់ថ្លៃប្រើប្រាស់អគ្គិសនីដោយការតភ្ជាប់បណ្តាញពីអ្នកជិតខាង ដែលបញ្ចេះម៉ាស៊ីនភ្លើង*

*ប៉ុន្តែមិនមានគ្រួសារណាមួយភ្ជាប់បណ្តាញអគ្គិសនីពីក្រុមហ៊ុនឯកជននោះទេ)* និង ក្រៅពីនេះ មានការប្រើប្រាស់ចន្លុះ ការប្រើប្រាស់អគ្គិសនីដែលបញ្ចេះដោយម៉ាស៊ីន គោយន្ត ឬម៉ាស៊ីនភ្លើងផ្ទាល់ខ្លួន និងការប្រើប្រាស់ពិលសម្រាប់បំភ្លឺ។

ប្រភពបំភ្លឺនៅពេលយប់មិនមានការប្រើប្រាស់អគ្គិសនីរដ្ឋនៅតំបន់គោលដៅទាំងឡាយនោះទេ ដោយឃើញមានតែភូមិក្បាលរមាស ក្នុងឃុំក្បាលរមាស ស្រុកសេសាន ខេត្តស្ទឹងត្រែងមួយប៉ុណ្ណោះ ដែលប្រជាពលរដ្ឋមានម៉ាស៊ីនភ្លើងមួយសម្រាប់ប្រើរួមគ្នា ហើយប្រជាពលរដ្ឋរៃអង្គាសលុយគ្នាដើម្បីទិញប្រេងមកចាក់ ប៉ុន្តែជាទូទៅប្រជាពលរដ្ឋភាគច្រើន(១០ភូមិ)ប្រើចង្កៀងប្រេងកាត ឬម៉ាស៊ូតដើម្បីបំភ្លឺនៅពេលយប់ ហើយមាន១ភូមិប្រើអំពូល/ចង្កៀងសាកអាគុយ និង១ភូមិទៀតប្រើចន្លុះសម្រាប់បំភ្លឺ។ (សូមមើលក្រាហ្វិកទី១២)

ក្រាហ្វិកទី១២- ប្រភពបំភ្លឺនៅពេលយប់




## ២.៤. មធ្យោបាយធ្វើដំណើរ

ប្រជាពលរដ្ឋ២៩.៨% មានម៉ូតូជាមធ្យោបាយធ្វើដំណើរ ប្រជាពលរដ្ឋ១៦.៨% មានទូកម៉ាស៊ីនជាមធ្យោបាយធ្វើដំណើរ ប្រជាពលរដ្ឋ១៥.៧% មានកង់ជាមធ្យោបាយធ្វើដំណើរ និងមានមធ្យោបាយធ្វើដំណើរផ្សេងៗទៀត ដូចជាទូកចែវ គោយន្ត

ដូចមានក្នុងតារាងខាងក្រោម។ តាមការសិក្សានេះដែរ ប្រជាពលរដ្ឋមួយចំនួនតូចស្មើនឹង៤.៧%ប៉ុណ្ណោះ មិនមានមធ្យោបាយធ្វើដំណើរអ្វីទាំងអស់។ គួរអោយកត់សម្គាល់ ប្រជាពលរដ្ឋប្រមាណជា៦៦% មានមធ្យោបាយធ្វើដំណើរលើសពីមួយប្រភេទ ហើយមធ្យោបាយធ្វើដំណើរជាទូទៅសម្រាប់ប្រជាពលរដ្ឋនៅតំបន់គោលដៅគឺកង់ ម៉ូតូ និងទូក។ (សូមមើលតារាងទី១៥)

តារាងទី១៥- មធ្យោបាយធ្វើដំណើរ

| មធ្យោបាយធ្វើដំណើរ | ចំនួន | ភាគរយ |
|---|---|---|
| ម៉ូតូ | ២១៥ | <u>២៩.៨</u> |
| ទូកម៉ាស៊ីន | ១២១ | <u>១៦.៨</u> |
| កង់ | ១១៣ | <u>១៥.៧</u> |
| ទូកតូចគ្មានម៉ាស៊ីន | ៨០ | ១១.១ |
| រទេះគោ/រទេះសេះ | ៧៨ | ១០.៨ |
| គោយន្ត | ៧៣ | ១០.១ |
| គ្មានមធ្យោបាយ | ៣៤ | ៤.៧ |
| ឡានតូច/ឡានទេសចរ/ឡានធំ | ៥ | ០.៧ |
| ម៉ូតូរ៉ឺម៉ក | ២ | ០.៣ |
| **សរុប** | **៧២១** | **១០០** |

*ចំនួនអ្នកតបសម្ភាសន៍សរុប៣១៥នាក់

## ២.៥ ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត

### សាលារៀន

នៅតាមភូមិនីមួយៗមានសាលារៀនបឋមសិក្សា ដែលកូនសិស្សអាចទៅចូលរៀននៅក្នុងភូមិ ឬនៅជិតភូមិ។ ទោះជាមានសាលារៀនបឋមសិក្សាដែលប្រជាពលរដ្ឋអាចបញ្ជូនកូនទៅរៀនមែន តែនៅមិនទាន់គ្រប់គ្រាន់នៅឡើយ ដោយសាលា

រៀនខ្លះមានសភាពទ្រុឌទ្រោម និងសាលារៀនខ្លះមានសិស្សច្រើនពេក។ មិនមានអនុវិទ្យាល័យ ឬវិទ្យាល័យនៅក្នុងតំបន់សិក្សាទេ ដែលនេះបង្ហាញថាសិស្សដែលបញ្ចប់ការសិក្សានៅបឋមសិក្សាអាចនឹងមានការលំបាក ក្នុងការបន្តការសិក្សាទៅកម្រិតអនុវិទ្យាល័យ ឬវិទ្យាល័យ ពីព្រោះជាទូទៅសាលាអនុវិទ្យាល័យ និងវិទ្យាល័យច្រើនមាននៅទីប្រជុំជនដូចជាទីរួមស្រុក ឬទីរួមខេត្តតែប៉ុណ្ណោះ។ លើសពីនេះ នៅឃុំស្រែអង្គ្រង ពីភូមិទៅអនុវិទ្យាល័យត្រពាំងក្របាម មានចម្ងាយប្រហែល ២២ គីឡូម៉ែត្រ។[40] ហើយនៅស្រុកសេសានទាំងមូលមានតែអនុវិទ្យាល័យចំនួនពីរប៉ុណ្ណោះ នៅឃុំកំភុន និងឃុំសាមឃួយ ដែលនៅឆ្ងាយពីឃុំ៥ដទៃទៀតក្នុងការសិក្សានេះ។[41]



រូបភាពទី២-សាលារៀនបឋមសិក្សានៅភូមិស្រែគរមួយ ឃុំស្រែគរ
ស្រុកសេសាន ខេត្តស្ទឹងត្រែង

[40] របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ខែធ្នូឆ្នាំ២០០៩ របាយការណ៍បញ្ចប់ «គម្រោងវារីអគ្គិសនីសេសានក្រោម២»

[41] «សៀវភៅទិន្នន័យស្រុកសេសានឆ្នាំ២០០៩» ខេត្តស្ទឹងត្រែង (Sesan District Data Book 2009, Stung Treng Province)

## មណ្ឌលសុខភាព

តាមរយៈការសិក្សាបង្ហាញថា មិនមានមណ្ឌលសុខភាពនៅតាមភូមិគោលដៅសិក្សានីមួយៗនោះទេ ប៉ុន្តែគេសង្កេតឃើញមានប៉ុស្តិ៍សុខភាពចំនួន២ប៉ុណ្ណោះ នៅភូមិក្បាលរមាស ឃុំក្បាលរមាស ស្រុកសេសាន ខេត្តស្ទឹងត្រែង និងភូមិ១ ឃុំស្រែអង្គ្រង ស្រុកកូនមុំ ខេត្តរតនគិរី ហើយប៉ុស្តិ៍សុខភាពទាំងនេះមិនសូវមានសកម្មភាពទេ គឺមានតែការផ្តល់ថ្នាំបង្ការសម្រាប់កុមារ និងមានថ្នាំក្តៅខ្លួនប៉ុណ្ណោះ ហើយក៏មិនមានគ្រូពេទ្យប្រចាំការដែរ។ ចម្ងាយពីឃុំមួយៗទៅកាន់មណ្ឌលសុខភាពមានបង្ហាញក្នុងតារាងខាងក្រោម។ (សូមមើលតារាងទី១៦)

តារាងទី១៦- ចម្ងាយជាមធ្យមពីឃុំទៅកាន់មណ្ឌលសុខភាពដែលជិតបំផុត

| ឈ្មោះឃុំ | ចម្ងាយ |
|---|---|
| តាឡាត | ១២៨ គ.ម |
| ភ្លុក | ៨.៥ គ.ម |
| ក្បាលរមាស | ៤០ គ.ម |
| ស្រែគរ | ៩០ គ.ម |
| ស្រែអង្គ្រង | គ្មានទិន្នន័យ |

(ប្រភព: របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញរបស់គម្រោងវារីអគ្គិសនីសេសានក្រោម២)

## អណ្តូង និងស្រះ

នៅតំបន់គោលដៅសិក្សា ជាតំបន់ដែលមានទីតាំងនៅតាមដងទន្លេសេសាន និងស្រែពក ដូច្នេះប្រជាពលរដ្ឋតិចតួចប៉ុណ្ណោះ ដែលបានជីកអណ្តូង ឬស្រះប្រើប្រាស់ ព្រោះពួកគេអាចប្រើប្រាស់ទឹកទន្លេ ដែលនៅជិតផ្ទះស្រាប់ដែលផ្គត់ផ្គង់ទឹកគ្រប់គ្រាន់ក្នុងជីវភាពប្រចាំថ្ងៃ។

## ផ្លូវថ្នល់ និងស្ពាន

តាមរយៈការអង្កេតនៅតាមបណ្តាភូមិនានាក្នុងការសិក្សា គឺមានផ្លូវតភ្ជាប់ទៅកាន់ភូមិ និងចេញចូលក្នុងភូមិ ប៉ុន្តែផ្លូវ ភាគច្រើនធ្វើអោយអ្នកដំណើរជួបការលំបាក

ក្នុងការធ្វើដំណើរនៅរដូវវស្សា ព្រោះអាចមានទឹកលិច និងផ្លូវខូចខាតស្ទើរតែទាំងស្រុង។ ភូមិខ្លះ ដូចជាភូមិស្រែស្រណុក ស្វាយរៀង តាឡាត និងរំពាត់ជាដើមក៏ជួបការលំបាកទាំងខែប្រាំង និងខែវស្សាដែរ ដោយសារតែផ្លូវចូលភូមិបានខូចខាត។ ចំណែកស្ពានមួយចំនួនក៏មានសភាពទ្រុឌទ្រោមដែលពិបាកក្នុងការធ្វើដំណើរដែរ។




រូបភាពទី៣- ផ្លូវថ្នល់ និងស្ពាននៅតំបន់សិក្សា

### វត្តអារាម

ដូចនៅតំបន់ផ្សេងៗនៅក្នុងប្រទេសកម្ពុជាដែរ ការគោរពប្រតិបត្តិព្រះពុទ្ធសាសនាមានសភាពខ្លាំងក្លាជាងសាសនាផ្សេងៗ។ ដោយសារមូលហេតុសាមញ្ញបែបនេះ បានជាទីអារាមជាច្រើនត្រូវបានកសាងនៅស្ទើរគ្រប់ភូមិទូទាំងប្រទេសកម្ពុជា។ ស្ថិតិដែលផ្តល់ដោយក្រសួងធម្មការ និងកិច្ចការសាសនា នៅខែមេសា ឆ្នាំ ២០១០ បង្ហាញថា វត្តអារាមនៅកម្ពុជាមានចំនួន៤៣៩២។[42]

ជាទូទៅ នៅតាមភូមិនីមួយៗក្នុងការសិក្សានេះ មានវត្តអារាមដែលនៅជិតភូមិ ឬនៅក្នុងភូមិតែម្តង ទោះជាមានភូមិមួយចំនួនមិនមានវត្តក៏គេមានរៀបចំជាសាលាឆាន់ ឬសាលាឆទានតំណាងវត្តនៅក្នុងភូមិដែរ។ ដូច្នេះ ប្រជាពលរដ្ឋនៅតាមភូមិនីមួយៗមានភាពងាយស្រួលដែលមានកន្លែងប្រារព្ធពិធីសាសនា ឬធ្វើបុណ្យទានផ្សេងៗនៅក្នុងភូមិរបស់ខ្លួន។

[42] http://news.xinhuanet.com/english2010/culture/2010-11/02/c_13587875.htm (Searched website on September 4, 2012)



រូបភាពទី៤- វត្តអារាមនៅតាមភូមិគោលដៅដែលប្រជាពលរដ្ឋតែងតែទៅគោរពបូជា

# ៣. ធនធានហិរញ្ញវត្ថុ

## ៣.១. មុខរបរ និងប្រាក់ចំណូល

### ៣.៣.១. មុខរបរចំបងរបស់មេគ្រួសារ

វិស័យកសិកម្មដើរតួនាទីយ៉ាងសំខាន់បំផុតក្នុងសង្គមកម្ពុជា ព្រោះវិស័យនេះបានជួយធានាដល់សុវត្ថិភាពស្បៀងទាំងនៅកម្រិតសហគមន៍ និងនៅកម្រិតជាតិ ក៏ដូចជាបានផ្តល់ឱកាសការងារ និងប្រាក់ចំណូលសម្រាប់ប្រជាពលរដ្ឋប្រមាណជា៨០% នៅក្នុងប្រទេសផងដែរ។[43] ជាទូទៅ ការប្រកបរបរចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋជនបទប្រទេសកម្ពុជាភាគច្រើនគឺ ពឹងផ្អែកលើការធ្វើស្រែចំការ។ យ៉ាងណាមិញ ក្នុងការសិក្សានេះបានបង្ហាញថាមាន៨៧% នៃមេគ្រួសារទាំងអស់គឺប្រកបរបរកសិកម្ម និងមាន១៣%ប្រកបរបរផ្សេងពីនេះ។ មុខរបរផ្សេងពីកសិកម្មមានដូចជា ៦.៣០%ប្រកបរបរដោយប្រើជំនាញដូចជាជាងកាត់ដេរ ជួសជុលម៉ូតូ... ចំណែកមេគ្រួសារ ដែលមានមុខរបរជាអ្នកលក់ដូរតិចតួចនៅក្នុងភូមិមាន២.៩០%

[43] Jan-Peter Mund, 2010 , The Agricultural Sector in Cambodia: "Trends, Processes and Disparities". (Search website on June 4, 2012) or see this link: www.pacific-news.de/pn35/PN35_JPM.pdf (Searched website on May 3, 2012)

អ្នកប្រកបរបរដោយប្រើកំលាំងមាន១.៦០% និងមេគ្រួសារដែលនៅផ្ទះ ឬគ្មានការងារធ្វើមាន ២.២០%។ (សូមមើលតារាងទី១៧)

តារាងទី១៧- មុខរបរមេគ្រួសារ

| មេគ្រួសារ | កសិករ | កម្មករ | គ្មានការងារ/នៅផ្ទះ | លក់ដូរ | ការងារប្រើជំនាញ (ជាងកាត់ដេរ, ជាងជួសជុលម៉ូតូ...) | សរុប |
|---|---|---|---|---|---|---|
| ស្ត្រី | ៣៣ | ២ | ៣ | ៣ | ១ | ៤២ |
| | ១០.៥០% | ០.៦០% | ១% | ១% | ០.៣០% | ១៣.៣០% |
| បុរស | ២៤១ | ៣ | ៤ | ៦ | ១៩ | ២៧៣ |
| | ៧៦.៥០% | ១% | ១.៣០% | ១.៩០% | ៦% | ៨៦.៧០% |
| សរុប | ២៧៤ | ៥ | ៧ | ៩ | ២០ | ៣១៥ |
| | ៨៧% | ១.៦០% | ២.២០% | ២.៩០% | ៦.៣០% | ១០០% |

### ៣.១.២. អ្នករកចំណូលចំបងក្នុងគ្រួសារ

ដូចគ្រួសារដទៃទៀតដែលរស់នៅតំបន់ផ្សេងៗដែរ បន្ទុកក្នុងការរកប្រាក់ចំណូលសម្រាប់គ្រួសារភាគច្រើនធ្លាក់ទៅលើបុគ្គលជាមេគ្រួសារ។ បុរសជាប្តី៦១% គឺជាអ្នករកចំណូលចំបង រីឯអ្នកដែលរកចំណូលចំបងទាំងប្តី និងប្រពន្ធមាន១៨% ត្រូវបានកត់ត្រា ចំណែក១៣%នៃអ្នករកចំណូលសម្រាប់គ្រួសារធ្លាក់ទៅលើកូនៗ។ គួរកត់សម្គាល់ មេគ្រួសារ និងអ្នកដែលទទួលបន្ទុករកចំណូលចំបងក្នុងគ្រួសារអាចជាមនុស្សផ្សេងគ្នាក្នុងគ្រួសារមួយចំនួន ដោយសារគ្រួសារទាំងនោះមានប្រពៃណីចាត់ទុកបុរសជាមនុស្សសំខាន់ក្នុងគ្រួសារដោយផ្តល់តំណែងជាមេគ្រួសារ ឬការសម្រេចចិត្តធំទៅបុរសជាអ្នកសម្រេចចិត្ត។ ដូច្នេះ ទោះជាបុរសក្នុងគ្រួសារមួយចំនួនមិនមែនជាអ្នករកចំណូលបានច្រើនជាងគេក្នុងការផ្គត់ផ្គង់គ្រួសារ ឬបុរសមិនធ្វើការងាររកប្រាក់ចំណូលក៏ត្រូវបានគេចាត់ទុកជាមេគ្រួសារដែរ។ (សូមមើលក្រាហ្វិកទី១៣)

ក្រាហ្វិកទី១៣- អ្នករកចំណូលចំបងក្នុងគ្រួសារ




## ៣.១.៣. ប្រភពចំណូលចំបងក្នុងគ្រួសារ

តាមរយៈការសម្ភាសន៍ប្រជាពលរដ្ឋតាមគ្រួសារគោលដៅ បានបង្ហាញថា ប្រភពចំណូលចំបងសម្រាប់គ្រួសាររបស់ពួកគេ ដែលមានភាគរយច្រើនជាងគេស្មើនឹង៨៨.៦% គឺការប្រកបរបរកសិកម្មដែលមានការដាំដុះដំណាំស្រូវ និងពូជដំណាំផ្សេងៗ។ ប្រភពចំណូលចំបងបន្ទាប់មក គឺការប្រកបរបរផ្សេងៗក្រៅពីការងារស្រែចំការមានចំនួន១០.២% ហើយការប្រកបរបរផ្សេងនេះរួមមាន៧.៩% រកស៊ីខ្នាតតូច/កម្មករមានជំនាញ/មន្ត្រីរាជការ ១.៦%ធ្វើជាកម្មករស៊ីឈ្នួលគេ និង0.៦% ប៉ុណ្ណោះដែលរកស៊ីខ្នាតធំ។ ចំណែកប្រភពចំណូលចំបងក្នុងគ្រួសារជាការប្រកបរបរនេសាទមានតិចតួចជាងគេស្មើនឹង១.៣% ឬ៤គ្រួសារប៉ុណ្ណោះ ហើយឧបករណ៍នេសាទបែបបុរាណដូចជាសន្ទូចរនង អួន និងសំណាញ់ គឺជាមធ្យោបាយដែលក្រុមអ្នកនេសាទទាំងនេះប្រើប្រាស់។ របរនេសាទជាមុខរបរចំបង មានចំនួនតិចតួចប៉ុណ្ណោះដោយសារប្រជាពលរដ្ឋភាគច្រើនបានយករបរនេសាទជាមុខរបរបន្ទាប់បន្សំ។ដូចគ្នានេះដែរ ការផ្តល់ព័ត៌មានពីប្រធានភូមិ និងអនុប្រធានភូមិ ក៏ដូចជាការពិភាក្សាក្រុម

ក៏បានលើកឡើងដែរថា មុខបរបរចំបង ឬប្រភពចំណូលចំបងរបស់ប្រជាពលរដ្ឋក្នុងភូមិគោលដៅ គឺការប្រកបរបរកសិកម្មដែលមានជាដំណាំស្រូវ ដំណាំចំការផ្សេង និងការចិញ្ចឹមសត្វជាលក្ខណ:គ្រួសារ។ (សូមមើលក្រាហ្វិទី១៨)

ក្រាហ្វិកទី១៨- ប្រភពចំណូលចំបងក្នុងគ្រួសារ




## ៣.១.៣.១. ទំហំដីដាំដុះដំណាំកសិកម្ម

ចំពោះប្រជាពលរដ្ឋចំនួន៨៨.៦% ដែលជាគ្រួសារពឹងអាស្រ័យលើរបរកសិកម្មជាប្រភពចំណូលចំបងឃើញថា ជាមធ្យមពួកគេដាំដុះដំណាំលើផ្ទៃដីទំហំ៣១៣អា (ឬ៣,១៣ហិចតា) ក្នុងមួយឆ្នាំ។ ក្នុងចំណោមគ្រួសារដែលប្រកបរបរកសិកម្មជាមុខរបរចំបងមានគ្រួសារភាគច្រើនចំនួន៨៦.៣% ដាំដុះដំណាំលើផ្ទៃដីទំហំលើសពី៥០អា និង២.២%ប៉ុណ្ណោះ ដែលដាំដុះលើផ្ទៃដី២០-៥០អា។

ទោះជាប្រទេសកម្ពុជា ត្រូវបានគេចាត់ទុកថាជាប្រទេសដែលពឹងផ្អែកលើកសិកម្មក្តី ប៉ុន្តែមានតែ១៦% ឬ២,៨៧លានហិចតានៃផ្ទៃដីរបស់ប្រទេសប៉ុណ្ណោះដែលជាដីកសិកម្ម។ ប្រសិនជា ដីកសិកម្មត្រូវបានបែកចែកស្មើៗគ្នានៅក្នុងចំណោម

គ្រួសារទាំងអស់នៅកម្ពុជា គ្រួសារមួយមានដីកសិកម្មប្រហែលជា១ហិចតា (០,៩២ ហិចតាក្នុងមួយគ្រួសារ ឬ១.០៩ហិចតាក្នុងមួយគ្រួសារនៅតំបន់ជនបទ)។[44] ប្រៀបធៀបទិន្នន័យនៃទំហំដីកសិកម្ម១,០៩ហិចតាក្នុងមួយគ្រួសារនៅតំបន់ជនបទ ជាមួយនឹងទំហំដីកសិកម្មជាមធ្យម៣,១៣ហិចតាក្នុងមួយគ្រួសារក្នុងការសិក្សានេះ ឃើញថាប្រជាពលរដ្ឋនៅតំបន់គោលដៅសិក្សា ជាមធ្យមមានដីកសិកម្មច្រើនជាង ដែលវាជាការអំណោយផលមួយដល់របរកសិកម្មប្រចាំគ្រួសាររបស់ពួកគេ។

## ៣.១.៤. ប្រភពចំណូលបន្ទាប់បន្សំក្នុងគ្រួសារ

ប្រជាពលរដ្ឋនៅតំបន់ជនបទប្រទេសកម្ពុជា ពឹងផ្អែកទៅលើប្រភពចំណូលជាច្រើនប្រភេទ សម្រាប់ការប្រកបរបរចិញ្ចឹមជីវិតអាស្រ័យទៅតាមលក្ខខណ្ឌរស់នៅនៃតំបន់នីមួយៗ។ ក្រៅពីមុខរបរចំបងដែលជាប្រភពចំណូលក្នុងគ្រួសារ មានមុខរបរជាច្រើនទៀត ជាប្រភពចំណូលបន្ទាប់បន្សំក្នុងគ្រួសារគោលដៅនីមួយៗ ដូចជា នេសាទ រកអនុផលព្រៃឈើ បរបាញ់ ធ្វើកម្មករ និងមន្ត្រីរាជការជាដើម។ គួរកត់សម្គាល់ ចំនួនគ្រួសារប្រមាណ១៣.៧%ប៉ុណ្ណោះ ដែលមិនមានមុខរបរផ្សេងក្រៅពីមុខរបរចំបង ខណ:ដែល៨៦.៣% មានមុខរបរបន្ទាប់បន្សំផ្សេងយ៉ាងហោចណាស់មួយក្រៅពីមុខរបរចំបងក្នុងការផ្គត់ផ្គង់ជីវភាពគ្រួសារ។ ចំពោះគ្រួសារដែលមានមុខរបរបន្ទាប់បន្សំទី១ ជាអ្នកនេសាទមាន៤៤.១% និងអ្នកទៅរកអនុផលពីព្រៃឈើមាន ១៩.៧%។ ចំណែកមុខរបរបន្ទាប់បន្សំទី២ មានដូចជា១៤% ជាអ្នកទៅរកអនុផលព្រៃឈើ និង១២.១%មានមុខរបរជាអ្នកនេសាទ។ (សូមមើលតារាងទី១៨និង១៩)

តាមរយ:ការពិភាក្សាក្រុម និងការសម្ភាសន៍ប្រធានភូមិ ឬអនុប្រធានភូមិក៏មិនខុសគ្នាដែរ ដោយពួកគេបានបញ្ជាក់ថាមុខរបរបន្ទាប់បន្សំរបស់ប្រជាពលរដ្ឋនៅក្នុងភូមិមានដូចជា រកអនុផលព្រៃឈើ បរបាញ់សត្វ នេសាទត្រី ធ្វើជាកម្មករស៊ីឈ្នួល ចិញ្ចឹមសត្វ និងលក់ដូរចាប់ហួយតូចតាចនៅតាមផ្ទះ។

[44] ខែកញ្ញា ឆ្នាំ២០១០ ដោ៉ សុថាត និងច័ន្ទ សុផល «ហិរញ្ញប្បទានក្នុងវិស័យកសិកម្ម និងសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មសម្រាប់កសិករខ្នាតតូច»

## តារាងទី១៨- ប្រភពចំណូលបន្ទាប់បន្សំទី១

| ប្រភពចំណូលបន្ទាប់បន្សំទី១ | ចំនួន | ភាគរយ |
|---|---|---|
| ធ្វើស្រែ | ១៧ | ៥.៤ |
| ធ្វើកម្មករ | ៩ | ២.៩ |
| នេសាទ | ១៣៩ | ៤៤.១ |
| រកស៊ីខ្នាតតូច | ២៨ | ៨.៩ |
| រកអនុផលព្រៃឈើ | ៦២ | ១៩.៧ |
| គ្មានការងារផ្សេង | ៤៣ | ១៣.៧ |
| បរបាញ់ | ៦ | ១.៩ |
| មន្ត្រីរាជការ | ១១ | ៣.៥ |
| **សរុប** | **៣១៥** | **១០០** |

## តារាងទី១៩- ប្រភពចំណូលបន្ទាប់បន្សំទី២

| ប្រភពចំណូលបន្ទាប់បន្សំទី២ | ចំនួន | ភាគរយ |
|---|---|---|
| ធ្វើស្រែ | ១ | ០.៣ |
| ធ្វើកម្មករ | ៨ | ២.៥ |
| នេសាទ | ៣៨ | ១២.១ |
| រកស៊ីខ្នាតតូច | ១៣ | ៤.១ |
| រកអនុផលព្រៃឈើ | ៤៤ | ១៤ |
| គ្មានការងារផ្សេង | ១៩១ | ៦០.៦ |
| បរបាញ់ | ១៥ | ៤.៨ |
| មន្ត្រីរាជការ | ៥ | ១.៦ |
| **សរុប** | **៣១៥** | **១០០** |

### ៣.១.៥. ប្រាក់ចំណូលប្រចាំឆ្នាំ[45]

ចំពោះប្រាក់ចំណូលប្រចាំឆ្នាំ ជាមធ្យមក្នុងមួយគ្រួសារអាចរកបាន ៩,៧០៦,៧១៤រៀល ឬ២៣៦៧.៥ដុល្លាអាមេរិក (១ដុល្លា៤១០០រៀលនៅ ខែឧសភា ឆ្នាំ២០១១)។ បើយោងតាមប្រាក់ចំណូលរបស់គ្រួសារនីមួយៗ ឃើញថាគ្រួសារប្រមាណ៤%ប៉ុណ្ណោះ អាចរកប្រាក់ចំណូលប្រចាំឆ្នាំបានតិចជាង១លានរៀល ៧៥% អាចរកប្រាក់ចំណូលប្រចាំឆ្នាំបានពី១លានទៅដល់៩លានរៀល និង២១%ទៀត អាចរកចំណូលប្រចាំឆ្នាំបានពី១០លានរៀល ឬលើសពីនេះ។

តារាងខាងក្រោមបង្ហាញថា មានប្រជាពលរដ្ឋរហូតដល់៨៥% អាចរកប្រាក់ចំណូលបានពី២,០០០,០០០រៀល (៤៨៧.៨ដុល្លាអាមេរិក) ឬលើសពីនេះក្នុងមួយឆ្នាំ។ ប៉ុន្តែបើធ្វើការប្រៀបធៀបរវាងចំនួនសមាជិកគ្រួសារ និងប្រាក់ចំណូលដោយយោងតាមតារាងខាងក្រោម គ្រួសារដែលមានសមាជិកពី៥-៩នាក់ មានចំនួន៦០% ដែលរកចំណូលបានចន្លោះពី២,០០០,០០០រៀល (៤៨៧.៨ដុល្លាអាមេរិក) ឬលើសពីនេះក្នុងមួយឆ្នាំ និងគ្រួសារដែលមានសមាជិកពី១-៤នាក់មានចំនួន២២.២% ដែលរកចំណូលបានចន្លោះពី២,០០០,០០០រៀល (៤៨៧.៨ដុល្លាអាមេរិក) ឬលើសពីនេះក្នុងមួយឆ្នាំ។ (សូមមើលតារាងទី២០)

ការប្រៀបធៀបប្រាក់ចំណូលជាតិដុលសម្រាប់មនុស្សម្នាក់ ក្នុងឆ្នាំ២០១០ របស់វិទ្យាស្ថានជាតិស្ថិតិនៅកម្ពុជា(៨៣០ដុល្លាអាមេរិក) ជាមួយនឹងប្រាក់ចំណូលសម្រាប់មនុស្សម្នាក់ប្រចាំឆ្នាំក្នុងការសិក្សានេះ(៤២៤.៣ដុល្លាអាមេរិក) បង្ហាញថាប្រជាពលរដ្ឋអាចរកចំណូលបានត្រឹមតែ៥១%ប៉ុណ្ណោះ នៃប្រាក់ចំណូល១០០% ស្តង់ដារប្រទេសកម្ពុជា ដែលនេះបញ្ជាក់ថាស្ថានភាពជីវភាពគ្រួសារប្រជាពលរដ្ឋនៅ

---

[45] ចំពោះការសិក្សាពីប្រាក់ចំណូលប្រចាំឆ្នាំក្នុងការសិក្សានេះ អ្នកស្រាវជ្រាវធ្វើការបូកសរុបប្រាក់ចំណូលពីគ្រប់ប្រភពទាំងអស់ដែលសមាជិកគ្រប់រូបក្នុងគ្រួសារអាចរកប្រាក់ចំណូលបានជាមធ្យមក្នុងមួយឆ្នាំ។ ប៉ុន្តែអ្នកស្រាវជ្រាវមិនធ្វើការសិក្សាលំអិតពីស្ថានភាពនៃប្រភពប្រាក់ចំណូលនីមួយៗដែលសមាជិកគ្រួសារអាចរកបាននោះទេ (***ឧ.ការនេសាទត្រី:*** *អ្នកស្រាវជ្រាវគ្រាន់តែចង់ដឹងថាជាមធ្យមក្នុង១ឆ្នាំ ប្រាក់ចំណូលដែលបានពីការនេសាទត្រីមានចំនួនប៉ុន្មាន ប៉ុន្តែមិនសិក្សាលំអិតអំពីខែដែលរកចំណូលបានច្រើន តម្លៃត្រីក្នុង១គីឡូក្រាម នៅរដូវសំបូរត្រី និងមិនសូវសំបូរត្រី ប្រភេទត្រីដែលរកបាន ជាដើមនោះទេ*) ពីព្រោះការសិក្សានេះមានពេលវេលា និងដែនកំណត់ច្បាស់លាស់។

តំបន់សិក្សាស្ថិតក្នុងភាពត្រឹមអាចរស់នៅបានក្នុងជីវភាព តែមិនទាន់មានភាពល្អប្រសើរនោះទេ។

តារាងទី២០-ចំនួនសមាជិកគ្រួសារធៀបនឹងប្រាក់ចំណូលប្រចាំឆ្នាំ

| ចំនួនសមាជិក | សមាជិក ១-៤ នាក់ | | សមាជិក ៥-៩ នាក់ | | សមាជិក ១០-១៤ នាក់ | | សរុប | |
|---|---|---|---|---|---|---|---|---|
| ប្រាក់ចំណូលប្រចាំឆ្នាំ(រៀល) | ចំនួន | % | ចំនួន | % | ចំនួន | % | ចំនួន | % |
| ១០០,០០០-៣៩៩,០០០ | ៣ | ០.៩ | ១ | ០.៣ | ០ | ០ | ៤ | ១.២ |
| ៤០០,០០០-៧៩៩,០០០ | ៣ | ០.៩ | ៤ | ១.២ | ០ | ០ | ៧ | ២.២ |
| ៨០០,០០០-១,១៩៩,០០០ | ៣ | ០.៩ | ៤ | ១.២ | ០ | ០ | ៧ | ២.២ |
| ១,២០០,០០០-១,៥៩៩,០០០ | ៩ | ២.៨ | ៦ | ១.៩ | ១ | ០.៣ | ១៦ | ៥ |
| ១,៦០០,០០០-១,៩៩៩,៩៩៩ | ៣ | ០.៩ | ១០ | ៣.១ | ០ | ០ | ១៣ | ៤.១ |
| ២,០០០,០០០-លើសពីនេះ | ៧០ | ២២.២ | ១៨៩ | ៦០ | ៩ | ២.៨ | ២៦៨ | ៨៥ |
| សរុប | ៩១ | ២៨.៨ | ២១៤ | ៦៧.៩ | ១០ | ៣.១ | ៣១៥ | ១០០ |

### ៣.១.៦. ការប្រៀបធៀបប្រាក់ចំណូលតាមប្រភេទមុខរបរចំបង

ប្រជាពលរដ្ឋមានមុខរបរផ្សេងៗគ្នាទៅតាមស្ថានភាពតំបន់មួយៗ ដូច្នេះ ការរកប្រាក់ចំណូលសម្រាប់គ្រួសារមួយៗក៏មានលក្ខណៈខុសៗគ្នាដែរ។ ក្រឡេកមើលតារាងទី២១ ស្តីពីប្រាក់ចំណូលជាមធ្យមប្រចាំឆ្នាំទៅតាមប្រភេទមុខរបរខាងក្រោមបង្ហាញថា គ្រួសារដែលមានប្រភពចំណូលចំបងធ្វើស្រែចំការ និងគ្រួសារដែលមានប្រភពចំណូលចំបងនេសាទ អាចរកប្រាក់ចំណូលប្រចាំឆ្នាំជាមធ្យមប្រហាក់ប្រហែលគ្នា ដោយឡែកគ្រួសារដែលមានប្រភពចំណូលចំបងផ្សេងពីការងារស្រែចំការ និងនេសាទហាក់មានសន្ទុះ នៃការរកប្រាក់ចំណូលប្រចាំឆ្នាំខ្ពស់ជាងគេដោយសារមុខរបរផ្សេងៗទាំងនោះក៏រួមមានការរកស៊ី លក់ដូរជាខ្នាតតូច និងខ្នាតធំផងដែរ។ (សូមមើលតារាងទី ២១)

តារាងទី២១- ប្រាក់ចំណូលប្រចាំឆ្នាំតាមប្រភេទមុខរបរចំបង

| ប្រភពចំណូលចំបង | ប្រាក់ចំណូលជាមធ្យម (រៀល)/ឆ្នាំ | ប្រាក់ចំណូលជាមធ្យម (ដុល្លាអាមេរិក)/ឆ្នាំ |
|---|---|---|
| ធ្វើស្រែចំការ | ៧,៥៩៨,១២០ | ១៨៥៣.២ |
| នេសាទ | ៧,៩៥២,៣៦០ | ១៩៣៩.៦ |
| មុខរបរផ្សេងៗ | ២៨,៣០៨,០៤០ | ៦៩០៤.៤ |

### ៣.១.៧. ចំនួនសមាជិកគ្រួសារដែលមិនអាចរកចំណូលបាន

ក្នុងគ្រួសារមួយមានតម្រូវការជាច្រើន ដែលទាមទារអោយសមាជិកគ្រប់ៗរូបទទួលបន្ទុកបំពេញតម្រូវការទាំងនោះក្នុងជីវភាព ប៉ុន្តែការខំប្រឹងប្រែងនេះមិនអាចធ្វើបានទាំងស្រុងទេសម្រាប់គ្រួសារខ្លះ ពីព្រោះក្នុងចំណោមសមាជិកគ្រួសារទាំងអស់អាចមានអ្នកដែលមិនអាចរកចំណូលបាន ដូចជាកុមារ ចាស់ជរា និងជនពិការជាដើម។ ស្របគ្នានេះដែរ ជាមធ្យមប្រជាពលរដ្ឋចំនួន២.៥នាក់ ក្នុងមួយគ្រួសារដែលមិនអាចរកប្រាក់ចំណូលបាន។ មានប្រជាពលរដ្ឋប្រមាណ៤៥.១% ដែលមានសមាជិកស្មើ ឬតិចជាងពាក់កណ្តាល ប៉ុន្តែលើសមួយភាគបួន នៃសមាជិកគ្រួសារទាំងអស់ដែលមិនអាចរកចំណូលបាន ហើយប្រជាពលរដ្ឋប្រមាណ៣៣.៣% មានសមាជិកដែលមិនអាចរកចំណូលបានលើសពាក់កណ្តាល នៃសមាជិកគ្រួសារទាំងអស់ និង២១.១% មានសមាជិកដែលមិនអាចរកចំណូលបានស្មើ ឬតិចជាងមួយភាគបួននៃសមាជិកទាំងអស់។ បើចំនួនសមាជិកដែលមិនអាចរកចំណូលបានក្នុងគ្រួសារមួយលើសពីពាក់កណ្តាលនៃសមាជិកទាំងអស់ អាចក្លាយជាបន្ទុកធ្ងន់សម្រាប់គ្រួសារ ឬអ្នកផ្គត់ផ្គង់ប្រាក់ចំណូលក្នុងគ្រួសារ ក្នុងការប្រឹងប្រែងរកប្រាក់ចំណូល ដើម្បីសម្រាលជីវភាពគ្រួសារ ក៏ដូចជាផ្គត់ផ្គង់ដល់សមាជិកដែលមិនអាចរកចំណូលបាន។ (សូមមើលតារាងទី២២)

តារាងទី២២-ចំនួនសមាជិកដែលមិនអាចរកចំណូលបាន

| ចំនួនសមាជិកដែលមិនអាចរកចំណូលបាន | ចំនួន | ភាគរយ |
|---|---|---|
| ស្មើ ឬតិចជាងមួយភាគបួននៃសមាជិកទាំងអស់ | ៦៨ | ២១.៦ |
| ស្មើ ឬតិចជាងពាក់កណ្តាល តែលើសពីមួយភាគបួន នៃសមាជិកគ្រួសារទាំងអស់ | ១៤២ | ៤៥.១ |
| ច្រើនជាងពាក់កណ្តាលនៃសមាជិកទាំងអស់ | ១០៥ | ៣៣.៣ |
| **សរុប** | **៣១៥** | **១០០** |

## ៣.១.៨. ការចិញ្ចឹមសត្វ

ជាទូទៅប្រជាពលរដ្ឋនៅតាមតំបន់ជនបទប្រទេសកម្ពុជា មានទំលាប់ចិញ្ចឹមសត្វស្រុកដូចជា មាន់ ទា ជ្រូក គោ ជាលក្ខណៈគ្រួសារ។ ម្យ៉ាងទៀត សត្វចិញ្ចឹមសម្រាប់គ្រួសារ មិនត្រឹមតែជួយផ្គត់ផ្គង់ចំណូលបន្ថែមពីការងារស្រែចំការប៉ុណ្ណោះទេ វាថែមទាំងជាប្រភពអាហារដ៏សំខាន់សម្រាប់គ្រួសារ និងអាចទាញយកផលប្រយោជន៍សម្រាប់វិស័យកសិកម្មផងដែរ។

ជាក់ស្តែង ប្រជាពលរដ្ឋនៅតំបន់សិក្សា សុទ្ធតែមានការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារដែលក្នុងនោះមានប្រជាពលរដ្ឋចំនួន៥១.៦% មានចិញ្ចឹមជ្រូក ៤-៩ក្បាល ឬគោ ឬក្របី ឬសេះ ចំនួន៣៩ក្បាល ចំណែកប្រជាពលរដ្ឋចំនួន ៣០.២% ចិញ្ចឹមជ្រូក ១-៣ក្បាល ឬគោ ឬក្របី ឬសេះ ចំនួន១២ក្បាល។ ដោយឡែក ប្រជាពលរដ្ឋចំនួន១៥.២% មិនមានចិញ្ចឹមសត្វគោ ក្របី សេះ ជ្រូក ពពែ នោះទេ។ អ្វីដែលគួរអោយកត់សម្គាល់ ប្រជាពលរដ្ឋប្រមាណជា១៣% ដែលមានចិញ្ចឹមជ្រូកលើសពី១០ក្បាល ឬគោក្របី សេះ លើសពី១០ក្បាល។ ក្នុងនោះដែរ ចំពោះគ្រួសារដែលចិញ្ចឹមសត្វជ្រូក គោ ក្របី គឺមិនមែនជាការចិញ្ចឹមសម្រាប់ការបរិភោគក្នុងគ្រួសារទេ តែជាការចិញ្ចឹមសម្រាប់កំលាំងអូសទាញក្នុងវិស័យកសិកម្ម និងសម្រាប់លក់ដូរ។ ក្រៅពីនេះ តាមគ្រួសារនីមួយៗមានចិញ្ចឹមជាសត្វមាន់ ទា ជាដើមសម្រាប់លក់ផង និងបរិភោគផង ។

## ៣.២. ស្ថានភាពជីវភាព និងអត្រាភាពក្រីក្រ

### ៣.២.១. កំចីស្រូវ/អង្ករ

ស្ថានភាពជីវភាពរបស់ប្រជាពលរដ្ឋមានលក្ខណៈចម្រុះ។ តាមរយៈការសាកសួរតាមគ្រួសារគោលដៅសិក្សាបានបង្ហាញថា ក្នុងកំឡុងពេល១២ខែចុងក្រោយមានប្រជាពលរដ្ឋចំនួន២២% ឬប្រហែលជាមួយភាគបួនបានខ្ចីស្រូវ/អង្ករ ឬជំពាក់ស្រូវ/អង្ករគេសម្រាប់យកមកបរិភោគក្នុងគ្រួសារ ចំណែកឯ៧៨%មិនបានខ្ចីស្រូវ/អង្ករគេមកបរិភោគនោះទេ។

ការខ្ចីស្រូវ/អង្ករនេះ ក៏ត្រូវបានរាប់បញ្ចូលទាំងគ្រួសារដែលបានខ្ចីលុយគេយកទៅទិញស្រូវ/អង្ករសម្រាប់ហូបនៅក្នុងគ្រួសារផងដែរ។ ទាំងនេះបង្ហាញថាមានប្រជាពលរដ្ឋតិចជាងពាក់កណ្តាលដែលមានការខ្ចីបុលស្រូវ/អង្ករគេសម្រាប់ហូបចុកក្នុងគ្រួសារ ដោយសារតែកង្វះខាតស្រូវអង្ករនៅចុងរដូវដាំដុះ ហើយការខ្ចីស្រូវ/អង្ករនេះក៏ជាទំលាប់របស់ប្រជាពលរដ្ឋនៅក្នុងភូមិដែរ។ ប៉ុន្តែគ្រួសារភាគច្រើន គឺអាចទប់ទល់នឹងការហូបចុកបានដោយមិនចាំបាច់ខ្ចី ឬបុលស្រូវ/អង្កគេទេ។ កង្វះខាតអង្ករមានរយៈពេលខុសគ្នាក្នុងចំណោមពលរដ្ឋ២២.២% ដែលបានរាយការណ៍ពីការខ្វះខាតរបស់ខ្លួន។ (សូមមើលតារាងទី២៣)

តារាងទី២៣- រយៈពេលនៃការខ្ចីស្រូវ/អង្ករ

| រយៈពេលនៃការខ្ចីស្រូវ/អង្ករ | ភាគរយ |
|---|---|
| ០-២ខែ | ៦.៧ |
| ៣-៧ខែ | ១៤.៩ |
| ៨-១២ខែ | ០.៦ |
| សរុប | ២២.២ |

### ៣.២.២. ប្រភេទទ្រព្យសម្បត្តិ

តាមរយៈការចុះបញ្ជីទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋ ក្នុងពេលស្រាវជ្រាវតាមគ្រួសារគោលដៅបានពិនិត្យឃើញថា មានប្រជាពលរដ្ឋចំនួន៣០.៥%មានទូរស័ព្ទដៃ

១៧.៣%មានកូនវិទ្យុតូច ៨.៩%មានម៉ាស៊ីនកិនស្រូវ។ ការសិក្សាក៏បានពិនិត្យឃើញផងដែរថា មានប្រជាពលរដ្ឋត្រឹមតែ៥.៣% ឬស្មើនឹង៣៩គ្រួសារតែប៉ុណ្ណោះ ក្នុងចំណោមអ្នកផ្តល់សម្ភាសន៍ទាំងអស់ ដែលគ្មានទ្រព្យសម្បត្តិផ្ទាល់ខ្លួនក្នុងផ្ទះទាល់តែសោះ ដែលបានរាយការណ៍ដូចមានបង្ហាញក្នុងតារាងប្រភេទទ្រព្យសម្បត្តិខាងក្រោម។ (សូមមើលតារាងទី២៤)

តារាងទី២៤- ប្រភេទទ្រព្យសម្បត្តិ

| ប្រភេទទ្រព្យសម្បត្តិ | ចំនួន | ភាគរយ |
|---|---|---|
| ទូរស័ព្ទដៃ | **២២៤** | **៣០.៤** |
| កូនវិទ្យុតូច | **១២៨** | **១៧.៣** |
| ម៉ាស៊ីនកិនស្រូវ | **៦៦** | **៨.៩** |
| ក្បាលចាក់វីដេអូ | ៥៩ | ៨ |
| ម៉ាស៊ីនភ្លើង | ៤៩ | ៦.៦ |
| វិទ្យុធំ | ៤៨ | ៦.៥ |
| ទូរទស្សន៍ពណ៌ | ៤៣ | ៥.៨ |
| គ្មានសម្ភារៈឬទ្រព្យសម្បត្តិក្នុងផ្ទះ | ៣៩ | ៥.៣ |
| ម៉ាស៊ីនបូមទឹក | ៣០ | ៤.១ |
| ទូរទស្សន៍ពណ៌ស-ខ្មៅ | ២៤ | ៣.៣ |
| ធុងបាសឬឧបករណ៍បំពងសម្លេង | ១៦ | ២.២ |
| ម៉ាស៊ីនបោកស្រូវ | ៩ | ១.២ |
| ម៉ាស៊ីនបញ្ចូលអាគុយ | ៣ | ០.៤ |
| **សរុប** | **៧៣៨** | **១០០** |

*ចំនួនអ្នកតបសម្ភាសន៍សរុប ៣១៥នាក់

### ៣.២.៣. ប័ណ្ណបញ្ជាក់ភាពក្រីក្រ

តាមរយៈការបង្ហាញប័ណ្ណបញ្ជាក់ពីភាពក្រីក្រតាមគ្រួសារនីមួយៗ ដែលបានទទួលរយៈពេល៤ឆ្នាំចុងក្រោយក្នុងការសម្ភាសន៍ បានបង្ហាញថាមានប្រជាពលរដ្ឋ

ចំនួន១៣%ដែលបានទទួលប័ណ្ណបញ្ជាក់ពីភាពក្រីក្រ (ID Poor) ដែលចេញដោយសាលាឃុំ។ (សូមមើលក្រាហ្វិកទី១៥)

អត្តសញ្ញាណបញ្ជាក់ភាពក្រីក្រសម្រាប់គ្រួសារនីមួយៗដែលផ្តល់ឲ្យទាំងនេះមានគោលបំណងដើម្បីផ្តល់សេវា និងជំនួយអភិវឌ្ឍន៍ផ្សេងៗដល់គ្រួសារក្រីក្រដោយផ្ទាល់ដើម្បីជួយសម្រាលជីវភាពពួកគេអោយចាកផុតពីភាពក្រីក្រ និងការពារពួកគេពីវិបត្តិចៃដន្យផ្សេងៗ (ដូចជាជម្ងឺធ្ងន់ធ្ងរ ខូចខាតផលដំណាំ) ដែលអាចនាំពួកគេឱ្យធ្លាក់កាន់តែជ្រៅក្នុងភាពក្រីក្រ។ ទិន្នន័យដែលបានមកពីអត្តសញ្ញាណកម្មគ្រួសារក្រីក្រអាចប្រើប្រាស់បាន សម្រាប់គណនាប្រៀបធៀបកម្រិតភាពក្រីក្រនៃភូមិនីមួយៗ។ អ្នកផ្តល់សេវាអាចប្រើប្រាស់ទិន្នន័យនេះដើម្បីកំណត់ឃុំ ឬភូមិក្រីក្រ និងគ្រួសារក្រីក្រនៅក្នុងតំបន់។[46]

ក្រាហ្វិកទី១៥- ប័ណ្ណបញ្ជាក់ភាពក្រីក្រ







រូបភាពទី៥-ប្រភេទប័ណ្ណបញ្ជាក់ភាពក្រីក្រ

### ៣.២.៤. អត្រានៃភាពក្រីក្រ

ភាពក្រីក្រត្រូវបានបែងចែកជាពីរកម្រិតគឺ ភាពក្រីក្រកម្រិតទី១ និងភាពក្រីក្រកម្រិតទី២។ ភាពក្រីក្រកម្រិតទី១គឺជាស្ថានភាពក្រីក្រខ្លាំង និងភាពក្រីក្រកម្រិតទី២ គឺ

46 http://www.mop.gov.kh/Projects/IDPoor/tabid/154/Default.aspx (Searched wesite on August 7, 2012)

ជាស្ថានភាពក្រីក្របន្ទាប់ពីកម្រិតទី១ ដោយផ្អែកលើការវាយតម្លៃដោយដាក់ពិន្ទុអំពីស្ថានភាពផ្ទះ មុខរបរ ទ្រព្យសម្បត្តិ និងស្ថានភាពផ្សេងៗទៀត (ឧ.ក្រីក្រកម្រិតទី១ មានពិន្ទុចាប់ពី៥៩-៦៨ ក្រីក្រកម្រិតទី២មានពិន្ទុចាប់ពី៤៥-៥៨)។[47]

បើយោងតាមសៀវភៅទិន្នន័យរបស់ស្រុកសេសានឆ្នាំ២០០៩ បានបង្ហាញថា អត្រាភាពក្រីក្រនៅឃុំតាឡាតមាន៣៧.៤០% ស្រែគរមាន៣៦.៥០% ភ្លុកមាន ៤២.២០% ក្បាលរមាស៤០.៥០% និងឃុំស្រែអង្គ្រងមាន ៤១.៥០%។[48]

តាមរយៈការបូកពិន្ទុដោយប្រើបញ្ជីសំនួរដូចគ្នានឹងបញ្ជីសំនួរ នៃការវាយតម្លៃអំពីភាពក្រីក្ររបស់គម្រោងអាយឌីពួ (ID Poor)[49] នៃក្រសួងផែនការដើម្បីកំណត់អត្តសញ្ញាណនៃគ្រួសារក្រីក្រ ដែលក្នុងនោះរួមមានការវាយតម្លៃអំពីស្ថានភាពផ្ទះ ស្ថានភាពមុខរបរ ស្ថានភាពទ្រព្យសម្បត្តិ និងសមាជិកដែលមិនអាចរកចំណូលបានជាដើមនោះ ឃើញថាប្រជាពលរដ្ឋភាគច្រើនស្មើនឹង៩៦.៨% ស្ថិតក្នុងស្ថានភាពជីវភាពមិនចូលក្នុងកម្រិតក្រីក្រទាំងពីរ (ក្រីក្រកម្រិតទី១ និងក្រីក្រកម្រិតទី២) ឬអាចនិយាយបានថាប្រជាពលរដ្ឋមានជីវភាពមធ្យមអាចរស់នៅបានទប់ទល់នឹងជីវភាព ប៉ុន្តែមិនទាន់មានការបញ្ជាក់អះអាងលំអិតថាអ្នកទាំងនេះស្ថិតក្នុងស្ថានភាពមាន ឬមធ្យមកម្រិតណានោះទេ។ ដោយឡែក មានប្រជាពលរដ្ឋចំនួន២.៩% ស្ថិតក្នុងស្ថានភាពក្រីក្រកម្រិតទី២ និង០.៣% ប៉ុណ្ណោះដែលស្ថិតក្នុងស្ថានភាពក្រីក្រកម្រិតទី១។ (សូមមើលក្រាហ្វិកទី១៦)

ប្រៀបធៀបរវាងគ្រួសារ ដែលមានប័ណ្ណបញ្ជាក់ពីភាពក្រីក្រមានចំនួន១៣% ខាងលើ ជាមួយគ្រួសារដែលស្ថិតក្នុងស្ថានភាពក្រីក្រកម្រិតទី១ និងទី២ ខាងក្រោម បង្ហាញថា គ្រួសារដែលស្ថិតក្នុងស្ថានភាពក្រីក្រទាំងពីរកម្រិតមានត្រឹមតែ៣.២% ប៉ុណ្ណោះ ដូច្នេះវាមានភាពខុសគ្នាដោយសារតែប័ណ្ណក្រីក្រដែលពួកគេទទួលបានគឺ

---

47 ក្រសួងផែនការ «បញ្ជីសំណួរសម្រាប់កំណត់ អត្តសញ្ញាណគ្រួសារក្រីក្រ»

48 «សៀវភៅទិន្នន័យស្រុកសេសាន ឆ្នាំ២០០៩» ខេត្តស្ទឹងត្រែង (Sesan District Data Book 2009, Stung Treng Province)

49 តាមរយៈសៀវភៅទិន្នន័យស្រុកសេសាន ឆ្នាំ២០០៩ គម្រោងអាយឌីពួ(ID Poor) មិនទាន់គ្របដណ្តប់ស្រុកសេសាន ខេត្តស្ទឹងត្រែងនៅឡើយទេ។

ក្នុងកំឡុងពេល៥ឆ្នាំចុងក្រោយបើគិតដល់ថ្ងៃសម្ភាសន៍ ដែលអាចធ្វើអោយជីវភាពពួកគេអាចមានភាពប្រែប្រួលក្នុងកំឡុងពេល៥ឆ្នាំចុងក្រោយនេះ។

ក្រាហ្វិកទី១៦- អត្រានៃភាពក្រីក្រ




## ៤. ធនធានសង្គម

### ៤.១. ប្រពៃណី សាសនា និងការទំនាក់ទំនង

ប្រទេសកម្ពុជា ជាប្រទេសដែលប្រកាន់យកព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ព្រោះប្រជាពលរដ្ឋប្រមាណជា៩០%កាន់សាសនាព្រះពុទ្ធ។[50] ទន្ទឹមនឹងនេះ តាមរយៈការសិក្សា ប្រជាពលរដ្ឋស្ទើរតែទាំងអស់ស្មើនឹង៩៨% កាន់សាសនាព្រះពុទ្ធ ១%មានជំនឿទៅលើអ្នកតា និង១%ទៀតមានជំនឿទៅលើដូងព្រលឹងផ្សេងៗ ឬព្រះសែន។ ទោះជាប្រជាពលរដ្ឋភាគច្រើនបំផុតមានជំនឿទៅលើសាសនាព្រះពុទ្ធ ក៏ពួក

[50] www.culturalprofiles.net/cambodia/directories/cambodia_cultural_profile/-35.html (Searched website on May 10, 2012)

គេនៅមានជំនឿលើការសែនព្រេននៅក្នុងព្រៃ និងមានសែនអ្នកតាក្នុងភូមិជាដើមដែរ។

ប្រជាពលរដ្ឋនៅក្នុងភូមិ ភាគច្រើនតែងជួបជុំគ្នានាពេលបុណ្យទានផ្សេងៗនៅវត្តអារាម ឬសាលាឆទានដែលមាននៅក្នុងភូមិ ជាពិសេសនាពេលមានបុណ្យប្រពៃណី និងបុណ្យសាសនាដូចជា បុណ្យចូលឆ្នាំខ្មែរ បុណ្យភ្ជុំបិណ្ឌ បុណ្យកឋិន បុណ្យផ្កា សាមគ្គី បុណ្យមាឃបូជា ពិសាខបូជា ចេញវស្សា ចូលវស្សា បុណ្យដាលាន ឬសែនស្រូវ បុណ្យបួសនាគ បុណ្យសែនអ្នកតា និងបុណ្យអុំទូក។

ការជួបជុំគ្នានាពេលបុណ្យសាសនា ក៏ដូចជាបុណ្យប្រពៃណីផ្សេងៗជាវិធីក្នុងការកសាងទំនាក់ទំនង និងការជួយគ្នាទៅវិញទៅមករវាងប្រជាពលរដ្ឋនៅក្នុងភូមិនីមួយៗ។ ក្នុងការជួបជុំគ្នានេះ ពួកគេបានធ្វើការងាររួមគ្នាដោយមានអ្នកខ្លះចូលបច្ច័យ(ថវិកា) អង្ករ និងរបស់របរផ្សេងៗ ដើម្បីរៀបចំកម្មវិធីបុណ្យ និងការសប្បាយជុំគ្នា។ *«អ្នកភូមិមានការសស្រាក់សស្រាំក្នុងការធ្វើបុណ្យ ដូចដល់រដូវបុណ្យភ្ជុំបិណ្ឌ ប្រជាពលរដ្ឋចែកវេនគ្នាកាន់ជាក្រុមកាន់បិណ្ឌពី បិណ្ឌ១រហូតដល់បិណ្ឌ ១៥ហៅបិណ្ឌធំ។ ពេលបុណ្យផ្កា ប្រជាពលរដ្ឋក៏ដាក់វេណធ្វើបុណ្យផ្កាទៅតាមបុណ្យតូចបុណ្យធំ។ បុណ្យដែលធំមានបុណ្យចូលឆ្នាំ បុណ្យភ្ជុំបិណ្ឌ បុណ្យមាឃបូជា បុណ្យផ្កា បុណ្យកឋិន»*។

មានប្រជាពលរដ្ឋតែ៣៧%ប៉ុណ្ណោះ ដែលនិយាយថា ក្នុងភូមិរបស់ខ្លួនមានការជួយគ្នា ឬប្រវ៉ាស់ដៃគ្នាក្នុងការធ្វើស្រែចំការទាំងរដូវដកស្ទូង និងរដូវប្រមូលផល។ ដោយឡែក មានប្រជាពលរដ្ឋភាគច្រើនរហូតដល់៦៣% ដែលនិយាយថានៅភូមិរបស់ខ្លួនមិនមានការប្រវ៉ាស់ដៃគ្នាក្នុងការធ្វើស្រែចំការនោះទេនាពេលបច្ចុប្បន្ន ប៉ុន្តែកាលពីមុននៅភូមិរបស់គេក៏ធ្លាប់មានដែរ តែបានបាត់បង់ទៅវិញបន្ទាប់ពីប្រជាពលរដ្ឋចាប់ផ្តើមយកការស៊ីឈ្នួលធ្វើស្រែចំការជាមុខរបរ។ ភាគច្រើន ភូមិដែលមិនមានប្រជាពលរដ្ឋធ្វើការប្រវ៉ាស់ដៃគ្នាមាននៅភូមិស្វាយរៀង ភូមិខ្សាច់ថ្មី និងភូមិតាឡាត ឃុំតាឡាត ស្រុកសេសាន ខេត្តស្ទឹងត្រែង និងភូមិ៣ ឃុំស្រែអង្គ្រង ស្រុកកូនមុំ ខេត្តរតនគិរី។ តាមរយៈការពិភាក្សាក្រុម នៅភូមិក្របីជ្រុំ ក្នុងឃុំក្បាលរមាស ភូមិខ្សាច់ថ្មី

ក្នុងឃុំតាឡាត និងភូមិភ្លុក ក្នុងឃុំភ្លុក ស្រុកសេសាន ខេត្តស្ទឹងត្រែង និងភូមិ២ ក្នុងឃុំស្រែអង្គ្រង ស្រុកកូនមុំ ខេត្តរតនគិរី ប្រជាពលរដ្ឋមានការជួយគ្នា ឬប្រវាស់ដៃគ្នា ក្នុងការធ្វើស្រែចំការដូចជាច្រូតស្រូវ ស្ទូងស្រូវ *«ពួកយើងធ្លាប់ធ្វើពីមុនមកដល់ឥឡូវនេះ។ សកម្មភាពជួយគ្នាមានដូចជាជួយច្រូត ជួយស្ទូង ដោយអ្នកហើយមុនទៅជួយអ្នកមិនទាន់ហើយមិនប្រកាន់គ្នា និងមានហូបបាយទឹកជុំគ្នាពេលទៅជួយគ្នាទៀត»*។ ចំណែកប្រធានភូមិ និងអនុប្រធានភូមិបានបង្ហាញថា ប្រជាពលរដ្ឋមកពី៦ភូមិ ដូចជាភូមិ១ ក្នុងឃុំស្រែអង្គ្រង ស្រុកកូនមុំ ខេត្តរតនគិរី ភូមិច្រប់ និងភូមិក្បាលរមាស ក្នុងឃុំក្បាលរមាស ភូមិស្រែគរពីរ ក្នុងឃុំស្រែគរ និងភូមិភ្លុក ក្នុងឃុំភ្លុក និងភូមិរំពាត់ ក្នុងឃុំតាឡាត ស្រុកសេសាន ខេត្តស្ទឹងត្រែង ជាភូមិដែលតែងតែជួយគ្នាទៅវិញទៅមក ឬប្រវាស់ដៃគ្នានៅរដូវធ្វើស្រែចំការ និងប្រមូលផល នេះជារូបភាពសាមគ្គីភាពរវាងអ្នកភូមិដូចគ្នា ដែលជាទំនាក់ទំនងសង្គមដ៏ចាំបាច់។

## ៤.២ ការសន្សំប្រាក់ និងធនាគារស្រូវនៅក្នុងភូមិ

ក្នុងចំណោមប្រជាពលរដ្ឋទាំង៣១៥គ្រួសារ មានប្រជាពលរដ្ឋចំនួន១៨% ប៉ុណ្ណោះដែលនិយាយថា នៅក្នុងភូមិមានសន្សំប្រាក់ដើម្បីជួយគ្នាទៅវិញទៅមក ដែលមានការប្រាក់ទាប ចំណែក៨២%និយាយថា នៅក្នុងភូមិមិនមានការសន្សំប្រាក់ ឬធនាគារស្រូវដើម្បីជួយគ្នានោះទេ។ ករណីសន្សំប្រាក់ ឬធនាគារស្រូវក្នុងភូមិមិនត្រូវបានរកឃើញទេនៅភូមិតាឡាត ភូមិរំពាត់ ភូមិស្រែគរពីរ ភូមិស្រែស្រណុក និងភូមិច្រប់ ក្នុងស្រុកសេសាន ខេត្តស្ទឹងត្រែង។ ការសន្សំប្រាក់ក្នុងភូមិ គឺដើម្បីយកថវិកានេះជួយគ្នាទៅវិញទៅមកពេលមានការខ្វះខាត។ ដោយឡែក ភូមិស្រែគរមួយមិនមានសន្សំប្រាក់ទេ តែមានធនាគារស្រូវ ឬស្រូវសហគមន៍ ដើម្បីអោយប្រជាពលរដ្ឋក្នុងក្រុមសន្សំ អាចខ្ចីស្រូវបានក្នុងសំណាងការទាប ព្រោះបើទៅខ្ចីពីអ្នកក្រៅនឹងអស់សំណាងការខ្ពស់។ (សូមមើលក្រាហ្វិកទី១៧)

ក្រាហ្វិកទី១៧- ការសន្សំប្រាក់ ឬធនាគាស្រូវក្នុងភូមិ




## ៥. ធនធានធម្មជាតិ

### ៥.១ ព្រៃឈើ និងផលប្រយោជន៍

ឈើជាច្រើនប្រភេទនៅតំបន់សិក្សា នៅមានលក្ខណៈសំបូរបែបនៅឡើយ តាមរយៈការចុះអង្កេតនៅតំបន់សិក្សាទាំង១៤ភូមិ ក្នុងឃុំទាំង៥។ ប្រជាពលរដ្ឋក្នុងតំបន់ ជាទូទៅបាននឹងកំពុងទាញយកផលប្រយោជន៍ និងអនុផលពីព្រៃឈើដូចជា កាប់ឈើមកធ្វើផ្ទះ/គ្រឿងសង្ហារឹមប្រើប្រាស់ និងកាប់ដើមឈើងាប់ៗ ឬរើសឈើដើម្បីធ្វើជាអុសដុត។ គ្រឿងសង្ហារឹមសម្រាប់បម្រើឲ្យទីផ្សារមួយចំនួនក៏មានប្រភពចេញពីតំបន់នេះដែរ។ ក្រៅពីនេះ អ្នកស្រុកបានទាញយកផលជាច្រើនទៀតពីអនុផលព្រៃឈើដូចជា ជ័រទឹក ទឹកឃ្មុំ វល្លិ៍ ស្លឹកឈើ ឫសឈើ និងផ្លែឈើព្រៃជាដើម សម្រាប់បម្រើឲ្យការរស់នៅប្រចាំថ្ងៃរបស់ពួកគេ។ នៅមានករណីតិចតួចដែលប្រជាពលរដ្ឋប្រើប្រាស់ព្រៃដ៏សំបូរបែបនេះសម្រាប់ការចិញ្ចឹមសត្វរបស់ពួកគេ។ (សូមមើលតារាងទី២៥)

តារាងទី២៥- ផលប្រយោជន៍នៃព្រៃឈើចំពោះជីវភាពប្រជាពលរដ្ឋ

| ផលប្រយោជន៍ | ចំនួន | ភាគរយ |
|---|---|---|
| កាប់ឈើធ្វើផ្ទះ/គ្រឿងសង្ហារឹមប្រើប្រាស់ | ២៥៧ | ៣៦.១ |
| កាប់ឈើ ឬរើសឈើងាប់សម្រាប់ដុត | ២៤២ | ៣៤ |
| កាប់ឈើដែលធ្វើផ្ទះ/គ្រឿងសង្ហារឹម សម្រាប់លក់ | ៧៨ | ១១ |
| រកជ័រទឹក ឬឃ្មុំ | ៦៨ | ៩.៦ |
| បោចវល្លិ៍ ស្លឹកឈើ ឫសឈើ ផ្លែឈើ | ៦៥ | ៩.១ |
| ជាកន្លែងសម្រាប់ចិញ្ចឹមសត្វ | ១ | ០.១ |
| សរុប | ៧១១ | ១០០ |

*ចំនួនអ្នកតបសម្ភាសន៍សរុប៣១៥នាក់

ផលប្រយោជន៍ទាំងនេះបញ្ជាក់ថា ធនធានព្រៃឈើពិតជាមានសារៈប្រយោជន៍ច្រើនសម្រាប់គ្រួសារគោលដៅជាច្រើននៅតាមភូមិក្បែរព្រៃ ជាពិសេសតំបន់គោលដៅដែលនឹងត្រូវរងផលប៉ះពាល់ ដែលបានបម្រើអោយផលប្រយោជន៍ជីវភាព ឬសម្រាលបញ្ហាជីវភាពគ្រួសារប្រជាពលរដ្ឋបានមួយផ្នែក។ បន្ថែមពីនេះព្រៃឈើជាប្រភពធនធាន ដែលមិនអាចកាត់ផ្ដាច់បានពីជីវភាពប្រជាពលរដ្ឋ ជាពិសេស ជនជាតិដើមភាគតិចមួយចំនួនដូចជា ជនជាតិព្នង គ្រឹង ទំពួន ព្រៅជាដើមដែលរស់នៅភូមិក្បាលរមាស និងភូមិស្រែស្រណុក ក្នុងឃុំក្បាលរមាស ភូមិរំពាត់ និងភូមិខ្សាច់ថ្មី ក្នុងឃុំតាឡាត នៅស្រុកសេសាន ខេត្តស្ទឹងត្រែងដែលពឹងផ្អែកជាចំបងលើធនធានព្រៃឈើ។

ច្បាប់ព្រៃឈើមានទំនាក់ទំនងជាមួយជនជាតិដើមភាគតិច ដែលអាស្រ័យផលពីធនធានព្រៃឈើ។ «ច្បាប់ព្រៃឈើ ឆ្នាំ២០០២» ត្រូវបានបង្កើតឡើងដើម្បីគ្រប់គ្រងព្រៃឈើនៅក្នុងប្រទេសកម្ពុជា ហើយច្បាប់នេះបានផ្ដល់ការធានាអប្បរមាដល់ជនជាតិដើមភាគតិចតាមរយៈការផ្ដល់សិទ្ធិស្របច្បាប់ក្នុងការទទួលបាន «សិទ្ធិប្រើប្រាស់ជាប្រពៃណី» ក្នុងតំបន់ព្រៃឈើ។[51] លើសពីនេះ មាត្រា៤០នៃច្បាប់ព្រៃឈើក៏បានរៀបរាប់ពីមូលដ្ឋាន ដែលបង្កើតអោយមានសិទ្ធិប្រើប្រាស់ជាប្រពៃណីទៅ

[51] ច្បាប់ស្តីពីព្រៃឈើ (២០០២) មាត្រា១៥

លើផលព្រៃឈើដោយបានចែងនូវសកម្មភាពមួយចំនួន ដែលជនជាតិដើមភាគតិច ត្រូវអនុញ្ញាតអោយធ្វើបាននៅក្នុងតំបន់ព្រៃបំរុងទុកអចិន្ត្រៃយ៍ ដោយមិនចាំបាច់មានលិខិតអនុញ្ញាត។[52]



រូបភាពទី៦- ព្រៃឈើនៅតាមដងផ្លូវចូលទៅកាន់ភូមិស្រែស្រណុក

## ៥.២. សត្វព្រៃ និងផលប្រយោជន៍

សត្វព្រៃគឺជាចំណែកមួយនៃធនធានធម្មជាតិ ដែលមាននៅក្នុងតំបន់ព្រៃឈើហើយសត្វព្រៃ ក៏បានផ្តល់ប្រយោជន៍យ៉ាងសំខាន់សម្រាប់ជីវភាពប្រជាពលរដ្ឋដែលពឹងអាស្រ័យលើធនធានពីព្រៃឈើដែរ។ ក្នុងនោះការបរិភោគសត្វព្រៃ និងការលក់ដូរតិចតួចខ្លះនៅតំបន់គោលដៅនៃការសិក្សានៅតែបន្តកើតមាន។

ប្រជាពលរដ្ឋរហូតដល់៧៨% នៅគ្រប់ភូមិទាំងអស់ក្នុងការសិក្សានេះយល់ថានៅតំបន់ជុំវិញក្បែរខាងដែលគេរស់នៅ គឺសំបូរសត្វព្រៃ ប៉ុន្តែមានតែប្រជាពលរដ្ឋប្រមាណ៥៩% ប៉ុណ្ណោះបានបង្ហើបថា បានទទួលផលប្រយោជន៍ពីសត្វព្រៃ។ ផលប្រយោជន៍ពីសត្វព្រៃដែលប្រជាពលរដ្ឋបានទទួលរួមមាន ការប្រមាញ់សត្វព្រៃមកធ្វើជាអាហារប្រចាំថ្ងៃ ការប្រមាញ់សត្វព្រៃយកទៅលក់ និងការប្រមាញ់សត្វព្រៃធ្វើជាឱសថព្យាបាលជម្ងឺផ្សេងៗ។ គួរកត់សម្គាល់ បើអ្នកភូមិរកសត្វព្រៃបានចំនួនច្រើន ទើបយកទៅលក់ ឬចែកអ្នកជិតខាង។ តាមការបញ្ជាក់ពីអ្នកភូមិ ការចាប់

[52] ច្បាប់ស្តីពីព្រៃឈើ (២០០២) មាត្រា៤០

សត្វព្រៃគឺតាមវិធីដាក់អន្ទាក់ ឬបណ្តើរឆ្កែរចូលក្នុងព្រៃ ហើយសត្វព្រៃដែលក្រុមការងារស្រាវជ្រាវសង្កេតឃើញអ្នកភូមិចាប់បានរួមមានជ្រូកព្រៃ ត្រកួត ឈ្លូស ចាបព្រៃពពូលជាដើម។ ចំពោះប្រធានភូមិ និងអនុប្រធានភូមិទាំងអស់បានបង្ហាញថាសត្វព្រៃក៏មិនខុសពីព្រៃឈើដែរ ទោះជាមិនសំបូរសត្វព្រៃនៅតំបន់ខ្លះ ប៉ុន្តែប្រជាពលរដ្ឋនៅតែអាចបានទទួលផលប្រយោជន៍ពីសត្វព្រៃ។ (សូមមមើលតារាងទី២៦)

យ៉ាងណាមិញ បើទោះជាប្រជាពលរដ្ឋជាងពាក់កណ្តាលបានទទួលផលប្រយោជន៍ខ្លះពីសត្វព្រៃ ប៉ុន្តែពួកគេបានបង្ហាញពីភាពមិនសូវសប្បាយចិត្តដោយសារបច្ចុប្បន្នពួកគេមិនបានទទួលផលប្រយោជន៍ច្រើនដូចកាលពីមុនទេ។ នេះមានន័យថាទិន្នផល និងផលចំណូលដែលបានពីសត្វព្រៃមានការថយចុះច្រើនដោយសារការរឹតបន្តឹងការការពារសត្វព្រៃពីសំណាក់អាជ្ញាធរ និងចំនួនប្រជាពលរដ្ឋនៅក្នុងភូមិមានការកើនឡើង ដែលធ្វើអោយមានតម្រូវការចែកផលប្រយោជន៍ពីសត្វព្រៃនេះ។ ដោយសារមានការហាមប្រាមចំពោះការប្រមាញ់សត្វព្រៃក្នុងការធ្វើអាជីវកម្ម អ្នកភូមិបានដឹងថាវាជាអំពើខុសច្បាប់ ប៉ុន្តែសត្វព្រៃមួយចំនួនក៏ត្រូវបានអនុញ្ញាត សម្រាប់ការបរិភោគលក្ខណ:គ្រួសារដែរ ដូចជាជ្រូកព្រៃជាដើម ពីព្រោះជ្រូកព្រៃមានចំនួនច្រើន ហើយវាតែងតែបង្កបញ្ហាដល់ដំណាំកសិកម្មរបស់អ្នកភូមិ។

យោងតាមច្បាប់ព្រៃឈើឆ្នាំ២០០២ បានបង្ហាញថា ពពួកសត្វព្រៃគ្រប់ប្រភេទនៅព្រះរាជាណាចក្រកម្ពុជាគឺជាសម្បត្តិរបស់រដ្ឋ និងជាសមាសភាគនៃធនធានព្រៃឈើដែលរួមមានពពួកថនិកសត្វ បក្សីសត្វ ឧរង្គសត្វ ថលជលិកសត្វ បាណកសត្វ និងសត្វឥតឆ្អឹងកងផ្សេងទៀតព្រមទាំងពង កូនរបស់វា។ គ្រប់ប្រភេទសត្វព្រៃទាំងអស់ត្រូវបានបែងចែកជាបីក្រុមគឺ ក្រុមប្រភេទជិតផុតពូជ ក្រុមប្រភេទមានដោយកម្រ និងក្រុមប្រភេទមានដោយបង្គួរ។[53]

រាល់ការធ្វើសកម្មភាពដូចខាងក្រោម ចំពោះប្រភេទសត្វក្នុងប្រភេទមានដោយបង្គួរត្រូវហាមឃាត់ លើកលែងតែមានលិខិតអនុញ្ញាតចេញដោយរដ្ឋបាលព្រៃឈើ៖

[53] ច្បាប់ព្រៃឈើ ឆ្នាំ២០០២ ជំពូកទី១០ មាត្រា៤៨

១- ការធ្វើសន្និធិការថែរក្សាជាលក្ខណៈសួនសត្វ ឬគ្រួសារ។

២-ការដឹកជញ្ជូន និងធ្វើពាណិជ្ជកម្មលើសពីបរិមាណចាំបាច់សម្រាប់ការស់ជាប្រពៃណី។[54] ដូច្នេះ ទាក់ទងនឹងច្បាប់ព្រៃឈើខាងលើនេះ ប្រជាពលរដ្ឋនៅតំបន់សិក្សាអាចមានសិទ្ធិប្រើប្រាស់ប្រភេទសត្វព្រៃមួយចំនួន ដែលស្ថិតក្នុងក្រុមប្រភេទមានដោយបង្គួរមិនលើសពីបរិមាណចាំបាច់ជាលក្ខណៈប្រពៃណីដែលបានអនុញ្ញាតដោយរដ្ឋបាលព្រៃឈើ លើកលែងតែការជួញដូរ ឬធ្វើពាណិជ្ជកម្មដែលត្រូវមានលិខិតអនុញ្ញាតចេញដោយរដ្ឋបាលព្រៃឈើ ដោយមានការឯកភាពដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

តារាងទី២៦- ផលប្រយោជន៍សត្វព្រៃចំពោះជីវភាពប្រជាពលរដ្ឋ

| ផលប្រយោជន៍ | ចំនួន | ភាគរយ |
|---|---|---|
| ប្រម៉ាញ់សត្វព្រៃជាអាហារ | **១៧៥** | **៥៩.៩** |
| ប្រម៉ាញ់សត្វព្រៃដើម្បីលក់ | **១១៣** | **៣៨.៧** |
| ប្រម៉ាញ់សត្វព្រៃដើម្បីធ្វើជាឱសថ | ៤ | ១.៤ |
| **សរុប** | ២៩២ | ១០០ |

*ចំនួនអ្នកតបសម្ភាសន៍សរុប៣១៥នាក់



រូបភាពទី៧- ប្រភេទសត្វព្រៃមួយចំនួនដែលប្រជាពលរដ្ឋអាចប្រមាញ់បាន

[54] ច្បាប់ព្រៃឈើ ឆ្នាំ២០០២ ជំពូកទី១០ មាត្រា៥០

## ៥.៣. ប្រភពទឹក និងផលប្រយោជន៍

### ប្រភពទឹកចំបងដែលប្រជាពលរដ្ឋប្រើប្រាស់ប្រចាំថ្ងៃ

ប្រជាពលរដ្ឋគ្រប់ភូមិទាំងអស់ ដែលបានចូលរួមក្នុងការសិក្សា រស់នៅតាមដងទន្លេសេសាន និងស្រែពក ហើយប្រើប្រាស់ទឹកទន្លេជាប្រភពទឹកចំបងសម្រាប់ជីវភាពប្រចាំថ្ងៃ លើកលែងតែភូមិច្រប់ ក្នុងឃុំក្បាលរមាស ស្រុកសេសាន ខេត្តស្ទឹងត្រែង គឺប្រជាពលរដ្ឋប្រើប្រាស់ទឹកអូរដែលនៅជិតនោះ ពីព្រោះទន្លេនៅឆ្ងាយពីភូមិ។



រូបភាពទី៨- ប្រភពទឹកទន្លេដែលប្រជាពលរដ្ឋប្រើប្រាស់ប្រចាំថ្ងៃ

### ផលប្រយោជន៍នៃទន្លេចំពោះជីវភាពប្រជាពលរដ្ឋ

ប្រជាពលរដ្ឋដែលរស់នៅតាមដងទន្លេសេសាន និងស្រែពកសុទ្ធសឹងតែបានទទួលផលប្រយោជន៍ពីទន្លេទាំងពីរសម្រាប់ជីវភាពប្រចាំថ្ងៃ។ តាមរយៈការសិក្សានេះបានបង្ហាញថា ប្រជាពលរដ្ឋចំនួន៩០.៧% បានទទួលផលប្រយោជន៍ដោយមានទឹកប្រើប្រាស់គ្រប់គ្រាន់សម្រាប់ក្រុមគ្រួសារ (ដូចជាទទួលទាន ដាំស្ល លាងសម្អាត បោកគក់ ងូតជាដើម) ប្រជាពលរដ្ឋចំនួន៣៥% អាចប្រកបរបរនេសាទ និង១៥.៩% មានទឹកគ្រប់គ្រាន់ក្នុងការប្រកបរបរកសិកម្មដាំដុះ និងចិញ្ចឹមសត្វផ្សេងៗ។ (សូមមើលតារាងទី២៧)

តារាងទី២៧- ផលប្រយោជន៍នៃទន្លេចំពោះប្រជាពលរដ្ឋ

| ផលប្រយោជន៍នៃទន្លេ | ចំនួន | ភាគរយ |
|---|---|---|
| មានទឹកប្រើប្រាស់គ្រប់គ្រាន់ក្នុងគ្រួសារ | **៣១០** | **៤០.៧** |
| នេសាទត្រី | **២៦៦** | **៣៥** |
| មានទឹកប្រើប្រាស់គ្រប់គ្រាន់សម្រាប់កសិកម្ម/ចិញ្ចឹមសត្វ | **១២១** | **១៥.៩** |
| អាចដាំដុះដំណាំតាមដងទន្លេ | ៦៣ | ៨.៣ |
| គ្មានផលប្រយោជន៍(មិនមានទន្លេនៅជិតភូមិ) | ១ | ០.១ |
| សរុប | ៧៦១ | ១០០ |

*ចំនួនអ្នកតបសម្ភាសន៍សរុប៣១៥នាក់



រូបភាពទី៩- ដំណាំលក្ខណៈគ្រួសារដែលស្រោចស្រពដោយទឹកទន្លេ

## ប្រភពទឹកដែលប្រជាពលរដ្ឋមានផ្ទាល់ខ្លួន

ដោយសារប្រជាពលរដ្ឋស្ទើរតែទាំងអស់ស្មើនឹង៩៩% ប្រើប្រាស់ទឹកទន្លេជាប្រភពទឹកចំបង ដូច្នេះមានតែប្រជាពលរដ្ឋតិចបំផុតប្រហែលជា១% ឬស្មើនឹង៤នាក់ប៉ុណ្ណោះ ដែលមានប្រភពទឹកផ្ទាល់ខ្លួនដូចជាអណ្តូង និងស្រះ ហើយប្រភពទឹកទាំងនេះអាចប្រើប្រាស់បានពេញមួយឆ្នាំ។ មួយវិញទៀត ក្នុងចំណោម៤គ្រួសារដែលមានប្រភពទឹកផ្ទាល់ខ្លួនសម្រាប់ប្រើប្រាស់នៅផ្ទះ មានមួយគ្រួសារចំណាយថវិកាអស់តិចជាង ១០០,០០០រៀល មួយគ្រួសារទៀតចំណាយថវិកាអស់ពី ១២០០,០០០-១,៥៩៩,០០០រៀល និងមាន២គ្រួសារទៀតចំណាយថវិកាអស់ពី

២,០០០,០០០រៀល ឬលើសពីនេះ ក្នុងការជីកស្រះ ឬអណ្តូងទឹក។ នេះបញ្ជាក់ថាប្រជាពលរដ្ឋនៅទីនោះមានទឹកទន្លេជាប្រភពទឹកប្រើប្រាស់ចំបង ដែលគ្រប់គ្រាន់សម្រាប់ការប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃដោយមិនចាំបាច់ជីកអណ្តូង ឬស្រះ ដើម្បីយកទឹកមកប្រើប្រាស់នោះទេ។ (សូមមើលក្រាហ្វិកទី១៨)

គួរកត់សម្គាល់ថា មានតែប្រជាពលរដ្ឋចំនួន៩%ប៉ុណ្ណោះ ក្នុងចំណោមប្រជាពលរដ្ឋដែលមិនមានប្រភពទឹកប្រើប្រាស់ផ្ទាល់ខ្លួនដូចជាអណ្តូង ឬស្រះ ដែលប្រើប្រាស់ប្រភពទឹកដូចជាអណ្តូងរួម ឬអណ្តូងអ្នកជិតខាងក្នុងភូមិបន្ថែមទៀតក្រៅពីទឹកទន្លេ ប៉ុន្តែមិនមានការបញ្ជាក់ពីការប្រើប្រាស់ទឹកភ្លៀងនៅតំបន់សិក្សានោះទេ។

ក្រាហ្វិកទី១៨- ប្រភពទឹកផ្ទាល់ខ្លួនដែលប្រជាពលរដ្ឋមាន




### ចម្ងាយនៃប្រភពទឹកប្រើប្រាស់ចំបងប្រចាំថ្ងៃនៅរដូវប្រាំង

ប្រជាពលរដ្ឋប្រើប្រាស់ប្រភពទឹកប្រចាំថ្ងៃ មានចម្ងាយជាមធ្យមត្រឹមតែ៩៦.៣៩ម៉ែត្រប៉ុណ្ណោះ ពីផ្ទះរបស់ខ្លួន។ ក្នុងនោះដែរ មានប្រជាពលរដ្ឋ៥៨.៧%រស់នៅចម្ងាយពីប្រភពទឹកតិចជាង១០០ម៉ែត្រ ឯប្រជាពលរដ្ឋ៣៩% រស់នៅចម្ងាយពីប្រភពទឹកពី១០០-៥០០ម៉ែត្រ និងមានប្រជាពលរដ្ឋ១.៣%ប៉ុណ្ណោះ ដែលរស់នៅក្នុងចម្ងាយ៥០១-១០០០ម៉ែត្រពីប្រភពទឹក។ (សូមមើលក្រាហ្វិកទី១៩)

ដោយសារចម្ងាយពីផ្ទះប្រជាពលរដ្ឋទៅកាន់ទន្លេ ឬអូរ (ចំពោះប្រជាពលរដ្ឋនៅភូមិច្រប់ប្រើទឹកអូរ) នៅរដូវប្រាំងជាមធ្យមមិនដល់១០០ម៉ែត្រ នេះបង្ហាញថាជាទូទៅប្រភពទឹកហាក់នៅមិនឆ្ងាយពីតំបន់ដែលប្រជាពលរដ្ឋរស់នៅឡើយ ហើយប្រជាពលរដ្ឋអាចប្រើប្រាស់ទឹកបានគ្រប់គ្រាន់ទៀត។

ក្រាហ្វិកទី១៩- ចម្ងាយពីផ្ទះទៅប្រភពទឹកប្រើប្រាស់ប្រចាំថ្ងៃនៅរដូវប្រាំង




## តំបន់ទេសចរណ៍ដែលមានក្នុងសហគមន៍

តាមរយៈការអង្កេតជាក់ស្តែង ក៏ដូចជាការសម្ភាសន៍តាមគ្រួសារគោលដៅបានបង្ហាញថាមានប្រជាពលរដ្ឋ១៧% ឬស្មើនឹង៥៥គ្រួសារប៉ុណ្ណោះដែលស្ថិតក្នុងភូមិភ្លុក ភូមិ១ ភូមិ២ និងភូមិ៣ ដែលនិយាយថាតំបន់រស់នៅរបស់ខ្លួនមានតំបន់ទេសចរណ៍។[55] ជាងនេះទៅទៀត ក្នុងចំណោម១៧% ដែលនិយាយថាមានតំបន់ទេសចរណ៍នៅតំបន់របស់ខ្លួន មាន១៦%និយាយថាពួកគេមិនបានទទួលផលប្រយោជន៍ដែលអាចទាញយកជាប្រាក់ចំណូលពីតំបន់ទេសចរណ៍នេះទេដោយសារ

[55] តំបន់ទេសចរណ៍ដែលប្រជាពលរដ្ឋលើឡើងនៅទីនេះគឺជាប្រភេទកន្លែងទេសចរណ៍តូចលើផ្ទៃទន្លេដែលមានទឹកទន្លេហូរខ្លាំងនៅម្តុំនោះ ហើយពេលមានបុណ្យទានធំៗមានប្រជាពលរដ្ឋនៅជិតខាងភូមិចុះទៅលេង ងូតទឹកកំសាន្ត តែមិនមែនជាតំបន់ទេសចរណ៍ដែលត្រូវបានចាត់ចូលបញ្ជីដោយក្រសួងឬមន្ទីទេសចរណ៍នោះទេ។

តែទីនោះជាតំបន់ទេសចរណ៍ធម្មជាតិលើដងទន្លេ ដែលមានលក្ខណៈតូចតាច មិនសូវមានអ្នកទេសចរណ៍មកកំសាន្តច្រើនទេ ប៉ុន្តែក៏មានប្រជាពលរដ្ឋចំនួនមួយប៉ុណ្ណោះដែលបញ្ជាក់ថា បានទទួលផលប្រយោជន៍ពីតំបន់ទេសចរណ៍នេះដូចជាលក់វត្ថុអនុស្សាវរីយ៍ នំចំណីដែលអាចបង្កើនប្រាក់ចំណូលក្នុងគ្រួសារ។ យ៉ាងណាមិញតាមទិន្នន័យនេះអាចកត់សម្គាល់បានថា ប្រជាពលរដ្ឋទាំងអស់ស្ទើរតែមិនបានទទួលផលប្រយោជន៍អ្វីពីកន្លែងទេសចរណ៍តូចៗ នៅទីនោះឡើយ។



រូបភាពទី១០- តំបន់ទេសចរណ៍ធម្មជាតិនៅភូមិភ្លុកឃុំភ្លុក
ស្រុកសេសាន ខេត្តស្ទឹងត្រែង

# ការយល់ដឹង និងទស្សនៈរបស់ប្រជាពលរដ្ឋ អំពីគម្រោងសាងសង់ទំនប់វារីអគ្គិសនី សេសានក្រោម២

## ១. គម្រោងសាងសង់ទំនប់

### ១.១. ប្រភពព័ត៌មានអំពីគម្រោង

ប្រជាពលរដ្ឋស្ទើរតែទាំងអស់(៩២.៣%) ដែលកំពុងរស់នៅតំបន់ដែលនឹងត្រូវទទួលរងផលប៉ះពាល់ក៏ដូចជាប្រធានភូមិ និងអនុប្រធានភូមិនៅតាមភូមិនីមួយៗ គឺសុទ្ធតែទទួលបានដំណឹង ឬឮថានឹងមានការសាងសង់ទំនប់វារីអគ្គិសនីសេសានក្រោម២ នេះ។ ប្រភពព័ត៌មានអំពីគម្រោងដែលប្រជាពលរដ្ឋបានទទួលគឺតាមរយៈអាជ្ញាធរមូលដ្ឋាន(ប្រធានភូមិ មេឃុំ អភិបាលស្រុក/ខេត្ត) ពាក្យចរចាមអារាម (ឮតៗគ្នា) តំណាងក្រុមហ៊ុនវៀតណាម អង្គការនានា និងប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ ដូចជាវិទ្យុ និងទូរទស្សន៍ជាដើម។ (សូមមើលតារាងទី២៨)

ទាក់ទងនឹងប្រភពព័ត៌មាននេះដែរ ប្រធានភូមិ និងអនុប្រធានភូមិ ទទួលបានព័ត៌មានពីប្រភពផ្សេងៗគ្នាទាក់ទងនឹងគម្រោងសាងសង់ទំនប់វារីអគ្គិសនី ដោយក្នុងនោះមាន៣០% បានទទួលព័ត៌មាននេះពីអាជ្ញាធរក្នុងស្រុក (អាជ្ញាធរឃុំ ស្រុក ឬខេត្ត) ៣៨%បានឮព័ត៌មានពីអង្គការផ្សេងៗ (ដូចជាអង្គការសេប៉ា ទន្លេបី អាដហុក និងអុកស្វាម) ២៧%បានឮដំណឹងពីក្រុមហ៊ុនវៀតណាម និង ៣%ដឹងដំណឹងតាមពាក្យចរចាមអារាម។ ចំណែកប្រភពព័ត៌មានពីអាជ្ញាធរក្នុងស្រុក គឺមានប្រធានភូមិ ឮតាមរយៈឯកឧត្តម ស៊ុយ សែម កាលពីពេលសម្ពោធការដ្ឋានសាងសង់ទំនប់នៅខេត្តស្ទឹងត្រែង និងឮតាមរយៈការផ្សព្វផ្សាយរបស់រាជរដ្ឋាភិបាលតាមរយៈថ្នាក់ខេត្ត ថ្នាក់ឃុំ។

តារាងទី២៨- ប្រភពព័ត៌មានអំពីគម្រោងសាងសង់ទំនប់វារីអគ្គិសនីសេសានក្រោម២

| ប្រភពព័ត៌មាន | ចំនួន | ភាគរយ |
|---|---|---|
| អាជ្ញាធរមូលដ្ឋាន (ប្រធានភូមិ មេឃុំ អភិបាលស្រុក/ខេត្ត) | ១៥៦ | ៣៤.១ |
| ពាក្យចរចាមអារាម(ឮតៗគ្នា) | ១៤២ | ៣១ |
| តំណាងក្រុមហ៊ុនវៀតណាម | ៧៧ | ១៦.៨ |
| អង្គការមិនមែនរដ្ឋាភិបាល | ៧៤ | ១៦.២ |
| ប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ (ដូចជាវិទ្យុ ទូរទស្សន៍...) | ៩ | ២ |
| សរុប | **៤៥៨** | **១០០** |

*ចំនួនអ្នកតបសម្ភាសន៍សរុប៣១៥នាក់

## ១.២. ព័ត៌មានដែលបានទទួលអំពីគម្រោង

ព័ត៌មានទាំងឡាយដែលប្រជាពលរដ្ឋនៅតំបន់គោលដៅ ដែលនឹងត្រូវទទួលរងផលប៉ះពាល់ដោយសារគម្រោងសាងសង់ទំនប់វារីអគ្គិសនីសេសានក្រោម ២ បានទទួលមានលក្ខណៈប្រហាក់ប្រហែលគ្នា ពីព្រោះពួកគេតែងបានជួបគ្នា និងនិយាយពីរឿងនេះ។ ប្រជាពលរដ្ឋប្រមាណ៧៥% បានដឹងថានឹងមានការសាងសង់ទំនប់វារីអគ្គិសនី តែមិនបានដឹងពីពេលវេលានៃការសាងសង់ពិតប្រាកដឡើយ។ ក្រៅពីនេះ ប្រជាពលរដ្ឋប្រមាណ៥៦% បានឮព័ត៌មានថានឹងមានទឹកលិចផ្ទះសំបែង និងផលដំណាំផ្សេងៗបន្ទាប់ពីការសាងសង់ទំនប់ហើយនឹងមានការជម្លៀសឬអោយប្រជាពលរដ្ឋទៅរស់នៅតំបន់ផ្សេងទៀត។ ចំណែកប្រជាពលរដ្ឋមួយចំនួន១៣% បានឮថា គេនឹងមានការផ្តល់សំណងចំពោះការផ្លាស់ទីលំនៅទៅតំបន់ថ្មីតែមិនទាន់មានភាពជាក់លាក់នៅឡើយទេ ហើយប្រជាពលរដ្ឋ៨% ក៏បានឮថា គេនឹងផ្តល់ភ្លើងអគ្គិសនីអោយប្រជាពលរដ្ឋប្រើប្រាស់បន្ទាប់ពីការសាងសង់។ អ្វីដែលគួរអោយកត់សម្គាល់មានប្រជាពលរដ្ឋ២.៨% បានរាយការណ៍ថា ក្រុមហ៊ុនវៀតណាមបានចុះវាស់វែងដីរបស់ប្រជាពលរដ្ឋ និងកត់ត្រាដើមឈើហូបផ្លែនៅក្នុងភូមិដែលមានតែមិនទាន់ឃើញមានការវាយតម្លៃចំពោះការវាស់វែងនោះនៅឡើយទេ។ ជារួមប្រជាពលរដ្ឋស្ទើរតែទាំងអស់សុទ្ធតែទទួលបានព័ត៌មាន ថានឹងមានគម្រោងសាងសង់

ទំនប់វារីអគ្គិសនីសេសានក្រោម២ ប៉ុន្តែគេមិនទាន់បានទទួលព័ត៌មានលំអិតច្បាស់លាស់ជាផ្លូវការនៅឡើយទេ *«ដឹងមិនច្បាស់ទេ គ្រាន់តែឮថាគេនឹងសាងសង់ទំនប់នៅសេសានក្រោមនេះ ពីព្រោះឮតៗគ្នា»* ។

## ១.៣. ទស្សនៈរបស់អាជ្ញាធរមូលដ្ឋានចំពោះគម្រោង

ដោយសារតែមានការយល់ឃើញថា គម្រោងសាងសង់ទំនប់វារីអគ្គិសនីសេសានក្រោម២ នឹងធ្វើអោយមានផលប៉ះពាល់ធំធេងដល់ជីវភាពរស់នៅ ដីស្រែចំការ ទ្រព្យសម្បត្តិប្រជាពលរដ្ឋ និងព្រៃឈើជាដើម ប្រធានភូមិ និងអនុប្រធានភូមិទាំងអស់មិនពេញចិត្ត និងមិនចង់អោយមានគម្រោងសាងសង់នេះកើតឡើងទេ។ ក្នុងលក្ខខណ្ឌនេះ ប្រធានភូមិ និងអនុប្រធានភូមិចំនួនពីររូប បានបញ្ជាក់បន្ថែមថា ទោះជាពួកគេមិនពេញចិត្តចំពោះគម្រោងនេះក៏ដោយ ប៉ុន្តែវាមិនមែនជារឿងដាច់ខាតទេ ព្រោះចំណែកណាមួយនៃគម្រោងនេះ អាចនឹងមានប្រយោជន៍ចំពោះប្រជាពលរដ្ឋដែរ ហើយពួកគេមិនប្រឆាំងនឹងការអភិវឌ្ឍរបស់រាជរដ្ឋាភិបាលទេ ប៉ុន្តែគេសូមអោយរដ្ឋាភិបាលគិតគូរពីផលប៉ះពាល់ផង ព្រោះវានឹងមានផលប៉ះពាល់ធំធេងដល់ការរស់នៅរបស់ប្រជាពលរដ្ឋ *«មិនចង់អោយសាងសង់ទំនប់ទេ តែហាមគេមិនបាន (ព្រោះនំមិនធំជាងនាឡ) ហើយវាពិបាកក្នុងការរស់នៅព្រោះនៅភូមិនេះមានដំណាំរបស់របរស្រាប់ប្រើប្រាស់ងាយស្រួលបើប្តូរទៅកន្លែងថ្មីវាពិបាក»*។

## ១.៤. ការប្រជុំពិភាក្សាពិគ្រោះយោបល់ពាក់ព័ន្ធនឹងគម្រោង

### ១.៤.១. ការវិភាគទៅលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមជាតំរូវការចាំបាច់ត្រូវតែអនុវត្តសម្រាប់គម្រោងអភិវឌ្ឍន៍នានាមិនថាជាក្រុមហ៊ុនឯកជន ក្រុមហ៊ុនពាក់កណ្តាលរដ្ឋ ឬដោយរដ្ឋាភិបាលនោះឡើយ។ អនុក្រឹត្យស្តីពីកិច្ចដំណើរការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាន បានបញ្ជាក់យ៉ាងច្បាស់ថា ក្នុងដំណើរការនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវតែលើកទឹកចិត្តអោយមានការចូលរួមពីសាធារណជន ព្រមទាំង

ទទួលយកមតិយោបល់ មកធ្វើការពិចារណាក្នុងកិច្ចដំណើរការអនុម័តគម្រោង។[56] តាមន័យនេះ ដំណើរការនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានចាំបាច់ត្រូវមានការចូលរួមពីប្រជាពលរដ្ឋដែលនឹងទទួលរងផលប៉ះពាល់ ដោយសារគម្រោងអភិវឌ្ឍន៍ ដើម្បីពួកគេ អាចទទួលបានការពិភាក្សាពិគ្រោះយោបល់ក្នុងដំណើរការនៃការអនុវត្តគម្រោងនូវដំណាក់កាលនីមួយៗ និងអាចសម្រេចចិត្តយល់ស្រប ឬមិនយល់ស្របចំពោះការអនុវត្តគម្រោងនោះ។ បើទោះណាជាការបញ្ជាក់នៅក្នុងអនុក្រឹត្យផ្តល់ឱកាសក្នុងការពិគ្រោះយោបល់ជាសាធារណៈក៏ពិតមែន ប៉ុន្តែចំនុចខ្វះខាតនៅតែមានដោយសារក្នុងមាត្រា១៥ និង១៧នៃអនុក្រឹត្យនេះ ផ្តល់រយៈពេលតែ៣០ថ្ងៃដល់ក្រសួងបរិស្ថាន ដើម្បីពិនិត្យទៅលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានមួយប៉ុណ្ណោះ។[57] កត្តាទាំងនេះ ជាមូលហេតុសំខាន់មួយដែលនាំអោយក្រសួងសាមីនិងស្ថាប័នពាក់ព័ន្ធ ដែលទទួលបានរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននេះមិនមានពេលវេលាគ្រប់គ្រាន់ក្នុងការពិនិត្យក៏ដូចជាពិគ្រោះយោបល់ ឬក៏សម្របសម្រួលមតិយោបល់ពីសហគមន៍ ដែលទទួលរងផលប៉ះពាល់ផ្ទាល់ដោយសារគម្រោងអភិវឌ្ឍន៍។

ការសិក្សាពីលទ្ធភាពសាងសង់គម្រោងវារីអគ្គិសនី ចែកចេញជាពីរដំណាក់កាល ដំបូងសិក្សាបុរេសមិទ្ធលទ្ធភាពនៃគម្រោង (ឆ្នាំ២០០៧ និង២០០៨) និងបន្ទាប់មកសិក្សាសមិទ្ធលទ្ធភាពនៃគម្រោង (ឆ្នាំ២០០៩ និង២០១០)។[58] យោងតាមរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ របស់គម្រោងទំនប់វារីអគ្គិសនីសេសានក្រោម២ បានបង្ហាញថាការពិគ្រោះយោបល់ជាសាធារណៈត្រូវបានធ្វើឡើងចំនួនពីរលើក។[59] ការពិគ្រោះយោបល់លើកទី១ ត្រូវបានធ្វើឡើងតាមរយៈអ្នកដឹកនាំនៅថ្នាក់ឃុំ និងថ្នាក់ភូមិ នៅឃុំចំនួន៥ ប៉ុន្តែមិនមានការបញ្ជាក់ថា

[56] អនុក្រឹត្យស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឆ្នាំ១៩៩៩, មាត្រា១ និង២

[57] អនុក្រឹត្យស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឆ្នាំ១៩៩៩, មាត្រា១៥ និង១៧

[58] រាជរដ្ឋាភិបាលកម្ពុជា លេខ: ៣១.សជណ.កបច ឆ្នាំ២០១១

[59] របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ គម្រោងវារីអគ្គិសនីសេសានក្រោម២ ក្នុងខេត្តស្ទឹងត្រែង ខែធ្នូ២០០៩ (PECC-1)

ប្រជាពលរដ្ឋប៉ុន្មាននាក់ ដែលរងផលប៉ះពាល់មកពីភូមិនីមួយៗនៅក្នុងឃុំដែលត្រូវបានអនុញ្ញាតអោយចូលរួមក្នុងការពិគ្រោះយោបល់លើកទី១នោះទេ ។ ចំណែកការពិគ្រោះយោបល់លើកទី២ មានអ្នកចូលរួមចំនួន៤៥ នាក់ ក្នុងនោះ២៦នាក់ជាមន្ត្រីរាជការ ១០នាក់ជាមេឃុំ ប្រធានភូមិ និងអនុប្រធានភូមិដែលមកពីសហគមន៍រងផលប៉ះពាល់ ៥នាក់មកពីអង្គការក្រៅរដ្ឋាភិបាល និង៤នាក់មកពីផ្នែកឯកជន ប៉ុន្តែមិនឃើញបញ្ជាក់ពីវត្តមានរបស់អ្នកភូមិក្នុងការពិគ្រោះយោបល់លើកទី២នេះទេ។ ដោយផ្អែកលើព័ត៌មានទាំងនេះ អាចសន្និដ្ឋានបានថា ដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ពិតជាបានផ្តល់ឱកាសដល់ប្រជាពលរដ្ឋមួយចំនួនបានចូលរួមក្នុងការពិភាក្សាពិគ្រោះយោបល់ពិតមែន ប៉ុន្តែការចូលរួមរបស់ប្រជាពលរដ្ឋនៅមានកម្រិតដោយសារមិនឃើញថា មានប្រជាពលរដ្ឋដែលរងផលប៉ះពាល់ទាំងអស់មកពីភូមិនីមួយៗបានមកចូលរួមឡើយនៅក្នុងការពិគ្រោះយោបល់ទាំង២លើក ជាពិសេសការពិគ្រោះយោបល់លើកទី២ មិនមានការចូលរួមពីប្រជាពលរដ្ឋទេ។ ដូច្នេះវាមិនទាន់គ្រប់គ្រាន់នៅឡើយ សម្រាប់ការពិគ្រោះយោបល់ជាសារធារណៈបែបនេះ ពីព្រោះការអះអាងបញ្ជាក់ក្នុងការសិក្សានេះក៏មិនបានរកឃើញថា មានប្រជាពលរដ្ឋបានចូលរួមក្នុងការពិភាក្សាពិគ្រោះយោបល់នេះដែរ។

### ១.៤.២. ការពិគ្រោះយោបល់រវាងប្រធានភូមិ/អនុប្រធានភូមិ ជាមួយក្រុមហ៊ុនអំពីគម្រោង

ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលតំរូវអោយមានការយកចិត្តទុកដាក់សំខាន់ទៅលើបញ្ហាផលប៉ះពាល់បរិស្ថានរបស់គម្រោង ទាំងបរិស្ថានរូបសាស្ត្របរិស្ថានជីវសាស្ត្រ និងបរិស្ថានសង្គម ដែលតំរូវអោយមានការសិក្សាវាយតម្លៃនិងរៀបចំផែនការដោះស្រាយអោយបានម៉ត់ចត់ និងសមស្របមានការពិគ្រោះយោបល់ជាមួយនឹងអ្នកពាក់ព័ន្ធ និងមានការសម្រេច ឯកភាពពីគ្រប់ស្ថាប័នជំនាញពាក់ព័ន្ធ ទើបអនុញ្ញាតិអនុវត្តគម្រោងអភិវឌ្ឍន៍។ ប៉ុន្តែភាពជាក់ស្តែង នៅតំបន់គោលដៅសិក្សា មានប្រធានភូមិ/អនុប្រធានភូមិចំនួន៨រូប ក្នុងចំណោម១៣រូប បានលើកឡើងថាពួកគេបានចូលរួមក្នុងកិច្ចប្រជុំពិភាក្សាពិគ្រោះយោបល់ជាមួយតំណាងក្រុមហ៊ុន ឬស្ថាប័ន

ពាក់ព័ន្ធអំពីគម្រោងសាងសង់ទំនប់វារីអគ្គិសនីសេសានក្រោម២។ ការពិគ្រោះយោបល់អំពីគម្រោងសាសង់នោះមានខ្លឹមសារថា *«នឹងមានគម្រោងសាងសង់ទំនប់វារីអគ្គិសនីសេសានក្រោម២ កើតឡើង ហើយនឹងមានការផ្តល់សំណងសមរម្យវិញ បើសិនជាមានផលប៉ះពាល់ តែមិនទាន់ច្បាស់ថាសំណងនោះបែបណានោះទេ»*។ បើទោះជាមានប្រធានភូមិ/អនុប្រធានភូមិលើសពីពាក់កណ្តាល បានចូលរួមក្នុងការពិភាក្សាពិគ្រោះយោបល់ក៏ពិតមែន ប៉ុន្តែនេះមិនអាចកំណត់ថា ជាការពិភាក្សាពិគ្រោះយោបល់ជាសាធារណៈនោះឡើយ ព្រោះមានតែប្រធានភូមិ/អនុប្រធានភូមិដែលបានចូលរួមចំណែក ឯប្រជាពលរដ្ឋដែលរងផលប៉ះពាល់មិនបានចូលរួមក្នុងការពិភាក្សានេះទេ។ ម្យ៉ាងទៀត ការពិគ្រោះយោបល់នេះក៏មិនទាន់បានផ្តល់ព័ត៌មានអោយបានជាក់លាក់អាចទុកចិត្តបាន ឬទុកឱកាសអោយប្រធានភូមិ/អនុប្រធានភូមិក្នុងការសម្រេចថា យល់ព្រម ឬមិនយល់ព្រមចំពោះគម្រោងនៅឡើយទេដោយគ្រាន់តែផ្តល់ជាដំណឹងអំពីគម្រោងប៉ុណ្ណោះ។

### ១.៤.៣.ការពិគ្រោះយោបល់រវាងប្រធានភូមិ/អនុប្រធានភូមិជាមួយប្រជាពលរដ្ឋក្នុងភូមិអំពីគម្រោង

ក្រៅពីមានការពិភាក្សាពិគ្រោះយោបល់រវាងប្រធានភូមិ/អនុប្រធានភូមិ និងអ្នកពិគ្រោះយោបល់ដូចជា តំណាងក្រុមហ៊ុន ឬអាជ្ញាធរពាក់ព័ន្ធ គឺមានការពិភាក្សាគ្នារវាងប្រធានភូមិជាមួយប្រជាពលរដ្ឋនៅក្នុងភូមិដែរ ដោយក្នុងនោះមានប្រធានភូមិ/អនុប្រធានភូមិចំនួន៧៧% បានរៀបចំការប្រជុំពិភាក្សានៅក្នុងភូមិជាមួយប្រជាពលរដ្ឋអំពីគម្រោងសាងសង់ទំនប់វារីអគ្គិសនីសេសានក្រោម២ ហើយការពិភាក្សានេះគឺជាពេលដែលអ្នកភូមិបានទទួលដំណឹងថាមានគម្រោងសាងសង់ ហើយជជែកគ្នាពីផលប៉ះពាល់បង្ហាញពីការព្រួយបារម្ភ និងរកដំណោះស្រាយជាសំណូមពរ និងពិភាក្សាគ្នាអំពីសំណងនៃផលប៉ះពាល់តែប្រធានភូមិចំនួន២៣%ទៀត មិនទាន់បានធ្វើការពិភាក្សានៅឡើយទេ។ អ្វីដែលហាក់មិនសូវមានភាពប្រក្រតីគឺមានប្រធានភូមិម្នាក់ ក្នុងចំណោមប្រធានភូមិទាំងអស់បានបង្ហើបថា មានករណីមួយបានកើតឡើង *«ការពិភាក្សាសួរប្រជាពលរដ្ឋថាយល់ព្រមអោយធ្វើទំនប់ ឬក៏អត់ (ប្រធានភូមិ*

*ពិភាក្សាជាមួយប្រជាពលរដ្ឋក្នុងភូមិបន្ទាប់ពីប្រជុំ និងបានដំណឹងពីក្រុមហ៊ុន)។ ប្រជាពលរដ្ឋបានផ្តិតមេដៃកុំអោយសាងសង់ទំនប់ (ប្រធានភូមិជាអ្នកប្រមូលមេដៃប្រជាពលរដ្ឋទៅអោយក្រុមហ៊ុនដើម្បីបញ្ជាក់ថាមិនយល់ព្រម) តែគេ(ក្រុមហ៊ុន) បែរជាថាប្រជាពលរដ្ឋបានផ្តិតមេដៃអោយធ្វើទំនប់ទៅវិញ* »។

# ២. ផលប៉ះពាល់នៃគម្រោង

## ២.១. ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីផលប៉ះពាល់នៃគម្រោង

ជាធម្មតា គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនីមួយៗជៀសមិនផុតពីការបង្កផលប៉ះពាល់ដល់ប្រជាពលរដ្ឋក្នុងតំបន់ និងបរិស្ថានធម្មជាតិតិច ឬច្រើនតាមលក្ខណៈ និងទំហំគម្រោង ប៉ុន្តែវាក៏បានផ្តល់មកវិញនូវផលប្រយោជន៍ច្រើនដល់ប្រជាពលរដ្ឋទូទៅសង្គមជាតិ និងសេដ្ឋកិច្ចសម្រាប់ប្រទេសទាំងមូលផងដែរ។ [60] ទន្ទឹមនឹងនេះប្រជាពលរដ្ឋ ក៏ដូចជាអាជ្ញាធរមូលដ្ឋានទាំងអស់សុទ្ធតែបានដឹងថាគម្រោងសាងសង់ទំនប់វារីអគ្គិសនីនេះ នឹងមានផលប៉ះពាល់ដល់ប្រជាពលរដ្ឋក្នុងភូមិ និងតំបន់ដែលពួកគេកំពុងរស់នៅ។ ប្រជាពលរដ្ឋទាំងឡាយយល់ថា បើមានការសាងសង់ទំនប់វារីអគ្គិសនីសេសានក្រោម២ វានឹងមានផលប៉ះពាល់ដល់មុខរបររកស៊ី ដីស្រែចំការដំណាំដាំដុះ សត្វចិញ្ចឹម ការនេសាទ ផ្ទះសំបែង ភូមិកំណើតដែលធ្លាប់ប្រកបរបរចិញ្ចឹមជីវិតប្រចាំថ្ងៃ និងបរិស្ថាន ដោយសារតែនឹងមានទឹកលិច *«វាប៉ះពាល់ដូចជាទឹកលិចផ្ទះសំបែង ដីស្រែចំការ បរិស្ថាន ព្រៃឈើ សត្វព្រៃត្រូវលិចទឹកងាប់អស់ ហើយខាងក្រោមទំនប់គ្មានទឹក ហើយត្រីក៏ឡើងមកមិនរួច ដូច្នេះវាធ្វើអោយខ្សត់ត្រី និងបាត់បង់ជំរកត្រី»* ។

## ២.២. ផលប៉ះពាល់ចំពោះហេដ្ឋារចនាសម្ព័ន្ធក្នុងភូមិ

យោងតាមសេចក្តីជូនដំណឹងរបស់រាជរដ្ឋាភិបាល លេខ ៣១ សជណ.កបច ឆ្នាំ២០១១ ដែលបានបង្ហាញតាមរយៈវិធានការបន្ធូរបន្ថយការប៉ះពាល់លើបរិស្ថាន

[60] រាជរដ្ឋាភិបាលកម្ពុជា លេខ: ៣១.សជណ.កបច ឆ្នាំ២០១១

និងសង្គមថា នឹងមានទឹកលិចធ្វើអោយមានផលប៉ះពាល់ដល់អង់តែនទូរគមនាគមន៍ចំនួន៣ សំណង់ធារាសាស្ត្រចំនួន១ អណ្តូងស្នប់ដៃចំនួន៣៨ និងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ដូចជាផ្លូវលំប្រវែង៧៩គីឡូម៉ែត្រ ផ្លូវជាតិប្រវែង៩.៤គីឡូម៉ែត្រ និងស្ពានចំនួន២៤៦ម៉ែត្រផងដែរ។ ដោយឡែកតាមការបញ្ជាក់ពីប្រជាពលរដ្ឋនៅតំបន់គោលដៅផ្ទាល់ ពួកគេមានការព្រួយបារម្ភថាការសាងសង់ទំនប់វារីអគ្គិសនីនឹងត្រូវប៉ះពាល់ដល់ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗនៅក្នុងភូមិ ដូចជាសាលារៀន វត្តអារាម ផ្លូវថ្នល់ មណ្ឌលសុខភាពស្ពាន ព្រៃអារក្ស/អ្នកតា/កន្លែងសែនព្រេន អណ្តូងទឹក ជង្រុកស្រូវសហគមន៍ និងសាលាឃុំជាដើម។ (សូមមើលតារាងទី២៩)

តារាងទី២៩- ផលប៉ះពាល់ចំពោះហេដ្ឋារចនាសម្ព័ន្ធក្នុងភូមិ

| ហេដ្ឋារចនាសម្ព័ន្ធ | ចំនួន | ភាគរយ |
|---|---|---|
| សាលារៀន | ២៨៧ | ៣៣.៧ |
| វត្តអារាម | ២៨៣ | ៣៣.២ |
| ផ្លូវ | ១៧១ | ២០.១ |
| មណ្ឌលសុខភាព | ៧២ | ៨.៥ |
| ស្ពាន | ១៥ | ១.៨ |
| អណ្តូង | ១០ | ១.២ |
| សាលាឃុំ | ៧ | ០.៨ |
| ព្រៃអារក្ស/អ្នកតា/សែនព្រេន | ៥ | ០.៦ |
| ជង្រុកស្រូវសហគមន៍ | ១ | ០.១ |
| មិនប៉ះពាល់ | ១ | ០.១ |
| **សរុប** | ៨៥២ | ១០០ |

*ចំនួនអ្នកតបសម្ភាសន៍សរុប៣១៥នាក់

## ២.៣. ផលប៉ះពាល់ចំពោះមុខរបរ និងការរកប្រាក់ចំណូល

ស្ទើតែ១០០% នៃប្រជាពលរដ្ឋដែលបានចូលរួមក្នុងការសិក្សាបាននិយាយថា ការសាងសង់ទំនប់វារីអគ្គិសនីសេសានក្រោម២ នឹងបង្កឲ្យមានផលប៉ះពាល់ដល់

មុខរបរនិងប្រាក់ចំណូលរបស់ប្រជាពលរដ្ឋ។ ផលប៉ះពាល់ចំពោះមុខរបរ និងការរកប្រាក់ចំណូលនោះរួមមាន ៧២% យល់ថាវានឹងធ្វើអោយទឹកលិចស្រែចំការ គ្មានកន្លែងដាំដុះ លិចដំណាំដាំដុះ៥៥% យល់ថាវានឹងធ្វើអោយខាតបង់ប្រាក់ចំណូល គ្មានកន្លែងប្រកបមុខរបរ ឬធ្វើអោយជីវភាពកាន់តែថយចុះ៥២% យល់ថាវានឹងធ្វើអោយទិន្នផលនៃការនេសាទធ្លាក់ចុះ ឬរកត្រីមិនបាន២០% យល់ថាវានឹងធ្វើអោយទឹកលិចព្រៃមិនអាចចូលព្រៃរកអនុផលព្រៃឈើ៩% យល់ថាវានឹងធ្វើអោយការចិញ្ចឹមសត្វពិបាក ឬមិនអាចចិញ្ចឹមសត្វ (ជ្រូក គោ ក្របី...) បានដោយសារនឹងមានទឹកលិច និងមានមួយចំនួនតូចប៉ុណ្ណោះ ១.២% និយាយថាគម្រោងនេះនឹងមិនមានផលប៉ះពាល់ដល់មុខរបររបស់ពួកគេទេ។ គួរបញ្ជាក់ថា មុខរបរធ្វើស្រែចំការ ដាំដំណាំ ចិញ្ចឹមសត្វ រកអនុផលព្រៃឈើ ជាពិសេសរបរនេសាទមិនត្រឹមតែដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្គត់ផ្គង់សេដ្ឋកិច្ចគ្រួសារនោះទេ ប៉ុន្តែវាថែមទាំងជាប្រភពអាហារប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋទៀតផង *«ខ្ញុំបារម្ភដីស្រែចំការ ដីភូមិ និងដំណាំរបស់ខ្ញុំជាច្រើន ព្រោះខ្លាចទឹកលិច នោះគ្រួសារខ្ញុំគ្មានអ្វីជាទីពឹងទេ»*។

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានបានបង្ហាញថាក្រៅពីការបាត់បង់ព្រៃឈើ និងដីកសិកម្ម គម្រោងនឹងបង្កជាឧបសគ្គមួយដែលកាត់បន្ថយទិន្នផលត្រីនៅក្នុងទន្លេទាំងពីរ។ ដូច្នេះ សេចក្ដីព្រួយបារម្ភរបស់ប្រជាពលរដ្ឋអំពីការបាត់បង់មុខរបរ ប្រាក់ចំណូល និងផលប្រយោជន៍ពីធនធានព្រៃឈើ និងទន្លេសម្រាប់ជីវភាពប្រចាំថ្ងៃ ក៏ជាអ្វីដែលបានលើកឡើងក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញដែរ។

## ២.៤. ផលប៉ះពាល់ចំពោះការអប់រំរបស់កុមារ

ការអប់រំនៅតែជាវិស័យឈានមុខក្នុងការអភិវឌ្ឍន៍ធនធានមនុស្ស និងនៅតែចាំបាច់សម្រាប់ប្រជាពលរដ្ឋគ្រប់រូប ពិសេសកុមារដែលនៅតំបន់ជនបទប្រទេសកម្ពុជា។ ប្រជាពលរដ្ឋប្រមាណ៩៩% និងអាជ្ញាធរភូមិប្រមាណ៩២% នៅតំបន់គោលដៅមានការព្រួយបារម្ភជាខ្លាំង ចំពោះផលប៉ះពាល់ទៅលើវិស័យអប់រំរបស់កុមារ

ពីព្រោះការសាងសង់ទំនប់វារីអគ្គិសនីសេសានក្រោម២ នឹងធ្វើអោយមានផលប៉ះពាល់ដល់ការទទួលបានការអប់រំរបស់កុមារក្នុងសហគមន៍ ព្រោះទឹកនឹងឡើងលិចដល់សាលារៀន និងភូមិស្រុកប្រជាពលរដ្ឋដែលធ្វើអោយកុមារមិនអាចទៅសាលារៀនបាន ហើយបើរង់ចាំការកសាងសាលារៀនថ្មី នៅកន្លែងតាំងទីលំនៅថ្មី នោះវាត្រូវការរយៈពេលយូរៗដូច្នេះ កុមារនឹងខកខានពេលវេលាក្នុងការរៀនសូត្រ លើសអាយុចូលរៀន និងបោះបង់ចោលការសិក្សា «*ប៉ះពាល់ក្មេងមិនបានចូលរៀនទេបើទឹកលិចសាលា ហើយពួកគេគ្មានចំណេះដឹងក្នុងខ្លួនទៅថ្ងៃអនាគត*» «*ទឹកលិចសាលាក្មេងលែងបានរៀន ហើយគ្រូក៏គ្មាន ដូច្នេះក្មេងត្រូវឈប់រៀន។ ទម្រាំតែសាងសង់សាលានៅកន្លែងថ្មីបាន ក្មេងលើសអាយុរៀនហើយ ដូច្នេះក្មេងត្រូវឈប់រៀន*»។

## ២.៥. ផលប៉ះពាល់ចំពោះសាសនា និងប្រពៃណី

សាសនា និងប្រពៃណីដែលប្រជាពលរដ្ឋនៅតំបន់គោលដៅប្រកាន់ខ្ជាប់នឹងមានការពិបាកនឹងខកខានព្រោះវាជាទំលាប់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ក៏ដូចជាទំលាប់ជាក្រុមក្នុងសហគមន៍។ ទន្ទឹមនឹងនេះ មានប្រជាពលរដ្ឋចំនួន៨០% យល់ថាការទៅនៅកន្លែងថ្មីនឹងធ្វើអោយមានផលប៉ះពាល់ដល់ពិធីសាសនានានាដែលពួកគេតែងតែប្រារព្ធ ប៉ុន្តែប្រជាពលរដ្ឋ២០%ផ្សេងទៀត មិនគិតដូច្នេះទេ។ ប្រការដែលប្រជាពលរដ្ឋភាគច្រើនយល់ថា នឹងមានផលប៉ះពាល់ចំពោះសាសនារបស់ពួកគេដោយសារតែកន្លែងគោរពបូជាសាសនា ដែលមាននៅកន្លែងចាស់ត្រូវបាត់បង់អស់ ហើយការផ្លាស់ទៅនៅទីតាំងថ្មីត្រូវកសាងអ្វីៗថ្មីទាំងអស់ រួមទាំងវត្តអារាមផងដែរ។ ដូច្នេះការសាងសង់វត្តថ្មីនឹងត្រូវចំណាយពេលយូរទៀត បើសិនជាទីអារាមនឹងត្រូវបានសាងសង់ឡើងវិញ តែប្រសិនបើមិនមានការសាងសង់វត្តអារាមជាថ្មីទេ ប្រជាពលរដ្ឋនឹងជួបការលំបាកដោយសារតែវត្តផ្សេងនៅឆ្ងាយពីភូមិពិបាកធ្វើដំណើរ និងមិនអាចជួបជុំគ្នាជាក្រុមសហគមន៍ធ្វើបុណ្យជាប្រចាំបាន។ ចំណែកការគោរពប្រពៃណីសែនព្រេនស្រូវដល់អារក្សអ្នកតា ជំនឿលើការគោរពខ្មោចអ្នកតា និងព្រៃអារក្សរបស់ប្រជាពលរដ្ឋក៏នឹងត្រូវបាត់បង់ ព្រោះប្រជាពលរដ្ឋទាំងឡាយមិនដឹងថា

ការតាំងទីលំនៅថ្មីអាចមានកន្លែងគោរពបូជាដូចកន្លែងចាស់ ឬអត់។ គួរបញ្ជាក់ថា ប្រជាពលរដ្ឋដែលជាជនជាតិដើមភាគតិច គឺជាក្រុមដែលមានទំនាក់ទំនងជិតស្និទ្ធ ជាមួយសាសនា និងវប្បធម៌របស់ខ្លួន ជាពិសេសការគោរពបូជា ឬសែនព្រេន ផ្សេងៗនៅតំបន់ព្រៃជាក់លាក់ ដូច្នេះវាអាចនឹងធ្វើអោយពួកគេជួបការលំបាក និង បាត់បង់ជំនឿផ្សេងៗខ្លះប្រសិនបើមានការតាំងទីលំនៅថ្មី *«ព្រោះនៅកន្លែងនេះ យើងមានវត្ត ព្រៃអារក្ស តែពេលយើងផ្លាស់ទីទៅនៅកន្លែងថ្មីពិតជាគ្មានវត្ត ហើយ ព្រៃអារក្សពិតជារកមិនបានខ្លាចអ្នកតាធ្វើអោយឈឺ» «ប៉ះពាល់ដល់អ្នកតាលិច ខ្មុម អ្នកតា ដីកប់ខ្មោច ខ្មោចដែលកប់ហើយមិនអាចរុះរើបានទេ»*។

ផ្ទុយទៅវិញប្រជាពលរដ្ឋដែលគិតថា នឹងមិនមានផលប៉ះពាល់ដល់សាសនា ប្រពៃណីផ្សេងៗរបស់ពួកគេដោយសារតែទោះជាពួកគេទៅរស់នៅកន្លែងណាក៏អាច គោរពសាសនាប្រពៃណីបានដែរ ដោយមិនមានអ្វីជាបញ្ហាចោទនោះទេ។

## ២.៦. ផលប៉ះពាល់ចំពោះព្រៃឈើ និងសត្វព្រៃ

ព្រៃឈើនិងសត្វព្រៃគឺជាប្រភពចំណូល ឬជាប្រភពអាហារមួយផ្នែកសម្រាប់ ជីវភាពប្រជាពលរដ្ឋនៅតំបន់គោលដៅនៃការសិក្សា ដោយសារតែជីវភាពពួកគេនៅ តែពឹងអាស្រ័យផលពីព្រៃឈើ និងសត្វព្រៃជាទំលាប់រហូតដល់សព្វថ្ងៃ ពិសេសគឺជន ជាតិដើមភាគតិច។ ការសាងសង់ទំនប់វារីអគ្គិសនីនឹងធ្វើអោយមានផលប៉ះពាល់ ដល់សត្វព្រៃ និងព្រៃឈើដោយសារតែទឹកនឹងជន់ឡើងលិចព្រៃឈើ ធ្វើអោយព្រៃ ឈើរលួយងាប់អស់លែងមានឈើប្រើប្រាស់ទៀត។ ម្យ៉ាងវិញទៀត ការបាត់បង់ ព្រៃឈើមានន័យថាបាត់បង់សត្វព្រៃ ព្រោះសត្វព្រៃមិនអាចរស់នៅបានដោយគ្មាន ព្រៃឈើឡើយ ដូច្នេះ វានឹងធ្វើអោយសត្វព្រៃបាត់បង់ជំរកត្រូវរត់ទៅរស់នៅកន្លែង ផ្សេងដែលផុតពីទឹកលិច ចំណែកសត្វខ្លះដែលមិនអាចរត់រួចនឹងត្រូវងាប់ *«បាត់បង់ ព្រៃឈើដោយសារគេឈូសឆាយយកដីធ្វើទំនប់ ព្រៃឈើនឹងត្រូវលិចអស់ បាត់បង់ ជំរកសត្វ សត្វខ្លះ អាចស្លាប់»*។

ផលប៉ះពាល់ទៅលើព្រៃឈើ និងជំរកសត្វព្រៃជាកត្តាគួរអោយកត់សម្គាល់ ដោយសារការបាត់បង់ព្រៃឈើ និង ជម្រកសត្វព្រៃរាប់ពាន់ហិចតាដោយសារ

គម្រោង។ ផ្អែកតាមការគិតគូរជាទឹកប្រាក់ពីការបាត់បង់ព្រៃឈើ គឺ២.៨លានដុល្លាអាមេរិកក្នុងមួយឆ្នាំ ជាតម្លៃនិរន្តរភាពតាមធម្មជាតិរបស់ព្រៃឈើ និង០.៩៩លានដុល្លាអាមេរិកក្នុងមួយឆ្នាំ ជាតម្លៃបានពីអនុផលព្រៃឈើក្នុងមួយឆ្នាំ។ តួលេខនេះមិនរាប់បញ្ចូលតំបន់ព្រៃឈើដែលនឹងត្រូវលិចលង់នៅក្នុងព្រៃសម្បទាន និងដីសម្បទានរបស់ក្រុមហ៊ុនដែលមានអជ្ញាប័ណ្ណរួចនោះទេ។[61]

## ២.៧. ផលប៉ះពាល់ចំពោះទន្លេ ត្រី ការនេសាទ និងឧបករណ៍នេសាទ

គម្រោងវារីអគ្គិសនីសេសានក្រោម២ គឺជាគម្រោងវារីអគ្គិសនីមួយដែលមានទំនប់ទប់ទឹកនៅខាងក្រោមចំណុចប្រសព្វរវាងទន្លេសេសាន និងទន្លេស្រែពកក្នុងស្រុកសេសាន ខេត្តស្ទឹងត្រែង។ គម្រោងទំនប់វារីអគ្គិសនីនេះ នឹងត្រូវប្រើប្រាស់ទឹកពីទន្លេទាំងពីរដើម្បីផលិតថាមពល ហើយវាក៏នឹងផ្តល់នូវផលប៉ះពាល់ចំពោះទន្លេ និងជីវចំរុះនៅក្នុងទន្លេផងដែរ។ ផលប៉ះពាល់មាន ដូចជាកម្ពស់ទឹកនឹងកើនឡើងខ្លាំងនៅក្នុងតំបន់អាងស្តុកទឹកលិចព្រៃឈើ និងកាកសំណល់ផ្សេងៗពីការសាងសង់ទំនប់ធ្វើអោយគុណភាពទឹកមានភាពកខ្វក់ល្អក់ មានជាតិគីមី និងជាតិពុល ដូច្នេះប្រជាពលរដ្ឋនឹងមិនអាចប្រើប្រាស់ទឹកទន្លេបាន *«ទឹកទន្លេមានការប្រែប្រួលទៅជាល្អក់អាចមានមេរោគច្រើនធ្វើអោយប្រើប្រាស់ទៅកើតជម្ងឺ ប្រជាពលរដ្ឋមិនអាចប្រើប្រាស់បានត្រឹមយចុះ»*។ ម្យ៉ាងវិញទៀត ទឹកនឹងឡើងខ្លាំងនាំអោយប្រជាពលរដ្ឋជួបការលំបាក ដោយមិនអាចកំណត់ទីតាំងសម្រាប់ការនេសាទបាន ហើយត្រីនឹងមិនអាចផ្លាស់ទី ឬហែលឡើងពីក្រោមទំនប់បានដែលជាហេតុធ្វើអោយត្រីលែងសំបូរ ឬត្រីគ្មានកន្លែងពងបានទៀត *«...បាត់បង់ជំរកត្រីពង ត្រីមួយចំនួនមិនអាចឡើងមកពងកូនបាន នាំអោយវាមានចំនួនថយចុះ»* ចំណែកសត្វខ្យង ខ្ចៅ គ្រំ រុក្ខជាតិតាមដងទន្លេ និងជីវៈចំរុះផ្សេងៗទៀតដែលមានក្នុងទន្លេនឹងត្រូវបាត់បង់ដែរ។ ពេលដែលត្រីមិនសូវសំបូរ វាអាចធ្វើអោយទិន្នផលនៃការនេសាទមានការធ្លាក់ចុះ ហើយឧបករណ៍នេសាទផ្សេងៗ ដូចជាមង សំណាញ់ជាដើមត្រូវខូចខាតដោយសារទឹក

---

[61] របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ គម្រោងវារីអគ្គិសនីសេសានក្រោម២ ក្នុងខេត្តស្ទឹងត្រែង ខែធ្នូ២០០៩ (PECC-1)

ហូរសោត់ទៅបាត់ ឬឧបករណ៍ខ្លះក៏អាចត្រូវទុកចោលដោយមិនអាចធ្វើការនេសាទទៀតបាន *«ឧបករណ៍នេសាទដូចជាមងសំណាញ់ ត្រូវខូចខាតដាក់មិនបានត្រូវរហែកព្រោះទឹកខ្លាំងពេកពុំមានកន្លែងនេសាទពិតប្រាកដ»* *«គិតថាការនេសាទមិនសូវបានទេ ព្រោះខ្យល់ត្រីដោយសារត្រីវាឡើងមិនរួចពីទំនប់។ ឧបករណ៍នេសាទត្រូវខាតបង់ខូចខាតអស់ ដូចជាមង អួន ត្រូវដាច់រហែកព្រោះទឹកធំពេក»*។

ទំនប់វារីអគ្គិសនីសេសានក្រោម២ នឹងបណ្ដាលអោយមានទឹកជំនន់ជន់លិចព្រៃឈើនានា ដែលបណ្ដាលអោយបាត់បង់ធនធានកាបូនដែលមិនអាចកើតឡើងវិញ និងទឹកមានការប្រែប្រួលដែលធ្វើអោយប៉ះពាល់ដល់របរនេសាទ។ [62] ប្រភេទត្រីបំលាស់ទីមួយចំនួនដូចជា ត្រីច្រកែង ត្រីប៉ាសេអ៊ី ត្រីឆ្កិន ត្រីប៉ាវ៉ា ត្រីប៉ាវ៉ាមុខពីរ និងត្រីផ្កាគរ មិនអាចធ្វើចរាចរទៅផ្នែកខាងលើទន្លេក្នុងកំឡុងខែឧសភា-មិថុនា និងចរាចរទៅខ្សែទឹកខាងក្រោមឆ្ពោះទៅទន្លេមេគង្គចន្លោះពីខែតុលា-ធ្នូ និងមានការបាត់បង់ធូន់ធូរនូវជីវចំរុះផ្សេងៗទៀតផង។[63] ផលប៉ះពាល់ជាអវិជ្ជមានចំពោះផលិតផលត្រីមិនត្រឹមតែចំពោះតំបន់គម្រោងនោះទេ ប៉ុន្តែវានឹងបណ្ដាលអោយមានផលប៉ះពាល់ដល់ផលិតផលត្រីនៅក្នុងប្រទេសកម្ពុជាទាំងមូលនិងប្រទេសជិតខាងផងដែរ។

ម្យ៉ាងទៀតរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ក៏មិនបានលើកឡើងច្រើនអំពីផលប៉ះពាល់ចំពោះមច្ឆានៅខ្សែទឹកខាងក្រោម និងមិនបានប៉ាន់ប្រមាណពីតម្លៃនៃផលប៉ះពាល់ចំពោះសហគមន៍ ដែលនៅខ្សែទឹកខាងក្រោមជាមួយនឹងខ្វង់ចំណាយចំពោះសំណងនៃសហគមន៍ទាំងនោះ ដែលជាអ្នកដែលនឹងត្រូវរងគ្រោះដោយការកាត់បន្ថយទិន្នផលត្រី។[64]

---

[62] http://www.internationalrivers.org/resources/stop-plans-to-construct-the-lower-sesan-2-hydropower-project-3681 (Searched website on Aug 14, 2012)

[63] ការអនុវត្តប្រសើរបំផុតក្នុងការផ្ដល់សំណង និងការតាំងទីលំនៅថ្មីសម្រាប់ទំនប់ខ្នាតធំ:ករណីសិក្សានៃផែនការគម្រោងទំនប់វារីអគ្គិសនីសេសានក្រោម២។ (Ian G. Baird, Ph.D, 2009)

[64] Understanding New Threats and Challenges from Hydro Power Development to Biodiversity and Community Rights in 3S River Basin. (Mark Grimsditch, April 2012)

### ២.៨. ផលប៉ះពាល់ចំពោះដីធ្លី និងដំណាំផ្សេងៗ

តាមរយៈរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញដែលបានទទួលស្គាល់ដោយក្រសួងបរិស្ថានបានបង្ហាញថា តាមរយៈកំពស់ទឹក៧៥ម អាងស្តុកទឹកនឹងត្រូវលិចលង់ទៅលើផ្ទៃដីប្រើប្រាស់សរុប៣០៥២៥ហិចតា ដែលក្នុងនោះរួមមានដីព្រៃឈើ២៨៩៦៩ហិចតា ផ្ទៃដីកសិកម្ម១២៩០ហិចតា និងព្រៃល្បោះនិងវាលស្មៅ២៦៦ហិចតា នៅក្នុងស្រុកសេសាន ខេត្តស្ទឹងត្រែង។ លើសពីនេះគម្រោងនឹងមានផលប៉ះពាល់ជាអវិជ្ជមានដល់ការអភិវឌ្ឍកសិកម្ម ពិសេសផលិតកម្មស្រូវ ហើយគម្រោងក៏ប៉ះពាល់ផងដែរទៅលើដំណាំមួយចំនួនដូចជា ពោត សណ្តែក ស្វាយចន្ទី និងឈើហូបផ្លែផ្សេងៗជាច្រើនមុខទៀត។[65]

តាមរយៈការសិក្សាជាក់ស្តែង ប្រជាពលរដ្ឋនៅជនបទស្ទើរតែទាំងអស់រស់នៅពឹងអាស្រ័យលើការធ្វើស្រែចំការ និងការដាំដំណាំឈើហូបផ្លែនៅក្នុងភូមិ តែបើមានការសាងសង់ទំនប់វារីអគ្គិសនីនឹងធ្វើអោយមានទឹកលិចភូមិ ធ្វើអោយខូចខាតផ្ទះសំបែង ដីដាំដំណាំ ស្រែចំការ បន្លែបង្កា ផលដំណាំដាំដុះសព្វគ្រប់ពិសេសដំណាំហូបផ្លែដូចជាស្វាយ ដូង ក្រូច ជាដើម ដែលមិនអាចប្រមូលផលបានទៀត ហើយក៏ជាដំណាំដែលត្រូវការរយៈពេលដាំដុះនិងថែរទាំយូរ «*...ដំណាំងាប់អស់ដោយសារទឹកលិច ហើយដីខ្ញុំក៏ត្រូវបាត់បង់អស់បើគេធ្វើទំនប់ពិតមែន ខ្ញុំបាត់ដើមដូង ស្រូវស្រែ ជាពិសេសដំណាំហូបផ្លែគ្រប់ប្រភេទ*»។

## ៣. ការតាំងទីលំនៅថ្មី

### ៣.១. ប្រភពព័ត៌មានអំពីការតាំងទីលំនៅថ្មី

តាមរយៈការសិក្សានេះ ការផ្តល់ព័ត៌មានអំពីការតាំងទីលំនៅថ្មីហាក់មិនទាន់មានភាពច្បាស់លាស់នៅឡើយ ដោយសារតែមានប្រជាពលរដ្ឋចំនួន៥៩% ប៉ុណ្ណោះដែលធ្លាប់បានឮថានឹងមានការតាំងទីលំនៅថ្មីសម្រាប់ភូមិ ដែលត្រូវទទួលរងផល

---

[65] របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ គម្រោងវារីអគ្គិសនីសេសានក្រោម២ ក្នុងខេត្តស្ទឹងត្រែង ខែធ្នូ២០០៩ (PECC-1)

ប៉ះពាល់។ ចំណែកឯឃុំស្រែអង្គ្រង ក្នុងស្រុកកូនមុំ ខេត្តរតនគិរី គឺប្រជាពលរដ្ឋទាំងអស់មិនបានឮពីការតាំងទីលំនៅថ្មីទេ។ (សូមមើលតារាងទី៣០)

ប្រធានភូមិ ឬអនុប្រធានភូមិចំនួន៦៩% បានដឹងព័ត៌មានអំពីការតាំងទីលំនៅថ្មី តែ៣១%មិនបានដឹងព័ត៌មានអំពីការតាំងទីលំនៅថ្មីទេ។ ពួកគាត់បានដឹងព័ត៌មានតាមរយៈដូចជា ៤១%ដឹងពីអាជ្ញាធរក្នុងស្រុកដូចជាមេឃុំ អភិបាលស្រុក/ខេត្ត ២៩% ដឹងពីតាមបណ្តាអង្គការនានា២៤% ដឹងពីតំណាងក្រុមហ៊ុនសាងសង់របស់វៀតណាម និង៦%បានដឹងពីពាក្យចរចាមអារាមតៗគ្នា។

តារាងទី៣០- ប្រភពព័ត៌មានអំពីការតាំងទីលំនៅថ្មី

| ប្រភពព័ត៌មាន | ចំនួន | ភាគរយ |
|---|---|---|
| អាជ្ញាធរមូលដ្ឋាន (ប្រធានភូមិ មេឃុំ អភិបាលស្រុក/ខេត្ត) | ១១៧ | ៤៥.២ |
| ពាក្យចរចាមអារាម (ឮតៗគ្នា) | ៦៥ | ២៥.១ |
| អ្នកតំណាងក្រុមហ៊ុនវៀតណាម | ៤៦ | ១៧.៨ |
| អង្គការមិនមែនរដ្ឋាភិបាល | ៣១ | ១២ |
| **សរុប** | **២៥៩** | **១០០** |

*ចំនួនអ្នកតបសម្ភាសន៍សរុប៣១៥នាក់

## ៣.២. ព័ត៌មានដែលទទួលបានអំពីការតាំងទីលំនៅថ្មី

ប្រជាពលរដ្ឋដែលបានដឹងថានឹងមានការរុះរើលំនៅទៅនៅទីតាំងថ្មី គ្រាន់តែជាការឮតៗគ្នាដោយមិនមានព័ត៌មានពិតប្រាកដបញ្ជាក់ថា ការតាំងទីលំនៅថ្មីជាផ្លូវការយ៉ាងណានោះនៅឡើយទេ។

ប្រជាពលរដ្ឋម្នាក់មកពីភូមិភ្លុកបញ្ជាក់ថា គាត់បានដឹងព័ត៌មាននៃការតាំងទីលំនៅថ្មី បន្ទាប់ពីបានចូលរួមសិក្ខាសាលាមួយនៅសណ្ឋាគារសេកុងស្តា ខេត្តស្ទឹងត្រែង(មិនចាំពេលវេលា) ហើយគាត់ត្រូវបានគេប្រាប់ថានឹងមានប្រជាពលរដ្ឋចំនួន ១៦គ្រួសារ ត្រូវជម្លៀសចេញទៅឃុំស្រែគរ ដែលមានចម្ងាយ៣០គីឡូម៉ែត្រពីភូមិដែលគេរស់នៅ ឬក៏ត្រូវជម្លៀសទៅភូមិក្បាលរមាស(៤០គមពីភូមិ)ពេលគេសាងសង់ទំនប់។ ប្រជាពលរដ្ឋម្នាក់ទៀតដែលមកពីស្រុកកូនមុំ ខេត្តរតនគិរី វិញនិយាយថា

*«សម្រាប់ស្រុកកូនមុំ មាន៣ឃុំមិនមានគម្រោងអោយចេញទេ បើមានទឹកលិចខូចខាតដោយសារទំនប់ក៏គេគ្មានគោលការណ៍សងដែរ។ មានតែឃុំស្រែគរក្បាលរមាស តាឡាត និង ស្រែតាមី (ខេត្តស្ទឹងត្រែង) ទើបគេឲ្យចេញ»*។

តាមរយៈការបញ្ជាក់ពីប្រជាពលរដ្ឋនៅភូមិខ្សាច់ថ្មីក្នុងការពិភាក្សាក្រុម បានអោយដឹងថា ទីតាំងបំរុងថ្មីគឺនៅទួលរន្ទះ ដែលមានចម្ងាយ៧គីឡូម៉ែត្រពីភូមិចាស់ ហើយពួកគេដឹងព័ត៌មាននេះពីប្រធានភូមិ មេឃុំ និងអង្គការសេប៉ា។

## ៣.៣. ការពិភាក្សាពិគ្រោះយោបល់អំពីការតាំងទីលំនៅថ្មី

តាមរយៈអជ្ញាធរភូមិគ្រប់ភូមិទាំងអស់ បានបញ្ជាក់ថាមិនទាន់មានតំណាងក្រុមហ៊ុន ឬស្ថាប័នណាមកធ្វើការពិភាក្សាពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋក្នុងភូមិរបស់ខ្លួនអំពីការតាំងទីលំនៅថ្មីនៅឡើយទេ។ ប៉ុន្តែក្នុងចំណោមប្រធានភូមិ ឬអនុប្រធានភូមិទាំង៦៩% ដែលបានដឹងព័ត៌មានទាក់ទងនឹងការតាំងទីលំនៅថ្មី ក្នុងនោះមានប្រធានភូមិ ឬអនុប្រធានភូមិចំនួន៣៥% បានប្រជុំពិភាក្សាជាមួយប្រជាពលរដ្ឋក្នុងភូមិអំពីការតាំងទីលំនៅថ្មី ប៉ុន្តែមិនទាន់ដឹងច្បាស់ពីទីតាំងពិតប្រាកដទេ *«គ្រាន់តែឮថាមានការតាំងទីលំនៅថ្មីដោយឆ្នាំ២០១១ រើប្រជាជនចេញពីភូមិស្រែពក ឆ្នាំ២០១២រើប្រជាជនចេញពីភូមិស្រែស្រណុក និងក្បាលរមាស និងឆ្នាំ២០១៣ រើប្រជាជនចេញពីភូមិក្របីជ្រុំ ប៉ុន្តែមិនទាន់ដឹងទៅកន្លែងណាអោយច្បាស់លាស់ទេ»*។ ព័ត៌មានអំពីការពិគ្រោះយោបល់សម្រាប់ការតាំងទីលំនៅថ្មី ត្រូវបានបញ្ជាក់បន្ថែមពីការពិភាក្សាក្រុមថា ប្រជាពលរដ្ឋពុំទាន់បានទទួលការពិភាក្សាពិគ្រោះយោបល់ណាមួយអំពីការតាំងទីលំនៅថ្មីនៅឡើយទេ លើកលែងតែនៅភូមិខ្សាច់ថ្មីដែលមានការពិភាក្សាពិគ្រោះយោបល់រវាងអជ្ញាធរភូមិ និងប្រជាពលរដ្ឋក្នុងភូមិ ដោយការពិភាក្សានេះនិយាយថា ការសាងសង់ទំនប់វានឹងត្រូវធ្វើអោយមានផលប៉ះពាល់ដល់ផ្ទះសំបែងប្រជាពលរដ្ឋ ដូច្នេះគេអោយប្រជាពលរដ្ឋរើទីលំនៅទៅនៅទួលរន្ទះ តែវាគ្រាន់តែជាគម្រោងមិនទាន់ពិតប្រាដកនៅឡើយទេ។

បើតាមព័ត៌មានពីប្រជាពលរដ្ឋគ្រួសារគោដៅវិញឃើញថា ក្នុងចំណោមប្រជាពលរដ្ឋជាងពាក់កណ្តាល(៥៩%) ដែលបានដឹង ឬឮថានឹងមានការប្តូរទីតាំងថ្មីមាន

ប្រជាពលរដ្ឋចំនួន៣៥%ប៉ុណ្ណោះ ដែលបាននិយាយថាមានការពិភាក្សាពិគ្រោះយោបល់អំពីការតាំងទីលំនៅថ្មី ចំណែក២៤%ទៀតបញ្ជាក់ថា មិនទាន់មានការពិភាក្សាពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋនៅក្នុងភូមិនៅឡើយទេ។

ក្នុងចំណោមប្រជាពលរដ្ឋ ដែលបានដឹងពីទីតាំងសម្រាប់ផ្លាស់ទីចំនួន២៧% បានអោយដឹងថាជាមធ្យមទីតាំងថ្មីមានចម្ងាយ១៣,២៧០ម៉ែត្រ ប្រហែល១៣គីឡូម៉ែត្រ ដោយក្នុងនោះចម្ងាយជិតបំផុតតិចជាង១គីឡូម៉ែត្រ និងចម្ងាយឆ្ងាយបំផុតលើសពី៣០គីឡូម៉ែត្រ។ ពួកគេបានបន្ថែមថា ពួកគេមិនពេញចិត្តចំពោះទីតាំងថ្មីនោះទេ ពីព្រោះពួកគេពេញចិត្តនឹងរស់នៅកន្លែងចាស់ដោយសារមានផ្ទះ និងដំណាំផ្សេងៗ ចំណែកពេលទៅនៅកន្លែងថ្មី គ្មានទឹកប្រើប្រាស់/មិនសំបូរទឹកប្រើប្រាស់/ប្រភពទឹកនៅឆ្ងាយ គ្មានដំណាំដាំដុះ ឈើហូបផ្លែ ឬស្រែចំការស្រាប់ ហើយដីមិនមានជីជាតិ ដាំដំណាំមិនបានល្អ និងមិនដឹងជាប្រកបមុខរបរអ្វី *«ព្រោះពេញចិត្តនឹងរស់នៅកន្លែងចាស់ ព្រោះមានផ្ទះ ដំណាំ និងដីស្រែស្រាប់»*។ ប្រធានភូមិ និងអនុប្រធានភូមិក៏បានយល់ស្របចំពោះចម្លើយរបស់ប្រជាពលរដ្ឋ ដែលមិនពេញចិត្តទីតាំងបំរុងថ្មីនេះដែរ។

## ៣.៤. ទស្សនៈចំពោះការតាំងទីលំនៅថ្មី

តាមរយៈការពិភាក្សាជាក្រុមនៅតាមភូមិចំនួន៥ ក្នុងចំណោមភូមិទាំងអស់ ក៏ដូចជាប្រជាពលរដ្ឋដែលត្រូវបានសម្ភាសន៍តាមផ្ទះគឺប្រជាពលរដ្ឋយល់ឃើញថា មិនចង់មានការតាំងទីលំនៅថ្មីនោះទេ ពីព្រោះគេគិតថាការទៅនៅកន្លែងថ្មីនឹងជួបការលំបាកដោយសារតែមិនទាន់ស៊ាំនឹងទឹកដីថ្មី និងគ្មានអ្វីទាំងអស់ ទំរាំដាំដំណាំហូបផ្លែ និងរៀបចំផ្ទះសំបែង ដីស្រែចំការបានវិញ គឺត្រូវការចំណាយពេលយូរ តែបើនៅកន្លែងចាស់គេមានផ្ទះ ដីស្រែ ដំណាំហូបផ្លែ និង ទ្រព្យសម្បត្តិផ្សេងៗ វាមានភាពងាយស្រួលក្នុងការរស់នៅ។ មួយវិញទៀត ប្រជាពលរដ្ឋមួយចំនួនក្នុងការពិភាក្សាក្រុមបានបង្ហាញថាពួកគេមិនប្រឆាំងនឹងការអភិវឌ្ឍន៍នោះទេ តែត្រូវផ្តល់សំណងនូវអ្វី ដែលពួកគេបាត់បង់អោយបានដូចដើម។ ហើយហេដ្ឋារចនាសម្ព័ន្ធនៅភូមិថ្មីក៏ត្រូវសាងសង់ឡើងវិញដែរ ទើបពួកគេព្រមចាកចេញ។ ប្រជាពលរដ្ឋប្រមាណជា២៨%

និយាយថា នឹងចាកចេញ ឬតាំងទីលំនៅថ្មីដោយសារតែនឹងមានទឹកលិចលង់ដល់ពួកគេ បើពួកគេមិនចេញក៏នៅមិនកើតដែរ ព្រោះគ្មានជំរើសផ្សេង «...*មិនប្រឆាំងទេ តែមិនចង់ផ្លាស់ទីលំនៅទៅប៉ុន្តែច្បាប់អស្សាមិករណ៍ (ច្បាប់ដកហូត)ចេញមកថារាល់ជនណាមិនព្រមប្រគល់ដីជូនរដ្ឋ រដ្ឋមានសិទ្ធិរឹបអូសនិងយកម្ចាស់ដាក់ពន្ធនាគារ ដូច្នេះយើងមិនអាចរារាំងបានទេ ធ្វើអោយស្របតាមការអភិវឌ្ឍរបស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាលយើង*»។ (សូមមើលតារាងទី៣១)

តាមការបញ្ជាក់ពីប្រធានភូមិ/អនុប្រធានភូមិទាំងអស់ ក៏មិនខុសពីប្រជាពលរដ្ឋដែរ គឺពួកគាត់បញ្ជាក់ថាប្រជាពលរដ្ឋភាគច្រើនមិនពេញចិត្តនឹងទីតាំងថ្មីទេ ដោយសំអាងលើហេតុផលកន្លែងថ្មីមិនទាន់មានអ្វីទាំងអស់ សម្រាប់ការកសាងជីវភាពខណៈដែលកន្លែងចាស់របស់គេគឺរស់នៅបានសុខហើយ។

តារាងទី៣១- ទស្សនៈចំពោះទីតាំងបំរុងថ្មី

| ការយល់ឃើញចំពោះទីតាំងបំរុងថ្មី | ចំនួន | ភាគរយ |
|---|---|---|
| មិនពេញចិត្តទៅរស់នៅទីតាំងថ្មីទេ ព្រោះធ្លាប់រស់នៅកន្លែងចាស់ងាយស្រួលមានផ្ទះ ដំណាំ មានមុខរបររកស៊ី | ២១៦ | ៦៩ |
| មិនចង់ទៅនៅកន្លែងថ្មីតែគ្មានជំរើស បើមិនទៅទឹកនឹងលិចស្លាប់ដូច្នេះត្រូវតែរើចេញ | ៨៩ | ២៨ |
| បើគេសាងសង់ទំនប់អោយរើចេញត្រូវតែផ្តល់សំណង | ៣ | ១ |
| មិនទាន់ដឹងគិតយ៉ាងណា | ៧ | ២ |
| សរុប | ៣១៥ | ១០០ |

## ៣.៥. ការសម្រេចចិត្តរបស់ប្រជាពលរដ្ឋប្រសិនបើរដ្ឋាភិបាលតំរូវអោយមានការតាំងទីលំនៅថ្មី

ប្រសិនជាមានការតំរូវពីរាជរដ្ឋាភិបាល អោយប្រជាពលរដ្ឋចាកចេញពីភូមិកំណើតទៅរស់នៅទីតាំងថ្មីគឺប្រជាពលរដ្ឋភាគច្រើនស្មើនឹង៨៥.៤% សម្រេចចិត្តថាយល់ព្រមតាមតំរូវការនេះ តែប្រជាពលរដ្ឋមួយចំនួនតូចប៉ុណ្ណោះស្មើនឹង១៤% មិន

អាចយល់ព្រមតាមតម្រូវការនោះទេ ខណៈពេលដែលអ្នកមិនទាន់អាចសម្រេចចិត្ត បានមានចំនួន០.៦%។ ជាការពិត ទោះបីជាប្រជាពលរដ្ឋភាគច្រើនសម្រេចចិត្តថា យល់ព្រមតាមតម្រូវការរបស់រាជរដ្ឋាភិបាល ប្រសិនជាមានការតម្រូវក៏ពិតមែន ប៉ុន្តែ មិនមែនជាការពេញចិត្តទេ គឺដើម្បីបំពេញកាតព្វកិច្ចជាប្រជាពលរដ្ឋព្រោះពួកគេ យល់ថា ខ្លួនឯងជាប្រជាពលរដ្ឋតូចតាចត្រូវស្តាប់តាមការដឹកនាំរបស់ថ្នាក់លើ មិន អាចតវ៉ា ប្រឆាំងនឹងគម្រោងអភិវឌ្ឍន៍បានទេ។ លើសពីនេះ ពួកគេគ្មានជំរើសផ្សេង ទៀតបើអ្នកភូមិទាំងអស់សុទ្ធតែព្រមចាកចេញហើយ ពួកគេត្រូវតែចាកចេញដែរ ព្រោះបើពួកគេមិនចាកចេញក៏គង់នឹងមានទឹកជំនន់លិច មិនអាចបន្តរស់នៅបាន។ ស្របទៅនឹងការយល់ព្រមតាំងទីលំនៅថ្មីនេះប្រជាពលរដ្ឋត្រូវការអោយមានការផ្តល់ សំណងសមរម្យជាមុនសិនទើបអាចចាកចេញ *«នឹងសម្រេចថាទៅ បើគេអោយទៅ ហើយយើងត្រូវតែទៅហើយ តែទៅទាំងបង្ខំ មិនចង់ទៅទាល់តែសោះ តែបើនៅត្រូវ ទឹកលិចស្លាប់ តើនៅយ៉ាងណា»*។ ដោយឡែក ចំពោះប្រជាពលរដ្ឋដែលនិយាយថា ពួកគេនឹងមិនចាកចេញពីភូមិកំណើតនោះទេ បើទោះជារដ្ឋាភិបាលតម្រូវក៏ដោយ ព្រោះតែភូមិកំណើតដែលរស់នៅបច្ចុប្បន្នងាយស្រួលរស់នៅ ពួកគេមិនចង់ចាក ចេញពីភូមិកំណើតដែលមានផ្ទះ ដំណាំ និងមុខរបរស្រេចនោះទេ ព្រោះការរើទៅ នៅកន្លែងថ្មីមិនទាន់មានអ្វីទាំងអស់មិនងាយស្រួលរស់នៅ *«...ព្រោះខ្ញុំមិនចង់ចាក ចេញពីផ្ទះរបស់ខ្ញុំ ខ្ញុំស្តាយផ្ទះសម្បែងរបស់ខ្ញុំ ទ្រព្យសម្បត្តិ ដីធ្លី ដំណាំហូបផ្លែ បើចង់ ទៅនៅកន្លែងថ្មីវាមានការពិបាកខ្លាំងណាស់» «ខ្ញុំដាច់ខាតមិនចេញពីផ្ទះរបស់ខ្ញុំទេ ទោះជាស្លាប់ក៏ដោយ»*។ (សូមមើលក្រាហ្វិកទី២០)

បើតាមព័ត៌មានដែលបានបញ្ជាក់ពីប្រធានភូមិ និងអនុប្រធានភូមិបានបង្ហាញ ថា ពួកគេចំនួន៦១.៥% ដែលគិតថាប្រជាពលរដ្ឋនឹងព្រមប្តូរទីលំនៅ បើសិនជារដ្ឋា ភិបាលតម្រូវ ព្រោះមិនអាចប្រឆាំងនឹងការអភិវឌ្ឍ តែបើមិនចាកចេញក៏គង់មានទឹក លិចនៅមិនបាន។ ផ្ទុយទៅវិញ ប្រធានភូមិចំនួន៣៨.៥%ទៀតគិតថា ប្រជាពលរដ្ឋ មិនព្រមផ្លាស់ប្តូរទីលំនៅទេ បើទោះជារាជរដ្ឋាភិបាលតម្រូវក៏ដោយ ព្រោះកន្លែងថ្មី មិនមានអ្វីទាំងអស់ ហើយសំណងមិនដឹងជាសមរម្យសម្រាប់ប្រជាពលរដ្ឋ ឬអត់។

ក្រាហ្វិកទី២០-ការសំរេចចិត្តរបស់ប្រជាពលរដ្ឋប្រសិនជាមានការតំរូវពីរដ្ឋាភិបាល អោយតាំងទីលំនៅថ្មី




## ៣.៦. ការរំពឹងទុកចំពោះជីវភាពពេលតាំងទីលំនៅថ្មី

ប្រជាពលរដ្ឋភាគច្រើនរហូតដល់៨៩% បានប៉ាន់ប្រមាណថា ជីវភាពរបស់ពួកគេនឹងអន់ជាងមុន ប្រសិនបើប្ដូរទៅរស់នៅកន្លែងថ្មី ពីព្រោះទីតាំងថ្មី គឺជាកន្លែងដែលមិនទាន់មានផ្ទះ ដំណាំផ្សេងៗ ទំរាំអាចកសាងកន្លែងនៅថ្មីបានដូចដើម ត្រូវការពេលវេលាយូរ ហើយកន្លែងថ្មីគឺជាកន្លែងដែលគ្មានមុខរបររកស៊ី ដើម្បីបានចំណូល មិនអាចរកត្រីបាន ពុំមានទឹកប្រើប្រាស់គ្រប់គ្រាន់/ប្រភពទឹកនៅឆ្ងាយ ដូច្នេះធ្វើអោយប៉ះពាល់ដល់ជីវភាព *«ជីវភាពកាន់តែថយចុះដោយសារបាត់បង់មុខរបរនៅកន្លែងចាស់ ពេលនៅកន្លែងចាស់ប្រជាពលរដ្ឋភាគច្រើនធ្វើស្រែចំការ និងនេសាទដើម្បីជីវភាព បើទៅនៅកន្លែងថ្មីមិនទាន់ដឹងប្រកបរបរអ្វីបាន មិនដឹងដីស្រែ កន្លែងនេសាទនៅណាអាចធ្វើបានដូចកន្លែងចាស់ឬអត់ ជាពិសេសត្រូវចំណាយពេលយូរដើម្បីរៀបចំកន្លែងថ្មីទៀត»*។ ម្យ៉ាងវិញទៀត មានប្រជាពលរដ្ឋមួយចំនួនតូច យល់ថាខ្លួនមានវ័យកាន់តែចាស់ហើយគ្មានកំលាំងទៅប្រកបរបររកស៊ី និងកាប់គាស់ដីចំការនៅកន្លែងថ្មីនោះទេ។ អ្នកផ្ដល់ចម្លើយមួយចំនួនតូចទៀតយល់ថា ការទៅនៅកន្លែងថ្មីនឹងធ្វើអោយមានជម្ងឺឈឺថ្កាត់កើតឡើង។ ដោយឡែកប្រជាពលរដ្ឋចំនួន៧% ឆ្លើយថាមិនដឹង ឬមិនអាចស្មានបានពីជីវភាព ពេលទៅនៅកន្លែងថ្មីដោយសារតែពួកគេមិនទាន់បានទៅឃើញកន្លែងថ្មី ដូច្នេះគេមិនហ៊ានស្មាន

ថាវានឹងយ៉ាងដូចម្ដេច។ ផ្ទុយពីចម្លើយខាងលើប្រជាពលរដ្ឋ៣% គិតថាជីវភាពនឹងមានភាពប្រសើរជាងមុន ដោយសារតែពេលទៅកន្លែងថ្មីគេនឹងនៅតែអាចដាំណាំបាន ហើយនិងមិនមានទឹកលិចទៀត។ ចំណែកឯប្រជាពលរដ្ឋចំនួន១%ប៉ុណ្ណោះដែលយល់ថាជីវភាពរបស់ខ្លួននឹងនៅតែដដែល ដោយសារតែគេនឹងនៅតែអាចប្រកបមុខរបរបានដដែលដូចពីមុន។ (សូមមើលក្រាហ្វិកទី២១)

ក្រាហ្វិកទី២១- ការរំពឹងទុកចំពោះជីវភាពពេលតាំងទីលំនៅថ្មី




## ៣.៧. តំរូវការសំខាន់ហើយចាំបាច់សម្រាប់ការតាំងទីលំនៅថ្មី

ប្រជាពលរដ្ឋប្រហែល៥០០០នាក់ ឬជាង១០០០គ្រួសារ នឹងត្រូវរងផលប៉ះពាល់ដោយផ្ទាល់ ដោយការលិចលង់នៃអាងស្តុកជាមួយនឹងកំពស់ទឹក៧៥ម៉ែត្រ។ បន្ថែមពីនេះ ប្រជាពលរដ្ឋនៅក្នុងតំបន់គម្រោងភាគច្រើនជាក្រុមជនជាតិផ្សេងៗ រួមមានពួង កាវែត ចារាយ គ្រឹង ព្រៅ និងខ្មែរឡាវ។ ដូច្នេះ ការផ្លាស់ប្តូរទីលំនៅសម្រាប់ប្រជាពលរដ្ឋទាំងនេះ ជាបញ្ហាចំបងដែលត្រូវពិចារណានូវការរៀបចំ និងការរចនាប្លង់គម្រោង។[66] ប្រជាពលរដ្ឋបង្ហាញពីតម្រូវការជាច្រើនសម្រាប់ការចាកចេញពីទីកន្លែងធ្លាប់រស់នៅ ដើម្បីទៅតាំងទីលំនៅថ្មីនៅកន្លែងមួយផ្សេងទៀត។ ការ

[66] របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ គម្រោងវារីអគ្គិសនីសេសានក្រោម២ ក្នុងខេត្តស្ទឹងត្រែង ខែធ្នូ២០០៩ (PECC-1)

ពិភាក្សាបង្ហាញថា ភាពចាំបាច់បំផុតក្នុងការផ្លាស់ទីទៅនៅតំបន់ផ្សេងមានបីធំៗគឺៈ ដីស្រែ និងដីចំការ ផ្ទះសម្បែង និងហេដ្ឋារចនាសម្ព័ន្ធ។ ប៉ុន្តែក៏នៅមានតំរូវការសំខាន់ៗផ្សេងទៀតដែរ ដូចជាប្រភពទឹក ដំណាំហូបផ្លែ គោក្របី និងរបស់របរផ្សេងៗទៀតដូចមានបង្ហាញក្នុងតារាងទី៣២ខាងក្រោម។ (សូមមើលតារាង៣២)

ប្រធានភូមិ និងអនុប្រធានភូមិសុទ្ធតែមានគំនិតមិនខុសគ្នាពីប្រជាពលរដ្ឋនៅក្នុងភូមិ «*ត្រូវអោយមានក្រុមជួយដឹកជញ្ជូន និងរុះរើផ្ទះ ផ្តល់សំណងអោយបានដូចអ្វីដែលប្រជាពលរដ្ឋមាន ឧ. ដី២ហិចតាត្រូវសងវិញ២ហិចតា ផ្ទះ៨ម៉ែត្រត្រូវសងវិញ៨ម៉ែត្រ។ ត្រូវមានសាលារៀន សាលាឆទាន ត្រូវរៀបចំកន្លែងខ្មមអ្នកតា និងព្រៃខ្មោចអោយវិញនៅទីតាំងថ្មីនោះ*»។

តារាងទី៣២- តំរូវការសំខាន់ហើយចាំបាច់សម្រាប់ការតាំងទីលំនៅថ្មី

| តំរូវការសំខាន់ | ចំនួន | ភាគរយ |
|---|---|---|
| ដីស្រែ និងដីចំការ | ២៦៣ | ២៧.៦ |
| ផ្ទះសំបែង | ២៦០ | ២៧.៣ |
| ហេដ្ឋារចនាសម្ព័ន្ធ | ១០៥ | ១១ |
| ប្រភពទឹក | ៩៨ | ១០.៣ |
| ដំណាំហូបផ្លែ | ៦៦ | ៦.៩ |
| គោ ក្របី | ៣៦ | ៣.៨ |
| ថវិកា | ៣៣ | ៣.៥ |
| អាហារបរិភោគ | ៣១ | ៣.២ |
| កន្លែងប្រកបរបរ | ២១ | ២.២ |
| អគ្គិសនី | ១២ | ១.៣ |
| កន្លែងនេសាទត្រី | ១០ | ១ |
| បង្គន់អនាម័យ | ១០ | ១ |
| កន្លែងចិញ្ចឹមសត្វ | ៩ | ០.៩ |
| **សរុប** | **៩៥៤** | **១០០** |

*ចំនួនអ្នកតបសម្ភាសន៍សរុប៣១៥នាក់

## ៣.៨. រយៈពេលដែលសមស្របក្នុងការត្រៀមខ្លួនតាំងទីលំនៅថ្មី

ពេលវេលាត្រៀមសម្រាប់ការចាកចេញ ឬរុះរើផ្ទះទៅនៅកន្លែងផ្សេងត្រូវបានពិភាក្សា។ ប្រជាពលរដ្ឋនៅតំបន់គោលដៅដែលនឹងត្រូវទទួលរងផលប៉ះពាល់ភាគច្រើនស្មើនឹង៣៩.៧% បានស្នើថាពេលវេលាដែលសមរម្យល្មមក្នុងការផ្លាស់ទីលំនៅបន្ទាប់ពីការជូនដំណឹងជាផ្លូវការគឺរយៈពេលតិចជាង១ឆ្នាំ ខណៈដែលប្រជាពលរដ្ឋ ២៨.៦%ទៀត ត្រូវការរយៈពេល១ឆ្នាំ។ (សូមមើលតារាងទី៣៣)

តារាងទី៣៣- រយៈពេលដែលសមរម្យក្នុងការរើចេញពីភូមិដើម្បីតាំងទីលំនៅថ្មី

| ល | រយៈពេល | ចំនួន | ភាគរយ |
|---|---|---|---|
| ១ | រយៈពេលតិចជាង១ឆ្នាំ | ១២៥ | ៣៩.៧ |
| ២ | រយៈពេល ១ឆ្នាំ | ៩០ | ២៨.៦ |
| ៣ | រយៈពេល ២ឆ្នាំ | ៣៩ | ១២.៤ |
| ៤ | រយៈពេល ៣ឆ្នាំ | ២០ | ៦.៣ |
| ៥ | រយៈពេល ៤ឆ្នាំ | ៥ | ១.៦ |
| ៦ | រយៈពេល ៥ឆ្នាំ | ៦ | ១.៩ |
| ៧ | ចេញពេលគេជូនដំណឹង/ចេញពេលអ្នកភូមិចេញ | ១០ | ៣.២ |
| ៨ | មិនរុះរើផ្ទះចេញជាដាច់ខាតសុខចិត្តស្លាប់នៅភូមិចាស់ | ៥ | ១.៦ |
| ៩ | ត្រូវការរយៈពេល ១០ឆ្នាំ | ៣ | ០.៩ |
| ១០ | មិនអាចស្មានបានទេ | ១២ | ៣.៨ |
| សរុប | | ៣១៥ | ១០០ |

ប្រជាពលរដ្ឋទាំងឡាយ រួមទាំងប្រធានភូមិ និងអនុប្រធានភូមិមួយចំនួនបានបង្ហាញពីទឹកចិត្តមិនមានការព្រួយបារម្ភខ្លាំងចំពោះពេលវេលា ដែលទុកអោយត្រៀមខ្លួនចាកចេញពីលំនៅដ្ឋានបច្ចុប្បន្នទេ ព្រោះពួកគេអាចរើចេញបានកាន់តែឆាប់ បើសិនជាការព្រមព្រៀងផ្តល់សំណង ក៏ដូចជាការព្រមព្រៀងរៀបចំទីលំនៅថ្មីត្រៀមបានរួចរាល់សម្រាប់ពួកគេនោះ។ តែផ្ទុយទៅវិញ ប្រសិនជាការព្រមព្រៀគ្នា

ក៏ដូចជាការរៀបចំផ្តល់សំណងទាំងឡាយ ជូនប្រជាពលរដ្ឋមិនទាន់បានរួចរាល់ នោះពួកគេនឹងត្រូវការពេលវេលាច្រើនក្នុងការត្រៀមខ្លួនជាមុន បន្ទាប់ពីមានសេចក្តីជូនដំណឹងជាផ្លូវការ *«ត្រូវការរយៈពេល១ឆ្នាំ ដើម្បីគិតគូររួមគ្នាក្នុងគ្រួសារមួយ ទាក់ទងនឹងដំណាំដាំដុះ ដីស្រែ ដីផ្ទះ និងទ្រព្យសម្បត្តិផ្សេងៗសម្រាប់ការទៅនៅកន្លែងថ្មី»*។

# ៤. ការផ្តល់សំណង

## ៤.១. ប្រភពព័ត៌មានអំពីការផ្តល់សំណង

មានតែប្រជាពលរដ្ឋប្រមាណជា៥០%ប៉ុណ្ណោះ ដែលបានដឹង ឬឮព័ត៌មានអំពីការផ្តល់សំណង បើទោះជាវាមិនមែនជាព័ត៌មានច្បាស់លាស់នៅឡើយក៏ដោយ។ ព័ត៌មានទាំងឡាយដែលពួកគេទទួលបាន ភាគច្រើនមានប្រភពចេញពីប្រធានភូមិ មេឃុំ តំណាងក្រុមហ៊ុនវៀតណាម និងពាក្យចាចាមអារាម។ (សូមមើលតារាងទី៣៤)

បើតាមការគូសបញ្ជាក់ពីប្រជាពលរដ្ឋក្នុងការពិភាក្សាក្រុមតាមភូមិ ប្រជាពលរដ្ឋបានដឹង ឬឮអំពីសំណងតាមរយៈការប្រជុំជាមួយអង្គការសិទ្ធិមនុស្ស អង្គការអុកស្វាម អង្គការសេប៉ា អង្គការឥតព្រំដែន អង្គការទន្លេបី និងប្រធានភូមិ ឬមេឃុំ។ ជាងនេះទៅទៀត ប្រធានភូមិ/អនុប្រធានភូមិចំនួន៦៩% បានដឹងឬឮព័ត៌អំពីការផ្តល់សំណង តែ៣១%ទៀត មិនបានដឹង ឬឮព័ត៌មានអំពីការផ្តល់សំណងដោយសារការសាងសង់ទំនប់នោះទេ។ ចំពោះប្រធានភូមិ និងអនុប្រធានភូមិដែលបានដឹង ឬឮព័ត៌អំពីការផ្តល់សំណងគឺពួកគេបានទទួលព័ត៌មានពីប្រភពដូចជា ២៩%ដឹងពីអាជ្ញាធរក្នុងស្រុក ៧%ដឹងពីបណ្តាអង្គការនានា ៥០%ដឹងពីតំណាងក្រុមហ៊ុនសាងសង់របស់វៀតណាម និង១៤% បានដឹងពីពាក្យចរចាមអារាមតៗគ្នា។

តារាងទី៣៤- ប្រភពព័ត៌មានអំពីការផ្តល់សំណង

| ប្រភពព័ត៌មាន | ចំនួន | ភាគរយ |
|---|---|---|
| អាជ្ញាធរមូលដ្ឋាន (ប្រធានភូមិ មេឃុំ អភិបាលស្រុក/ខេត្ត) | ៨៥ | **៣៨.៦** |
| តំណាងក្រុមហ៊ុនវៀតណាម | ៥៧ | **២៥.៩** |
| ពាក្យចរចាមអារាម(លឺតៗគ្នា) | ៥៥ | **២៥** |
| អង្គការមិនមែនរដ្ឋាភិបាល | ២១ | ៩.៥ |
| ប្រព័ន្ធផ្សព្វផ្សាយ (វិទ្យុ,ទូរទស្សន៍...) | ២ | ០.៩ |
| សរុប | **២២០** | **១០០** |

*ចំនួនអ្នកតបសម្ភាសន៍សរុប៣១៥នាក់

## ៤.២. ព័ត៌មានដែលទទួលបានអំពីការផ្តល់សំណង

ប្រជាពលរដ្ឋ ក៏ដូចជាប្រធានភូមិ និងអនុប្រធានភូមិដែលបានដឹង ឬឮព័ត៌មានអំពីការផ្តល់សំណង គឺពួកគេគ្រាន់តែបានឮថានឹងមានការផ្តល់សំណងចំពោះការខូចខាតរបស់ប្រជាពលរដ្ឋ នៅពេលសាងសង់ទំនប់វារីអគ្គិសនីសេសានក្រោម២ ប៉ុន្តែពួកគេមិនបានដឹងអំពីព័ត៌មានលំអិតជាក់លាក់ជាផ្លូវការនោះទេ។ អ្វីដែលជាព័ត៌មានពួកគេបានដឹង គឺ៣៨%ឮថាគេនឹងសងជាផ្ទះ និងដីភូមិ ២៨%ឮថាគេនឹងសងជាដីស្រែចំការ ១៤%ឮថាគេនឹងសងដំណាំដាំដុះដែលពួកគេមាន និង៨%ឮថាគេនឹងសងជាលុយចំពោះការខូចខាត តែមិនដឹងសងក្នុងតម្លៃណាពិតប្រាដកនៅឡើយទេ។ ក្រៅពីនេះ មានប្រជាពលរដ្ឋតិចតួចប៉ុណ្ណោះដែលឮថាការផ្តល់សំណងនោះគឺរួមមានហេដ្ឋារចនាសម្ព័ន្ធនិងមានអគ្គិសនីប្រើប្រាស់។ តាមការបញ្ជាក់បន្ថែមពីប្រធានភូមិបានអោយដឹងថា ភូមិក្របីជ្រុំ ក្នុងឃុំក្បាលរមាស និងភូមិភ្លុក ឃុំភ្លុក ស្រុកសេសាន ខេត្តស្ទឹងត្រែង មានក្រុមជនជាតិវៀតណាមដែលជាតំណាងក្រុមហ៊ុនចុះមកវាស់វែងដី និងផ្ទះប្រជាពលរដ្ឋរួចហើយ តែមិនទាន់ផ្តល់ព័ត៌មានអោយប្រជាពលរដ្ឋវិញអំពីសំណងជាក់លាក់បែបណានៅឡើយទេ «*ឮគេថាគេសងជាដីស្រែ ផ្ទះសំបែង និងដំណាំផ្សេងៗ ហើយគេចុះកត់ត្រាទុកដើម្បីសងប្រជាពលរដ្ឋអោយសមតាមអ្វីដែលខូចខាត*»។

## ៤.៣. ការប្រជុំពិភាក្សាពិគ្រោះយោបល់អំពីសំណង

មានប្រជាពលរដ្ឋត្រឹមតែ២២% និងប្រធានភូមិ/អនុប្រធានភូមិចំនួន២៣% ប៉ុណ្ណោះ ដែលបានលើកឡើងថាមានការប្រជុំពិភាក្សា និងពិគ្រោះយោបល់អំពីសំណងនៃផលប៉ះពាល់ចំពោះការខូចខាតទ្រព្យសម្បត្តិផ្សេងៗ ដោយសារគម្រោងសាងសង់ទំនប់វារីអគ្គិសនីដោយមានការចូលរួមរវាងប្រជាពលរដ្ឋ និងអ្នកផ្តល់សំណងដែលជាតំណាងក្រុមហ៊ុនវៀតណាម។ យោងតាមទិន្នន័យនេះ លទ្ធផលបង្ហាញថាមានចំនួនគ្រួសារតិចតួចណាស់ ដែលបានចូលរួមក្នុងការពិភាក្សាពិគ្រោះយោបល់អំពីសំណង ព្រោះក្នុងចំណោម១៨ភូមិ មានប្រជាពលរដ្ឋប្រមាណ២២% ប៉ុណ្ណោះ ដែលបានចូលរួមចំណែកភាគច្រើនរហូតដល់៧៨%មិនបានដឹងពីការពិភាក្សាពិគ្រោះយោបល់នេះទេ។ កាន់តែគួរអោយចាប់អារម្មណ៍នោះ ភូមិចំនួនបីដូចជាភូមិតាឡាត និងភូមិស្វាយរៀង ក្នុងឃុំតាឡាត ស្រុកសេសាន ខេត្តស្ទឹងត្រែង និងភូមិ៣ ក្នុងឃុំស្រែអង្គ្រង ស្រុកកូនមុំ ខេត្តរតនគិរី ដែលបានចូលរួមក្នុងការពិភាក្សាក្រុមក្នុងការសិក្សានេះបានបញ្ជាក់ថា មិនទាន់មានការពិភាក្សាពិគ្រោះយោបល់រវាងប្រជាពលរដ្ឋ និងអ្នកផ្តល់សំណងនៅឡើយទេសម្រាប់ភូមិរបស់ពួកគេ។

ប្រជាពលរដ្ឋទាំង២២% ដែលបានចូលរួមប្រជុំពិភាក្សា និងពិគ្រោះយោបល់អំពីសំណងបាននិយាយថាភាគីក្រុមហ៊ុនសាងសង់ទំនប់យល់ព្រមសងវិញនូវផ្ទះ ដីស្រែ និងដំណាំ កាលពីពេលប្រជុំនោះ តែមិនទាន់បានបញ្ជាក់ពីទំហំដី និងទីតាំងដែលត្រូវសងនោះឡើយ។ ក្នុងនោះដែរ ប្រជាពលរដ្ឋមួយចំនួនទៀតនិយាយថាក្រុមហ៊ុននឹងសងជាថវិកា សម្រាប់ការខូចខាតទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋ *«ក្រុមហ៊ុនគេថា សងដីស្រែ សងដីចំការដែលយើងមានហើយដំណាំដាំដុះផ្សេងគេសងជាប្រាក់(មិនទាន់បញ្ជាក់ពីតម្លៃ) ដីភូមិគេអោយមួយប្លង់(មិនទាន់បញ្ជាក់ពីទំហំ) ដីស្រែគេឈូសអោយវិញ»*។ ទោះបីជា អ្នកដែលបានចូលរួមក្នុងការពិភាក្សាពិគ្រោះយោបល់បានដឹងដំណឹងខ្លះពីការផ្តល់សំណង ប៉ុន្តែពួកគេបានអះអាងថាមិនទាន់មានភាពប្រាកដ និងច្បាស់លាស់នៅឡើយទេ *«គេបានប្រាប់ពីសំណង តែសំណងទាំងនោះមិនទាន់ច្បាស់ទេថាជាសំណងអ្វី គ្រាន់តែគេប្រាប់ថាមានសំណង»*។ អ្វី

ដែលគួរអោយកត់សម្គាល់ តាមរយៈភូមិនីមួយៗគឺមានប្រជាពលរដ្ឋភាគច្រើនដែលមិនបានដឹងថាមានការពិភាក្សាអំពីសំណងនោះទេ ប៉ុន្តែពួកគេគ្រាន់តែបានឮពាក្យចរចាមអារាមថា គេនឹងផ្តល់សំណងជាលុយទៅលើដើមឈើហូបផ្លែនិងវាស់វែងផ្ទះប្រជាពលរដ្ឋដើម្បីសងប៉ុណ្ណោះ។ ស្របគ្នានេះដែរ បើទោះជានៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញរបស់គម្រោងទំនប់វារីអគ្គិសនីសេសានក្រោម២ បានបញ្ជាក់ថាមានការពិគ្រោះយោបល់ចំនួនពីរលើកនៅក្នុងឆ្នាំ២០០៨ក៏ដោយ ប៉ុន្តែរបាយការណ៍នេះមិនបានបញ្ជាក់ថាបានរៀបចំការពិភាក្សាពិគ្រោះយោបល់អំពីសំណងជាមួយប្រជាពលរដ្ឋដែលត្រូវរងផលប៉ះពាល់នោះទេ។

ដោយសារប្រជាពលរដ្ឋភាគច្រើនមិនបានដឹង ឬចូលរួមក្នុងការពិភាក្សាពិគ្រោះយោបល់អំពីសំណង ហើយរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានក៏មិនបានបញ្ជាក់ថា មានការពិភាក្សាពិគ្រោះយោបល់អំពីសំណងនៃផលប៉ះពាល់ ហេតុនេះបញ្ហាសំណងនៅតែជាក្តីបារម្ភសម្រាប់ប្រជាពលរដ្ឋទាំងឡាយ ដែលនឹងត្រូវទទួលរងផលប៉ះពាល់ដោយសារគម្រោង ព្រោះពួកគាត់មិនបានបញ្ចេញយោបល់ថាសំណងបែបណាដែលពួកគាត់អាចទទួលយកបាន ហើយក៏មិនបានទទួលដំណឹងថាសំណងបែបណាដែលក្រុមហ៊ុននឹងផ្តល់អោយប្រជាពលរដ្ឋជាផ្លូវការ។

## ៤.៤. សំណងដែលសមរម្យហើយអាចទទួលយកបាន

### ៤.៤.១. ការវិភាគទាក់ទងគោលការណ៍សំណង

យោងតាមគោលនយោបាយដោះស្រាយតាំងទីលំនៅថ្មី ដើម្បីស្តារឡើងវិញនូវសេដ្ឋកិច្ច និងសង្គមរបស់ប្រជាពលរដ្ឋដែលបាត់បង់ជីវភាពរបស់ធនាគារអភិវឌ្ឍន៍អាស៊ី មាន៣ចំណុចដែលទាមទារអោយមានគឺ៖

ទី១-ការផ្តល់សំណងចំពោះការបាត់បង់ទ្រព្យសម្បត្តិ និងប្រាក់ចំណូល

ទី២-ការជួយផ្ទេរ និងការជួយតាំងទីលំនៅថ្មី

ទី៣-ការធ្វើអោយប្រសើរឡើងវិញ និងការស្តារឡើងវិញនូវជីវភាព។[67] គោលនយោបាយរបស់ធនាគារនេះ ក្នុងការផ្តល់សំណងត្រូវស្មើនឹងស្ថានភាពនៅពេលដែលពុំទាន់មានគម្រោង មានន័យថាត្រូវតែមានអត្រាជំនួសការខាតបង់។ ប្រជាពលរដ្ឋទទួលរងផលប៉ះពាល់យ៉ាងហោចណាស់គួរតែមានស្ថានភាពល្អប្រសើរដូចពេលដែលពួកគេនៅពីមុនបន្ទាប់ពីធ្វើការតាំងទីលំនៅថ្មី។ ការចំណាយលើការជំនួសឲ្យត្រូវស្មើនឹងការចំណាយទីផ្សារបូកនិងការចំណាយប្រតិបត្តិការនៅពេលណា ដែលទីផ្សារឆ្លុះបញ្ចាំងព័ត៌មានថ្លៃដែលគួរអោយជឿទុកចិត្តបាន និងមានជម្រើសក្នុងការជ្រើសរើសសំណងសម្រាប់ការខាតបង់ទ្រព្យសម្បត្តិ។[68] គម្រោងសាងសង់ទំនប់វារីអគ្គិសនីសេសានក្រោម២នេះ ក៏មានការពាក់ពន្ធ័នឹងច្បាប់អស្សាមិករណ៍ដែរ បើយោងតាមច្បាប់ស្តីពីអស្សាមិករណ៍ជំពូកទី១ មាត្រា៥ គម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈក៏រួមមានការសាងសង់ ឬពង្រីកស្ថានីយថាមពល រចនាសម្ព័ន្ធ ឧបករណ៍ និងខ្សែសម្រាប់ការបញ្ជូន និងចែកចាយថាមពលអគ្គិសនីដែរ។[69] ក្នុងច្បាប់នេះបានបញ្ជាក់ថាប្រាក់សំណងដែលត្រូវផ្តល់ទៅអោយម្ចាស់អចលនវត្ថុ និង/ឬម្ចាស់សិទ្ធិ ត្រូវគិតតាមថ្លៃទីផ្សារ ឬថ្លៃជំនួសនៅកាលបរិច្ឆេទនៃការចេញសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍ ហើយថ្លៃទីផ្សារ ឬថ្លៃជំនួសត្រូវកំណត់ដោយគណៈកម្មការ ឬភ្នាក់ងារឯករាជ្យមួយតាមការជ្រើសរើសរបស់គណៈកម្មាធិការអស្សាមិករណ៍។[70] លើសពីនេះ

[67] According to ADB's resettlement policy to restore the economic and social base of people who lose their livelihood, three things are required: 1) compensation for lost of assets and income; 2) transfer and relocation assistance; 3) rehabilitation and restoration of lives. (ADB resettlement summary: a guide to good practice)

[68] ១៩៩៨, ធនាគារអភិវឌ្ឍន៍អាស៊ី «សេចក្តីសង្ខេបនៃសៀវភៅណែនាំស្តីពីការតាំងទីលំនៅសារជាថ្មី» ឬ http://www.adb.org/sites/default/files/Resettlement_Handbook_Summary_KH.pdf (Searched website on Aug 16, 2012)

[69] ច្បាប់អស្សាមិករណ៍ ឆ្នាំ២០០៩ (ជំពូកទី១ មាត្រា៥)

[70] ច្បាប់អស្សាមិករណ៍ ឆ្នាំ២០០៩ (ជំពូកទី៤ មាត្រា២២)

ម្ចាស់អចលនវត្ថុ និង/ឬម្ចាស់សិទ្ធិមានសិទ្ធិទទួលនូវសំណងលើការខូចខាតអចលនវត្ថុជាក់ស្តែង ដែលមានចាប់ពីថ្ងៃចេញសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍ ដែលជាកាលបរិច្ឆេទចុងក្រោយសម្រាប់មានសិទ្ធិទទួលបាននូវសំណងសមរម្យ និងយុត្តិធម៌។[71]

ទោះជាយ៉ាងណា ក្នុងក្របខណ្ឌច្បាប់នៅកម្ពុជា មិនទាន់មានចែងអំពីគោលការណ៍ផ្តល់សំណង ឬនីតិវិធីលំអិតអំពីការផ្តល់សំណងសមរម្យ និងយុត្តិធម៌ឡើយ។ តាមរយៈការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញនៅចុងឆ្នាំ២០០៩ ដែលទទួលស្គាល់ដោយក្រសួងបរិស្ថាន ក៏មិនមានបង្ហាញពីគោលនយោបាយ និងផែនការក្នុងការដោះស្រាយសំណងលម្អិតរបស់ខ្លួន ចំពោះគម្រោងទំនប់វារីអគ្គិសនីសេសានក្រោម២នេះដែរ។ ដូច្នេះ ចំនុចទាំងនេះអាចនឹងនាំអោយជួបផលលំបាកក្នុងការទទួលបានសំណងដែលសមរម្យ និងយុត្តិធម៌សម្រាប់សហគមន៍ ដែលនឹងត្រូវទទួលរងផលប៉ះពាល់ដោយសារគម្រោងទំនប់នេះ។

### ៤.៤.២. សំណងដែលប្រជាពលរដ្ឋយល់ថាសមរម្យហើយអាចទទួលយកបាន

យ៉ាងណាមិញ ចំពោះយោបល់ប្រជាពលរដ្ឋទាក់ទងនឹងសំណងសម្រាប់ការខូចខាតដោយសារគម្រោងសាងសង់ទំនប់វារីអគ្គិសនីនេះ គឺពួកគេមានការពិបាកក្នុងការឆ្លើយនូវអ្វីដែលជាភាពសមរម្យសម្រាប់ប្រជាពលរដ្ឋ និងអ្នកផ្តល់សំណងអាចធ្វើទៅបាន។ ក្នុងនោះដែរ មានប្រជាពលរដ្ឋចំនួន៧៥% យល់ថាសំណងដែលសមរម្យហើយអាចទទួលយកបានចាំបាច់ត្រូវតែផ្តល់ជូនពួកគេវិញនូវផ្ទះ ដីភូមិ ដីស្រែចំការ (ទំហំដូចនៅកន្លែងចាស់) ដែលមានជីជាតិ ដំណាំដាំដុះផ្សេងៗរួមបញ្ចូលទាំងដំណាំហូបផ្លែ និងកន្លែងប្រកបរបរអោយមានដូចកាលរស់នៅភូមិចាស់វិញព្រោះវាជាតំរូវការចាំបាច់សម្រាប់ជីវភាពប្រចាំថ្ងៃ។ ក្រៅពីនេះ មានប្រជាពលរដ្ឋ

[71] ច្បាប់អស្សាមិករណ៍ ឆ្នាំ២០០៩ (ជំពូកទី៤ មាត្រា២៣)

ចំនួន២០% យល់ថាសំណងចំពោះការខូចខាតទ្រព្យសម្បត្តិទាំងអស់ដែលប្រជាពលរដ្ឋមានត្រូវធ្វើឡើងតាមតម្លៃទីផ្សារជាក់ស្តែងបច្ចុប្បន្នអោយបានសមរម្យ។ ម្យ៉ាងវិញទៀត មានប្រជាពលរដ្ឋចំនួន១២% យល់ថាសំណងដែលសមរម្យហើយអាចទទួលយកបាន គឺត្រូវសងជាសាច់ប្រាក់សម្រាប់ផ្គត់ផ្គង់ជីវភាពពេលចេញទៅនៅកន្លែងថ្មីជាមធ្យមចំនួន១២៧២៩.១៩ដុល្លាអាមេរិក សម្រាប់មួយគ្រួសារ។ ទោះជាតម្រូវការផ្ទះសំបែង ដីភូមិ ដីស្រែ និងដីចំការជាកត្តាចាំបាច់ក្នុងជីវភាព ប៉ុន្តែបើគ្មានហេដ្ឋារចនាសម្ព័ន្ធនោះទេ ការរស់នៅរបស់ប្រជាពលរដ្ឋក៏មិនអាចមានការរីកចំរើនបានដែរ។ ដោយសារហេតុផលនេះ ប្រជាពលរដ្ឋចំនួន១០% យល់ថាការផ្តល់សំណងសម្រាប់ការទៅរស់នៅកន្លែងថ្មីត្រូវតែរួមបញ្ចូលទាំងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗដូចជាសាលារៀន មន្ទីរពេទ្យ វត្តអារាម ប្រភពទឹកប្រើប្រាស់ ផ្លូវថ្នល់។ល។ ទើបប្រជាពលរដ្ឋអាចទៅរស់នៅកន្លែងថ្មីបាន។ ទាក់ទងនឹងការផ្តល់សំណងនេះដែរ មានប្រជាពលរដ្ឋចំនួនប្រហែលជា៣%ប៉ុណ្ណោះ ត្រូវការសំណងជាសាច់ប្រាក់អោយបានសមរម្យចំពោះដំណាំឈើហូបផ្លែ ដែលគេបានខិតខំចំណាយពេលដាំជាយូរទំរាំបានផល និងក្រៅពីនេះក៏នៅមានការលើកឡើងផ្សេងៗគ្នាទៀតទាក់ទងនឹងសំណងសមរម្យពីសំណាក់ប្រជាពលរដ្ឋមួយចំនួនតូច ដូចជាត្រូវការការពិភាក្សាគ្នាជាមុនត្រូវការអោយមានភ្លើងអគ្គិសនីប្រើប្រាស់ជាដើម។

# ជំពូកទី៤-សេចក្តីសន្និដ្ឋាន សំណូមពរ និង អនុសាសន៍

## ១. សេចក្តសន្និដ្ឋាន

ការសិក្សាស្រាវជ្រាវអំពី «ទំនប់វារីអគ្គិសនីសេសានក្រោម២ : ស្ថានភាពជីវភាពបច្ចុប្បន្នរបស់ប្រជាពលរដ្ឋមូលដ្ឋាន» បានបង្ហាញពីស្ថានភាពជីវភាពរស់នៅនាពេលបច្ចុប្បន្នរបស់ប្រជាពលរដ្ឋមុនពេលសាងសង់ទំនប់ ដើម្បីជាមូលដ្ឋានសម្រាប់ធ្វើការប្រៀបធៀបស្ថានភាពជីវភាពរបស់ប្រជាពលរដ្ឋ បន្ទាប់ពីពួកគេផ្លាស់ទីលំនៅទៅរស់នៅតំបន់ថ្មី។ ការអង្កេតនេះ ក៏បានរកឃើញពីការយល់ដឹង និងទស្សនៈផ្សេងៗរបស់ប្រជាពលរដ្ឋ ជុំវិញគម្រោងសាងសង់ទំនប់វារីអគ្គិសនីដូចជា ផលប៉ះពាល់ សំណង និងការតាំងទីលំនៅថ្មី ដើម្បីជាព័ត៌មានបង្ហាញទឹកចិត្តប្រជាពលរដ្ឋ ចំពោះគម្រោងសាងសង់ទំនប់វារីអគ្គិសនីនៅតំបន់សេសានក្រោមនេះ។

បច្ចុប្បន្ន ការរស់នៅរបស់ប្រជាពលរដ្ឋនៅតំបន់សិក្សាមានស្ថានភាពធម្មតា ទាំងការប្រកបរបរចិញ្ចឹមជីវិត និងសកម្មភាពប្រចាំថ្ងៃដោយមិនមានការអាក់ខានអ្វីឡើយ លើកលែងតែគម្រោងសាងសង់ផ្សេងៗដូចជា ការសាងសង់ផ្ទះថ្មី ឬពង្រីកជួសជុលផ្ទះជាដើម គឺត្រូវផ្អាករង់ចាំសេចក្តីជូនដំណឹងពិតប្រាកដជាផ្លូវការអំពីគម្រោង។ បើនិយាយពីស្ថានភាពជីវភាពរបស់ប្រជាពលរដ្ឋ យោងតាមការសិក្សានេះ អាចសន្និដ្ឋានបានថា ជាទូទៅ គឺមធ្យមអាចរស់នៅទប់ទល់នឹងជីវភាពបានដោយសារប្រជាពលរដ្ឋភាគច្រើនលើសលប់ស្មើនឹង៩៦.៨% មានជីវភាពមិនស្ថិតក្នុងស្ថានភាពក្រីក្រដែលការសិក្សាបានវាយម្លៃ។ ទោះជាមានប្រជាពលរដ្ឋត្រឹមតែ៣.២% ស្ថិតក្នុងស្ថានភាពក្រីក្រ ប៉ុន្តែពួកគេអាចអាស្រ័យផលពីអនុផលព្រៃឈើនិងទន្លេដែលមានស្រាប់តំបន់របស់ពួកគេបាន ដោយមិនជួបការលំបាកដល់ថ្នាក់ខ្វះម្ហូបអាហារនោះទេ ពីព្រោះតំបន់ដែលពួកគេរស់នៅជាតំបន់ដែលមានអំណោយផលល្អពីធម្មជាតិសម្រាប់ការរស់នៅរបស់ពួកគេ។ ចំពោះការរស់នៅចម្រុះគ្នាជាមួយជនជាតិភាគតិចផ្សេងៗ និងការប្រកាន់ខ្ជាប់ជំនឿសាសនាប្រពៃណី និងទំនៀមទំលាប់ផ្សេងរបស់ប្រជាពលរដ្ឋ អាចនឹងជួបការលំបាកក្នុងការបន្សាំខ្លួនទៅនឹងការរស់នៅ

នៅតំបន់ថ្មី ប្រសិនបើការតាំងទីលំនៅថ្មីពិតជាកើតមាន ជាពិសេសប្រជាពលរដ្ឋជនជាតិដើមភាគតិច ដោយសារការរស់នៅរបស់ពួកគេអាស្រ័យស្ទើរតែទាំងស្រុងទៅលើធនធានធម្មជាតិដូចជា ព្រៃឈើ សត្វព្រៃ និងទន្លេជាដើម។

ទោះបីជា ប្រជាពលរដ្ឋភាគច្រើននៅតំបន់សិក្សាទទួលបានការអប់រំទាបនៅឡើយ បើប្រៀបធៀបនឹងប្រជាពលរដ្ឋនៅតំបន់ទីប្រជុំជន ឬទីក្រុងក៏ពិតមែន ប៉ុន្តែពួកគេមានការយល់ដឹងអំពីការអភិវឌ្ឍន៍ និងកាតព្វកិច្ចជាប្រជាពលរដ្ឋ។ ក្នុងនោះ ប្រជាពលរដ្ឋស្ទើរតែទាំងអស់បានបង្ហាញពីទឹកចិត្តស្រលាញ់ភូមិកំណើត មិនចង់ចាកចេញពីភូមិកំណើត និងមិនចង់អោយមានគម្រោងសាងសង់ទំនប់វារីអគ្គិសនីសេសានក្រោម២ កើតឡើងនោះទេ ដោយសារវានឹងបង្កអោយមានផលប៉ះពាល់យ៉ាងធំធេងដល់ធនធានធម្មជាតិ និងបរិស្ថាននានា ពិសេសប៉ះពាល់ដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋជាច្រើនគ្រួសារ ប៉ុន្តែពួកគេដឹងថាតម្រូវការអភិវឌ្ឍជារឿងសំខាន់ដែលក្នុងនាមជាប្រជាពលរដ្ឋកម្ពុជា ត្រូវតែចូលរួមចំណែកទាំងអស់គ្នា។ យោងតាមឆន្ទៈក្នុងការចូលរួមក្នុងការអភិវឌ្ឍនេះឃើញថា ទោះជាប្រជាពលរដ្ឋភាគច្រើនអាចសម្របតាមតម្រូវការរបស់រដ្ឋាភិបាល ប្រសិនជាមានការចាំបាច់ក្នុងការតាំងទីលំនៅថ្មីក៏ពិតមែន ប៉ុន្តែប្រជាពលរដ្ឋក៏ត្រូវការអោយរាជរដ្ឋាភិបាល ឬម្ចាស់ក្រុមហ៊ុនវិនិយោគគម្រោងផ្តល់អោយពួកគេវិញនូវលក្ខខណ្ឌសមរម្យដូចជា ការផ្តល់សំណង ឬតម្លៃជំនួសដែលបានគិតគូរយ៉ាងម៉ត់ចត់ពីផលប៉ះពាល់ និងមានភាពទទួលខុសត្រូវចំពោះជីវភាពពួកគេ ទើបការចូលរួមក្នុងការអភិវឌ្ឍរបស់ពួកគេអាចធ្វើទៅបាន។ ក្នុងលក្ខខណ្ឌនេះ អាចបញ្ជាក់បានថាជាជម្រើសទីមួយ គឺប្រជាពលរដ្ឋមិនត្រូវការអោយមានគម្រោងអភិវឌ្ឍន៍ ទំនប់វារីអគ្គិសនីសេសានក្រោម២ នោះទេ ប៉ុន្តែ ប្រសិនជាជម្រើសទីមួយនេះ មិនអាចធ្វើទៅបាន ប្រជាពលរដ្ឋក៏មិនប្រឆាំងនឹងគម្រោងដែរ ដោយពួកគេគ្រាន់តែត្រូវការអោយផ្តល់សំណង ឬតម្លៃជំនួសវិញសមរម្យ យុត្តិធម៌ និងអាចទទួលយកបានតែប៉ុណ្ណោះ។

ការពិភាក្សាពិគ្រោះយោបល់ពេញលេញចំពោះគម្រោងទំនប់ខ្នាតធំនេះ មិនត្រូវបានធ្វើឡើងជាមួយអ្នកទទួលរងផលប៉ះពាល់ទាំងអស់ នៅតាមភូមិនីមួយៗទេ

ហើយការផ្តល់ព័ត៌មានផ្សេងៗអំពីគម្រោងសាង់សង់ទំនប់ ក៏មិនត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយដែរ ដោយសារប្រជាពលរដ្ឋភាគច្រើនគ្រាន់តែបានឮព័ត៌មានផ្សេងដោយគ្មានមូលដ្ឋានពិតប្រាកដ និងមិនទាន់បានទទួលព័ត៌មានជាក់លាក់ជាផ្លូវការនៅឡើយទេ។ បើយោងតាមរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញឆ្នាំ២០០៩ ក៏មិនបានបញ្ជាក់ច្បាស់លាស់ថាការពិគ្រោះយោបល់ដែលបានធ្វើឡើងក្នុងដំណាក់កាលវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមមានការចូលរួមយ៉ាងពេញលេញពីសំណាក់គ្រួសារទាំងអស់មកពីគ្រប់ភូមិទាំងឡាយ ដែលនឹងទទួលរងផលប៉ះពាល់នោះទេ។ ម្យ៉ាងទៀត ការផ្តល់រយៈពេលត្រឹមតែ៣០ថ្ងៃសម្រាប់ក្រសួងបរិស្ថានក្នុងការពិនិត្យ និងផ្តល់យោបល់ទៅលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានមួយ ក៏មិនទាន់គ្រប់គ្រាន់ក្នុងការធ្វើការពិនិត្យអោយបានសព្វជ្រុងជ្រោយនោះដែរ។ បញ្ហាទាំងនេះ នាំអោយមានការសន្និដ្ឋានថា ការពិគ្រោះយោបល់ជាសាធារណៈ ការផ្សព្វផ្សាយព័ត៌មាន និងសុំការយល់ព្រមពីប្រជាពលរដ្ឋក្នុងការអនុវត្តគម្រោងហាក់នៅមានកម្រិតនៅឡើយ។

សរុបសេចក្តីមក យោងតាមឯកសារជាច្រើនរួមមានឯកសារវាយតម្លៃហេតុប៉ះពាល់បរិស្ថាន សេចក្តីជូនដំណឹងរបស់រាជរដ្ឋាភិបាលកម្ពុជា ការអនុវត្តប្រសើរបំផុតក្នុងការផ្តល់សំណង និងការតាំងទីលំនៅថ្មីសម្រាប់ការសាងសង់ទំនប់ខ្នាតធំ និងការចុះសិក្សាស្រាវជ្រាវជាក់ស្តែងនៅតំបន់ ដែលនឹងត្រូវទទួលរងផលប៉ះពាល់ដោយសារគម្រោងទំនប់វារីអគ្គិសនីសេសានក្រោម២ បានបង្ហាញថា គម្រោងសាងសង់នេះ ពិតជាមានផលប៉ះពាល់ធំធេងដល់ជីវភាពប្រជាពលរដ្ឋរាប់ពាន់នាក់ ធនធានធម្មជាតិ និងបរិស្ថានផ្សេងៗពិតប្រាកដមែន។ បន្ថែមពីនេះ ប្រសិនបើមិនមានការយកចិត្តទុកដាក់យ៉ាងម៉ត់ចត់ អំពីផលប៉ះពាល់ទាំងឡាយអោយបានសព្វជ្រុងជ្រោយដោយគិតគូរពីតម្រូវការប្រជាពលរដ្ឋជាធំ មិនមានផែនការសំណងឲ្យបានសមស្រប និងច្បាស់លាស់ មិនមានការរៀបចំផែនការតាំងទីលំនៅជាមុនឲ្យបានសមស្រប នោះផលប៉ះពាល់ទាំងឡាយ អាចជះឥទ្ធិពលជាអវិជ្ជមានទៅលើ

ជីវភាពរស់នៅ និងសន្តិសុខស្បៀងរបស់ប្រជាពលរដ្ឋ គោលដៅកាត់បន្ថយភាពក្រីក្រ និងគោលដៅអភិវឌ្ឍន៍សហសវត្សរ៍របស់កម្ពុជា។

## ២. សំណូមពរ

ដោយសារការព្រួយបារម្ភពីបញ្ហាជីវភាព ការភ័យខ្លាចពីសុវត្ថិភាព សន្តិសុខទៅថ្ងៃអនាគត និងមិនចង់ធ្វើការបំលាស់ទីពីភូមិកំណើតបច្ចុប្បន្នដែលមានទំនាក់ទំនងនឹងប្រពៃណីសាសនា ក៏ដូចជាមនោសញ្ចេតនាស្រលាញ់ភូមិកំណើត ប្រជាពលរដ្ឋភាគច្រើនបានសំណូមពរទៅកាន់រាជរដ្ឋាភិបាល ក៏ដូចជាក្រុមហ៊ុនវិនិយោគទំនប់វារីអគ្គិសនី ដើម្បីកុំអោយសាងសង់ទំនប់វារីអគ្គិសនីសេសានក្រោម២ឡើង។ ប៉ុន្តែ ប្រសិនជារាជរដ្ឋាភិបាលមិនអាចបញ្ឈប់គម្រោងសាងសង់បាន ដោយសារយល់ឃើញថា ការសាងសង់នេះនឹងទទួលបានផលប្រយោជន៍ច្រើនចំពោះការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ដូច្នេះប្រជាពលរដ្ឋសំណូមពរយ៉ាងទទូចទៅកាន់រាជរដ្ឋាភិបាល និងក្រុមហ៊ុនវារីអគ្គិសនីអោយគិតគូរយ៉ាងយកចិត្តទុកដាក់ក្នុងការផ្តល់សំណងអោយបានសមរម្យ និងយុត្តិធម៌ជាមុនដូចជា សងផ្ទះ ដីស្រែចំការ ដំណាំដាំដុះផ្សេងៗ ពិសេសដំណាំហូបផ្លែ សត្វចិញ្ចឹម និងសងការខូចខាតទ្រព្យសម្បត្តិផ្សេងៗ និងកន្លែងប្រកបរបររកស៊ីដល់ប្រជាពលរដ្ឋ ហើយជួយជាសេវាដឹកជញ្ជូនក្នុងការរើទីតាំង ជួយជាថវិកាមួយចំនួន និងស្បៀងអាហារហូបចុកសម្រាប់ផ្គត់ផ្គង់ការចាប់ផ្តើមជីវភាពរស់នៅកន្លែងថ្មី។

ម្យ៉ាងវិញទៀត ការតាំងទីលំនៅថ្មីអាចធ្វើទៅបានលុះត្រាតែរាជរដ្ឋាភិបាល និងក្រុមហ៊ុនវិនិយោគទំនប់វារីអគ្គិសនី បានគិតគូរពិចារណាយ៉ាងយកចិត្តទុកដាក់លើការសាងសង់ហេដ្ឋារចនាសម្ពន្ធ័រូបវ័ន្តដូចជា សាលារៀន ផ្លូវថ្នល់ មន្ទីរពេទ្យ វត្តអារាម ប្រភពទឹក។ល។ ពេលប្រជាពលរដ្ឋប្តូរទៅនៅកន្លែងថ្មី ទើបធ្វើអោយកត្តាជីវភាព ក៏ដូចជាចលនាសង្គមនៅក្នុងសហគមន៍អាចមានដំណើរការទៅបាន។ ក្រៅពីការសំណូមពរទាំងនេះ ប្រជាពលរដ្ឋសំណូមពរដល់រាជរដ្ឋាភិបាល និងក្រុមហ៊ុន

ជួយផ្តល់អគ្គិសនីអោយប្រជាពលរដ្ឋប្រើប្រាស់ដោយឥតគិតថ្លៃ ឬគិតក្នុងតម្លៃទាបសមរម្យ ព្រោះពួកគេជាអ្នកទទួលរងផលប៉ះពាល់ដោយសារតែគម្រោងនេះ។

សំណូមពរជាចុងក្រោយគឺ រាជរដ្ឋាភិបាលត្រូវធានាថាការទៅនៅទីតាំងថ្មីត្រូវមានសុវត្ថិភាពដីធ្លីដោយពុំមានការរំលោភបំពានណាមួយកកើតឡើងឡើយ។

## ៣. អនុសាសន៍

### ❖ ចំពោះរាជរដ្ឋាភិបាល:

១. គួរតែអោយក្រុមហ៊ុនវិនិយោគគម្រោងសិក្សាអោយបានលម្អិត និងច្បាស់លាស់ជាងនេះ ទាក់ទងនឹងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដោយមានគុណភាព ស្មោះត្រង់ មានការចូលរួមពិភាក្សា និងពិគ្រោះយោបល់យ៉ាងពេញលេញ និងទូលំទូលាយជាមួយប្រជាពលរដ្ឋដែលរងផលប៉ះពាល់ដោយផ្ទាល់ និងផ្សព្វផ្សាយអោយបានទូលំទូលាយក្នុងចំណោមអ្នកពាក់ព័ន្ធទាំងឡាយ មុនពេលចាប់ផ្តើមអនុវត្តគម្រោងនេះ។ ចំណុចនេះរួមបញ្ចូលទាំងការផ្តល់ឱកាសគ្រប់គ្រាន់ដល់សង្គមស៊ីវិលក្នុងការចូលរួមផ្តល់យោបល់ចំពោះរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានផងដែរ។

២. ចំពោះការផ្សព្វផ្សាយព័ត៌មានអំពីគម្រោងអភិវឌ្ឍន៍ សំណង និងការតាំងទីលំនៅថ្មីហាក់មិនទាន់មានសកម្មភាពច្បាស់លាស់ ដូច្នេះត្រូវធានាថាព័ត៌មានទាំងអស់ត្រូវបានផ្សព្វផ្សាយជាសាធារណៈ ហើយប្រជាពលរដ្ឋដែលនឹងត្រូវទទួលរងផលប៉ះពាល់អាចទទួលបានព័ត៌មានគ្រប់គ្រាន់ និងច្បាស់លាស់ ពិសេសផ្តល់លទ្ធភាពអោយប្រជាពលរដ្ឋបានចូលរួមបញ្ចេញយោបល់ សម្រេចចិត្ត និងបង្ហាញពីការពេញចិត្តចំពោះគម្រោងអភិវឌ្ឍន៍សំណង និងទីតាំងបំរុងថ្មី។

៣. ត្រូវពង្រឹងក្រុមការងារតាមដាន និងត្រួតពិនិត្យទៅលើសកម្មភាពអនុវត្តគម្រោងមុនពេលសាងសង់ អំឡុងពេលចាប់ផ្តើម និងក្រោយពេលសាងសង់ដើម្បីប្រាដកថា ក្រុមហ៊ុនបានធ្វើតាមសេចក្តីណែនាំ និងគោលការណ៍ទាំងឡាយ

របស់រាជរដ្ឋាភិបាល ដើម្បីជៀសវាងការបំពានសេចក្ដីទុកចិត្ត និងកិច្ចសន្យាដែលអាចធ្វើអោយមានផលប៉ះពាល់ជាអវិជ្ជមានទៅលើប្រជាពលរដ្ឋ។

៤. គប្បីត្រូវរៀបចំអោយមានគណៈកម្មការវាយតម្លៃសំណងនិងផ្ដល់សំណងដែលមានផែនការច្បាស់លាស់ និងគ្រប់គ្រងការអនុវត្តផ្ដល់សំណង សំដៅធានាអោយមានគណនេយ្យភាព តម្លាភាព យុត្តធម៌ និងសុវត្ថិភាពសម្រាប់ប្រជាពលរដ្ឋក្នុងសហគមន៍ដែលត្រូវទទួលសំណង។ ចំពោះសំណងនៃផលប៉ះពាល់ មិនមែនសងត្រឹមតែទ្រព្យសម្បត្តិដែលបាត់បង់នោះទេ តែត្រូវសងផលទុន ពេលវេលាកំលាំងដែលខាតបង់ទាំងឡាយដែលប្រជាពលរដ្ឋខិតខំកសាងនៅកន្លែងចាស់ និងត្រូវសងនូវផលប៉ះពាល់រយៈវែង ហើយធានាជួយផ្គត់ផ្គង់ជីវភាពប្រជាពលរដ្ឋរហូតគេអាចពង្រឹងជីវភាពខ្លួនឯងបាន។ លើសពីនេះ នាពេលអនាគត គួរតែបង្កើតអោយមានច្បាប់នៃការផ្ដល់សំណងចំពោះផលប៉ះពាល់ ដោយសារការអភិវឌ្ឍផ្សេងៗដើម្បីធានាថាប្រជាពលរដ្ឋមិនបាត់បង់ផលប្រយោជន៍ ឬរងគ្រោះដោយសារការអភិវឌ្ឍន៍ជាពិសេសគឺ ស្របតាមគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រដ្ឋាភិបាល។

៥. ការតាំងទីលំនៅថ្មីសម្រាប់ប្រជាពលរដ្ឋ ដែលត្រូវទទួលរងផលប៉ះពាល់ត្រូវមានផែនការលំអិត ច្បាស់លាស់ជាមុន ពិសេសទីតាំង និងពេលវេលាពិតប្រាកដ។ បន្ថែមពីនេះ ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់គម្រោងទំនប់វារីអគ្គិសនីសេសានក្រោម២ ភាគច្រើនគឺមានជីវភាពពឹងផ្អែកលើវិស័យកសិកម្មដែលមានការធ្វើស្រែចំការ ដាំដំណាំផ្សេងៗ នេសាទ និងរកអនុផលព្រៃឈើ ដូច្នេះការតាំងទីលំនៅថ្មី ត្រូវតែបានគិតគូរពីធនធានទាំងឡាយ ដែលប្រជាពលរដ្ឋត្រូវការចាំបាច់និងអាស្រ័យផលជាប្រចាំអោយមាននៅកន្លែងតាំងទីលំនៅថ្មី ដើម្បីធានាសុវត្ថិភាពមុខរបរ និងសុវត្ថិភាពស្បៀងសម្រាប់ជីវភាព។

៦. ការចាប់យកដី និងកាន់កាប់ដីនៅកន្លែងរស់នៅថ្មីអាចនឹងបង្កអោយមានបញ្ហាវិវាទដីធ្លីកើតឡើងក្នុងចំណោមប្រជាពលរដ្ឋ ក៏ដូចជាភាគីពាក់ព័ន្ធផ្សេងៗ ដូច្នេះរាជរដ្ឋាភិបាលត្រូវធានាអោយបាននូវសុវត្ថិភាពដីធ្លី និងសិទ្ធិកាន់កាប់ដីធ្លីជូន

ប្រជាពលរដ្ឋ ដោយបង្កើតអោយមានក្រុមការងារទទួលបន្ទុកពន្លឿនការរៀបចំកម្មសិទ្ធិដីធ្លី ឬចុះបញ្ជីដីធ្លី។

៧. ជនជាតិដើមភាគតិច គឺជាប្រជាពលរដ្ឋដែលត្រូវតែយកចិត្តទុកដាក់ខ្លាំងបំផុតសម្រាប់ការអភិវឌ្ឍនានា ពីព្រោះពួកគេជាជនដែលងាយរងគ្រោះ។ ជនជាតិដើមភាគតិចជាជនដែលរស់នៅតាមតំបន់ព្រៃភ្នំ និងអាស្រ័យផលពីបរិស្ថានធម្មជាតិដូចជាព្រៃឈើ សត្វព្រៃ ទន្លេ ដងអូរជាដើម ដោយពួកគេមិនអាចស៊ាំនឹងការរស់នៅដោយគ្មានធនធានទាំងនេះឡើយ ដូច្នេះគួរតែពិនិត្យអោយជាក់លាក់ថាតើអ្វីជាសិទ្ធិជនជាតិដើមភាគតិច ហើយគួរអភិវឌ្ឍន៍បែបណាដើម្បីធានាថាជនជាតិដើមភាគតិចទាំងឡាយមិនទទួលរងគ្រោះពីការអភិវឌ្ឍន៍ ហើយវប្បធម៌ ប្រពៃណីសាសនារបស់ពួកគេត្រូវបានអភិរក្ស។

៨. ផលប៉ះពាល់ជាអវិជ្ជមាន និងវិធានការបន្ធូបន្ថយទាំងឡាយដែលបានបង្ហាញតាមរយៈការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដែលអ្នកជំនាញបានផ្តល់យោបល់ ត្រូវធ្វើយ៉ាងណាអោយស្ថិតក្នុងវិធានការការត្រៀមរៀបចំការពារទុកជាមុន ជៀសវាងធ្វើអោយមានប៉ះពាល់ដល់សុវត្ថិភាព និងសន្តិសុខប្រជាពលរដ្ឋនៅពេលក្រោយ។

៩. គួរតែបង្កើតអោយមានច្បាប់វាយតម្លៃហេតុប៉ះពាល់បរិស្ថាន(EIA) ដើម្បីធានាអោយមានសុក្រឹតភាព គុណភាព និងប្រសិទ្ធភាពនៃសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាននានា និងការគោរពតាមច្បាប់ដែលបានចែងជាធរមាន។

- **ចំពោះក្រុមហ៊ុនវិនិយោគទំនប់វារីអគ្គិសនី:**

១០. ត្រូវអនុវត្តតាមគោលការណ៍ និងសេចក្តីណែនាំទាំងឡាយដែលបានចែងក្នុងច្បាប់ និងអនុក្រឹត្យផ្សេងៗរបស់ព្រះរាជាណាចក្រកម្ពុជា ដូចជាធ្វើការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដោយមានការចូលរួមពីប្រជាពលរដ្ឋនៅតាមសហគមន៍នីមួយៗអោយពេញលេញ មានផែនការសំណង និងផែនការតាំងទីលំនៅថ្មីអោយបានច្បាស់លាស់ និងមានការទទួលខុសត្រូវរាល់ការខូចខាតទាំងឡាយដែលបណ្តាលមកពីការសាងសង់ទំនប់។

១១. ចំពោះការផ្សព្វផ្សាយព័ត៌មានច្បាស់លាស់ផ្លូវការអំពីគម្រោងអភិវឌ្ឍន៍ សំណង និងការតាំងទីលំនៅថ្មី មិនត្រូវបានប្រជាពលរដ្ឋភាគច្រើនបានដឹងឡើយ ដូច្នេះ ត្រូវធានាថាព័ត៌មានទាំងអស់ត្រូវបានផ្សព្វផ្សាយជាសាធារណៈ ហើយប្រជាពលរដ្ឋដែលនឹងត្រូវទទួលរងផលប៉ះពាល់អាចទទួលបានព័ត៌មានគ្រប់គ្រាន់ និងច្បាស់លាស់ ពិសេសទុកលទ្ធភាពអោយប្រជាពលរដ្ឋបានចូលរួមបញ្ចេញយោបល់សម្រេចចិត្ត និងបង្ហាញពីការពេញចិត្តចំពោះគម្រោងអភិវឌ្ឍន៍ សំណង និងទីតាំងបំរុងថ្មី។

១២. ត្រូវរៀបចំសំណងសម្រាប់ផលប៉ះពាល់ភ្លាម ឬសម្រាប់តំរូវការមូលដ្ឋានមុនពេលចេញសេចក្ដីជូនដំណឹងអោយប្រជាពលរដ្ឋផ្លាស់ប្ដូរលំនៅដ្ឋានដើម្បីការពារភាពខ្វះទីជំរក ស្បៀងអាហារ និងតម្រូវការចាំបាច់ផ្សេងៗ។ ម្យ៉ាងទៀត សំណងនៃផលប៉ះពាល់ដោយប្រយោល ផលប៉ះពាល់រយៈពេលវែង និងផលប៉ះពាល់ចំពោះពេលវេលា ព្រមទាំងកំលាំងពលកម្មក៏ត្រូវរៀបចំអោយបានសមរម្យអាចទទួលយកបាន យុត្តិធម៌ និងទាន់ពេលវេលាដែរ។

១៣. ត្រូវធានាសម្របសម្រួលការផ្ដល់សំណង ឬតម្លៃជំនួសអោយមានភាពប្រហាក់ប្រហែលគ្នានូវអ្វីដែលជាទ្រព្យសម្បត្តិ និងធនធានដែលមាននៅភូមិចាស់របស់ប្រជាពលរដ្ឋដូចជាផ្ទះ ដីភូមិ ដីស្រែនិងដីចំការ ទីតាំងដែលមានព្រៃឈើក្បែរប្រភពទឹក ដីមានជីជាតិអាចប្រកបរបររកស៊ីបានជាដើម។

១៤. បន្ទាប់ពីការផ្លាស់ទីលំនៅជីវភាពប្រជាពលរដ្ឋ អាចនឹងមិនទាន់ដូចដើម ដោយសារត្រូវចំណាយពេលវេលាច្រើនដើម្បីរៀបចំទីតាំងថ្មី និងបង្កើតមុខរបរថ្មី ដូច្នេះ ក្រុមហ៊ុនត្រូវរៀបចំផែនការស្ដារជីវភាពឡើងវិញ សម្រាប់ប្រជាពលរដ្ឋដើម្បីអោយពួកគេអាចមានស្ថេរភាពជីវភាព។

១៥. សហគមន៍ដែលទទួលរងផលប៉ះពាល់ដោយផ្ទាល់ និងដោយប្រយោល ក្នុងតំបន់គម្រោង គួរមានលទ្ធភាពប្រើប្រាស់ថាមពលអគ្គិសនីក្នុងតម្លៃទាបសមរម្យទាបជាងតម្លៃលក់ចេញទៅក្រៅតំបន់ ព្រោះពួកគេជាអ្នកដែលបានចូលរួមចំណែកក្នុងការអភិវឌ្ឍគម្រោងវារីអគ្គិសនីនេះដែរ។

១៦. គួរមានការពិភាក្សាលំអិតជាមួយរដ្ឋាភិបាល និងសិក្សាពីវិធីនៃការអភិវឌ្ឍដែលប្រកបដោយនិរន្តរភាពទាំងធនធានបរិស្ថានធម្មជាតិ និងសង្គម ពិសេសគិតគូរយ៉ាងយកចិត្តទុកដាក់ចំពោះការអភិវឌ្ឍ ដែលប៉ះពាល់ដល់ជនជាតិដើមភាគតិច ដើម្បីធានាថាជនជាតិដើមភាគតិចអាចរក្សាបាននូវទំនៀមទម្លាប់ប្រពៃណីរបស់ខ្លួនដោយមិនប៉ះពាល់ដល់ជីវភាពរស់នៅ។

❖ **ចំពោះអង្គការមិនមែនរដ្ឋាភិបាលផ្សេងៗដែលធ្វើការងារពាក់ព័ន្ធ:**

១៧. ត្រូវធ្វើការជិតស្និទ្ធជាមួយសហគមន៍ដើម្បីឃ្លាំមើលរាល់សកម្មភាព ឬដំណើរការអនុវត្តទាំងឡាយណាដែលជាចំនុចមិនប្រក្រតី ឬអវិជ្ជមានរបស់ក្រុមហ៊ុនចំពោះប្រជាពលរដ្ឋ ដើម្បីអោយការអនុវត្តទាំងឡាយស្ថិតក្នុងការរិះគន់ស្ថាបនាសំដៅអោយមានការរីកចំរើន។

១៨. គួរមានក្រុមការងារជាដៃគូរជាមួយរដ្ឋាភិបាលដើម្បីធ្វើការរួមគ្នាធ្វើយ៉ាងណាអោយក្រុមហ៊ុនអនុវត្តន៍តាមគោលការណ៍របស់រដ្ឋាភិបាល និងជួយសម្រួលអោយជីវភាពប្រជាពលរដ្ឋប្រសើរឡើងបន្ទាប់ពីមានការតាំងទីលំនៅថ្មី។

១៩. ផ្តល់វគ្គបណ្តុះបណ្តាល និងវិធីសាស្រ្តនៃការតស៊ូមតិដល់សហគមន៍ដែលនឹងត្រូវទទួលរងផលប៉ះពាល់ ដើម្បីអោយពួកគេកាន់តែមានការយល់ដឹងពីសិទ្ធិ និងតួនាទីរបស់ខ្លួនក្នុងការអភិវឌ្ឍ។

២០. ផ្តល់វគ្គអប់រំបន្ថែមផ្សេងៗពីអនាម័យ សុខភាព និងវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដើម្បីអោយប្រជាពលរដ្ឋអាចយល់ដឹងកាន់តែច្រើន និងមានជំនាញផ្សេងៗអាចបង្កើតមុខរបរថ្មីបាន បន្ទាប់ពីមានការតាំងទីលំនៅថ្មី។

❖ **ចំពោះសហគមន៍:**

២១. ត្រូវមានការចងក្រងគ្នាជាក្រុមសហគមន៍ មានប្រធានក្រុមដឹកនាំ មានគណៈកម្មការប្រជាពលរដ្ឋនៅតាមភូមិនីមួយៗ ដើម្បីចែករំលែកព័ត៌មានផ្សេងៗ ឃ្លាំមើលគម្រោងអភិវឌ្ឍន៍ និងចងក្រងឯកសារសំខាន់ពាក់ព័ន្ធនឹងគម្រោង ហើយស្វែងរកជំនួយ ឬរាយការណ៍ជាបន្ទាន់ បើសិនជាមានភាពមិនប្រក្រតីណាមួយកើតឡើងតាំងពីការចាប់ផ្តើមគម្រោងដើម្បីធានារក្សាផលប្រយោជន៍រួមក្នុងសហគមន៍។

២២. ត្រូវយល់ដឹងពីសិទ្ធិ និងតួនាទីរបស់ខ្លួនក្នុងការចូលរួមអភិវឌ្ឍន៍ប្រទេស ហើយត្រូវតែចូលរួមក្នុងការពិភាក្សាពិគ្រោះយោបល់នានា ទាក់ទងនឹងគម្រោងអភិវឌ្ឍ ដើម្បីអោយបានដឹងពីផែនការផ្សេងៗ ហើយលើកយកមកពិភាក្សាផ្លាស់ប្តូរយោបល់ក្នុងចំណោមប្រជាពលរដ្ឋ និងអាជ្ញាធរភូមិជាមុន និងស្វែងរកជំនួយបន្ថែមបើសិនជាចាំបាច់។

❖ **ចំពោះអ្នកស្រាវជ្រាវបន្តទៀត:**

២៣. សិក្សាលំអិត អំពីផលប៉ះពាល់នៃគម្រោងចំពោះបរិស្ថានធនធានធម្មជាតិ និងបម្រែបម្រួលអាកាសធាតុ។

២៤. សិក្សាអំពីគម្រោងស្តារប្រាក់ចំណូល ដែលជាតម្រូវការរបស់ប្រជាពលរដ្ឋ ដើម្បីដាក់ស្នើរកជំនួយពីអង្គការផ្សេងៗដើម្បីផ្គត់ផ្គង់ និងស្តារប្រាក់ចំណូលរបស់ប្រជាពលរដ្ឋឡើងវិញ។

២៥. សិក្សាពីរបៀបគ្រប់គ្រងទឹកជំនន់សម្រាប់ទំនប់វារីអគ្គិសនីខ្នាតធំ ឬសិក្សាពីបទពិសោធន៍ នៃការគ្រប់គ្រងទឹកជំនន់ពីទំនប់វារីអគ្គិសនីនៃប្រទេសផ្សេងៗ ដែលធ្លាប់បានទទួលភាពជោគជ័យ និងផ្តល់ជាអនុសាសន៍សម្រាប់ការអនុវត្តន៍គម្រោងវារីអគ្គិសនីនេះ និងគម្រោងអគ្គិសនីដទៃទៀតនៅកម្ពុជា។

២៦. សិក្សាពីគុណសម្បត្តិ និងគុណវិបត្តិនៃការសាងសង់ទំនប់វារីអគ្គិសនីខ្នាតធំ ដោយរួមបញ្ចូលទាំងការប្រៀបធៀបផលប្រយោជន៍នៃការសាងសង់ទំនប់ធៀបនឹងផលប៉ះពាល់។

២៧. សិក្សាពីស្ថានភាពជីវភាព និងផលប៉ះពាល់នៃការអភិវឌ្ឍទំនប់វារីអគ្គិសនីសេសានក្រោម២ ចំពោះប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ដោយប្រយោលពីគម្រោង។

# ឯកសារយោង

វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ«ជំរឿនសហគ្រាសនៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១១» ភ្នំពេញ ខែមិនា ឆ្នាំ២០១២។

ក្រសួងអប់រំយុវជន និងកីឡា «ស្ថិតិ និងសូចនាករអប់រំ ២០១០/២០១១» ភ្នំពេញ ខែមិនា ឆ្នាំ២០១១។

ព្រឹត្តិបត្រកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី ច្បាប់ទី២ «ដីជាជីវិត» ខែវិច្ឆិកា ២០១១។

រាជរដ្ឋាភិបាលកម្ពុជា សេចក្តីជូនដំណឹងលេខ: ៣១ សជណ.កបច
ចុះហត្ថលេខាដោយនាយករដ្ឋមន្ត្រី ហ៊ុន សែន ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១១

រដ្ឋសភា លិខិតលេខ: សធ៩-០១១/១១ ចុះហត្ថលេខាដោយប្រធានរដ្ឋសភា
សម្តេច ហេង សំរិន ថ្ងៃទី១០ ខែ មិថុនា ឆ្នាំ២០១១

កម្មវិធីសមធម៌ប្រចាំសប្តាហ៍លើកញ្ញក់ទូរទស្សន៍ជាតិកម្ពុជា ទទក «ទំនប់វារីអគ្គិសនីសេសានក្រោម២» ផ្សាយថ្ងៃទី២១ ខែសីហា ឆ្នាំ២០១១។

ង៉ោ សុថាត និងច័ន្ទ សុផល «ហិរញ្ញប្បទានក្នុងវិស័យកសិកម្ម និងសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មសម្រាប់កសិករខ្នាតតូច» ភ្នំពេញ ខែកញ្ញា ឆ្នាំ២០១០។

EVN,PECC1 និង KCC «របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញគម្រោងទំនប់វារីអគ្គិសនីសេសានក្រោម២ ខេត្តស្ទឹងត្រែង ប្រទេសកម្ពុជា» ភ្នំពេញ ខែធ្នូ ឆ្នាំ២០០៩។

វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ «ជំរឿនទូទៅនូវប្រជាសាស្ត្ររបស់ប្រទេសកម្ពុជា ឆ្នាំ២០០៨» ភ្នំពេញ ខែសីហា ២០០៩។

វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ «ការសិក្សាពីសេដ្ឋកិច្ចសង្គម ឆ្នាំ២០០៩»។

វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ «របាយការណ៍ជាតិស្តីពីតារាងស្ថិតិផ្នែកទី១ និងទី២» ភ្នំពេញ ២០០៨។

សៀវភៅច្បាប់ស្តីពីអស្សាមិករណ៍ ឆ្នាំ២០០៩។

លោក ភីតធ័រ ស្ទីស «ការចិញ្ចឹមជីវិតនៅតំបន់អាងទន្លេស្រែពកនៅប្រទេសកម្ពុជា: ការសិក្សាព័ត៌មានដើម» ខែមិនា ឆ្នាំ២០០៦។

សៀវភៅច្បាប់ភូមិបាល ឆ្នាំ២០០១ ។
សៀវភៅច្បាប់ស្តីពីព្រៃឈើ ឆ្នាំ២០០៣ ។

អនុក្រឹត្យស្តីពីកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ឆ្នាំ១៩៩៩។

រាជរដ្ឋាភិបាលកម្ពុជា «សេចក្តីសង្ខេប ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣»។

ធនាគារអភិវឌ្ឍន៍អាស៊ី «សេចក្តីសង្ខេបនៃសៀវភៅណែនាំស្តីពីការតាំងទីលំនៅសារជាថ្មី» ឆ្នាំ១៩៩៨។

Ministry of Environment of Cambodia and UNDP Cambodia, “CAMBODIA HUMANDEVELOPMENT REPORT 2011” 2011.

The Cambodia Daily, Volume 47, Issue 73, Tuesday, January 25, 2011.

Mark Grimsditch “Understanding New Threats and Challenges from Hydropower Development to Biodiversity and Community Rights in the 3SRivers Basin” April 2012.

World Health Organization, CBR Guidelines: “Livelihood Component”, 2010.

Food and Agriculture Organization of the United Nations and National Institute of Statistics/Ministry of Planning “National Gender Profile of Agricultural Households, 2010” Phnom Penh, May 2010.

UNDP "Current Status of Cambodian Millennium Development Goals (CMDG)" September 2010.

Ministry of Planning "STRATEGIC PLAN UPDATE 2009-2013" June 2010.

Jan-Peter Mund, The Agricultural Sector in Cambodia: "Trends, Processes and Disparities" 2010.

Baird, Ian G, Rivers Coalition in Cambodia "Best Practices in Compensation and Resettlement for Large Dams: The Case of the Planned Lower Sesan 2 Hydropower Project in Northeastern Cambodia" May 2009.

According to the reported of the NGOs comments on the EIA report which prepare by the NGO Forum on Cambodia August 2009.

World Health organization, Gwénaëlle Legros, Ines Havet, Nigel Bruce, and Sophie Bonjour "THE ENERGY ACCESS SITUATION IN DEVELOPING COUNTRIES" November 2009.

The NGO Forum on Cambodia, Probe International, "Powering 21$^{st}$ Century Cambodia with Decentralized Generation" A Primer for Rethinking Cambodia's Electric Future, October 2009 .

National Committee for Sub-National Democratic Development (NCDD), Koun Mom District Databook 2009. (Rathanakiri province)

National Committee for Sub-National Democratic Development (NCDD), Sesan District Databook 2009. (Stung Treng province)

Power Engineering Consulting Joint Stock Company 1-Vietnam "A Complete Environmental Impact Assessment Report of Lower Sesan 2 Hydro Power Project, Stung Treng Province" Phnom Penh, December 2009.
MRC Sea for Hydropower on the Mekong Mainstream Inception Report VOL I II, (National Scoping Consultation Summaries) 23 October 2009.

ADB "The susstainable livelihoods approach" November 2008.

SBK Research, "Survey of Implementers and Stakeholders at Sub-national Level on Issues relating to Identification of Poor Households in Kratie and Siem Reap provinces" March-May 2008.

Ministry of Planning "Implementation Manual on the Procedures for Identification of Poor Households" October 2008.

Power Engineering Consulting Joint Stock Company 1-Vietnam. "Environmental Impact Assessment Report of Lower Sesan 2 Hydro Power Project, Stung Treng Province" Phnom Penh, October 2008.

Royal Government of Cambodia, Ministry of Planning "A Poverty Profile of Cambodia 2004" February 2006.

Philippa Thomas, Disability Policy Officer " Poverty reduction and development in Cambodia: Enabling disabled people to play a role" April 2005.

Jock Campbell, Philip Townsley, Emma Whittingham,… "Understanding the Factors that Support or Inhibit Livelihoods Diversification in Coastal Cambodia" 2005.

Hart Feuer "Social Capital, and Income-Generation Capacity" December 2004.

Kaing Khim, Thay Somony, Nao Thouk, Cambodia PRA Report "Understanding Livelihoods Dependent on Inland Fisheries" March 2003.

Bruce Mc Kenney and Prom Tola, CDRI: Baseline Assessment "Natural Resources and Rural Livelihoods in Cambodia" 2002.

World Bank, "OP 4.12 - Involuntary Resettlement" December 2001.

Chea Vannaren, Fisheries activities in Stung Treng province Cambodia.

Olivier Serrat, Southeast Asia Department, Asian Development Bank "The Livelihoods Framework"

Royal Government of Cambodia "National Strategic Development Plan Update 2009-2013, for Growth, Employment, Equity and Efficiency to Reach Cambodia Millenium Development Goals" November 2009.

http://www.foodsecurityatlas.org/khm/country/access/livelihoods
(Searched website on March 29, 2011)

http://www.baitongcambodia.org/bai-tong-cambodia/420
(Searched website on April 05, 2011)

www.world66.com/asia/southeastasia/cambodia/culture
(Searched website on April 05, 2011)

www.culturalprofiles.net/cambodia/Directories/Cambodia_Cultural_Profile/-1732.html (Searched website on April 05, 2011)

www.everyculture.com/Bo-Co/Cambodia.html
(Searched website on April 05, 2011)

http://en.wikipedia.org/wiki/Religion_in_Cambodia
(Searched website on April 05, 2011)

http://www.internationalrivers.org/node/4578.
(Searched website on March 28, 2011)

http://www.trust.org/alertnet/news/cambodia-dam-threatens-livelihoods-will-increase-hunger-campaigners (Searched website on March 28, 11)

http://www.adb.org/Documents/Handbooks/Resettlement_Summary/chap1.pdf
(Searched website on February 3, 2011)

http://www.mop.gov.kh/Projects/IDPoor/tabid/154/Default.aspx
(Search website on February 4, 2011)

www.adb.org/projects/tonle_sap (Search website on February 6, 2011)

www.internationalriver.org "Proposed Lower Sesan 2 Dam, Cambodia Fails to Uphold Best Practice, August 2009" (Searched website on March 28, 2011)

http://en.wikipedia.org/wiki/Lower_Se_San_2_Hydropower_Dam
(Searched website on February 3, 2011)

http://www.foodsecurityatlas.org/khm/country/provincial Profile/Rattanakiri
(Searched website on March 31, 2011)

http://english.thesaigontimes.vn/Home/business/environment/18592/
(Searched website on December 10, 2011)

http://www.banktrack.org/show/dodgydeals/lower_sesan_2_hydropower_project
(Searched website on November 20, 2011)

http://thesoutheastasiaweekly.com/?p=962
(Searched website on November 28, 2011)

http://www.nis.gov.kh/ (Searched website on November 28, 2011)

http://www.worldfishcenter.org/resource_centre/WF_3136.pdf
(Searched website on June 19, 2012)

http://www.mop.gov.kh/Projects/IDPoor/tabid/154/Default.aspx
(Searched wesite on August 7, 2012)

# ឧបសម្ព័ន្ធ

## រូបភាពនៃសកម្មភាពចុះស្រាវជ្រាវ




សកម្មភាពនៃការពិភាក្សាក្រុមនៅក្នុងវត្ត




សកម្មភាពសម្ភាសន៍តាមផ្ទះ




សកម្មភាពក្រុមការងារស្រាវជ្រាវនៅតំបន់សិក្សា

## បញ្ជីសំណួរសម្រាប់ការសិក្សាស្រាវជ្រាវ

សម្រាប់បញ្ជីសំណួរប្រភេទផ្សេងគ្នាដែលបានប្រើប្រាស់ក្នុងការសិក្សានេះសូមចូលទៅកាន់វិបសាយ http://www.ngoforum.org.kh/docs/other/RIC_Questionnairs_of_LSS2.zip

**វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា**
អាសយដ្ឋានៈ ផ្ទះលេខ ៩-១១ ផ្លូវលេខ ៤៧៦ សង្កាត់ទួលទំពូង ១
ប្រអប់សំបុត្រ ២២៩៥ ភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខៈ (៨៥៥-២៣) ២១៤ ៤២៩
ទូរសារលេខៈ (៨៥៥-២៣) ៩៩៤ ០៦៣
អ៊ីម៉ែលៈ **ngoforum@ngoforum.org.kh**
គេហទំព័រៈ **www.ngoforum.org.kh**